# ប្រជុំរឿងព្រេងខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ភាគ ១

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ភ្នំពេញ
ព.ស.២៥៤៥ គ.ស.២០០១

# ប្រជុំរឿងព្រេងខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ភាគ ១

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ព.ស.២៥៤៥ គ.ស.២០០១

# មាតិការឿង


| រឿង | ទំព័រ |
|---|---|
| អារម្ភបទ | គ |
| ១- រឿងមនុស្សពីរនាក់នៅផ្ទះជិតគ្នា | ១ |
| ២- ចចក | ៤ |
| ៣- ពស់កេងកង | ៧ |
| ៤- គង់ហ៊ាន | ១១ |
| ៥- ពាក្យសុភាសិត តម្លៃ ៣០ តម្លឹង | ១៥ |
| ៦- បាយាស្ត្រី | ២៣ |
| ៧- អាកុហកស៊ី | ២៨ |
| ៨- បុរសចេះថ្នាំពិសពស់ | ៣២ |
| ៩- មនុស្សឆោតបួននាក់ | ៣៤ |
| ១០- ក្អែកមួយ ជាក្អែកដប់ | ៣៨ |
| ១១- ចៅសុក្រ និង ចៅសៅរ៍ | ៤៣ |
| ១២- គ្រូ និង សិស្ស | ៤៦ |
| ១៣- កម្លោះពីរនាក់ ចង់បានប្រពន្ធគេ | ៥១ |
| ១៤- ជាតិខ្លាធំ | ៥៤ |
| ១៥- ចោរចិត្តជា | ៥៧ |
| ១៦- ឪពុកក្មេករើសកូនប្រសា | ៦៥ |
| ១៧- រឿងអាសុខស្លូត អាសុខកាច | ៧៤ |
| ១៨- សម្លាញ់ពីរនាក់ | ៨៣ |
| ១៩- សួស្តី និង អពមង្គល | ៨៧ |
| ២០- ខ្លាចាញ់ប្រាជ្ញាគីង្គក់ និងអណ្តើក | ៩២ |
| ២១- ខ្លា ស្វា និង ទន្សាយ | ៩៨ |
| ២២- អណ្តើក និង ស្វា | ១០៣ |

| រឿង | ទំព័រ |
| --- | --- |
| ២៣– ដង្កូវ និង ក្អែក | ១០៥ |
| ២៤– បងថ្លៃ និង ប្អូនថ្លៃ | ១០៨ |
| ២៥– បុរសកុហក ៤ នាក់ | ១១០ |
| ២៦– បុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍ | ១១៣ |
| ២៧– បុរសមានកូន ៤ នាក់ រៀនវិជ្ជា ៤ បទ | ១១៥ |
| ២៨– ចៅអាចម៍សេះ | ១២១ |
| ២៩– ស្រីក្មេងកមាស | ១២៤ |
| ៣០– បុរសកាស ៣០ | ១២៦ |
| ៣១– បុរសជីកក្ដាម | ១៣០ |
| ៣២– ស្រីមាយាដកខ្វី | ១៣៦ |
| ៣៣– តាចន្ទរំលៀក | ១៣៩ |
| ៣៤– អន្តរាយឫទ្ធិនៃសត្វអស្សតរ | ១៤៤ |

## សេចក្ដីបញ្ជាក់

ក្នុងគ្រាបោះពុម្ពចាប់ពីលើកទី ៥ មក, យើងបានកែប្រែសម្រួលប្រយោគ និងពាក្យពេចន៍ខ្លះ ៗ ដែលពីមុនមកមានការគក់ឆ្គងលំបាកស្ដាប់ ឲ្យមានដំណើរទំនងងាយស្រួលស្ដាប់ឡើងវិញតទៅ ។

ក្រុមជំនុំទំនៀមទម្លាប់

## សេចក្ដីបញ្ជាក់
## ចំពោះការបោះពុម្ពឡើងវិញ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវរើសរកក្បួនខ្នាតទាក់ទង នឹងអក្សរសាស្ត្រសាសនា អក្សរសាស្ត្រទូទៅ មកបោះពុម្ពឡើងវិញ ដើម្បីរក្សាស្នាដៃ របស់បុព្វបុរសខ្មែរយើង ។

ក្នុងការបោះពុម្ព សៀវភៅប្រជុំរឿងព្រេងទាំងប្រាំបួនភាគឡើងវិញនេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានថតចម្លងតាមច្បាប់ដើមទាំងស្រុង និងសូមអភ័យ ទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមាន ដោយអចេតនាទៅលើ អក្ខរាវិរុទ្ធក្ដី កំហុសក្នុងការរៀបរៀងឃ្លាក្ដី នោះគឺ ជាលក្ខណៈដែលមានក្នុងច្បាប់ ដើមពីមុនមក ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ២០០១
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

# អារម្ភកថា

ប្រទេសកម្ពុជាយើង មានរឿងព្រេង ច្រើនជាអនេក មិនអាចគណនាត្រារាប់ចំនួន ថា ប៉ុណ្ណោះ ប៉ុណ្ណេះបាន ។ រឿងទាំងនោះ ចាត់ជាពួក ៗ គឺ :

ក ) រឿងទាក់ទងដោយប្រវត្តិសាស្ត្រ ដូចរឿង ភ្នំប្រុសភ្នំស្រី នៅខេត្តកំពង់ចាម, ភ្នំទ្រុងមាន់ ភ្នំបាណន់ ភ្នំសំពៅ នៅខេត្តបាត់ដំបង, ភ្នំសែនហាននៅខេត្តកំពត, ភ្នំនាងកង្រី នៅខេត្តកំពង់ឆ្នាំង ជាដើម ។

ខ ) រឿងទាក់ទងដោយតុលាការកាត់ក្តី ដូចរឿង សុភាទន្សាយ និង រឿងផ្សេងៗ ដែលមានក្នុងសាស្ត្រាក៏ងកន្រ្តៃ ជាដើម ។

គ) រឿងទាក់ទងដោយការនេសាទ របៀបទាក់ ឬ បរបាញ់ មានការទាក់ដំរីជាដើម ។

ឃ) រឿងទាក់ទងដោយទំនៀមទម្លាប់ មានទំនៀមមង្គលការជាដើម ។

រឿងសាស្ត្រាល្បែង ក៏បានច្រើនលើសគណនា ដូចរឿង ព្រះជិនវង្ស ស័ង្ខសិល្បជ័យ ជ័យទត្ត ជាដើម ។

ទាំងរឿងព្រេង ទាំងសាស្ត្រាល្បែង ជារឿងពិរោះពិសា មានសារប្រយោជន៍ខាងផ្លូវវណ្ណគតិអក្សរសាស្ត្រ ហើយជារឿងសម្រាប់ដឹកនាំអ្នកអាន អ្នកស្តាប់ ឲ្យកើតសតិបញ្ញា យល់ការខុសត្រូវជ្រៅរាក់ច្រើនមានគំនិតខ្ពស់ ស្គាល់ទោសគុណ, រួមយ៉ាងខ្លី គឺឲ្យស្គាល់គតិលោកគតិធម៌ ។

ចំពោះរឿងសាស្ត្រាល្បែង យើងបានសង្កេតដំណើររឿងនីមួយ ៗ ឃើញបានគតិ ២ យ៉ាង គឺខាងដើមរឿង ច្រើននិយាយពីការកំសត់ព្រាត់ប្រាស កណ្តាលរឿងច្រើននិយាយពីការច្បាំងគ្នា ការប្រណាំងប្រជែងគ្នា ជាគតិលោក, ខាងចុងបំផុតរឿងច្រើនតែនិយាយពីតួឯក ក្នុងរឿងចេញបួសជាតាបសឫសី ដែលជាគតិធម៌ ដើម្បីទាញអារម្មណ៍អ្នកអានអ្នកស្តាប់ ឲ្យត្រេកត្រអាលក្នុងកាម តាមផ្លូវលោកជាដើម ឲ្យនឿយណាយចាកកាម តាមផ្លូវធម៌ជាខាងចុង, ហើយជាពិសេសបំផុត គឺច្រើនតែជារឿងឃោសនា ដើម្បីទាញទិដ្ឋិអ្នកអាន–ស្តាប់ ឲ្យជឿកម្មផល តាមគតិពុទ្ធសាសនា ។

ឯរឿងព្រេង និងរឿងសាស្ត្រាល្បែងទាំងប៉ុន្មាន • ដែលកើតមាននៅប្រទេសកម្ពុជាយើងនេះ ចែកជា ២ ផ្នែក :

១) លោកអ្នកប្រាជ្ញបុរាណ បាននិពន្ធទុក ហើយបច្ឆាជនបានចារជាក់ស្លឹករឹត ខ្លះ សរសេរដាក់ក្រាំងខ្លះ ដាក់សៀវភៅខ្លះគ ។ គ្នាទុកនៅតាមវត្តអារាម ស្រុកនានា ពេញប្រទេសកម្ពុជាទាំងមូល ។

២) ចាស់បុរាណ បាននិទានទុក ហើយបច្ឆាជន បានដំណាល ប្រាប់គ្នាត ៗ មក ដោយមាត់ទទេ ឥតបានចារសរសេរឡើយ ។

បើពុំប្រមូលកត់ត្រាទុកទេ រឿងទាំងនោះ នឹងនៅរាត់រាយ រកកំណត់ចំនួនពុំបាន ហើយនឹងបាត់បង់ ឬ នឹងប្រែក្លាយទៅជារឿងសម័យថ្មីអស់បាត់ពូជដើម ព្រោះហេតុនេះ បានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ បានខិតខំស្រាវជ្រាវរក និង ប្រមែប្រមូល ទាំងរឿងដែលចារជាសាស្ត្រា ទាំងរឿងដែលនិទានមាត់ទទេ ដោយវិធីទាក់ទង រវាងសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំនេះ ដែលមាននៅតាមស្រុកខេត្តនានា និងកត់ត្រាតាមចាស់ ៗ ដែលចេះចាំស្ទាត់ មកតម្កល់ទុកក្នុងមន្ទីរក្រុមជំនុំទំនៀមទម្លាប់ និងដោយវិធីចារ សរសេរចម្លង អំពីវត្តអារាមទាំងឡាយក្នុងព្រះរាជាណាចក្រ បកតម្កល់ទុកក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងដោយវិធីចុះផ្សាយ ក្នុងទស្សនាវដ្តីកម្ពុជសុរិយា ជាយូរឆ្នាំមកហើយផង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានស្រង់រឿងព្រេងទាំងប៉ុន្មាន ដែលមានក្នុងមន្ទីរក្រុមជំនុំទំនៀមទម្លាប់ ក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ និងក្នុងទស្សនាវដ្តីកម្ពុជសុរិយា ដែលបានសន្សំទុកជាយូរឆ្នាំហើយនោះ មកប្រមូលរៀបចំ បោះពុម្ពជាសៀវភៅដោយញែកចែកជាភាគ ។ ឲ្យឈ្មោះថា **ប្រជុំរឿងព្រេងខ្មែរ** ដើម្បី :

ក) ឲ្យរឿងព្រេងខ្មែរទាំងប៉ុន្មាន បានមូលគ្រគូលគ្នា ស្រួលដល់លោកអ្នកត្រូវការរកទៅអាន ។

ខ) រក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណ ទុកជាកេរ្តិ៍តទៅ កុំឲ្យបាត់បង់ ។

គ) ឲ្យយុវជនអ្នកអាន បានឃើញច្បាស់ថា ជាតិខ្មែរយើង មានកេរ្តិ៍តិកអក្សរខ្មែរ ច្រើនជាអនេក ។

ឃ) ឲ្យយុវជនអ្នកអាន បានស្គាល់ព្រឹត្តិការណ៍អក្សរសាស្ត្រខ្មែរសម័យបុរាណ

ង) ឲ្យយុវជនអ្នកអាន បានចេះចាំរឿងនិទាន និងពាក្យពេចន៍បុរាណច្រើន បែកប្រាជ្ញា អាចធ្វើការចរចា និង ការនិពន្ធរបស់ខ្លួន ឲ្យមានសម្រស់ ។

ច) ឲ្យយុវជនអ្នកនិពន្ធ ងាយប្រៀបធៀបវោហារ ពាក្យពេចន៍សម័យចាស់ និង សម័យថ្មី ហើយធ្វើសេចក្ដីនិពន្ធរបស់ខ្លួនឲ្យមានលំអឲ្យត្រូវគ្រប់សម័យ ។

ចំពោះសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគទី ១ និង ភាគទី ២ ខាងចុងបំផុតរឿងនីមួយ ៗ យើងបានដាក់សុភាសិត តម្រូវតាមគតិដែលមានក្នុងផ្ទៃរឿងនោះ ។ សម្រាប់លោកអ្នកអានពិចារណា ។

ឯពាក្យពេចន៍ និង ប្រយោគក្នុងរឿងនីមួយ ៗ យើងទុកឲ្យនៅតាមបុរាណជាច្រើន វៀរលែងតែរឿងណា ដែលកត់ត្រាតាមមាត់ចាស់ ៗ និទាន ទើបប្រើរបៀបសម័យថ្មី ។

ចំណែកអក្ខរាវិរុទ្ធ យើងបានកែតម្រូវតាម វចនានុក្រមខ្មែរ សម័យបច្ចុប្បន្ន ។

យើងសង្ឃឹមថា សៀវភៅប្រជុំរឿងព្រេងនេះ នឹងបានជាកម្លាំងមួយ អាចជួយពង្រីករក្សាសាស្ត្រជាតិ ឲ្យមានវឌ្ឍនាការជាតិយេ្យាភាព ។

១ មករា ១៩៥៩

**គ្រុមជំនុំធំនៀមធម្លាប់ខ្មែរ**

# ១– រឿងមនុស្សពីរនាក់នៅផ្ទះជិតគ្នា (១)

កាលពីព្រេងនាយ មានមនុស្សពីរនាក់នៅផ្ទះជិតគ្នា ។ ថ្ងៃមួយចៅទាំងពីរនាក់នោះ បបួលគ្នាទៅដាក់អន្ទាក់សត្វ ។ បបួលគ្នាហើយ ដល់ថ្ងៃរសៀលគងភ្នំ ក៏នាំគ្នាដើរចេញទៅ ។ លុះដល់ព្រៃដាកន្លែងដាក់អន្ទាក់ អ្នកមួយថា "ខ្ញុំនឹងដាក់នៅគល់ឈើនេះ ត្បិតឈើនេះមានផ្លែ យប់ៗសត្វចំណាំតែមកស៊ីផ្លែឈើនេះ" ។ អ្នកមួយទៀត ឆ្លើយថា "ខ្ញុំក៏ចង់ដាក់កន្លែងហ្នឹងដែរ ប៉ុន្តែឥឡូវ បើអ្នកដាក់នៅគល់ឈើមានតែខ្ញុំដាក់នៅចុងឈើ រួចយើងចាំមើល ព្រឹកឡើងរបស់អ្នកណាជាប់សឹមដឹង" និយាយគ្នាហើយ, ម្នាក់ដាក់នៅគល់ឈើ ម្នាក់ដាក់នៅចុងឈើ ស្រេចហើយ, វិលមកផ្ទះវិញ លាគ្នាទៅផ្ទះតែរៀងខ្លួន ។

ឯអ្នកដាក់អន្ទាក់នៅចុងឈើនោះ លុះវិលមកដល់ផ្ទះហើយ, យប់នោះគិតគ្នាពីរនាក់ប្ដីប្រពន្ធថា "តាំងពីដូនតាមក មិនដែលឮថាអ្នកឯណាដាក់អន្ទាក់លើចុងឈើ ឲ្យជាប់សត្វជើងបួនដែលដើរនៅលើដីទេ ឥឡូវនេះ អញដាក់នៅលើចុងឈើ តើធ្វើម្ដេចនឹងបានសត្វ? ដូច្នេះ ត្រូវអញរួកពីពេលមាន់រងាវទៅមើល, បើឃើញសត្វជាប់អន្ទាក់គេនៅដី អញដោះយកទៅចងនឹងអន្ទាក់អញឯចុងឈើ, ដល់ព្រឹកឡើងអញទៅមើលជាមួយអ្នកនោះ ហើយអញដោះយកសត្វទៅជូនលោកសុភាសេក, បើវាមិនសុខចិត្តដូចម្ដេច ។ មុខជាកើតក្ដី គង់តែដល់សុភាសេកមិនខាន, សុភាសេកនិងកាត់ក្ដីឲ្យវាចាញ់ជាប្រាកដ" ។ ប្ដីប្រពន្ធគិតគ្នា ហើយដេកទៅ, ដល់មាន់រងាវរួកពីដេក លប់មុខ ស៊ីស្លា ហើយចេញពីផ្ទះដើរដល់អន្ទាក់បានឃើញអន្ទាក់នៅដី

---

១– ទស្សនាវដ្ដី កម្ពុជសុរិយា លេខ ១០–១១–១២ ឆ្នាំ ១៩៣៦ ទំព័រ ១៤៩ មិនមានឃើញឈ្មោះអ្នករៀបរៀងទេ ។

ជាប់ក្តាន់ ១ ក៏ដោះយកឡើងទៅចងនឹងអន្ទាក់របស់ខ្លួន រួចតម្លើងអន្ទាក់នៅដីដូចដើម ក៏ប្រញាប់វិលមកផ្ទះវិញ ។ លុះព្រឹកព្រហាមស្រាង ៗ ឡើង អ្នកមួយដែលដាក់អន្ទាក់នៅដី មកស្រែកហៅឲ្យទៅមើលអន្ទាក់អ្នកមួយ ឆ្លើយថា កុំរលះរលាំងថ្វី. អន្ទាក់ខ្ញុំ ខ្ញុំមិនសង្ឃឹមទេ ត្បិតនៅលើចុងឈើ ក្រែងតែអន្ទាក់អ្នកនៅដីនោះ ខ្ញុំមិនហ៊ានថា បើបានចែកគ្នាស៊ីផង " ។ ពាក្យនេះ ជាពាក្យចំអកឲ្យអ្នកមួយ ត្បិតដឹងការណ៍មុនហើយ ។ អ្នកទាំងពីរនិយាយហើយចុះពីផ្ទះដើរចេញទៅ លុះដើរទៅដល់ មិនឃើញអន្ទាក់នៅដីជាប់សត្វ ឃើញតែអន្ទាក់នៅលើចុងឈើជាប់វិញ ។ ចៅដែលជាម្ចាស់អន្ទាក់នៅចុងឈើថា " ហ្ន៎ មើលចុះ មិនជឿខ្ញុំ ខ្ញុំថាកុំដាក់នៅគល់ ឲ្យដាក់នៅចុងឥឡូវ មើលរបស់នរណាជាប់ហ្ន៎ ? " ហើយឡើងទៅដោះយកសត្វចុះមកនាំគ្នាវិលមកផ្ទះវិញ ក៏លាគ្នាទៅផ្ទះដោយខ្លួនទៅ ។ ឯចៅដែលបានក្តាន់ ក៏ប្រញាប់យកទៅជូនសុភាសេកហើយជម្រាបថា " ខ្ញុំហើយនឹងចៅម្នាក់នោះ ទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅចុងឈើ អ្នកមួយនោះដាក់នៅគល់ឈើ ខ្ញុំនេះជាមនុស្សវៀច ក្តីនេះគង់តែមកដល់លោក ដូច្នេះ តាមតែលោកមេត្តារកសេចក្តីយ៉ាងណា ឲ្យតែក្តីខ្ញុំឈ្នះវាចុះ ខ្ញុំនឹងដឹងគុណលោកទៅថ្ងៃមុខ ,, ។ សុភាសេកបានសាច់ក្តាន់ហើយ ឆ្លើយថា " ឯងទៅរកស្លាម្លូមកឲ្យឆាប់ឲ្យទាន់ព្រឹកនេះ បើវាមកប្តឹងរញ្ជាបង្គាប់អីចឹងដែរ បើវាមកមិនទាន់អញនឹងកាត់សេចក្តីឲ្យវាចាញ់បានដោយងាយ , ឯងប្រញាប់ទៅចុះ " ។

ឯអ្នកដែលដាក់អន្ទាក់លើគល់ឈើ លុះវិលមកផ្ទះហើយ ដង្ហើមតូចដង្ហើមធំមិនសុខចិត្ត ក៏យកសេចក្តីទៅប្តឹងសុភាសេក ។ ក៏បង្គាប់សេចក្តីដូចបង្គាប់ចៅមុន ។ លុះព្រឹកឡើង អ្នកដែលដាក់អន្ទាក់នៅលើចុងឈើ ក៏យកអីវ៉ាន់ទៅដល់មុន ។ ឯអ្នកដែលដាក់អន្ទាក់នៅដី ដោយខ្លួនជាអ្នកក្រលំបាកតោកយ៉ាក ដើររកទិញអីវ៉ាន់ពុំបានពុំទាន់ ភ័យក្រែងខ្លួនចាញ់គេ ហើយគេយកទោសផង ក៏រត់ពីភូមិមួយទៅភូមិមួយបានជួបនិងសុភាទន្សាយ ។ សួរថា "មានដំណើរអីបានជារត់ដូច្នេះ ? ឈប់សិន " ។ ចៅនោះឆ្លើយថា លោកអើយអាណិតដោះទុក្ខខ្ញុំផង ត្បិតខ្ញុំហើយនឹងអ្នកមួយទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅគល់ឈើ គេដាក់ទៅចុងឈើ ព្រឹកឡើងទៅមើល ពុំឃើញអន្ទាក់នៅដីជាប់សត្វ ឃើញតែអន្ទាក់នៅចុងឈើជាប់ក្តាន់មួយ ខ្ញុំមិនសុខចិត្ត

បានយកសេចក្ដីទៅប្ដឹងសុភាសេក ។ គេថា អ្នកណាយកអីវ៉ាន់ទៅដល់មុន, អ្នកនោះឈ្នះ ហេតុនេះ បានជាខ្ញុំភ័យ ឥឡូវគេទៅដល់មុនខ្ញុំហើយ ដូច្នេះតាមតែលោកអាណិតខ្ញុំផង ” ។ សុភាទន្សាយឆ្លើយថា “ ណ្ហើយ ! កុំភ័យចាំថ្ងៃរសៀលខ្ញុំនឹងនាំទៅ” ។ ចៅនោះក៏អរ ។ លុះដល់ថ្ងៃរសៀល សុភាទន្សាយទៅដល់ផ្ទះសុភាសេក ។ ស្រែកសួរមកថា “ ដូចម្ដេចក៏យូរម្ល៉េះ ? ក្ដីចាញ់គេហើយ ” ។ សុភាទន្សាយឆ្លើយថា “ យើងខ្ញុំបានជាយូរនេះ ពីព្រោះអាល័យតែមើលត្រីក្រាញ់ហើរឡើងស៊ីស្លឹកអំពិល ” ។ សុភាសេកថា “ពីដូនដីតាមកគ្មាននរណាដែលឃើញដែលឮថា ត្រីក្រាញ់ឡើងស៊ីស្លឹកអំពិលទេ” ។ សុភាទន្សាយឆ្លើយថា “ ពីដូនដីតាពីម៉ែពីឪបង្កើតមក នរណាដែលឃើញដែលឮថា អន្ទាក់នៅដីមិនជាប់សត្វទៅជាប់ឯអន្ទាក់នៅចុងឈើវិញ ហើយសត្វជើងបួនផង, ដែលឮទេ អស់អ្នកស្រុក ? ។ នោះសុភាសេកស្ងៀម ពុំហ៊ានស្ដីតបទៀត ។ សុភាទន្សាយក៏កាត់សេចក្ដីឲ្យចៅដែលដាក់អន្ទាក់នៅដីឈ្នះ ។ ឯសុភាសេក ដែលអង្គុយធ្វើជាសុភានោះ ក៏ខ្មាសដោយសារខ្លួនជាអ្នកល្មោភជំនួសសាច់ក្ដាន់ ក៏ស្ងៀមបែរមុខផ្ទប់ទៅខាងជញ្ជាំងដូចឆ្មាលបកណ្ដុរ ។

**លោភលន់ខ្មាស និងាសច្បាប់**

## ២- រឿងចចក(១)

កាលពីព្រេងនាយ មានចចកគ្រោសធំមួយ ដល់ខែលំហើយ វាដើររកត្រពាំងបឹងបួដែលរីងទឹក ដើម្បីចាប់ត្រីស៊ី ។ លុះទៅដល់ត្រពាំងមួយរីងទឹកអស់ នៅតែប្រឡង់មួយ ឃើញសុទ្ធតែភក់ មានត្រី កំពឹស បង្កង ក្ដាមជាច្រើនណាស់ ។ ចចកឃើញហើយ មានចិត្តត្រេកអររីករាយគិតថា " ថ្ងៃនេះអញមានលាភធំណាស់ ជាលាភចម្លែកជាងសព្វថ្ងៃ " ។ ឯកំពឹសមានប្រាជ្ញា ឮចចកថាដូច្នោះហើយ ក៏និយាយលួងលោមចចកថា " យើងទាំងអស់គ្នាសុទ្ធតែចំណីបងចចកឯងទាំងអស់ហើយ ប៉ុន្តែយើងប្រឡាក់ភក់ណាស់ បងឯងស៊ីយើងទាំងភក់ដូច្នេះ មិនឆ្ងាញ់ពិសាទេ " ។ ចចកឆ្លើយថា " ធ្វើដូចម្ដេចនឹងឆ្ងាញ់ពិសា ? " ។ កំពឹសឆ្លើយថា " ត្រូវបងចចកយកយើង ទៅលាងទឹកឲ្យជ្រះស្អាត ហើយសឹមស៊ី នោះទើបឆ្ងាញ់ពិសា " ។ ចចកថា " ធ្វើដូចម្ដេចនឹងយកទៅលាងបាន បើច្រើនដល់ម៉្លេះ ? " ។ កំពឹសថា " បងចចកកុំព្រួយចិត្ត ខ្ញុំធានាគិតឲ្យបងបានស្រួល ប៉ុន្តែត្រូវបងឯងតាមខ្ញុំ " ។ ចចកឆ្លើយឡើងថា " បងឯងធ្វើដូចម្ដេចក៏ខ្ញុំតាមទាំងអស់ " ។ កំពឹសថា " ធ្វើដូច្នេះ ចូរបងឯងចូលមកដេកននៀលក្នុងភក់នេះ ហើយយើងរាល់គ្នា នឹងបានតោងខាំរោមបងឯង បងឯងនាំយើងទៅរកស្ទឹងបឹងបួឯណា ដែលមានទឹកថ្លាច្រើន បងឯងលាងយើងឲ្យស្អាត ហើយសឹមបងឯងស៊ីឆ្ងាញ់ពីសាតាមចិត្តចុះ " ។ ឯចចក ជាសត្វលោភហើយល្ងង់ ក៏ធ្វើតាមពាក្យកំពឹស ។ កំពឹសនិងត្រី ក៏បបួលគ្នាតោងរោមចចកទៅ លុះទៅដល់បឹងមួយធំវែង មានទឹកថ្លាល្អ ចចកដើរចុះទៅក្នុងទឹក អស់ត្រីកំពឹស លោតទៅក្នុងទឹក ហើយប្រាប់ថា " បងចចកឯង ទៅជញ្ជូនមកឲ្យអស់សិន សឹមមកស៊ីឲ្យឆ្អែតតែម្ដង យើងនៅចាំបងនៅទីនេះ " ។ ចចក ក៏ទៅជញ្ជូនត្រីនិងកំពឹសមក លុះគ្រា

---

១- កម្ពុជសុរិយាលេខ ១០-១១-១២ ឆ្នាំ ១៩៣៦ ទំព័រ ១៤៣ គ្មានឈ្មោះអ្នករៀបរៀងទេ ។

តែអស់ពីត្រពាំងនោះ ។ ពួកត្រី កំពឹស ក្តាម ខ្យង ដឹងថា ចចកជញ្ជូនអស់ហើយ ក៏នាំគ្នាមុជក្នុងទឹកបាត់អស់ទៅ ។ ឯចចក ដឹងថាកំពឹសបញ្ឆោតដូច្នេះហើយខឹងណាស់ ដើរទៅបបួលអស់សត្វធំ តូច ដំរី រមាស ខ្លា គ្រប់ភាសាសត្វ ទាំងពស់ថ្លាន់ ពស់ធំ ពស់តូច ទាំងសត្វហើរ គ្មានសេសសល់ដល់តិច បបួលគ្នាមកបាចទឹកបឹងនោះឲ្យរីង និងបានចាប់ត្រីក្នុងបឹងនោះ ស៊ីឲ្យអស់ បានឲ្យពស់ថ្លាន់ធ្វើជាទំនប់ អស់សត្វឯទៀតក៏បបួលគ្នាបាច ។ សត្វក្នុងបឹង ដឹងថា ចចកបបួលគ្នាបាចទឹកឲ្យរីងទាំងបឹង ភ័យណាស់ ក៏គិតគ្នាថា " យើងធ្វើម្តេច នឹងបានឲ្យសត្វទាំងអស់នេះលែងបាចទឹក ? " កាលនោះត្រីក្រាញ់ ឆ្លើយឡើងថា " ខ្ញុំឮគេនិយាយថា បងសុភា-ទន្សាយជាអ្នកមានប្រាជ្ញា ចេះដោះទុក្ខមនុស្សសត្វផង ជាច្រើនណាស់ហើយ បើដូច្នេះខ្ញុំនឹងទៅពឹងបងសុភាទន្សាយ ឲ្យមកជួយដោះទុក្ខអស់យើង " ។ ពួកត្រីគិតគ្នាហើយ ក៏ប្រើត្រីក្រាញ់ទៅអញ្ជើញសុភាទន្សាយ ។ ត្រីក្រាញ់ ប្រឹងនឿលទៅលុះដល់ត្រូវថ្ងៃក៏ក្រៀមស្រកាអស់ ដល់យប់ សុភាទន្សាយចេញមករកស៊ី បានឃើញត្រីក្រាញ់នឿលដូច្នោះ ក៏សួរថា "បងត្រីក្រាញ់ទៅណា ? " ។ ត្រីក្រាញ់ឃើញសុភាទន្សាយហើយមានចិត្តត្រេកអរណាស់និយាយអង្វរថា បងសុភាទន្សាយ អាណិតខ្ញុំ ត្បិតត្រីទាំងអស់ក្នុងបឹងគេប្រើខ្ញុំមក ឲ្យអញ្ជើញបងសុភាទន្សាយទៅ ត្បិតឮទាំងសត្វទាំងមនុស្សនិយាយថា បងជាអ្នកមានប្រាជ្ញា ចេះកាត់សេចក្តីដោះទុក្ខ បើអ្នកឯណាកើតទុក្ខ បងតែងទៅជួយដោះទុក្ខគេ មិនដែលខាន ឥឡូវមានដំរី ក្របី គោ រមាស រមាំង ប្រើស ក្តាន់ ជ្រូក ពស់ធំ ពស់តូច ទាំងសត្វហើរ គី កុក ក្រៀល បង្កៀលខ្យង ទុង ទោម ក្អែកទឹក ប្រវឹក ស្មោញ ទាំងប៉ុន្មាន បានបបួលគ្នាមកបាចទឹកបឹងឲ្យរីង នឹងបានចាប់របស់ ត្រី អណ្តើក កន្ធាយ ស៊ីជាចំណីឲ្យអស់ពីបឹងនេះឯងបើដូច្នេះ បងសុភាទន្សាយអាណិតជួយដោះទុក្ខអស់បងប្អូនខ្ញុំ ឲ្យបានរួចពីភ័យម្តងនេះ នឹងបានល្បីកេរ្តិ៍ឈ្មោះតទៅ, អស់យើងនឹងតបគុណបងសុភាទន្សាយឯង យើងមិនភ្លេចគុណដរាបដល់រស់ជីវិត ។ ឯទន្សាយឮត្រីក្រាញ់និយាយអង្វរដូច្នោះក៏ឆ្លើយថា " បងត្រីក្រាញ់ទៅមុនចុះ ទៅប្រាប់អស់បងប្អូនកុំឲ្យភិតភ័យ ចាំខ្ញុំជួយដោះឲ្យរួច កុំមានចិត្តបារម្ភឡើយ " ។ ត្រីក្រាញ់ក៏ត្រឡប់ទៅវិញ ។ ឯទន្សាយ លុះព្រឹកព្រហាម

ឡើងទៅមាត់បឹង ឃើញអស់សត្វកំពុងបាចទឹក ក៏យកស្លឹកឈើ ដែលដង្កូវស៊ីធ្លុះៗ មកធ្វើជាសំបុត្រ ហើយស្រែកហៅអស់សត្វទាំងនោះថា នែ ! បងប្អូនទាំងអស់ ចាំស្តាប់ខ្ញុំ ត្បិតព្រះឥន្ទ្រលោកឲ្យខ្ញុំនាំសំបុត្រមកប្រាប់គ្រប់គ្នាថា " ព្រះឥន្ទ្រលោកមកកាច់ជើងត្រី ប្រមុំជើងអក កាប់ក្បាលឆ្កែចចក ដកភ្លុកដំរីស " ។ អស់សត្វឮថាសំបុត្រព្រះឥន្ទ្រដូច្នោះភ័យណាស់ ផ្អើលបោលជាន់គ្នា ពានលើដំរី ក្របី រមាស រមាំងៗ ស្ទុះបោលទៅជាន់លើពស់ថ្លាន់ជាទំនប់ ដាច់ខ្លួនជាពីរ-បីកំណាត់ ធ្លាយទំនប់លិចទឹកស្លាប់អស់ ។ សត្វទាំងនោះក៏ទៅជាចំណីត្រីវិញ ។ តាំងអំពីថ្ងៃនោះមក អស់សត្វទាំងពួង កោតខ្លាចប្រាជ្ញាសុភាទន្សាយ ទុកសុភាទន្សាយ ជាគ្រូបាអាចារ្យទាំងអស់ ។

## អណ្តាតជាអាទិ៍គន្លង ស្លាប់ផងរស់ផង ពីព្រោះអណ្តាត

# ៣-រឿង ពស់កេងកង (១)

កាលពីព្រេងនាយ នៅលើដីយើងនេះ គ្រប់ស្រុកទាំងអស់មិនមានពស់ពិស និង ពស់ឥតមានពិសទេ មានតែពស់កេងកង ។

មាននិទានថា : កាលដើមឡើយ មានមនុស្ស ២ នាក់ប្ដីប្រពន្ធ, ប្រពន្ធឈ្មោះ នាងទី បានកូនស្រីមួយឈ្មោះនាងអេត ។ ប្ដីនោះ ទៅជួញអង្ករ បាត់ជាយូរអង្វែង ។ ថ្ងៃមួយ អស់បងប្អូនជិតខាង គេបបួលគ្នាទៅរកឧស ។ ឯនាងទីឮគេថាបបួលគ្នា ក៏ទៅជាមួយនឹងគេដែរ យកនាងអេតជាកូនទៅផង លីដឹងចូលព្រៃ បានឃើញឧស មួយធំ ។ នាងទីយកដឹងពុះឧសលុះពុះយូរបន្តិចទៅដឹងក៏របោះធ្លាក់ទៅក្នុងរន្ធពស់ ។ នាងទីមើលទៅឃើញដឹងនិងពស់កេងកង ក៏និយាយនឹងពស់នោះឲ្យហុចដឹងឲ្យ ។ ឯពស់កេងកងឆ្លើយឡើងថា "អើ! បើនាងឯង ដោយអញ ធ្វើប្រពន្ធអញ ទើបអញ ឲ្យដឹង បើនាងឯងមិនដោយអញ មិនធ្វើជាប្រពន្ធអញទេនោះ អញមិនឲ្យដឹងទេ" ។ នាងទីឮពស់កេងកងថាដូច្នោះហើយ ហេតុតែជាស្រីខ្លួច ក៏ទទួលព្រមថា ។ អើ ! លែងតែអ្នកឲ្យដឹងមកខ្ញុំចុះ ចាំល្ងាច សឹមខ្ញុំឲ្យមេអេតមកហៅ" ។ ពស់កេងកង ឮនាងទីថាដូច្នោះ ក៏ឲ្យដឹងមក ។ នាងទីផ្ដាំថា "ដល់ល្ងាច សឹមឲ្យមេអេតមកហៅ" ហើយនាងទី ក៏ទូលឧសទៅផ្ទះជាមួយនឹងនាងអេត ។ លុះដល់ព្រលប់ នាងទី ក៏ប្រើ មេអេតជាកូន ឲ្យទៅហៅពស់កេងកង ។ នាងអេតទៅដល់ឈរនៅមាត់រន្ធពស់ ហៅថា "ពស់កេងកងអើយ នាងទីឲ្យហៅ !" ។ ឯពស់កេងកងឮហើយ លូន ចេញមក ។ នាងអេតឃើញពស់ ក៏ភ័យខ្លាចព្រឺស្ញើបអស់ទាំងខ្លួន ប៉ុន្តែខ្លាចម្ដាយ ព្រោះម្ដាយប្រើមក ក៏ខំសង្កត់ចិត្តនាំពស់ទៅផ្ទះ ។ ពស់នោះធំណាស់ លូនទៅលើ ស្មៅបាក់រាបអស់ ដល់ផ្ទះហើយ ក៏ឡើងទៅដេកជាមួយនឹងនាងទី ។ នាងទីនិយាយ

---

១ ច្បាប់សរសេរដៃរបស់ E Aymonier ទំព័រ ៣៤ ខាងផ្នែកភាសាខ្មែរ និងបុះ កម្ពុជសុរិយា លេខ ១ ២.៣ ឆ្នាំ១៩..៣ ទំព័រ ៥៥ គ្មានឈ្មោះអ្នករៀបរៀងទេ ។

នឹងពស់កេងកងថា “ ខ្ញុំមានប្ដី ឥឡូវនេះ គាត់ទៅជួញអង្ករពីរ-បីឆ្នាំមកម្ដង ៗ ” ។ ពស់កេងកង សួរថា “ ប្ដីនាងឯង ទៅប៉ុន្មានថ្ងៃ ប៉ុន្មានខែទៀត នឹងមកដល់ ? ។



នាងនី ឆ្លើយថា “មិនដឹងជាប៉ុន្មានខែ ប៉ុន្មានថ្ងៃទៀត នឹងមកដល់ទេ” ពស់កេងកង និង នាងនី ក៏ដេកលក់ជាមួយគ្នាទៅ, ដល់ជិតភ្លឺទើបពស់កេងកង លានាងនីទៅរូងវិញ ។ នាងនី ផ្ដាំថា “ បើប្ដីខ្ញុំមក ខ្ញុំមិនឲ្យមេអេតទៅហៅទេ អ្នកកុំមក, បើប្ដីខ្ញុំមិនទាន់មកនោះ ខ្ញុំប្រើមេអេតឲ្យទៅហៅអ្នក សឹមអ្នកមក ” ។ ពស់កេងកងក៏ទៅឯរូងខ្លួនវិញទៅ ។ រាល់តែល្ងាច នាងនី ប្រើមេអេតឲ្យទៅហៅពស់កេងកង ។ នាងអេតខ្លាចម្ដាយ ក៏ទៅហៅ តាមពាក្យម្ដាយប្រើ ប៉ុន្តែក្នុងចិត្តខ្លាចពស់នោះណាស់ ត្បិតពស់នោះធំណាស់ ហើយវែងផង ។ មួយទៀត ខឹងក្នុងចិត្ត ត្បិតម្ដាយសហាយនឹងពស់ ។ នាងអេតទៅដល់មាត់រូងហើយហៅថា “ ពស់កេងកងអើយ នាងនីឲ្យហៅ ” ពស់កេងកងឮ ក៏លូនចេញមក ហើយឆ្លើយថា “ អេតអេតអើយ ! ថាអញមិនទៅ ឪពុកអេតនៅកាត់ក្បាលអញដាច់ ” ។ នាងអេត ឆ្លើយថា “ ឪពុកអញទៅ

ផ្ចួញអង្ករ ពីរ-បីឆ្នាំមិនទាន់មកដល់ ” ។ ពស់កេងកង ឮនាងអេតប្រាប់ដូច្នោះ ក៏លូន ចេញអំពីរន្ធមក ហើយចេះតែទៅមក ។ តែសព្វថ្ងៃ ។ នាងនី សហាយនឹងពស់កេង កងទាល់តែដើម ។ លុះយូរបន្តិចទៅ ប្ដីនាងនី មកពីផ្ចួញអង្ករវិញឃើញនាងនីពោះធំ នឹកសង្ស័យ ក៏សួរនាងអេតជាកូន ។ នាងអេតប្រាប់ឪពុកវាថា “ ម៉ែ គាត់សហាយ នឹងពស់កេងកង តែវេលាព្រលប់កាលណា ឲ្យខ្ញុំទៅហៅតែសព្វថ្ងៃ ” ។ ឪពុកឮ នាងអេតប្រាប់ដូច្នោះក៏និយាយនឹងនាងអេតថា “ ដល់ល្ងាចហងឯងទៅហៅពស់នោះ ទៀត អញចាំកាប់វានៅមាត់ទ្វារហើយហងឯងកុំឲ្យម្ដាយហងឯងដឹង” ។ ឯនាងអេត លុះដល់ព្រលប់ ក៏ទៅហៅពស់កេងកងថា “ ពស់កេងកង ។ ! នាងនីឲ្យហៅ ” ។ ពស់កេងកង ឮហើយ ឆ្លើយថា “ អេត អេតអើយ ! ថាអញមិនទៅ ឪពុកអេតនៅ កាត់កអញដាច់ ” ។ នាងអេតឆ្លើយថា “ ឪពុកអញទៅផ្ចួញអង្ករពីរ_បីឆ្នាំមិនទាន់ មកដល់ ” ។ ពស់កេងកង ឮនាងអេតប្រាប់ដូច្នោះ ស្មានថា ឪពុកនាងមិនទាន់មក ពីផ្ចួញអង្ករមែន ក៏ទៅដូចសព្វថ្ងៃ ។ ឯឪពុកនាងអេត កាន់ដាវពួននៅមាត់ទ្វារចាំកាប់។ ពស់កេងកងលូនចូលក្នុងទ្វារបន្តិច ឪពុកនាងអេតកាត់កដាច់ ហើយកាត់មួយកំណាត់ ខាងកន្ទុយយកទៅដាក់លើស្កាក មួយកំណាត់ខាងក្បាល យកទៅដាក់លើមែកពុទ្រា ឯកណ្ដាលខ្លួន ឲ្យនាងអេតយកទៅពន្លះពន្លាត់ស្បែកចោល ហើយផ្ដាំនាងអេតថា “ កុំឲ្យម្ដាយហងឯងដឹង តែត្រូវទុកសាច់ សួឲ្យម្ដាយហងឯងស៊ី ” ។ ឪពុកនាងអេត ក៏លាងឈាមពស់ជ្រះអស់ បិទឲ្យមានសល់។ឯនាងនីពុំបានដឹងជាប្ដីកាប់ពស់សហាយ ស្លាប់ទេ ព្រោះពេលនោះនាងនីមិននៅ ទៅសួរបងប្អូននៅផ្ទះឆ្ងាយ ។ លុះព្រឹកឡើង នាងអេតយកសាច់ពស់មកស្ងួទុកឲ្យនាងនីជាម្ដាយស៊ី ។ នាងនីឃើញសម្លខ្លាញ់រលើប ទាំងចានទាំងឆ្នាំង ក៏សួរនាងអេតថា “ បានសាច់អ្វីស្លមេអេត ! ” ។ នាងអេតប្រាប់ ថា “ សាច់ជ្រូក ” ។ នាងនី គិតស្មានថា សាច់ជ្រូកមែន ក៏ឲ្យមេអេតដួសសម្ល យកមកស៊ីបាយ ។ កាលនាងអេត ដួសសម្លមកឲ្យនាងនីជាម្ដាយស៊ីនោះ មានក្អែក មួយ វាឃើញក្បាលពស់ដាក់លើមែកពុទ្រា វាចង់ស៊ីសាច់ពស់ វាបូលថា “ កឡូវ។ ក្មេងក្មួមលេបសាច់ប្ដីឯង ” ។ នាងនី កំពុងស៊ីបាយ ឮក្អែកបូលដូច្នោះ ក៏មើលទៅ លើមែកពុទ្រាឃើញក្បាលពស់កេងកងលើមែក ហើយនាងនី នឹកអាណិតស្រក់ទឹក

ភ្នែក តែនាងពុំហ៊ានយំ ព្រោះខ្លាចប្ដីដែលអង្គុយស៊ីបាយជាមួយគ្នា ។ ប្ដីឃើញនាងនីស្រក់ទឹកភ្នែក ក៏សួរថា " ហេតុម្ដេច បានជាស្រក់ទឹកភ្នែក ? " ។ នាងនីឆ្លើយថា " ស៊ីបាយក្ដៅ សម្លក្ដៅ រឭកកូនចៅ រលោងទឹកភ្នែក " ។ ឯក្អែកនោះ ចេះតែបួលថា " កទ្បុវ ៗ ក្មេមក្មមលេបសាច់ប្ដីឯង ក្បាលដាក់លើដើមពុទ្រា កន្ទុយដាក់លើស្លាក " ។ នាងនីមើលទៅលើស្លាកឃើញកន្ទុយពស់កេងកងលើនោះ ។ ឯប្ដីនាងនីដឹងថាប្រពន្ធសហាយនឹងពស់កេងកងពិតប្រាកដហើយ ក៏នឹកភ្នកក្នុងចិត្ត ខឹងចង់សម្លាប់នាងនី ប៉ុន្តែធ្វើមិនឲ្យនាងនីដឹងខ្លួន ។ ដល់នាងនី ផើមចាស់ផ្ទៃ ជិតនឹងសម្រាល ប្ដីបបួលទៅកក់សក់នៅមាត់បឹង លុះដើរទៅដល់មាត់បឹង ប្រាប់ប្រពន្ធថា " ទៅទៀតឲ្យឆ្ងាយពីស្រុកគេ យើងនឹងកក់សក់លេងឲ្យសប្បាយតែពីរនាក់ម្ដង " ។ នាងនីមិនដឹងខ្លួនឯង ថាប្ដីសម្លាប់ ស្មានថាប្ដីនាំទៅកក់សក់មែន ក៏ដើរចូលទៅក្នុងព្រៃឆ្ងាយទៅ ។ លុះឃើញកំពង់មួយ រាបស្អាត វាលល្អ ប្ដីប្រាប់ប្រពន្ធថា " កំពង់នេះរាបសប្បាយ យើងឈប់កក់សក់នៅនោះចុះ " ឯនាងនី មិនដឹងខ្លួនជាប្ដីគិតសម្លាប់ ក៏អង្គុយកក់សក់នៅមាត់ច្រាំង ។ ប្ដីនោះក៏ហូតដាវកាប់នាងនីពីក្រោយខ្នង មិនឲ្យដឹងខ្លួន ដាច់ពាក់កណ្ដាលខ្លួនស្លាប់ទៅ ។ ពេលនោះ ឃើញសុទ្ធតែកូនពស់លូនចេញអំពីពោះនាងនីមក ។ ប្ដីនាងនីក៏កាប់កូនពស់នឹងដាវ ខ្លះកាប់មិនទាន់ ក៏លូនចូលទៅក្នុងក្រហែងដី ខ្លះមុជក្នុងទឹក ខ្លះចូលទៅក្នុងព្រៃ ។ ព្រោះហេតុនេះ បានជាមានពស់ច្រើនបែបច្រើនយ៉ាង មកដល់ឥឡូវនេះ ។

## ឃ្លាតឆ្ងាយ ណាយចិត្ត

# ៤– រឿងគង់ហ៊ាន (១)

កាលពីព្រេងនាយ មានមនុស្សម្នាក់ ឈ្មោះគង់ មានប្រពន្ធពីរ ។ មួយឈ្មោះនាងអៅ មួយឈ្មោះនាងគំ ។ ថ្ងៃមួយអ្នកគង់នាំប្រពន្ធទាំងពីនាក់ទៅសួរបងប្អូនទៅស្រុកឆ្ងាយ ។ តាមផ្លូវទៅស្រុកនោះ មានខ្លាសាហាវ ។ អ្នកគង់បណ្ដើរប្រពន្ធទាំងពីរនាក់ ទៅដល់ព្រៃធំមួយ ជិតស្រុកគេ, ព្រៃនោះតែងមានខ្លាដេញខាំមនុស្ស ក្របី គោ ស៊ីតែរឿយ ៗ ។ លុះអ្នកគង់ទៅដល់កន្លែងនោះ ខ្លាក៏ស្ទុះដេញ ស្រែកសន្ធាប់ពីចម្ងាយមក ។ អ្នកគង់រត់ចូលរូងឈើ ញ័រដៃញ័រជើង រាកនោមព្រោះភ័យណាស់ ។ នាងអៅនិងនាងគំ ខំព្រួតគ្នាវាយខ្លានោះស្លាប់ទៅ ។

ឯអ្នកគង់ ឃើញប្រពន្ធវាយខ្លាស្លាប់ហើយ បានស្ទុះអ្នីម្នាចេញពីរូងឈើមក យកដំបងវាយខ្លាស្លាប់ស្រាប់នោះថែមទៀត ។ ប្រពន្ធទាំងពីរបន្ទោសប្ដីថា " ខ្លាគេវាយងាប់ហើយ ធ្វើជាមកវាយថែមទៀត ប្រុសអី ។

កំសាកញីដូច្នេះ " ។ អ្នកគង់ ដេរបំពានទៅប្រពន្ធថា " មិនដែលមានស្រីណាវាយខ្លាស្លាប់ទេ មានតែប្រុស ទើបហ៊ានវាយខ្លា ទាល់តែស្លាប់ " ហើយអ្នកគង់ក៏បានបោចវល្លិចងខ្លានោះ នាំប្រពន្ធសែងចូលទៅក្នុងស្រុក ។ អស់អ្នកស្រុកឃើញអ្នកគង់សែងខ្លាមក គេបបួលគ្នាទៅមើលពាសពេញហើយគេសួរថា " អ្នកឯង ធ្វើដូចម្ដេច បានជាបានខ្លានេះ ត្បិតខ្លានេះសាហាវណាស់ វាតែងតែខាំបំពុស្ស ម្នាក្របីគោ ស៊ីច្រើនណាស់ហើយ " ។ ប្រពន្ធអ្នកគង់ក៏និយាយប្រាប់អ្នកស្រុកថា " អ្នកគង់គាត់ឃើញខ្លាវាបោលមក គាត់រត់ចូលក្នុងរូងឈើ ខ្ញុំពីរនាក់ជាស្រី ។

---

១ ច្បាប់សរសេរដៃ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យលេខ C.20B របស់លោក E Aymonier បាត់ការប្រមូលក្រង ទំព័រ ២៦ ខាងភាសាខ្មែរ និងកម្ពុជសុរិយាលេខ៤៤៦ ឆ្នាំ ១៩៣៧ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ព្រួតគ្នាវាយខ្លាទាល់តែស្លាប់ ។ អ្នកគង់ឮប្រពន្ធនិយាយប្រាប់គេដូច្នោះ ក៏បញ្ចោររំលោភទៅលើប្រពន្ធថា “ មិនដែលមានស្រីណាខ្លាំងពូកែ ហ៊ានវាយខ្លាស្លាប់ទេ មានតែប្រុសទើបខ្លាំងពូកែ ហ៊ានវាយខ្លាឲ្យស្លាប់បាន ” ។ អ្នកគង់ ក៏អួតប្រាប់អ្នកស្រុកថា “ កាលដែលខ្លា វាស្ទុះមកនឹងខាំដូច្នេះ ខ្ញុំផាក់ស្នៀតគុនដូច្នេះបានជាវាយវាបាន ” ហើយអ្នកគង់ ធ្វើជាលោតគុនវាយខ្លា ឲ្យអ្នកស្រុកមើល ។ ឯអស់អ្នកស្រុក កោតខ្លាចអ្នកគង់រាល់គ្នា ហើយឲ្យឈ្មោះថា “ គង់ហ៊ាន ” តាំងពីថ្ងៃនោះមក ឮល្បីឈ្មោះគង់ហ៊ាន ជាអ្នកពូកែ ចេះគុនវាយខ្លាស្លាប់ ។ រឿងនេះជ្រាបដល់ស្ដេច ។ ក៏ឲ្យយកទៅចិញ្ចឹមធ្វើជាសេនាសម្រាប់ច្បាំងសង្គ្រាម ។

លុះយូរបន្តិចទៅ ចួនជា មានសឹកគេលើកមកច្បាំងយកនគរ ស្ដេចទ្រង់ប្រើគង់ហ៊ានឲ្យទៅច្បាំង ។ គង់ហ៊ាន ឮស្ដេចទ្រង់ប្រើឲ្យទៅជួយច្បាំងសឹកដូច្នោះ ភ័យណាស់ ពុំដឹងបើគិតដូចម្ដេច នឹងមិនទៅច្បាំងមិនបាន ត្បិតស្ដេចទ្រង់ប្រើហើយ ហើយខ្លួនបានទាំងល្បីឈ្មោះជាអ្នកខ្លាំងពូកែផង ត្រឡប់មកវិញ ដេកសន្ធឹកសន្ធៃ អត់បាយ ។ ប្រពន្ធទាំងពីរនាក់ចូលទៅសួរថា ម្ដេចបានជាអ្នកដេកអត់បាយដូច្នេះ មានបើហេតុភេទអ្វី ប្រការដូចម្ដេច ? ។ គង់ហ៊ានប្រាប់ថា ត្បិតស្ដេចទ្រង់ប្រើបងឲ្យទៅច្បាំងសឹក ឥឡូវនេះ បងខ្លាចសឹកនោះណាស់ មិនដឹងបើគិតដូចម្ដេចទេ ប្រពន្ធឆ្លើយឡើងថា អ្នកកុំព្រួយចិត្ត ធានាលើខ្ញុំទាំងអស់អ្នកក្រោកឡើង ពិសាបាយឲ្យឆ្អែត ងូតទឹកឲ្យស្រួលខ្លួនចុះ ។ គង់ហ៊ានឮប្រពន្ធលួងលោមដូច្នោះ បានធូរក្នុងចិត្ត ក្រោកឡើងងូតទឹក ស៊ីបាយ រៀបគ្រឿងប្រដាប់ទៅច្បាំង, លុះរៀបរួចហើយដល់បានពេលាល្អ ក៏ចូលទៅក្រាបបង្គំលាស្ដេចចេញទៅច្បាំង , យកទាំងប្រពន្ធទៅផង ។ គង់ហ៊ានជិះខាងក្បាលដំរី ប្រពន្ធជិះខាងក្រោយ មានរេហ៍ពលហែហមអមមុខក្រោយជាក្បួនទ័ព គ្រៀបត្រាពាសពេញ លុះជិះទៅជិតខ្មាំងសត្រូវ មើលឃើញច្បាស់ប្រាកដ គង់ហ៊ានភ័យណាស់ លេចអាចម៍លេចនោមញ័រដៃជើង ដូចគេអង្រួនក្បាលដំរី ។ ឯដំរីគិតស្មានថា គេអង្រួនឲ្យខ្លួនបោលចូល ក៏ចេះតែបោលសម្រុកចូលទៅ មុនរេហ៍ពលទាំងអស់គ្មាននរណាតាមទាន់ ។

ឯខ្មាំងសត្រូវ ឃើញគង់ហ៊ានបំបោលដំរីចូលដូច្នោះ គិតស្មានថាបេទីពនេះពូកែណាស់ ក៏បាក់ទឹកចិត្ត រត់យកតែព្រះអាយុរដោយខ្លួនទៅ ។ គង់ហ៊ាន ឃើញខ្មាំងរត់ទៅអស់ ក៏ធ្វើជាអួតក្អេងក្អាង ឲ្យអស់នាហ្មឺននិងរេហ៍ពលកោតខ្លាច ។ អស់នាហ្មឺន ឃើញគង់ហ៊ានលេចអាចម៍ដាក់ក្បាលដំរី ស្អុយពាសពេញដូច្នោះ គេសួរថា " លោកមេទ័ព ថ្វីក៏លេចលាមកដូច្នេះ ? " ។ គង់ហ៊ានឆ្លើយឡើងថា " បើកំពុងតែច្បាំងនឹងសត្រូវហើយឈឺផ្ទៃ នឹងចុះទៅដោះទុក្ខសត្វឯណាបាន មានតែដោះទុក្ខសត្វលើក្បាលដំរីដូច្នេះឯង បើរវល់តែដោះទុក្ខសត្វ ខ្មាំងវាមិនកាប់ស្លាប់ឥតអំពើទៅហើយ ឬ ? "

អស់នាហ្មឺននិងរេហ៍ពល ឮគង់ហ៊ាននិយាយដូច្នោះ, អ្នកខ្លះមានប្រាជ្ញា គេដឹងថា គង់ហ៊ានខ្លាច, អ្នកខ្លះមិនសូវមានប្រាជ្ញា ក៏កោតខ្លាចគង់ហ៊ានណាស់ ។ ឯគង់ហ៊ាន បានឈ្នះទ័ព ត្រឡប់ចូលមកក្នុងនគរវិញ ហើយចូលទៅក្រាបថ្វាយបង្គំស្ដេច ។

ស្ដេចទ្រង់ជ្រាបថា គង់ហ៊ានទៅច្បាំងឈ្នះ ដេញខ្មាំងរត់ខ្ចាត់ខ្ចាយអស់ទៅ ទ្រង់ត្រេកអរណាស់ ទ្រង់ព្រះរាជទានយសសក្តិជានាហ្មឺនធំ ហើយ ព្រះរាជទានព្រះរាជទ្រព្យ គ្រឿងបណ្ណាការជាច្រើន ។

តាំងតែពីថ្ងៃនោះមក គង់ហ៊ាន រឹតតែអួតខ្លាំងពូកែក្អេងក្អាងឡើងទៀត ។

លុះក្រោយមកទៀត មានក្រពើសាហាវមួយ ចេះតែដេញខាំអស់មនុស្សម្នា អ្នកឈ្មួញជួញលក់ដូរ ដើររកស៊ីខាងជើងទឹកជើងកំពង់ គេខ្លាចរអាគ្រប់គ្នា មិនមានអ្នកណាហ៊ានចុះមុជទឹក ឬដើរឆ្លងសោះ ។ អស់រាស្ត្រលំបាកចិត្តណាស់ ។ រឿងនោះក៏ជ្រាបទៅដល់ស្ដេច ។ ទ្រង់ត្រាស់ប្រើឲ្យគង់ហ៊ានទៅចាប់ក្រពើ ។ ឯគង់ហ៊ាន ឮព្រះបន្ទូលដូច្នោះ នឹកភ័យណាស់ ប៉ុន្តែមិនហ៊ានទទឹងព្រះបន្ទូល ក៏ទទួលថា នឹងយកអាសាសូមទ្រង់កុំព្រួយព្រះរាជហឫទ័យ ។ គង់ហ៊ាន ត្រឡប់មកដល់ផ្ទះនិយាយនឹងប្រពន្ធថា " គេហ៍អើយ ! ឥឡូវនេះ ស្ដេចទ្រង់ប្រើយើងឲ្យទៅចាប់ក្រពើក្នុងទន្លេ ត្បិតក្រពើសាហាវណាស់, ម្តងនេះ ឃើញជាមិនរួចខ្លួនទេ មុខជាក្រពើខាំស្លាប់មិនខាន, ពីមុន នៅលើគោក គ្រាន់នឹងមើលទៅ

ឃើញ ឥឡូវនេះនៅក្នុងទឹក ធ្វើដូចម្ដេចនឹងគេចរួច ? ប៉ុន្តែស្ដេចទ្រង់ប្រើហើយ នឹងមិនទៅក៏មិនបាន បើដូច្នេះ មានតែទៅលោតទឹកឲ្យក្រពើខាំស្លាប់តែម្ដងទៅ ” គង់ហ៊ាន គិតគ្នានឹងប្រពន្ធដូច្នោះហើយ ក៏ហៅអស់កូនក្មួយមក ធ្វើជាទៅចាប់ក្រពើ ។ អស់មនុស្សម្នា មហាជន បានឮថា គង់ហ៊ានបានទៅចាប់ក្រពើក៏បបួលគ្នាទៅមើលពាសពេញ ។ លុះគង់ហ៊ានទៅដល់កំពង់ទឹក បានឃើញក្រពើ ហែលមកប្របច្រាំង ត្រង់ទីដែលមានដើមឈើពីរដើមដុះជិតគ្នា មានប្រគាប គាត់ក៏ស្ទុះលោតចុះទៅក្នុងទឹកត្រង់ទីនោះ ដោយគិតថា លោតទៅឲ្យក្រពើវាខាំឲ្យស្លាប់ទៅទេ , ប៉ុន្តែ ក្រពើវាឮសូរសន្ធឹកគង់ហ៊ានលោតចុះ ក៏ភ្ញាក់ព្រើត ប្រឹងលោតឡើងដូចគេប្រហកក្ទុះប្រគាបឈើ ជាប់ពាក់កណ្ដាលខ្លួន រុញទៅមុខ ក៏មិនរួច ថយមកក្រោយក៏មិនរួច ។ គង់ហ៊ាន មុជទៅក្នុងទឹក ងើបឡើងឃើញក្រពើជាប់នឹងដើមឈើដូច្នោះ ស្រែកបង្គាប់កូនក្មួយ ឲ្យយកលំពែងមកចាក់ កាប់ ក្រពើនោះស្លាប់ទៅ ។ ឯអ្នកដែលមើលទាំងប៉ុន្មាន គេគិតស្មានថា គង់ហ៊ានចាប់ក្រពើ បោះមកឲ្យជាប់នឹងដើមឈើ ក៏កោតខ្លាចគង់ហ៊ានក្រៃពេក ។

គង់ហ៊ាន បានឃើញក្រពើស្លាប់ដូច្នោះ ក៏រឹតតែក្អេងក្អាង អួតខ្លាំងពូកែឡើងទៀត ហើយចូលទៅក្រាបទូលស្ដេច តាមខ្លួនបានចាប់ក្រពើចោលឡើងមកលើគោក ។ ស្ដេចក៏ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានយសសក្តិ ឲ្យគង់ហ៊ាន ឡើងជាធំលើសពីមុនទៀត ហើយទ្រង់ព្រះរាជទានទាំងអំណាច ទាំងរង្វាន់ជាច្រើន ។

## សំណាបយោធជី ស្រីយោធប្រុស

## ៥. រឿងពាក្យសុភាសិត តម្លៃ ៣០ តម្លឹង(១)

កាលពីព្រេងនាយ មានជនពីរនាក់ប្ដីប្រពន្ធ, បុរសជាប្ដី បានឃើញគេរៀនរបៀនពូកែ ចង់រៀនណាស់ យកប្រាក់ ៣០ តម្លឹង លាប្រពន្ធដើរទៅរករៀន ដើរពីស្រុកមួយដល់ខែត្រមួយឮគេថា ទីត្រង់ណា មានអ្នកចេះរបៀនអាគមគាថាពូកែ ក៏ទៅរកត្រង់នោះ ដល់ទៅជួបនឹងគ្រូណាពូកែ គេសូត្រឲ្យស្ដាប់ គេធ្វើឲ្យមើលដូចម្ដេច ៗ ក៏ចេះតែមិនចូលចិត្ត, លុះដើរឆ្ងាយទៅ ៗ ក៏បានជួបនឹងតាចាស់ម្នាក់ ។ តាចាស់សួរថា "អ្នកឯងទៅណា ដើរមកតែម្នាក់ឯង ស្វះស្វែងរកអ្វី?" ។ បុរសនោះឆ្លើយថា "ឱ! តាអើយ! ខ្ញុំមកនេះ ត្បិតឮគេថា នៅទីនេះ មានគ្រូចេះរបៀនពូកែ បានជាខ្ញុំខំសង្វាតមក ក្រែងតាចេះដឹង ប្រដៅចៅផង" ។ តាចាស់ឆ្លើយថា តាមានរបៀនបីបទ តម្លៃ ៣០ តម្លឹង បើចៅឯងកាន់ជាប់ ចៅឯងមិនច្រុតទេ គង់បានដូចចិត្ត បើមានកិច្ច មានដំណើរអ្វី ឲ្យសូត្ររបៀនតានេះចុះ ពូកែណាស់" ។ បុរសនោះថា "តាសូត្រឲ្យខ្ញុំស្ដាប់មើល! បើខ្ញុំចូលចិត្ត ខ្ញុំយក" តានោះសូត្រឲ្យស្ដាប់ថា "រពឹសដៃផ្ទៃឆ្អែត, ដេកយប់ កុំនិយាយនឹងស្រី, ឃ្លានកុំអាលស៊ី" ។ បុរសនោះស្ដាប់បាន ចូលចិត្ត ក៏ប្រគល់ប្រាក់ ៣០ តម្លឹងឲ្យតានោះ ហើយទន្ទេញរបៀនទាំងបីបទនោះ ចាំស្ទាត់រត់មាត់ ។ ឯតាចាស់ប្រាប់ថា "បើចៅកាន់របៀនទាំងបីបទនេះបាន តាឲ្យទទេ មិនយកតម្លៃទេ" ហើយតាចាស់ ប្រគល់ប្រាក់ឲ្យបុរសនោះវិញ ។ បុរសនោះក៏លាតាចាស់នោះ វិលមកស្រុកវិញ ។ មាត់បុរសនោះចេះតែទន្ទេញរបៀនបីបទនោះ ចប់តែតាមផ្លូវមក ពុំមានភ្លេច ។ លុះដើរឆ្ងាយ បន្តិចមក ជួបនឹងសំពៅឈ្នួញមួយ, បុរសនោះ ក៏សុំសំពៅគេដោយសារមកស្រុក, ជង្ហោ

---

១- ច្បាប់សរសេរនៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ G. 20.B របស់លោក E.Aymonier ប្រមូលប្រាង ទំព័រ ៤៨ ខាងភាសាខ្មែរ ។

សំពៅ ក៏ព្រមឲ្យដោយសារ ។ បុរសនោះ តាំងពីចុះមកនៅក្នុងសំពៅថ្ងៃណា ក៏ចេះតែទន្ទេញរបៀនបីបទនោះ ហើយចេះតែជួយលាង ជួយថែទាំ ជួយជួសជុលសំពៅ ដូចជារបស់ខ្លួន ។ នាយសំពៅនឹកក្នុងចិត្តថា “ អ្នកនេះតាំងតែពីចុះដោយសារសំពៅអញកាលណាមក គាត់ចេះតែធ្វើការដូចជារបស់គាត់ នឹកហើយ ក៏ស្រឡាញ់បុរសនោះ ឲ្យរៀបបាយទឹកឲ្យស៊ីតែរាល់ថ្ងៃរៀងមក ។ ឯបុរសនោះពុំខ្ជិលសោះ ចេះតែខំធ្វើការក្នុងសំពៅ ដូចជាកូនឈ្នួលឯទៀតៗ ។ នាយសំពៅ នឹកតែក្នុងចិត្តថា “ បើកាលណាបានដល់ស្រុក អញនឹងចែករបស់ទ្រព្យឲ្យចៅនេះរកស៊ីតទៅ ” ។ លុះបើកសំពៅមកដល់កណ្ដាលស្រុកមួយ បានឃើញវិហារមួយគេរៀបអណ្ដាប់ពោរពាស សុទ្ធតែចំណី ស្រា បាយ ទុកឲ្យយក្សវា មកស៊ី ។

ឯអ្នកសំពៅ កាលដល់វិហារនោះ ក៏ចតសំពៅ ឡើងទៅលេងឃើញចំណីទាំងនោះ ពុំមានមនុស្ស ក៏នាំគ្នាស៊ីផឹកស្រាស្រវឹងដេកនៅក្នុងវិហារនោះទាំងអស់គ្នា ខានតែបុរសម្នាក់នោះ មាត់គាត់ចេះតែទន្ទេញថា “ រពឹសដៃថ្ពៃឆ្អែត ដេកយប់ កុំនិយាយនឹងស្រី ឃ្លាន កុំឆាលស៊ី” ដោយគិតថា “ចំណីអស់នេះមានហេតុអ្វីមួយហើយ បានជាគេរៀបទុកនៅទីនេះ, ឥឡូវ ពួកទាំងអស់នេះស៊ី គង់តែមានភ័យមិនខាន” គិតដូច្នោះហើយ ពុំហ៊ានស៊ី ឡើងទៅពួនលើធ្នឹមវិហារ ដោយស្ងៀមស្ងាត់ចាំលបមើល។

លុះដល់ថ្ងៃត្រង់ យក្សមកដល់ ហើយវាខឹងខ្លាំងណាស់ថា “ នរណាក៏ហ៊ានមកស៊ីចំណីអស់នេះ ” ។ យក្សថាហើយ ក៏ប្រើដំបងមកវាយមនុស្សដែលដេកនោះស្លាប់ទាំងអស់ទៅ ។ ឯដំបងក៏វិលមកខាងយក្សវិញ ហើយយក្សកាច់កអស់មនុស្សទាំងនោះស៊ីអស់ទៅ រួចក្រឡេកមើលក្រឡេមក្រឡឹម ។ បុរស ឃើញយក្ស ភ័យណាស់ មាត់ចេះតែទន្ទេញរបៀនបីបទ ហើយគិតថា “ បើអញស្រែក ក្រែងយក្សឮ វាឃើញអញ ហើយវានឹងស៊ីអញទៀត” គិតហើយ ក៏លោតចុះពីលើធ្នឹម ស្រែករាំស ឡើង យក្សភ័យណាស់ រត់ចោលដំបងទៅបាត់ទៅ ។ បុរសនោះ បានដំបងវាយឯងហើយ ក៏ដើរត្រឡប់មកស្រុក ចោលសំពៅនៅកំពង់វិហារនោះឯង ។

លុះដើរមកដល់ផ្ទះ ក្នុងវេលាយប់ បុរសនោះ យកដំបងទៅលាក់ក្រោមជណ្ដើរ យកថ្មសង្កត់លើ ហើយឡើងទៅដេកលើផ្ទះ ។ ប្រពន្ធសួរ ប្រាប់ប្រពន្ធថា ចាំព្រឹក

សឹមនិយាយប្រាប់ " ។

ក្រោយពេលដែលប្ដីទៅ ប្រពន្ធនៅផ្ទះ វាមានសហាយ, វេលាយប់ ដែលប្ដីមកដល់ផ្ទះ សហាយនោះ វាមកស្ដាប់នៅក្រោមផ្ទះ វាចង់ដឹងរឿងឆាប់ វាឲ្យមេស្រីសហាយវា សួរថា ដំណើរដូចម្ដេច ក៏ចាំព្រឹកទើបនិយាយបាន ? " ។ ប្រពន្ធចេះតែឧបអង្វែល ។ ទ្រាំពុំបាន ប្ដីក៏និយាយប្រាប់ថា : អញនិយាយនឹងឯងនេះខុសគ្រូហើយ ត្បិតគ្រូផ្ដាំថា " ដេកយប់ កុំនិយាយនឹងស្រី " ឥឡូវនេះ អញនិយាយ ខុសបណ្ដាំគ្រូហើយ ។ ប្រពន្ធ សួរថា " អ្នកទៅបានរបស់អ្វីមកខ្លះ " ។ ប្ដីថា " បានតែរបៀនបីបទ ហើយត្រឡប់មកវិញ ដល់កណ្ដាលផ្លូវ បានដំបងវាយឯងទៀត " ។ ប្រពន្ធសួរថា " ដំបងនោះ ទុកនៅឯណា ឥឡូវនេះ ? ខ្ញុំចង់ឃើញ " ។ ប្ដីថា " អញទុកក្រោមជណ្ដើរ យកថ្មគ្រប " ថាហើយក៏ដេកលក់ទៅ។

សហាយ លបស្ដាប់ឮហើយ ក៏ទៅក្រោមជណ្ដើរ រើសយកដំបងនោះទៅបាត់ទៅ ។

លុះព្រឹកព្រហាមស្រាង ៗ ឡើងបុរសនោះ រឭកពីដេក ចុះទៅរកដំបងពុំឃើញក៏ប្រាប់ប្រពន្ធថា "អញប្រាប់មិនជឿ អញថា ខុសគ្រូហើយ ឯងចេះតែលួងអញទាល់តែអញប្រាប់ ឥឡូវនេះ មនុស្សឮ វាលួចយកដំបងបាត់ហើយ " ។ ប្រពន្ធឮហើយ ដឹងថា សហាយលួច ក៏មិនស្ដី ដណ្ដាំបាយឲ្យប្ដីស៊ី ។ រួចហើយ បុរសនោះក៏យកខ្សែមកចងថ្មដែលគ្របលើដំបងនោះ នាំទៅប្ដឹងមេស្រុក ឲ្យជំនុំជម្រះរកចោរឲ្យ ។ មេស្រុក ពុំដឹងបើជំនុំជម្រះដូចម្ដេច ពីព្រោះថ្មមិនចេះស្ដី គេជេរថា " អាកំព្រើល ! តាំងពីដូនតាមក នរណាដែលឃើញដំបងវាយឯង " គេគម្រាមហើយគេដេញចេញទៅ ។ បុរសនោះចេះតែអូសថ្មទៅប្ដឹង តាំងតែពីមេស្រុក ដល់ទៅលោកយមរាជ អ្នករាជការគ្រប់ក្រសួង គេចេះតែដេញចេញ គេថា មនុស្សឆ្កួត គេមិនឲ្យចូល ។ បុរសនោះ អូសថ្មទៅថ្វាយស្ដេច ។ ទ្រង់សួរសព្វគ្រប់ហើយ ទ្រង់មានព្រះបន្ទូលប្រាប់អស់នាម៉ឺនថា "មែនបានគេថា, មានប្រឡាយ បានទឹករាហូរ, មានសម្រាម បានភ្លើងឆេះ, អស់នាម៉ឺន កុំថាវាឆ្កួត សេចក្ដីនេះមែនហើយបានជាវាហ៊ានថា ស្ដេចមានបន្ទូលប្រាប់បុរសថា " ណ្ហើយ វិលទៅផ្ទះចុះ

កាលណាអញប្រើឲ្យគេទៅហៅសឹមមក " ។ បុរសនោះទទួលថា " ព្រះករុណាថ្លៃវិសេស " ហើយក្រាបថ្វាយបង្គំលាទៅវិញ ។

ក្រោយពេលបុរសនោះទៅ ស្ដេចទ្រង់ព្រះរាជបញ្ជា ឲ្យប្រាប់បណ្ដារាស្ដ្រថា " ត្បិតស្ដេចឲ្យអស់ព្រះស្នំចេញរាំបីថ្ងៃបីយប់ ឲ្យបណ្ដារាស្ដ្រមើលតាមចិត្តពុំមានឃាត់ឃាំងឡើយ " ហើយទ្រង់ឲ្យរៀបលេងល្ខោន ។ កាលនោះ អស់រាស្ដ្រសឹងតែចូលទៅមើលគ្រប់គ្នា ។ ស្ដេចទ្រង់យាងចូលទៅ ក្នុងព្រះរាជដំណាក់ ជ្រើសរើសប្រេងក្រអូបយ៉ាងឯកមួយដបដែលសម្រាប់តែស្ដេច អស់រាស្ដ្រនិងនាម៉ឺន ពុំដែលមាន ទ្រង់ប្រើអាមាត្យម្នាក់ យកទៅឲ្យបុរសនោះ ហើយប្រាប់ថា " ស្ដេចទ្រង់ព្រះរាជទានឲ្យអ្នកឯង និងប្រពន្ធអ្នកឯងលាប, ប៉ុន្ដែឲ្យអ្នកឯងនៅផ្ទះ កុំទៅមើលល្ខោន ឲ្យតែប្រពន្ធទៅមើលបានហើយ" ។ អាមាត្យអ្នកយកទៅឲ្យប្រាប់សព្វគ្រប់ហើយ " វិលទៅក្រាបបង្គំទូលស្ដេចវិញ ។ បុរសនោះបានប្រេង ក៏ហៅប្រពន្ធមកហុចប្រេងទៅឲ្យ ប្រាប់ថា "ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ព្រះរាជទានប្រេងនេះមក ព្រោះទ្រង់អាណិតស្រឡាញ់យើង ឲ្យយើងលាបទៅមើលល្ខោននឹងគេ, តែឥឡូវនេះអញឈឺក្បាល ឯងយកទៅលាប ហើយទៅមើលល្ខោននឹងគេចុះ ។ ឯប្រពន្ធ ឮប្ដីបើកឲ្យទៅ ហើយឲ្យទាំងប្រេងទៅលាបផងដូច្នោះ អរពន់ពេក ដោយពុំបានដឹងកលជាគេចាប់ ក៏យកប្រេងទៅឲ្យសហាយលាបផង ហើយបណ្ដើរគ្នាទៅមើលល្ខោនឈរទន្ទឹមគ្នា លុះបន្តិចទៅស្ដេចទ្រង់ធុំក្រអូបប្រេងនោះ ទ្រង់ខ្សឹបប្រាប់នាម៉ឺនម្នាក់ "ចូរអ្នកទៅហិតក្លិនអស់បណ្ដារាស្ដ្រ ដែលមើលល្ខោនទាំងប៉ុន្មាន បើធុំក្លិនប្រេងក្រអូបយ៉ាងនោះ ប៉ុន្មាននាក់ ចូរអ្នកនាំយកមកឲ្យអញជាឆាប់ " ។

នាម៉ឺននោះ ក្រាបថ្វាយបង្គំហើយ ទៅហិតមនុស្សឯទៀត មិនធុំសោះ ធុំតែប្រុសម្នាក់ ស្រីម្នាក់ ដែលឈរទន្ទឹមគ្នា លាបប្រេងក្រអូបទាំងពីរនាក់នោះ ក៏នាំទាំងប្រុសទាំងស្រី យកទៅថ្វាយស្ដេច ។ ឲ្យលែងរាំទៅ ហើយទ្រង់ឲ្យហៅទាំងប្រុសទាំងស្រី មកដល់ហើយ ទ្រង់សួរថា " នេះជាប្រពន្ធចោរឯងមែនឬ ? " បុរសនោះក្រាបទូលថា " មែន " ។ ទ្រង់មានព្រះបន្ទូលសួរ ទៅប្រុសសហាយនោះថា ឯងបានទៅលួចដំបងចោរនេះមែនឬ ? " ។ សហាយនោះក្រាបបង្គំទូល

ថា "លួចមែន " ។ ទ្រង់ឲ្យទៅយកដំបងនោះមក ឲ្យយកសហាយទាំងប្រុសស្រីនោះ ទៅដាក់ច្រវាក់ធ្វើទោស ។ បុរសជាម្ចាស់ដំបង ក្រាបថ្វាយបង្គំសូមទោស ហើយក៏ប្រគល់ទាំងផ្ទះសម្បែង ទាំងប្រពន្ធឲ្យទៅសហាយនោះទាំងអស់ដោយពុំមានខឹងអ្វីឡើយ ។ ប្រុសសហាយនោះ អរណាស់សំពះសូមទោស រួចវិលទៅវិញ ។

ឯបុរសម្ចាស់ដំបង ថ្វាយដំបងទៅស្តេច ហើយក្រាបលាទៅទៀតស្តេចឃាត់ក៏ពុំព្រម ទ្រង់មានព្រះបន្ទូលថា " ដំបងវាយឯងនេះថ្លៃណាស់ទ្រង់ព្រះរាជានុញ្ញាតឲ្យបើកឃ្លាំងមាស–ប្រាក់ឲ្យបុរសនោះយកតាមចិត្ត ។ បុរសនោះ រើសអស់ទាំងឃ្លាំងមាសប្រាក់អម្បាលនោះទៅ ឃើញកាំបិតបន្ទោះមួយចាស់ នៅក្រោមឃ្លាំង ក៏យកកាំបិតនោះ និងប្រាក់បន្តិចបន្តួចគ្រាន់ចាយតាមផ្លូវ ហើយចូលទៅក្រាបថ្វាយបង្គំលាស្តេច ដើរចេញទៅទៀត ។ ស្តេចពុំមានព្រះបន្ទូលអ្វីទេ . តែអស់នាហ្មឺន គេគ្រះគិះដៀលបុរសនោះ ថាជាមនុស្សឆោត ប្រាក់មាសមិនយក ទៅយកឯកាំបិតច្រែះស៊ី ។

បុរសនោះ ក៏ដើរចេញអំពីនគរនោះ បានទៅដល់នគរមួយផងទៀត ។ ជួនជាថ្ងៃនោះ ស្តេចនគរនោះទ្រង់មានព្រះបន្ទូលបង្គាប់សេដ្ឋីម្នាក់ថា "ព្រឹកស្អែក ទ្រង់នឹងទៅក្រសាលព្រៃ ឲ្យមហាសេដ្ឋីធ្វើរទេះមួយយ៉ាងល្អល្អះ ឲ្យឆ្លាក់ក្បាច់ លាបលនឲ្យហើយ ឲ្យទាន់ក្នុងពេលព្រឹកស្អែកនេះ បើធ្វើពុំទាន់ នឹងយកទោសដល់ជីវិត ។ រីឯមហាសេដ្ឋីនោះ ធ្វើពុំទាន់ ហើយពុំធ្វើរទេះ បែរជាធ្វើឯមឈូសទៅវិញ ។

ថ្ងៃនោះ ជួនជាបុរសនោះ ដើរទៅឃើញសេដ្ឋីនោះ កំពុងតែធ្វើបុណ្យ ក៏សួរថា "ចុះលោកមានការអ្វី បានជាធ្វើបុណ្យមានក្តារមឈូសផងដូច្នោះ ? " ។ គេប្រាប់ថា "ស្តេចឲ្យធ្វើរទេះមួយ លាបលនយ៉ាងល្អ ឲ្យទាន់ព្រឹកនេះ ស្តេចក្រសាលព្រៃ បើធ្វើពុំទាន់ស្តេចនឹងយកទោសដល់ជីវិត , ឥឡូវនេះ មហាសេដ្ឋីធ្វើពុំទាន់ ដឹងខ្លួនថាស្លាប់ បានជាធ្វើមឈូសធ្វើបុណ្យវិញ " ។

បុរសនោះ ឆ្លើយថា " ក្រអីចុំណ្ណឹង ឲ្យតែបាយខ្ញុំស៊ីខ្ញុំនឹងធ្វើឲ្យ ។ ទាន់ព្រឹកនេះ " ។ មហាសេដ្ឋីបានឮដូច្នោះ អរណាស់ ហើយក៏ឲ្យរៀបបាយទឹកស៊ីឆ្អែត រួច

ប្រគល់ឈើឲ្យធ្វើរទេះ ។ បុរសនោះ ក៏ធ្វើតែនឹងកាំបិត១ដែលយកពីក្រោមបាតឃ្នាំង មកនោះ បានរួចស្រេចក្នុងយប់នោះហើយលាបលនយ៉ាងល្អ ព្រឹកឡើង ក៏អូសរទេះទៅថ្វាយស្ដេចៗ ទ្រង់ទតឃើញ ទ្រង់ឲ្យរៀបប្រដាប់ប្រដាទៅក្រសាលព្រៃ ។ ឯមហាសេដ្ឋីលុះរួចពីស្លាប់ហើយ ក៏នឹកក្នុងចិត្តថា. "អ្នកនេះ មានគុណធ្ងន់ណាស់ ឥឡូវនេះ នឹងរកអ្វីសងឲ្យស្មើគ្នាន មានតែកូនក្រមុំ ១ ល្មមឲ្យមានប្ដីដូច្នោះ មានតែអញការឲ្យអ្នកនោះ" គិតហើយ ក៏ហៅមកការឲ្យទៅ ។ លុះការរួចហើយ ក្នុងយប់នោះ ពេលផ្សំដំណេក បុរសនោះ គិតល្បងចិត្តប្រពន្ធ ហើយធ្វើជាផឹកស្រាស្រវឹងដេកទៅ លុះយប់យូរបន្តិចក៏ធ្វើជាក្អួតប្រឡាក់ប្រពន្ធអស់ ។ កូនសេដ្ឋីឃើញកំអួតប្ដីប្រឡាក់ខ្លួនដូច្នោះ ក៏ស្រែកឡើងក្នុងយប់នោះថា "លោកឪពុករកប្ដីឲ្យខ្ញុំជាមនុស្សប្រមឹក ក្អួតប្រឡាក់ខ្ញុំអស់ហើយ ខ្ញុំទ្រាំមិនបានទេ » ។ មហាសេដ្ឋីឮកូនស្រែកដូច្នោះ ក៏ឃាត់ថា "កូនដេកទៅ កុំនិយាយ ត្បិតប្ដីកំពុងស្រវឹង ហើយគេមានគុណផង" ឃាត់ដូចម្ដេច ក៏កូនស្រីមិនស្ដាប់ហើយរាចេះតែរអ៊ូថា "បើឲ្យទៅក្ដែក្នាទ្រាំបាន ឯមនុស្សប្រមឹកខ្ញុំទ្រាំមិនបានទេ" ។

លុះព្រឹកឡើង បុរសនោះ រលីកពីដេក ក៏ចូលទៅរកសេដ្ឋីប្រគល់កូនឲ្យវិញ ប្រាប់ថា "មិនព្រមយកទេ" រហើយថា មិនបានពាល់ដៃជើងឡើយ ។ មហាសេដ្ឋីឃាត់សុំទោសឲ្យកូនយ៉ាងណាក៏បុរសនោះពុំព្រមនៅ ពុំព្រមយក ហើយលាមហាសេដ្ឋី យកតែកាំបិតដើរទៅទៀត ។ លុះស្ដេចយាងមកពីព្រៃ ទ្រង់ឲ្យទៅរកជាងដែលធ្វើរទេះនោះ ពុំឃើញ ទ្រង់ស្ដាយណាស់ ទ្រង់ឲ្យអស់នាហ្មឺនចាត់សំបុត្ររកគ្រប់ខេត្ត ក៏ពុំឃើញហើយទ្រង់ស្ងៀមទៅ ។

ឯបុរសនោះ លាសេដ្ឋីដើរទៅឆ្ងាយ ក៏បានទៅដល់នគរមួយដទៃទៀត ។ ស្ដេចនគរនោះ ទ្រង់ឲ្យនាហ្មឺនម្នាក់ៗ ទៅដេកវេន ចាំយាមនៅចុងព្រះរាជរោងរាល់យប់ ។ ស្ដេចទ្រង់ចេញកាប់តែរាល់យប់ ចាប់តាំងពីថ្ងៃដែលទ្រង់បង្គាប់មកនោះ ស្លាប់អស់ជាច្រើន ។

នៅថ្ងៃដែលបុរសនោះទៅដល់ជួនត្រូវលើវេនចៅហ្វា ទៅដេកថ្វាយស្ដេចកាប់ចៅហ្វានោះ ក៏ធ្វើបុណ្យទានក្នុងថ្ងៃនោះ ។ បុរសនោះទៅដល់សួរគេថា " លោក

មានការណ៍អ្វី បានជាធ្វើបុណ្យទាន ហើយហេតុដូចម្ដេច ក៏បានជាកូនប្រពន្ធលោកយំរាល់គ្នាដូច្នេះ " ។ គេប្រាប់ថាលោក លោកត្រូវទៅដេកវេន ថ្វាយស្ដេចកាប់ ក្នុងពេលល្ងាចនេះ បានជាលោកធ្វើបុណ្យមុនស្លាប់ " ។ បុរសនោះថា « ឲ្យតែបាយខ្ញុំស៊ីចុះ ខ្ញុំទៅដេកថ្វាយស្ដេចកាប់ជួស» ។ គេឮដូច្នោះ ក៏ទៅជម្រាបចៅហ្វាឲ្យហៅបុរសនោះទៅ ហើយឲ្យរៀបបាយទឹកឲ្យស៊ី ។ រួចហើយសួរថា «បើអ្នកទៅដេកវេនថ្វាយស្ដេចជួសខ្ញុំ ខ្ញុំនឹងធ្វើបុណ្យឲ្យអ្នក» ។ បុរសនោះក៏ទទួលទៅដេកជួស ហើយសុំគ្រឿងប្រដាប់ដែលចៅហ្វានោះពាក់ យកមកពាក់ រួចហើយ ក៏លីកកាំបិតបន្ទោះ ចូលទៅដេកនៅចុងព្រះរាជរោងចាំស្ដេចចេញកាប់ ។ លុះទៅដល់ចុងព្រះរាជរោង បុរសនោះ ពុំដេកឡើយ ចាំមើលស្ដេច , ពេលយប់ជ្រៅស្ងាត់ ស្ដេចទ្រង់បើកទ្វារចេញមកទ្រង់កាន់ព្រះខ័ន យាងចូលមកនិងកាប់បុរសនោះ ឃើញស្ដេចយាងចូលមកជិត ក៏ស្ទុះចូលទៅចាប់ស្ដេចនេះជាប់ ហើយក៏ចាក់នឹងកាំបិតបន្ទោះបង្ហូសពីរបីដង ។ ហើយសួរថា «នរណា ចូលមកទាំងយប់នេះ ? ស្ដេចទ្រង់ឲ្យអញចាំយាមក្នុងយប់នេះ» ថាហើយ ក៏ចាក់បង្ហូសទៀត ។ ស្ដេចទ្រង់មានព្រះបន្ទូលថា « ទេ អញទេ » ។ « នរណាអញទេ ។ ! ។ «អញជាស្ដេច » ។ « ស្ដេចអីមកពេលនេះ , អញមិនដឹងទេ ! ត្បិតស្ដេចទ្រង់ឲ្យអញចាំរាជរោងយប់នេះ» ។

សួរដេញដោលដូច្នោះហើយ បុរសក៏លុតជង្គង់ថ្វាយបង្គំស្ដេចសូមទោស ។ ស្ដេចត្រាស់សួរថា «ចៅនៅឯណា ! ។ បុរសនោះថា « ខ្ញុំនៅផ្ទះចៅហ្វា » ។ ស្ដេចទ្រង់ជ្រាប ទ្រង់ញញឹម ហើយទ្រង់ចូលទៅវិញ ។

លុះព្រឹកឡើង បុរសនោះ លីកកាំបិតចេញពីក្នុងវាំងមកផ្ទះចៅហ្វា ។ អ្នកផងឃើញហើយ ឆ្ងល់ថា « បុរសនោះ ទៅដេកវេនថ្វាយស្ដេចកាប់ ម្ដេចក៏មិនស្លាប់ត្រឡប់ជាមកវិញ » ។ ចៅហ្វាសួរ បុរសនោះក៏ជម្រាបតាមដំណើរ សព្វគ្រប់ហើយជប្រាបថែមថា « ស្ដេចសព្វថ្ងៃនេះមិនមែនជាកាចទេ ត្បិតទ្រង់ពិសោធរកមនុស្សប្រាជ្ញចេះដឹងក្នុងនគរដើម្បីរក្សាស្ដេច បានជាទ្រង់ចាត់មនុស្សឲ្យយាម តែអ្នកដែលទៅយាមចេះតែដេកលក់ទើបស្ដេចទ្រង់កាប់ ចុះបើសត្រូវចូលទៅលុកលុយស្ដេចហើយយើងដេក

លក់នោះ តើនឹងជាយ៉ាងណាទៅ ? » ។ បុរសនោះនិយាយរឿងប្រាប់សព្វគ្រប់ ទើបភ្ញាក់ខ្លួនគ្រប់គ្នា ។

ចៅហ្វាយនោះ មានកូនក្រមុំមួយ ក៏ឲ្យជាប្រពន្ធបុរសនោះ ដោយគិតថា បុរសនេះ មានគុណធ្ងន់ណាស់ ។

លុះព្រឹកឡើង ស្ដេចទ្រង់ឲ្យហៅបុរសនោះមក ទ្រង់ឲ្យធ្វើជានាហ្មឺនធំរក្សាព្រះនគរ បន្ទាប់ពីព្រះអង្គ ។

វេលាស្ដេចទ្រង់ព្រះជរាទៅ ទ្រង់ពុំមានព្រះរាជបុត្រ នឹងសោយរាជ្យស្នងមានតែព្រះរាជធីតាមួយអង្គ ក៏ទ្រង់ព្រះរាជទានព្រះរាជធីតា និងរាជសម្បត្តិ ឲ្យបុរសនោះសោយរាជ្យជាស្ដេចតទៅ ។

## ពាក្យពិត មិនចេះស្លាប់

# ៦. រឿង មាយាស្រី(១)

កាលពីព្រេងនាយ មានបុរសម្នាក់ មានប្រពន្ធ នៅជាមួយគ្នា តែពុំមានកូនពុះយូរទៅ ប្រពន្ធនោះមានសហាយ នាំមកដេកក្នុងផ្ទះតែសព្វថ្ងៃ ។

ថ្ងៃមួយ ប្តីទៅជីកដំឡូងក្នុងព្រៃ ដល់ថ្ងៃក្តៅចូលទៅអាស្រ័យនៅខ្ទមអ្នកតា ១ ។ ប្រពន្ធរៀបចំអីវ៉ាន់ទៅបន់អ្នកតានោះ ឲ្យទៅធ្វើប្តីឲ្យស្លាប់ នឹងយកសហាយធ្វើប្តី, រៀបស្រេចហើយ ក៏យកអីវ៉ាន់នោះដើរចូលទៅក្នុងខ្ទមអ្នកតានោះ ។ ប្តីឃើញប្រពន្ធដើរចូលទៅខ្ទមអ្នកតា ក៏នឹកឆ្ងល់ថាប្រពន្ធអញ វាមករកអ្វីក្នុងខ្ទមអ្នកតានេះ?» គិតហើយ ក៏ចូលទៅពួន ក្រោយខ្នងអ្នកតា លបស្តាប់ប្រពន្ធ ។

ឯប្រពន្ធ ក៏ចូលទៅអុជទៀនធូប ហើយបន់អ្នកតាថា « ខ្ញុំមិនចង់យកប្តីខ្ញុំទេ ខ្ញុំយកប្តីទៀត សូមអ្នកតាកាច់ប្តីខ្ញុំឲ្យស្លាប់ទៅ ខ្ញុំនឹងថ្វាយជ្រូកមួយ » ។

ប្តីឮដូច្នោះ, ក៏ឆ្លើយឡើងពីក្រោយខ្នងអ្នកតា « អើ បើនាងមានសហាយ ហើយបើចង់ឲ្យកាច់ប្តីនាងឯងឲ្យស្លាប់នោះ ងាយទេ វិលទៅផ្ទះវិញ ត្រូវរកមាន់ក្រាបទាំងមេទាំងពងមួយសំបុក ស្ងោរឲ្យប្តីនាងឯងស៊ីទៅ វាស្លាប់ហើយ » ។

មេនោះឮដូច្នោះ ស្មានថាអ្នកតាបង្គាប់ ក៏ប្រញាប់វិលមកផ្ទះវិញរកទិញបានមេមាន់ក្រាបមួយសំបុក ស្ងោរទុកឲ្យប្តីស៊ី ដើម្បីនឹងឲ្យស្លាប់ ហើយនឹងបានយកសហាយ ។

---

១– ច្បាប់សរសេរដៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ C.20.B របស់លោក E– Aymonier ទំព័រ ៥៦ ខាងភាសាខ្មែរ និង កម្ពុជសុរិយា លេខ ៧-៨.៩: ឆ្នាំ១៩៣៧ ទំព័រ ៣២៩ គ្មានឈ្មោះអ្នករៀបរៀងទេ ។

លុះដល់ព្រលប់ ប្ដីមកពីជីកដំឡូង ដល់ផ្ទះហើយ សួរថា « គេហ៍អើយ ! បានអីស៊ីបាយ ? » ។ មេនោះឆ្លើយថា « ខ្ញុំបានមេនិងពង មាន់ក្រាបមួយសំបុក ស្ងោរទុកឲ្យអ្នក » ប្ដីថា « រៀបបាយមកស៊ី » ។

ប្រពន្ធក៏លើកបាយ ព្រមទាំងមេ និងពងមាន់ក្រាប មកឲ្យប្ដីស៊ី ។ ប្ដីស៊ីអស់ហើយ ធ្វើជាឈឺ ដេកថ្ងូរហ៊ឺ ៗ ។ មេនោះ អរណាស់គិតស្មានថា ប្ដីឈឺមែន ត្រូវនឹងពាក្យអ្នកតាបង្គាប់ហើយ ត្បិតឮថ្ងូរ ។ ឯប្ដី ក៏ធ្វើជាដេកទៅ ។ មេនោះ គិតស្មានថា ប្ដីស្លាប់ ក៏បើកទ្វារនាំយកសហាយចូលទៅដេកជាមួយ ។

អ្នកទាំងពីរកំពុងតែនិយាយគ្នា ប្ដីក៏ក្រោកឡើងអង្គុយ ហៅប្រពន្ធមកប្រាប់ថា « រងាណាស់ »

ឯប្រុសសហាយ ឃើញប្ដីមេនោះ ក្រោកឡើងអង្គុយដូច្នោះស្ទុះរត់ពុំទាន់ ក៏ចូលទៅពួនក្នុងពាងធំ ១ នៅខាងដំណេក សម្ងំចាំប្ដីនោះដេក ខ្លួននឹងចេញពីពាងទៅដេកនឹងមេនោះទៀត ។

ប្ដីបានឃើញ តែធ្វើមិនឃើញមិនដឹង ប្រាប់ប្រពន្ធថា « រងាណាស់ ឯងដាំទឹកឲ្យគ្នាងូតបន្តិច នឹងអាលស្លាប់ » ។ មេនោះ ឮថាចង់ស្លាប់ដូច្នោះ អរណាស់ ត្បិតត្រូវនឹងពាក្យដែលត្រូវបន់អ្នកតា ។

លុះប្រពន្ធដាំទឹកពុះហើយ ប្ដីថា « ទៅដងទឹកត្រជាក់បាន ១ ក្អមមកយកមកលាយនឹងទឹកក្ដៅនេះ » ។ ប្រពន្ធឮប្ដីប្រើដូច្នោះ ក៏យកក្អមចេញទៅដងទឹក ។ ប្ដីឃើញប្រពន្ធចេញទៅបាត់ ក៏ក្រោកឡើងដើរទៅលើកទឹកពុះ ១ ខ្ទះនោះ យកទៅស្រោចលើសហាយ ដែលនៅក្នុងពាងនោះស្លាប់ទៅ ហើយចូលទៅដេកវិញ ធ្វើជាថ្ងូរហ៊ឺ ៗ ទៀត ។

មេនោះវិលពីដងទឹកមកវិញ មើលទៅឃើញសហាយត្រូវទឹកក្ដៅរួញសរសៃដូចគេដកចេញពីពាងមក ក៏ឱនខ្សឹបថា « ថ្វីក៏មិនឱនទៅរាមិនទាន់ទេ » ។ អានោះឆ្ងក់ដដែល ។ មេនោះយកដៃទៅចាប់ជ្រមុជទៅ ត្រូវស្លឹកត្រចៀក រលេះជ្រុះទាំងសក់ មើលបានដឹងជាប្ដីស្រោចទឹកក្ដៅស្លាប់សហាយទៅហើយ ក៏ពុំស្ដី យកគម្របពាងមកគ្របហើយយកទឹកឲ្យប្ដីងូត ។ ឯប្ដីក៏មិនស្ដី ទឹកក៏មិនងូត ប្រាប់ប្រពន្ធថា

អញគ្រាន់បើហើយ ” ហើយហៅប្រពន្ធចូលទៅដេកទៅ ។

លុះព្រឹកព្រហាមឡើង មេនោះ ពុំដឹងបើគិតដូចម្ដេច និងយកខ្មោចឲ្យរួចចេញផុតពីផ្ទះ ក៏នឹកឃើញថា “ក្នុងស្រុកនេះ មានចោរ ៤ នាក់ តែងតែលបលួចអីវ៉ាន់អ្នកផងសព្វថ្ងៃ សព្វយប់គ្រប់ភូមិ, ដូច្នេះអញនឹងគិតឲ្យចោរទាំង ៤ នាក់នោះ យកខ្មោចចេញពីផ្ទះអញទៅចោលក្នុងព្រៃឲ្យបាន” គិតហើយក៏ដើរខ្ចីសំពត់ហូល អាវព្រៃគេ យកមកហាលជុំវិញផ្ទះ ។ ឯចោរទាំង ៤ នាក់នោះ ឃើញហើយគិតគ្នាថា “ ដើ! មេនោះមានណាស់តើ ! យប់នេះ យើងទៅលបលួចវាឲ្យបានកុំខាន, សព្វថ្ងៃយើងស្មានថាវាក្រ ”

មេនោះក៏ហាលសំពត់ហូល អាវព្រៃនោះ លុះដល់ពេលល្ងាចយកទៅជូនគេវិញ ហើយយកខ្សែចងរឹតរូតពាងខ្មោចនោះឲ្យជាប់ ទុកឲ្យចោរចូលលួចមកសែងយកទៅ ។

ឯចោរទាំង ៤ នាក់ លុះយប់ ក៏បបួលគ្នាទៅលួច ចូលទៅរករបស់ទាំងនោះពុំឃើញ, ប្រទះឃើញតែពាងមួយ ចងមាត់ជាប់ បើកពុំរួច ។ ចោរទាំង ៤ នាក់ និយាយគ្នាថា “របស់អស់នោះវាដាក់ក្នុងពាងនេះហើយ , បើដូច្នេះត្រូវយើងសែងពាងនេះ” ថាហើយ ក៏នាំគ្នាសែងពាងនេះទៅ ដល់ព្រៃឆ្ងាយ ក៏ស្រាយលូកមើល ។

អាមួយលូកដៃទៅ ត្រូវសក់ថា “ អើយ សូត្រ ” ដកដៃចេញ ។ អាមួយលូកដៃទៅ ត្រូវស្លឹកត្រចៀក ត្រូវភ្នែក ច្រមុះ ស្រែកថា អើយខ្មោចទេ ” ។ អាមួយ មិនជឿ លូកដៃទៀត ត្រូវដើមទ្រូង ដឹងថាខ្មោចមែន ក៏ស្ទុះរត់ចោលហើយខឹងណាស់ថា ត្បិតមេនោះ បញ្ឆោតឲ្យសែងខ្មោចចោលបាន ។ ចោរទាំង ៤ នាក់ គិតគ្នាថា “យើងឃ្លាំមើលមេនោះ បើឃើញវាដើរទៅណាតែម្នាក់ឯងត្រូវគ្នាយើងចោមរោម ចាប់វាវាយ ឲ្យរារាង កុំឲ្យវាបញ្ឆោតយើងទៀត ។

ជួនជាថ្ងៃមួយ មេនោះ ចុះទៅកំពង់រកទិញអីវ៉ាន់ ត្បិតមានសំពៅទើបនឹងមកដល់ពីស្រុកក្រៅ ។ មេនោះ ដើរដល់កណ្ដាលផ្លូវ ក៏ជួបនឹង ចោរទាំង ៤ នាក់នោះ ចោរឃើញក៏នាំគ្នាព្រួតចាប់ នឹងវាយ ហើយជេរពីរឿងដែលវាបញ្ឆោត

នោះ ។ មេនោះ ឆ្លើយថា «រណ្ដើយអ្នក បើអ្នកវាយខ្ញុំ ក៏ឥតប្រយោជន៍ដែរ ត្បិតខ្ញុំទៅទារប្រាក់ពីនាយសំពៅ, ដូច្នេះចូរមក ! អញ្ជើញទៅនឹងខ្ញុំ ។ ទារប្រាក់បាន ចែកគ្នាចាយលេង » ។

ចោរទាំង ៤ នាក់ឮថាវាទៅទារប្រាក់ដូច្នោះ ក៏ចូលចិត្តបបួលគ្នាទៅ មេនោះផ្ដាំចោរទាំង ៤ នាក់ថា « អស់អ្នក ឈរចាំខ្ញុំ នៅលើច្រាំងចុះ បើកាលណាឃើញខ្ញុំបោយដៃនោះ អ្នកនាំគ្នាចុះទៅចុះ បានប្រាក់ហើយ » ។

មេនោះ និយាយផ្ដាំចោរទាំង ៤ នាក់ ហើយ ក៏ចុះទៅសំពៅនិយាយនឹងនាយសំពៅ លក់ចោរទាំង ៤ នាក់, វាថាចោរនោះជាខ្ញុំរបស់វា ហើយចង្អុលបង្ហាញនាយសំពៅថា «នុ៎ះន៏! វាទាំង ៤ នាក់ បើវាចុះមក ខ្ញុំឡើងទៅលើគោក សូមអ្នកចាប់ដាក់ច្រវាក់វាឲ្យជាប់ទៅ កុំឲ្យវារត់បាន » ។ នាយសំពៅព្រមហើយ សួរថា «ខ្ញុំនាងឯងទាំង ៤ នាក់លក់ថ្លៃប៉ុន្មាន? ។ មេនោះថា «ម្នាក់ថ្លៃពីរណែន » ។ នាយសំពៅឲ្យមួយណែនកន្លះ វាក៏ព្រមលក់ ហើយចេញមកក្រៅ បក់ដៃហៅចោរទាំង ៤ នាក់ ។ ចោរទាំង ៤ នាក់គិតស្មានថា វាហៅឲ្យទៅយកប្រាក់ក៏នាំគ្នាចុះទៅ, ដល់ហើយ ស្រាប់តែនាយសំពៅ ប្រើមនុស្សឲ្យដាក់ច្រវាក់ នៅបាតសំពៅទាំងអស់គ្នា ។ មេនោះ ក៏យកប្រាក់ឡើងមកបាត់ ។ បានប្រាក់ហើយ មេនោះ ដើរវិលមកផ្ទះវិញ ដល់កណ្ដាលផ្លូវចួនជាយប់ ពុំហ៊ានដើរទៅទៀត ក៏ឡើងទៅដេក លើដើមឈើមួយនៅប្របផ្លូវនោះ ។

ឯចោរទាំង ៤ នាក់ លុះនាយសំពៅដាក់ច្រវាក់ជាប់ហើយ ក៏និយាយគ្នាថា ដើមេនេះ ហៅពេញជាប្រាជ្ញាធំ វាបញ្ឆោតឲ្យយើងសែងខ្មោចទៅចោលក្នុងព្រៃ ហើយឥឡូវវាលក់យើងបានទៀត» ។ ចោរទាំង ៤ នាក់ ខឹងណាស់ កាច់ច្រវាក់បាក់រត់ចេញពីសំពៅ ដើរឡើងមកលើគោក រត់មកទាំងយប់នោះ ជួនជាយប់យូរណាស់ក៏នាំគ្នាឡើងទៅដេកលើដើមឈើធំ ដែលមេនោះដេក ។ ចោរបីនាក់ ឡើងទៅដេកលើមែកដោយខ្លួនពីគ្នា ។ ចោរម្នាក់ ឡើងទៅក៏ជួបនាងនោះ នៅលើចុងឈើ , អាចោរនោះ ថា «អី! ហងឯងស្លាប់ហើយ ម្ដងនេះ! ហងឯងធ្លាប់បញ្ឆោតយើង ឥឡូវ ហងឯង រត់ចុះបើរួច!» ។

# ៧– រឿងអាកុហកស៊ី(១)

កាលពីព្រេងនាយ មានក្មេងម្នាក់ នៅជាមួយម្ដាយ ចិញ្ចឹមជ្រូកកំរៀរ១, ដល់ជ្រូកនោះធំឡើង ក្មេងនោះចង់ស៊ីសាច់ជ្រូក ក៏និយាយនឹងម្ដាយថា «ម៉ែ! ខ្ញុំចង់ស៊ីសាច់ជ្រូក សូមម៉ែឲ្យខ្ញុំកាប់ជ្រូកយើងនោះស៊ីផឹកស្រាទេ?» ។ ម្ដាយឃាត់ថា «កុំ! ឯងស៊ីអីក៏ច្រើនម៉្លេះ ទុកវានឹងលក់យកប្រាក់កាសចាយ» ។ កូនឮម្ដាយឃាត់ដូច្នោះ ក៏នឹកតែក្នុងចិត្តចង់ស៊ីសាច់ជ្រូកតែសព្វថ្ងៃពុំមានភ្លេច ។ មានកាលមួយថ្ងៃ កូននោះភ្ញាក់ឡើងពីដេក និយាយប្រាប់ម្ដាយថា «ត្បិតទេវតាប្រាប់ខ្ញុំថា មានមាសប្រាក់ច្រើនណាស់ម៉ែ សូមម៉ែជូនខ្ញុំទៅយក» ។ ម្ដាយឮកូននិយាយប្រាប់ដូច្នោះ សួរថា «មាសប្រាក់នៅឯណា» ។ កូនឆ្លើយថា «ម៉ែទៅនឹងខ្ញុំចុះបើខ្ញុំបង្គាប់ដូចម្ដេច ម៉ែធ្វើតាមខ្ញុំ» ។ កូនយកកញ្ជើ នាំម្ដាយដើរទៅក្នុងព្រៃឆ្ងាយអំពីស្រុក ហើយកូនយកកញ្ជើទៅគ្របលើដី ប្រឹងសង្កត់ហើយស្រែកប្រាប់ម្ដាយថា «ម៉ែ! ជួយសង្កត់ផង មាសប្រាក់នៅក្នុងដីនេះច្រើនណាស់ ម៉ែសង្កត់ឲ្យជាប់ចុះ ខ្ញុំនឹងទៅរកចបជីកមកជីកយកមាសប្រាក់, ម៉ែឯងនៅសង្កត់ឲ្យជាប់ កុំលែង បើម៉ែលែង មាសប្រាក់និងបាត់អស់ទៅ» ឯម្ដាយឮកូនថាដូច្នោះ ក៏ខំសង្កត់កញ្ជើនោះឲ្យកូន, ឯកូននោះ ក៏រត់ត្រឡប់មកផ្ទះវិញ ចាប់ជ្រូកនោះ យកមកកាប់ចំអិនជាអាហារបបួលអស់បងប្អូនអ្នកផ្ទះជិតខាងមកស៊ីផឹកស្រាលេងសប្បាយ ។ ម្ដាយនៅចាំកូនឯព្រៃ ទន្ទឹងពុំឃើញមកឃ្លានបាយអស់កម្លាំង រោយដៃរោយជើង របូតចេញពីលើកញ្ជើពុំឃើញមានអ្វីសោះ។ លុះម្ដាយ ចាំយូរពេក នឹកថា កូនបញ្ឆោតហើយ ក៏លែងកញ្ជើចោលត្រឡប់ទៅផ្ទះវិញ

---

១ ច្បាប់សរសេរដៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ C.20,B, របស់លោក E. Aymonier ទំព័រ ២៩ ផ្នែកភាសាខ្មែរ និង ក្នុងកម្ពុជសុរិយា លេខ ១០–១១–១២ ឆ្នាំ ១៩៣៧ ទំព័រ ២៩ គ្មានឈ្មោះអ្នករៀបរៀងទេ ។

មេនោះលើកប្រាក់បង្ហាញ ហើយនិនខ្សឹបថា "ណ្ហើយអ្នក! អ្នកកុំស្តី កុំឲ្យអ្នកទាំងបីនាក់ទៀតដឹង, ហើយយើងត្រូវយកគ្នាជាប្តីប្រពន្ធ នឹងយកប្រាក់នេះទៅចាយរកស៊ីស្រួលផាង អ្នកកុំធ្វើបាបខ្ញុំធ្វើអ្វី" ។

អាចោរព្ទដូច្នោះ ក៏មិនស្តី ខិតចូលទៅជិត លូកឱបកៀកមេនោះហើយថា អើប្អូនឯង ហៅប្រាជ្ញាធំ បញ្ឆោតខ្ញុំពីរបីផងហើយ ឥឡូវបងបាននាងជាប្រពន្ធ ដោយសារព្រេងសំណាងយើង" និយាយហើយក៏ឱបតាមចិត្តមេត្រី ។ មេនោះពុំបម្រះហើយថា "ខ្ញុំខ្លាចក្រែងអ្នកស្រឡាញ់ខ្ញុំមិនស្មោះ, ឯខ្ញុំស្រឡាញ់អ្នកស្មោះ ចិត្តមួយហើយ" ។ អាចោរនោះថា "បងស្រឡាញ់ស្មោះហើយ នាងពុំដឹងចិត្តបង ចង់ឲ្យបងស្បថ ឬឲ្យបងធ្វើម្តេច?" ។ មេនោះ ថា "បងស្រឡាញ់ចិត្តមួយនឹងគ្នា មានតែលិទ្ធអណ្តាតគ្នា "ទើបមេនោះ លៀនអណ្តាត ហើយឱនទៅរកអាចោរនោះ ។ ឯអាចោរ លិទ្ធអណ្តាតមេនោះ ហើយលៀនអណ្តាត ឲ្យមេនោះលិទ្ធវិញ, មេនោះខាំអណ្តាតអាចោរនោះ ដាច់អស់មួយកំណាត់ហើយច្រានទម្លាក់ពីលើចុងឈើ ធ្លាក់ដល់ដី ស្រែកឮតែឡុល ៗ ។

ឯចោរបីនាក់ គិតស្មានថា នាយសំពៅចោមចាប់ ក៏លោតពីលើមែកឈើរត់ទៅហើយស្រែកហៅគ្នាថា "រ៉ុយ! គ្នាយើងរត់ នាយសំពៅដេញហើយ" ។ អាចោរដែលដាច់អណ្តាតនោះ ស្រែកហៅគ្នាវាថា "មេនោះ នៅលើចុងឈើ ត្រូវមកចាប់" ប៉ុន្តែវាដាច់អណ្តាតដូច្នោះ និយាយមិនច្បាស់ ឮតែឡុល ៗ, គ្នាវាគិតស្មានថា គេដេញចាប់ចេះតែប្រឹងរត់យកតែព្រះអាយុរៀងខ្លួន ។

ឯមេនោះ ចុះពីលើចុងឈើ យកប្រាក់ទៅផ្ទះឲ្យប្តី នៅរកស៊ីជាមួយនឹងប្តី ជាសុខសប្បាយតទៅ ។

## អ្នកមានប្រាជ្ញា តែងនាំអាត្មាឱ្យសុខចម្រើន

# ៧–រឿងអាកុហកស៊ី(១)

កាលពីព្រេងនាយ មានក្មេងម្នាក់ នៅជាមួយម្ដាយ ចិញ្ចឹមជ្រូកកំរៀរ១, ដល់ជ្រូកនោះធំឡើង ក្មេងនោះចង់ស៊ីសាច់ជ្រូក ក៏និយាយនឹងម្ដាយថា «ម៉ែ! ខ្ញុំចង់ស៊ីសាច់ជ្រូក សូមម៉ែឲ្យខ្ញុំកាប់ជ្រូកយើងនោះស៊ីផឹកស្រាទេ?» ។ ម្ដាយយាត់ថា «កុំ! ឯងស៊ីអីក៏ច្រើនម្ល៉េះ ទុកវានឹងលក់យកប្រាក់កាសចាយ» ។ កូនឮម្ដាយយាត់ដូច្នោះ ក៏នឹកតែក្នុងចិត្តចង់ស៊ីសាច់ជ្រូកតែសព្វថ្ងៃពុំមានភ្លេច ។ មានកាលមួយថ្ងៃ កូននោះភ្ញាក់ឡើងពីដេក និយាយប្រាប់ម្ដាយថា «ត្បិតទេវតាប្រាប់ខ្ញុំថា មានមាសប្រាក់ច្រើនណាស់ម៉ែ សូមម៉ែជូនខ្ញុំទៅយក» ។ ម្ដាយឮកូននិយាយប្រាប់ដូច្នោះសួរថា «មាសប្រាក់នៅឯណា» ។ កូនឆ្លើយថា «ម៉ែទៅនឹងខ្ញុំចុះបើខ្ញុំបង្គាប់ដូចម្ដេចម៉ែធ្វើតាមខ្ញុំ» ។ កូនយកកញ្ជើ នាំម្ដាយដើរទៅក្នុងព្រៃឆ្ងាយអំពីស្រុក ហើយកូនយកកញ្ជើទៅគ្របលើដី ប្រឹងសង្កត់ហើយស្រែកប្រាប់ម្ដាយថា «ម៉ែ! ជួយសង្កត់ផង មាសប្រាក់នៅក្នុងដីនេះច្រើនណាស់ ម៉ែសង្កត់ឲ្យជាប់ចុះ ខ្ញុំនឹងទៅរកចបជីកមកជីកយកមាសប្រាក់, ម៉ែឯងនៅសង្កត់ឲ្យជាប់ កុំលែង បើម៉ែលែង មាសប្រាក់និងបាត់អស់ទៅ» ឯម្ដាយឮកូនថាដូច្នោះ ក៏ខំសង្កត់កញ្ជើនោះឲ្យកូន, ឯកូននោះ ក៏រត់ត្រឡប់មកផ្ទះវិញ ចាប់ជ្រូកនោះ យកមកកាប់ចំអិនជាអាហារបបួលអស់បងប្អូនអ្នកផ្ទះជិតខាងមកស៊ីផឹកស្រាលេងសប្បាយ ។ ម្ដាយនៅចាំកូនឯព្រៃ ទន្ទឹងពុំឃើញមកឃ្លានបាយអស់កម្លាំង រោយដៃរោយជើង របូតចេញពីលើកញ្ជើពុំឃើញមានអ្វីសោះ។ លុះម្ដាយ ចាំយូរពេក ទើបថា កូនបញ្ឆោតហើយ ក៏លែងកញ្ជើចោលត្រឡប់ទៅផ្ទះវិញ

១ ច្បាប់សរសេរដៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ C.20,B, របស់លោក E. Aymonier ទំព័រ ២៩ ផ្នែកភាសាខ្មែរ និង ក្នុងកម្ពុជសុរិយា លេខ ១០-១១-១២ ឆ្នាំ១៩៣៧ ទំព័រ ២៩ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ឃើញកូនកំពុងតែស៊ីសាច់ជ្រូក ផឹកស្រាលេងសប្បាយដូច្នោះ ក៏ខឹងនឹងកូនណាស់ ហើយនិយាយនឹងប្អូនខ្លួនថា “ត្បិតកូននោះវាខូចណាស់ ទុកចិញ្ចឹមមិនបានទេ ត្រូវឯងច្រកការុងយកទៅទម្លាក់ក្នុងទឹកសម្លាប់ទៅ ” ។ ប្អូនឮដូច្នោះ សួរទៅបងថា “ ដំណើរដូចម្ដេច បានជាយកកូនច្រកការុង ទៅចោលក្នុងទឹកសម្លាប់ ? ” ។ បងនិយាយប្រាប់ទៅប្អូនតាមដំណើរសព្វគ្រប់ថា “ វាចេះបញ្ឆោតអញឲ្យទៅក្នុងព្រៃ ថាទៅយកមាសប្រាក់ ហើយឲ្យអញនៅចាំក្នុងព្រៃ លុះត្រាតែដល់ថ្ងៃឃ្លានបាយ ស្ទើរតែនឹងដាច់ពោះ, ឯវា មកកាប់ជ្រូក ស៊ីផឹកស្រាលេងសប្បាយ, ជ្រូកអញតែមួយទុកលក់ឲ្យគេ យកប្រាក់ចាយទេតើ ” ។ ប្អូននោះក៏ទៅចាប់អាកុហកស៊ីច្រកក្នុងការុងធំ ។ ចងមាត់ការុងជាប់ល្អ ហើយលើកលីយកទៅនឹងចោលក្នុងទឹកទន្លេ, លុះទៅដល់មាត់ទន្លេអាកុហកស៊ី និយាយនឹងមាវាថា “ លោកមាអាណិតខ្ញុំ ៗ មុខជាស្លាប់ហើយ បើដូច្នេះ សូមលោកមាអាណិតទៅយកក្បួនកុហក មកឲ្យខ្ញុំបន្តិច ត្បិតខ្ញុំស្លាប់ទៅ នឹងទៅនៅឯឋានខ្មោច បើគ្មានក្បួនកុហក នឹងកុហកខ្មោចស៊ីពុំបានទេ នោះនឹងដាច់ពោះស្លាប់ ” ។ ឯមាឮក្មួយអង្វរដូច្នោះ ក៏សួរទៅក្មួយវិញថា “ ក្បួនកុហកនោះ ឯងទុកនៅឯណា? ” ។ ក្មួយប្រាប់ទៅមាថា “ខ្ញុំដាក់នៅលើធ្នឹម ” ។ មាក៏ដាក់អាកុហកស៊ី ទុកចោលនៅមាត់កំពង់ទឹក ហើយត្រឡប់ទៅរកក្បួន នឹងយកមកឲ្យអាកុហកស៊ីវិញ ។

កាលនោះមានមនុស្សកើតឃ្លង់ម្នាក់ ដើរមកជិតអាកុហកស៊ី ។ ក៏ធ្វើនិយាយថា “អញមកគមឃ្លង់ក្នុងការុងនេះ យូរថ្ងៃហើយ មិនដឹងជាហើយឬនៅ ឃើញហាក់ដូចសះជាហើយ ” ។ មនុស្សឃ្លង់ឮអាកុហកស៊ី ថា គមឃ្លង់ក្នុងការុងដូច្នោះ ដោយខ្លួនកើតឃ្លង់ ក៏សួរថា “គមឃ្លង់ក្នុងការុងនេះ បានជាឬ ? ” ។ អាកុហកស៊ី ប្រាប់ថា ត្បិតខ្ញុំកើតឃ្លង់ គេឲ្យគមក្នុងការុងនេះយូរថ្ងៃហើយ មិនដឹងជាហើយឬនៅទេ អាណិតស្រាយមាត់ការុងឲ្យខ្ញុំបន្តិច ” ។ មនុស្សឃ្លង់ ក៏ស្រាយមាត់ការុង

ឲ្យអាកុហកស៊ីចេញមក ។ អាកុហកស៊ី ចេញពីការុង ពោសខ្លួនមើល ហើយប្រាប់ថា ជាឃ្លង់ហើយ ! ” អាគម្លង់ ឮពាក្យអាកុហកស៊ី ថា តមឃ្លង់ក្នុងការុងជាដូច្នោះ ក៏និយាយថាឲ្យគ្នាតមឃ្លង់ផង ។ អាកុហកស៊ី ឮដូច្នោះ អរណាស់ គិតថា“ អញរស់ស្លាប់ហើយ ” បានជាអាគម្លង់ស្លាប់ជួស ។ អាកុហកស៊ីប្រាប់អាគម្លង់ថា បើឯងចង់ជាឃ្លង់ឆាប់ ត្រូវកាន់ត្រណមឲ្យជាប់កុំនិយាយស្ដីនឹងអ្នកណាឲ្យសោះ, បើនរណាមកសួរក្ដី មកជេរ មកវាយដូចម្ដេច ៗក្ដី ត្រូវកុំនិយាយ កុំស្ដីខំកាន់ត្រណមឲ្យខ្ជាប់ ទើបបានជាឆាប់ ។ អាគម្លង់ឮអាកុហកស៊ី ថាដូច្នោះក៏ទទួលចាំ ហើយចូលទៅក្នុងការុង ។ អាកុហកស៊ី ចងមាត់ការុងជាប់ហើយរត់បាត់ទៅ ។ មានោះ រកតប្រាអាកុហកស៊ីពុំឃើញ ដឹងថា អាកុហកស៊ីបញ្ឆោតខ្លួន ខឹងណាស់ ក៏នឹកក្នុងចិត្តថា បើអញទៅដល់ អញនឹងទម្លាក់វាទៅក្នុងទឹកឲ្យស្លាប់ភ្លាម ហើយខំដើរទៅ ដល់ហើយ ក៏ស្ទុះចូលទៅដាល់វាយអាគម្លង់ ដោយស្មានថាជាអាកុហកស៊ី ។ អាគម្លង់ខំអត់ព្រោះចង់ជាឃ្លង់ លុះវាយធាក់អស់ចិត្តហើយ មានោះ ក៏លើកការុងបោះទៅក្នុងទឹកឲ្យស្លាប់ ។

ឯអាកុហកស៊ី រត់រួចពីនេះទៅ ៗ ជួបនឹងមនុស្សកុហកម្នាក់ ចេះកុហកដូចគ្នាកំពុងតែមុជទឹក ។ អាកុហកនោះ ឃើញអាកុហកស៊ី កំពុងដើរទៅពីចម្ងាយ ក៏ធ្វើជាមុជទឹកយូរបន្តិច ងើបឡើង ហើយលើកកាសឡើងបង្ហាញថា “អញមុជទឹកទៅខាងក្រោម មានគេលេងបៀ អញលេងឈ្នះ បានកាសប្រាក់ច្រើន ប៉ុន្តែយកមកមិនរួច យកបានតែមួយត្រណោតមក ” ។ អាកុហកស៊ី ឮដូច្នោះក៏ជឿគិតស្មានថាមែន ហើយក៏ផ្លាស់សំពត់លោតចុះទៅក្នុងទឹក ខំមុជទៅ ទង្គិចក្បាលនឹងគល់ឈើបែកឈាម ដឹងខ្លួនថា គេជាមនុស្សកុហក ក៏នឹកក្នុងចិត្តឃើញ

ឧបាយកុហកវិញ ហើយអើបឡើង និយាយទៅនឹងអាដែលបញ្ឆោតនោះថា៖ “អ្នកអើយ! ខ្ញុំអុជទឹកទៅតាមពាក្យអ្នកឯងរម្យាញមិញ បានឃើញគេលេងបៀ ប៉ោ ធូកំតាក់ ច្រើនណាស់ ហើយខ្ញុំលេងឈ្នះគេ បានប្រាក់កាសជាច្រើន ខ្ញុំទារពីគេ ៗ ថា ឲ្យមកទារយកពីអ្នកឯងនេះ តែខ្ញុំមិនព្រម ខ្ញុំចេះតែទារ គេខឹងនឹងខ្ញុំ គេវាយខ្ញុំបែកក្បាល ហើយគេថា ឲ្យខ្ញុំមកយកពីអ្នកឯង បើអ្នកមិនជឿ អ្នកមើលក្បាលខ្ញុំ ដែលបែកនេះចុះ ។ អាកុហកនោះ ដឹងថាអាកុហកស៊ីមានប្រាជ្ញាចេះកុហកទល់នឹងកុហកមិនចាញ់ខ្លួន ក៏ស្រាយកាសចែកឲ្យពាក់កណ្ដាល ហើយសុំគ្នាធ្វើជាបងប្អូន ដើររកស៊ីកុហកគេ តាំងពីថ្ងៃនោះទៅ ។

## បន្លាមុត យកបន្លាដោះ

## ៨– រឿងបុរសចេះថ្នាំពិសពស់(១)

មានថ្ងៃមួយ បុរសឈ្មោះសុខ ធ្វើដំណើរទៅកាប់ឫសក្នុងព្រៃ ។ លុះទៅដល់ព្រៃ ជាកន្លែងកាប់ឫសនោះហើយ ឃើញខ្លាធំមួយស្លាប់នៅជើងដំបូងក្បែរច្រកចូលផ្លូវ ។ ចៅសុខពិនិត្យមើលហេតុសព្វគ្រប់ទៅឃើញថា ខ្លានេះ ស្លាប់ដោយពស់ចឹក ព្រោះនៅខាងក្រោមខ្លានោះ មានរន្ធពស់មួយ ។ បុរសនោះមានចិត្តសប្បុរសចំពោះសាកសពសត្វនោះណាស់ ក៏ស្រាយថង់យាមយកថ្នាំមកដុះលាបស្រឡាបឲ្យ ។ លុះបានមួយស្របក់ ខ្លាដឹងខ្លួនឡើង ឃើញខ្លួនប្រឡាក់សុទ្ធតែថ្នាំដែលលាប ក៏មានសេចក្ដីទោមនស្សនឹងបុរសដែលលាបថ្នាំឲ្យ ហើយស្ដីឲ្យថា ហេតុដូចម្ដេច បានជាអ្នកឯងហ៊ានយកអ្វីមកប្រឡាក់ខ្លួនអញយ៉ាងនេះ ! ។ បុរសនោះ ឆ្លើយថា យើងដើរមក បានឃើញបងឯងស្លាប់ ដោយពស់ចឹក ហើយយើងដុះថ្នាំស្រឡាបលាបឲ្យបងឯងរស់តើ ! ។ ខ្លាថា អញមានស្លាប់អី ពស់ចឹកអញកាលណា ! អញកំពុងដេកលក់ស្រួលទេតើ ! បើដូច្នោះ អញត្រូវប្រហារជីវិតឯងធ្វើជាអាហារ ។ ចៅសុខមានសេចក្ដីតក់ស្លុត នឹងសេចក្ដីស្លាប់ជាខ្លាំង ក៏អង្វរខ្លាថា បងអើយ ! អាណិតយើងផង កុំអាលពិឃាដយើងក្នុងគ្រានេះ ចាំយើងទៅរកអ្នកប្រាជ្ញណាឲ្យគេជំនុំជំរះឲ្យ បើរកទៅឃើញថាយើងខុស សឹមបងប្រហារជីវិតយើង បើយើងត្រូវ ត្រូវទុកជីវិតយើង ។ ខ្លាក៏ព្រមតាមសេចក្ដីអង្វររបស់ចៅសុខ។ វិលមកវិញ ប្រទះសេះនឹងក្របី នៅក្បែរផ្លូវក៏និយាយថា បងទាំងពីរ អាណិតជួយយកអាយុយើងផង ព្រោះខ្លាដែលពស់ចឹក បានរស់ឡើង ៗដែលយើងដាក់ថ្នាំឲ្យ តែវាប្រាថ្នាប្រហារជីវិតយើង ថាយើងធ្វើឲ្យវាភ្ញាក់ ហើយធ្វើឲ្យប្រឡាក់ខ្លួនវាអស់ ។

---

១ កម្ពុជសុរិយាលេខ ១០-១១-១២ ឆ្នាំ ១៩៣៧ ទំព័រ ២០១ គ្មានឈ្មោះអ្នករៀបរៀងទេ ។

សត្វទាំងពីរ ដឹងសេចក្ដីសព្វគ្រប់ ក៏ពិចារណាទៅឃើញថា តាមពិតត្រូវតែទៅកាត់សេចក្ដីឲ្យបុរសនេះឈ្នះខ្លា ប៉ុន្តែបើអញឲ្យបុរសនេះឈ្នះទៅ មុខជាខ្លាគុំអញ ស៊ីអញជាអាហារពុំលែង ក៏ប្រាប់ទៅចៅសុខថា បងឯងខុសមែនហើយត្រូវឲ្យខ្លាស៊ីទៅ ។ ចៅសុខ រឹតតែភ័យឡើងក៏លាសេះនិងក្របី ដើរយ៉ាងលឿនទៅទៀត លុះប្រទះនិងសុភាទន្សាយចៅសុខក៏ប្ដឹងតាមដំណើរ ។ សុភាទន្សាយដឹងរឿងសព្វគ្រប់ ក៏ប្រាប់សុខថា ឲ្យទៅនិយាយអង្វរខ្លាទៀតទៅ សឹមយើងទៅជួប ។

គ្រាដែលបុរសនោះ កំពុងជជែកនឹងខ្លា សុភាទន្សាយទៅដល់ ក៏ធ្វើជាសួរថា បងឯងទាំងពីរនាក់ ទាស់គ្នាពីរឿងអ្វី ! ។ ខ្លានិងចៅសុខ ក៏បានប្ដឹងតាមដំណើររៀង ៗ ខ្លួន ។

សុភាទន្សាយ កាត់សេចក្ដីថា បើដូច្នេះ ត្រូវបងខ្លាឯង ទៅដេកនៅត្រង់កន្លែងដដែល ឲ្យឃ្លុំដូចពីមុន បើដល់ពេលត្រូវភ្ញាក់ ហើយពុំស្លាប់ទេ សឹមបងឯងមកពិឃាដមនុស្សនេះ ធ្វើជាអាហារចុះ ។

ខ្លាទៅដេកតាមបង្គាប់, ពស់ក៏ចេញពីរន្ធមកចឹកខ្លានោះស្លាប់ទៅ ។ សុភាទន្សាយ ឃើញខ្លាស្លាប់ហើយ ក៏ប្រាប់ទៅបុរសនោះថា បងឯងកុំលាបថ្នាំឲ្យវាទៀត ប្រាប់ហើយ ក៏លាចៅសុខទៅលំនៅវិញ ។

**ធ្វើគុណ បានទោស**

# ៩- រឿងមនុស្សបួននាក់(១)

កាលពីព្រេងនាយ មានបុរសឆោត ៤ នាក់ ព្រួបព្រៀងគ្នាដើររៀនក្តី ។ លុះដើរបន្តិចទៅ ចាប់បានអណ្តើក ៥ បុរសទាំង ៤ នាក់នោះ ក៏យកអណ្តើកនោះមកចែកគ្នា ដល់ចែកទៅចែកមក នៅសល់អណ្តើកមួយ ។ មនុស្សទាំងអស់នោះ មិនសុខចិត្តតែរៀងខ្លួន ក៏ចែកគ្នាម្តងទៀត ចែកទៅចែកមក សល់អណ្តើកមួយដដែល មិនដឹងគិតធ្វើដូចម្តេច ។ បុរសទាំង ៤ នាក់នោះ ទាល់គំនិត ក៏អង្គុយមើលមុខគ្នា ធ្វើភ្នែកឡឹងឡង់ៗ ។ ក្នុងវេលានោះ មានបុរសម្នាក់ទៀត ដើរទៅកាន់ទីនោះ ប្រទះនឹងមនុស្សទាំង ៤ នាក់នោះ ក៏ឈរមើលគេចែកអណ្តើកគ្នា ហើយបុរសម្នាក់នោះ ឃើញឆោតដូច្នោះ ក៏សើច ហើយនិយាយនឹងបុរស ៤ នាក់នោះ "មើលទៅអ្នក ដូចជាមិនសូវប្រសប់សោះ" ។ បុរស ៤ នាក់គ្រាន់តែឮសម្តីប៉ុណ្ណោះ ក៏និយាយថា: "ឱលោក! បើលោកចេះ អាណិតមកចែកឲ្យយើងបន្តិច" ។ បុរសម្នាក់នោះ ឮដូច្នោះ ក៏ដើរចូល អង្គុយជិត ចាប់អណ្តើក ៥ នោះមក ហើយរើសមើលអណ្តើកណាដែលធំជាងគេ យកមកទ្រាប់អង្គុយ នៅសល់អណ្តើក ៤ ក៏ចែកឲ្យបុរស ៤ នាក់នោះ មួយម្នាក់ ។ បុរស ៤ នាក់ ក៏សុខចិត្តរៀងខ្លួន ហើយទាំងអស់គ្នា សួរគេនោះថា "អ្នក! មើលទៅអ្នកប្រហែលជាចេះក្តី?" ។ បុរសនោះ ឆ្លើយថា ខ្ញុំចេះ" ។ បុរសទាំង ៤ នាក់ ក៏តបទៅវិញថា "ឱ! បើអ្នកចេះក្តី សូមមេត្តាប្រាប់យើងផង" ។ បុរសម្នាក់នោះ ឆ្លើយថា "បើអ្នកចូលចិត្តឲ្យខ្ញុំប្រាប់ ត្រូវអ្នកទន្ទេញតាមខ្ញុំ ។ បុរស ៤ នាក់

១ កម្ពុជសុរិយា លេខ ១០-១១ ១២ ឆ្នាំ ១៩៣៧ ទំព័រ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ឆ្លើយថា "បាទ" ហើយបុរសនោះ ប្រាប់ឲ្យអ្នកទាំង ៤ នោះ ឲ្យទន្ទេញរៀងខ្លួន គឺ:

ប្រាប់ បុរសទី ១ ថា: ទំពក់វាទៅ ទើបព្នោរវាជ្រុះ

– បុរសទី ២ ថា: មានប្រឡាយ ទើបទឹកវាហូរ,

– បុរសទី ៣ ថា: មានសម្រាម ទើបភ្លើវាដុះ,

– បុរសទី ៤ ថា: មែន ទើបគេថា ។

បុរស ៤ នាក់ ក៏ទន្ទេញពាក្យនេះ ចេះចាំគ្រប់ ៗ គ្នាទៅ, ហើយបុរស ៤ នាក់នោះ នាំគ្នាទៅឆ្ងាយទៅ បានដល់ភូមិមួយ នឹងរកផ្ទះសម្បែងសំណាក់ ក៏គ្មាន ។ លុះបន្តិចទៅ បានប្រទះនឹងយាយចាស់មេម៉ាយម្នាក់ ក៏និយាយសុំផ្ទះយាយចាស់នោះសំណាក់ គាត់ក៏ព្រមឲ្យ ហើយបុរសនោះ នាំគ្នាទាំង ៤ នាក់ សំណាក់នៅផ្ទះយាយនោះទៅ ។ យប់នោះអ្នកទាំង ៤ ក៏នាំគ្នាទន្ទេញពាក្យក្ដីដែលបុរសម្នាក់នោះប្រាប់ទន្ទេញមិនឈប់ឈរទាល់តែភ្លឺ ។ យាយចាស់ខឹងណាស់ ព្រឹកឡើងគាត់ទៅប្ដឹងមេស្រុក! យប់មិញនោះ មានបុរស ៤ នាក់មកសុំផ្ទះខ្ញុំសំណាក់ បុរសទាំង ៤ នាក់ ចេះតែនិយាយ-ទន្ទេញទាល់តែភ្លឺ តែមិនដឹងពាក្យថាដូចម្ដេច ស្ដាប់មិនបានសោះ ខ្ញុំខានដេករាល់ព្រឹក, ហេតុនេះខ្ញុំមកប្ដឹងលោក សូមលោកហៅមនុស្សទាំង ៤ នាក់នោះមកជំនុំជម្រះឲ្យខ្ញុំ" ។ មេស្រុកបានស្ដាប់ ក៏ឲ្យបម្រើទៅហៅបុរសទាំង ៤ នាក់នោះមក ហើយសួរថា "ហេតុដូចម្ដេច បានជាឯងទន្ទេញអ្វី ទាល់តែភ្លឺ រកតែយាយចាស់គាត់ដេកពួនមិនបាន, ចុះដែលឯងទន្ទេញនោះ តើទន្ទេញពាក្យអ្វី?" បុរសទាំង ៤ នាក់នោះ ឆ្លើយថា "ខ្ញុំទន្ទេញពាក្យក្ដី" ។ មេស្រុកបង្គាប់ទៅទៀតថា ចូរឯងរាល់គ្នាសូត្រពាក្យនោះ ម្ដងម្នាក់ទៅមើល! អញនឹងស្ដាប់" ។

បុរស ទី ១ ថា: ទំពក់វាទៅ ទើបព្នោរវាជ្រុះ,

បុរស ទី ២ ថា: មានប្រឡាយ ទើបទឹកវាហូរ,

បុរស ទី ៣ ថា: មានសម្រាម ទើបភ្លើវាដុះ,

បុរស ទី ៤ ថា ៖ មែន ទើបគេថា ។

ស្ដាប់ពាក្យនោះហើយ " មេស្រុក ក៏គាត់សេចក្ដីថា ឯងទាំង ៤ នាក់ ត្រូវនៅជាខ្ញុំបម្រើយាយចាស់នេះ " ។ បុរសអស់នោះ ក៏ទៅនៅធ្វើជាខ្ញុំបម្រើយាយនោះទៅ ។ យាយនោះគាត់ប្រើឲ្យធ្វើការសព្វសារពើ តែរាល់ថ្ងៃ ។

លុះនៅនឹងយាយនោះបាន ២-៣ ខែទៅ យាយគាត់ប្រើបុរសទាំង ៤ នាក់នោះ ឲ្យទៅកាប់ឈើធ្វើទូក ។ អ្នកទាំង ៤ នាក់ ក៏នាំគ្នាចូលទៅដល់ព្រៃធំ ហើយដើររកឈើណាមានប្រហោងទើបកាប់ ។ លុះចូលទៅដល់ក្នុងព្រៃជ្រៅ បានប្រទះឈើធំ ១ ដើម មានប្រហោង បុរសទាំង ៤ និយាយគ្នាថា " យើងបានប្រទះឈើប្រហោងហើយ យើងត្រូវនាំគ្នាកាប់ឈើនេះ " ។ បុរសទាំង ៤ នាក់ មូលមាត់គ្នា ក៏កាប់រំលំឈើប្រហោងនោះ លុះឈើជិតរលំបុរសទាំង ៤ នាក់ ស្រែកថា " កនយើង ! ជិតរលំហើយ អាណាម្នាក់រត់ទៅចាំទ្រ កុំឲ្យបែកឈើយើងក្រែងធ្វើទូកមិនកើត " ។ បុរសម្នាក់ ក៏ស្ទុះទៅចាំទ្រ ដល់ឈើនោះបាក់មកសង្កត់ស្លាប់ធ្វើមាត់ស្ញេញ ។ បុរស ៣ នាក់ ឃើញដូច្នោះ ក៏នាំគ្នាសើចថា " យើ អានេះ ខ្លាំងណាស់វ៉ុ ! ឈើទំហំប៉ុណ្ណឹងគោតពែវាទ្រទាំបាន ហើយវាសើចថែមទៀត " ។ បុរស ៣ នាក់ នាំគ្នាមើលបុរសម្នាក់ដែលស្លាប់, ដល់យូរពេក ក៏ស្រែកហៅថា " យី ! មកឆាប់ឡើងនឹងអាលទៅ ឃ្លានបាយណាស់ " ។ លុះឃើញនៅស្ងៀម ក៏នាំគ្នាដើរចូលទៅមើល ។ កាលដឹងថា បុរសនោះស្លាប់, បុរស ៣ នាក់ភ័យណាស់ និយាយគ្នាថា " យើងនៅមិនបានទេ តែយើងខំនៅ មុខជាគេប្ដឹងថា យើងវាយសម្លាប់អានេះ, បើដូច្នេះ ត្រូវយើងនាំគ្នារត់ " ថាហើយ ក៏ព្រមព្រៀងគ្នារត់ទៅ ។ ដល់ពេលយប់ វង្វេងផ្លូវមិនដឹងរត់ទៅឯណា ក៏ស្រាប់តែវិលវល់ ទៅត្រង់កំពង់ផ្ទះយាយ ហើយនាំគ្នាលួចទូកយាយនោះអុំទៅត្រើយម្ខាង ។ បុរសទាំង ៣ នាក់នាំគ្នាចុះទូក, ម្នាក់នៅខាងកន្សៃ បែរមុខទៅខាងកន្សៃ, ម្នាក់នៅខាងក្បាល ក៏

បែរមុខទៅខាងក្បាល, ម្នាក់ទៀតអង្គុយកណ្ដាល បាចទឹកទូក តែមិនបានស្រាយខ្សែចំណងទូកនោះចេញ ចេះតែនាំគ្នាអុំ ។ មួយយប់ទាល់ភ្លឺនៅតែដដែល ។ លុះភ្លឺស្រាងឡើង យាយចាស់ចុះដងទឹក ប្រទះបុរស ៣ នាក់ ហើយស្រែកថា " យើ អានេះ រត់ទៅណា ? " ។ បុរស ៣ នាក់ ត្រឡេកឃើញយាយចាស់ជាចៅហ្វាយខ្លួន ក៏ទាល់ប្រាជ្ញាមិនដឹងបើរត់ទៅណា ក៏ទៅនៅបម្រើយាយចាស់វិញដដែលទៅ ។

## ចេះ រមេះក្បាច់

# ១០- រឿង ក្អែកមួយជាក្អែកដប់(១)

កាលពីព្រេងនាយ មានបុរស ២ នាក់ ម្នាក់ឈ្មោះអាខិល ម្នាក់ឈ្មោះអាខូច នៅស្រុកទីទៃពីគ្នា គំនិតដោយខ្លួន ។ អាខូចផុះអាចម៍ដាក់ពេញពាង ១ ហើយយកអាចម៍ល័ក្ខបិទភ្ជិតយ៉ាងល្អ មិនឲ្យក្លិនចេញក្រៅបាន ។ អាខិលធ្វើកាំបិត ១ មានផ្លែប៉ុនចង្កើះអកកំបោរផងប៉ុនកដៃស្រោមធំវែងប្រហែល ១ ល្វូក អាខិល ស្ពាយកាំបិតនោះដើរទៅលក់ ឯអាខូច ក៏ពុនពាងអាចម៍នោះដើរទៅលក់ដែរ ។ អាខិលទៅពីនេះ អាខូចមកពីនោះ ជួបគ្នាកណ្តាលផ្លូវ អាខូច ពពាយនាយថា អ្នកអើយទិញផ្អកយកទៅពិសា ផ្អកចារយ៉ាងល្អ ស្ងោរក៏បាន ចំហុយក៏បាន ឆ្ងាញ់របស់ខ្ញុំណាស់ ។ អាខិល ឆ្លើយថា ទាស់តែលក់ដាវខ្ញុំមិនដាច់ គ្មានលុយទិញ បើដូរជាដាវនេះ ព្រមដូរឬទេ? ។ អាខូច ឃើញដាវនោះវែង ក៏ឆ្លើយថា "ដូរក៏ដូរ" ។ អាខិលប្រគល់ឲ្យអាខូច ហើយអួតថា ដាវខ្ញុំនេះ មុតបំផុត មេដែករបស់ខ្ញុំផង បើត្រូវការ សឹមហូតកាប់តែម្តង អ្នកឯងកុំប្រញាប់ហូតមើល បើហូតលព្រើល ។ សិកទៅវិញមិនចុះទេ ដាវខ្ញុំពូកែ ខ្ញុំស្តាយរបស់ខ្ញុំណាស់ បើកុំតែខែនេះក្រម្លូបពេក កុំអីខ្ញុំមិនដូរទេ" ។ អាខូច ក៏ប្រគល់ពាងអាចម៍ឲ្យទៅអាខិល ហើយហាមថា "ផ្អកខ្ញុំហ្នឹងក៏ដែរ ដល់ពេលស៊ីសឹមបើកយកមកចំហុយ កុំអាលបើកមើល ក្រែងវាស្អុយ រុយបែងក្រែងវាធុំខ្មោះ

---

១ កម្ពុជសុរិយាលេខ ១០.១១.១២ ឆ្នាំ ១៩៣៨ ទំព័រ ១១៩ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

ស៊ីមិនទាន់អស់ វាទៅជាខានឆ្ងាញ់ ទឹកឃើញដិដូនជិតា បានតែខ្វារស៊ីទៅ " ។ អាទាំងពីរ បែកគ្នាទៅដល់ផ្ទះរាល់ខ្លួន ហើយតៀនប្រពន្ធក្នុងថា ដណ្ដាំបាយទៅ អញបានផ្អក " ។ ប្រពន្ធថា " បានផ្អកពីណា ? ។ អាខិលថា " ដូរដារគេ ៗ ថា ផ្អកចាវគេឆ្ងាញ់ពីសាណាស់ " ។ ប្រពន្ធក៏អរពេញចិត្ត ទើតថា " ប្តីចេះធ្វើករបិត ដូរផ្អក " ស្ទុះភ្លែតទៅលាងចានដួសបាយ ហើយកាន់ករបិតយ៉ាងតំរឹល កកិលទៅ ជិតពាងផ្អក យកករបិតគាស់អាចម៍ល័ក្តនោះបើកឡើង ហើយលូកខ្វារបាន ១ ក្តាប់ ដាក់ផ្ទាប់ទៅក្នុងចាន សល់នៅដៃប៉ុន្មាន ក៏លិទ្ធជ្លប់ ភ្លក្សមើល ងើបមុខឡើងថា " យី ! ផ្អកចាវអីក៏ស្អុយដូចអាចម៍ គ្មានឆ្អឹងនិង សាច់ កខិកកខក់ ម៉ដ្ឋផង់យ៉ាងហ្នឹង តើផ្អកត្រីអ្វី ? ។ ប្តីថា " ក្រែងត្រីពោ " ។ ប្រពន្ធ ក៏លូកក្នុងរាវរកក្បាល លូក បានពាក់កណ្តាល ក្នុតចង្កោរជាង ២០ រ៉ក ដឹងជាក់ជាអាចម៍ មិនមែនផ្អក បកបន្ទោស ទៅម្ចាស់ដើម ភ្លើមលេបបាយមិនរួច ។

និយាយអំពីអាខូច គ្រេកអរណាស់ ដើរទៅផ្ទះអួតប្រាប់ប្រពន្ធថា " អាចម៍មួយ ពាង ដូរបានដារមួយដែរ " ទទួលខឹងនឹងឆ្កែវានោមច្រោសស្លឹកគ្រៃ កន្ត្រាក់ដារ លោតទៅដល់ដី បម្រុងនឹងកាប់ឆ្កែសម្លាប់ ក៏ចាប់ដងដារហូតខិច ឃើញផ្លែដារនោះ ខ្លីកំប៉ិច គេចឡើងលើផ្ទះ បង្ហាញប្រពន្ធមើល ហើយសើចទាំង ២ នាក់ សើចហើយ ប្រាប់ប្រពន្ធថា " ប្រាជ្ញាអានោះ ស្មើនឹងអញ ។ ទៅបបួលវាធ្វើសំឡាញ់ គ្រាន់រកស៊ី ពីរនាក់ នឹងបានមាសប្រាក់ដោយងាយ" ។ លុះទៅប្រទះនឹងអាខិល ដើរមកពីនាយ សើចពព្រាយ និយាយសួរថា "ឯងទៅណា ! " ។ អាខិលឆ្លើយថា " អញមកសុំ ឯងធ្វើសំឡាញ់ " ។ អាទីមួយក៏ថា " អញសុំឯងធ្វើភ្លើដែរ " ហើយក៏សុខចិត្តដើរ ពីរនាក់ ទៅដល់ផ្ទះមហាសេដ្ឋីម្នាក់ចាស់ ជរា ឈឺស្លាប់ គេដាក់ក្នុងក្តារមឈូស បម្រុងបូជាថ្ងៃស្អែក ។ ចំណែកកូនចៅនិងប្រពន្ធ យំសោកគ្រប់គ្នា វេលានោះ អាទាំងពីរ ស៊ើបសួរអ្នកដើរខាងក្រោថា " អ្នកណាស្លាប់ បានជាគេយំ ! " ។ គេប្រាប់ថា " មហាសេដ្ឋីស្លាប់ " ។ អាទាំងពីរនាក់គិតគ្នាថា ឯងត្រូវក្លែងសំបុត្រ

មួយច្បាប់ ទៅប្រាប់ថា សំបុត្រសេដ្ឋីឲ្យមកយកទ្រព្យរបស់ អញបន្ទុលបច្ចូលដេក ក្នុងមឈូល អំពីលើខ្មោចសេដ្ឋី ស្តីតបនឹងឯង " ។ អាមួយ ក៏បន្ទំដេកដូចគំនិត ។ អ្នកនៅជិតមិនបានឃើញ មិនបានដឹង ត្បិតភ្នែកខំសំឡឹងប្រឹងឈ្ងោកមើលក្រាំងសូត្រព្រះធម្ម កូនចៅតូចធំ រវល់តែយំសោក ។ អាខ្វិចដើរទៅរកក្រដាសបានធ្វើសំបុត្រក្លែង កាន់ដើរទៅ សម្តែងសូត្រឲ្យគេស្តាប់ថា " សំបុត្រអំពីមហាសេដ្ឋីប្រាប់ថា ចៅខ្វិចកំសត់តាំងពីតូចជាកូនធម៌ ឥឡូវ អាពុកជរាហើយ កូនអើយ! ចូរទៅយករបស់ទ្រព្យទុកចាយឲ្យសប្បាយចិត្តចុះ " ។ កូនចៅប្រុសស្រី គេមិនសុខចិត្ត ព្រោះត្បិតគ្មានត្រាហត្ថលេខាសេដ្ឋី ។ អាខ្វិចឆ្លើយថា " ខ្ញុំសូមសន្យានឹងអស់កូនចៅអញ្ជើញទៅហៅ ទៅសួរលោកចុះ បើលោកស្តី ទុំៈខ្ញុំត្រង់ពិត បើលោកស្ងៀម ទុំៈខ្ញុំក្លែងបញ្ឆោតទេ " ។ កូនសេដ្ឋីចូលភ្លាម ទៅស្រែកហៅឪពុក ។ អាខ្វិលឆ្លើយថា " អើ " ! ។ កូនសួរថា " ឪពុកបានឲ្យសំបុត្រទៅកូនធម៌ មកយករបស់មែនឬ " ។ អាខ្វិលថា អើ! " កូនអញឈ្មោះខ្វិច វាមកហើយឬ! " ។ កូនឆ្លើយថា " ទានប្រោស! មកហើយ ។ អាខ្វិលថាអើ / មើលយករទេះមួយធំ ក្របីមួយនឹម ទឹមរទេះនោះ ហើយយកមាស ប្រាក់ កែវ កង សំពត់ អាវ រាល់ផ្ទុកក្នុងរទេះ ឲ្យល្មមតែក្របីនោះអូសរួចបានប៉ុន្មាន ឲ្យវាយកទៅចុះ " ។ កូនចៅស្រីប្រុស ចាញ់ឧបាយកលអាខ្វិលអាខ្វិច ក៏ខឹងខ្មោចសេដ្ឋី ស្លាប់ហើយចេះស្តី ហៅពេញជាអស្ចារ្យ ឥឡូវនឹងបើកក្តារមើលឲ្យច្បាស់ ចាស់ៗ ហាមប្រាមថា មើលមុខខ្មោចមិនបាន ខ្លាចដេកយប់ទៅ មមើមមាយ ម្ល៉ោះហើយក៏ជៀជាក់យកមាស និង ប្រាក់ សំពត់ អាវសំលៀកបំពាក់ និង កន្ទេល ពូក ខ្នល់ ខ្នើយ ហើយថែម តុ ថាស ចានល្អៗ អំបិលប្រហុក៥ក្រឡអង្ករ ៥ ការុង ដាក់ផ្ទុងទៅឲ្យអាខ្វិចអាខ្វិល បង្វិលរទេះយ៉ាងធំ ជជែក យំ ទឹកភ្នែកឲ្យដោយខឹងដោយចញ្ចោះ ទាំងស្រីទាំងប្រុស ហើយក៏ដឹកក្របីមួយនឹម ទឹមរទេះប្រគល់ឲ្យអាខ្វិចទៅ ។ អានេះគ្រេកអរឡើងបររទេះចេញទៅ អ្នកទាំងអស់ដែលនៅចេះតែច្រួល មិនស្រួលព្រោះត្បិតខឹងនិងស្តាយ ។ អាខ្វិល លួចមើលនាយអាយ

លបចេញប្រិច រត់តាមទៅបន្តិច ក៏ទាន់រទេះ ហើយនិយាយគ្នាថា " យើងបានទ្រព្យរបស់ តែទាស់ឃ្លានបាយ បើឈប់ដណ្ដាំបាយ នៅរៀងអាយ ក្រែងមិនស្ទាត់ខ្លាចចោរ តាមមកស្ទាក់ប្លន់យកទ្រព្យមួយរទេះ, បើដូច្នេះឯងឈប់ចាំអញ ។ ទៅសុំបាយគេស៊ីខ្លះ យកខ្លះមកឲ្យឯង " ។ អាមួយព្រមហើយ អាមួយក៏ដើរទៅរកថ្នាំតាមផ្លូវ យកមកនឹងលាយបាយ ឲ្យពុលស្លាប់អន្តរាយ នឹងយកទ្រព្យរបស់ទាំងអស់តែម្នាក់ឯង ។ អាមួយដែលនៅចាំរទេះ ក៏ធ្វើខ្នាដាក់ស្ទាក់ផ្លូវបម្រុងឲ្យត្រូវអានោះស្លាប់ នឹងយកទ្រព្យតែម្នាក់ឯងដែរ ។ វេលានោះ អាមួយទៅសុំបាយគេស៊ី ។ រួចហើយសុំមួយចានផ្ញើសំឡាញ់ គេមិនកំណាញ់ ក៏រកស្លឹកចេកខ្ចប់ឲ្យមានទាំងត្រីអាំងផង ។ អានោះ ក៏លាគេដើរចេញមក ហើយយកថ្នាំប្រឡាក់បាយ មកដល់ខាងអាយ ក៏ត្រូវនឹងខ្នានោះស្លាប់ អាមួយដើរប្រញាប់ ចាប់បាយស៊ី ទើបនឹងស្ដាំអាសិរពិសថ្នាំក៏ពុលស្លាប់បន្ទាប់គ្នា ។ ឯក្របីនោះ ក៏អូសរទេះចូលព្រៃ វែតករតោកទៅជ្រកក្នុងទឹកត្រពាំង ប្រឆាំងដាច់ខ្សែទាម ដេកត្រាំទឹកទៅ ។ ដល់វេ-លាព្រឹក មានបុរសម្នាក់ ដើរទៅឃើញទ្រព្យរបស់ទាំងអស់ នៅក្នុងព្រៃទឹកម្ដងភ័យ ទឹកម្ដងអរ ថា ឯង អ្នកក្រ មិនដែលប្រទះទ្រព្យច្រើនណាស់ដូច្នេះបើវិលលកយកទៅផារបស់ខ្លួន ក្រែងពុំបានសុខ ក៏រុញរទេះសម្រុកទៅទុកក្នុងព្រៃ ចងក្របីជាប់ ត្រឡប់ទៅផ្ទះវិញ ហើយក៏ពិសោធមារយាទប្រពន្ធ ដោយគិតថា " បើប្រពន្ធមារយាទល្អ នឹងយកទ្រព្យនោះទៅផារបស់ខ្លួន បើនិយាយទៅមិនចេះលាក់នឹងយករបស់ទាំងអស់ ទៅជូនរាជការផែនដី ជាប្រយោជន៍ដើម្បីឲ្យតែសុខខ្លួន " ។ គិតហើយ ដើរដល់ផ្ទះ ក៏កុហកប្រាប់ប្រពន្ធថា អញជុះអាចម៍មិញ ។ មានសត្វក្អែកមួយ ហើរចេញអំពីគ្ទិត តែឯងអាណិត បិទមាត់ឲ្យឈឹង កុំឲ្យនរណាគេដឹងមួយជាពីរតែចូលត្រចៀកគេ វាបែកការអាក្រក់ណាស់ កើតមានទំនុំជម្រះ សួរទៅសួរមកហើយគ្មានទាំងសាក្សីបានដឹងនឹងអាង ក្រែងគេយកអញទៅគ្នាង ឬយកទៅដាក់

គុក ” ប្រពន្ធមិនលាក់ទុក ក៏ដើរទៅប្រាប់គេថា “ មានក្អែកហើរចេញពីក្ដិតប្ដីអញ តែឯងកុំបាត់ ” មេប្ញយទៀតមិនអត់ ទៅប្រាប់គេថែមទៀត ក្អែក ៥ ប្រាប់លើស មួយ ៗ ពគ្នា ដរាបដល់ក្អែកដប់ ។ រឿងនោះ ក៏ជ្រួតជ្រាបទៅដល់ព្រះមហាក្សត្រ ។ ទ្រង់ចាត់ប្រើរាជអមាត្យ ឲ្យស្រាវជ្រាវរកដល់បុរសនោះ ៗ ក៏ថ្វាយបង្គំគាល់ ស្ដេច ទ្រង់ឆ្ងល់ ត្រាស់សួរថា “ មែន ឬ មិនមែន ” ។ បុរសក្រាបទូលថា “ ទូលព្រះ បង្គំជាខ្ញុំ កុហកប្រពន្ធចង់ដឹងចិត្ត ព្រោះត្បិតឃើញទ្រព្យច្រើន ។ បុរសនោះ រៀប រាប់ក្រាបទូលដូចខាងលើ ហើយក្រាបបង្គំលាទៅទីមរទេះយកទ្រព្យមកថ្វាយស្ដេច ។ ទ្រង់ព្រះរាជទាន ឲ្យបុរសនោះពាក់កណ្ដាល ពាក់កណ្ដាលដាក់ឃ្លាំង ។

**ធ្វើផ្ទះ កុំជាក់ជណ្ដើរ**
**ឈោះខ្ញុំបម្រើ កុំឱ្យបាយស៊ី**

# ១១ – រឿងចៅសុក្រ និង ចៅសៅរ៍ (១)

កាលពីព្រេងនាយ មានបុរសពីរនាក់ ជាសម្លាញ់នឹងគ្នា មួយឈ្មោះចៅសុក្រ មួយឈ្មោះ ចៅសៅរ៍ បានបួសនៅវត្តជាមួយគ្នា ។ បួសយូរបន្តិចទៅ ក៏សឹកមកវិញ សឹកមកហើយ ក៏ជាសម្លាញ់នឹងគ្នាទៀត សន្យានឹងគ្នាថា "បើនរណាក្រ ត្រូវជួយគ្នា" ហើយបុរសទាំងពីរនាក់ក៏មានប្រពន្ធកូន នៅរកស៊ីទិទៃពីគ្នា ។ ចៅសុក្រ រកស៊ីទៅមានទ្រព្យរបស់ច្រើន ។ ឯចៅសៅរ៍ ល្ងង់ខ្លៅ ក្រលំបាក ហើយប្រពន្ធក៏មានសហាយផង ។ ចៅសុក ដឹងថា ប្រពន្ធចៅសៅរ៍ មានសហាយ ហើយក្រលំបាកដូច្នោះ ក៏ទៅសួរចៅសៅរ៍, ទៅដល់ឃើញចៅសៅរ៍ ក្រលំបាកណាស់មែន ក៏បបួលចៅសៅរ៍ ទៅរកស៊ីហើយនិយាយថា "ត្រូវឯងតាមពាក្យអញ" ។ ចៅសៅរ៍ ក៏ព្រមតាមពាក្យចៅសុក្រ ។ ចៅសុក្រ បបួលចៅសៅរ៍ទៅកាប់ឈើ ធ្វើក្តារមឈូសលក់ ។ ចៅសៅរ៍ តាមពាក្យចៅសុក្រ ក៏ព្រមទៅជាមួយគ្នា ។ ឯកូនសេដ្ឋី ដែលសហាយនឹងនាងប៉ិច ជាប្រពន្ធចៅសៅរ៍ ឃើញចៅសៅរ៍ មិននៅផ្ទះ ក៏ទៅដេកនឹងប្រពន្ធចៅសៅរ៍ រួចហើយវិលទៅផ្ទះវិញ ។ ចៅសុក្រ និង ចៅសៅរ៍ ធ្វើក្តារបឈូសបានមួយ ក៏យកមកដាក់ក្នុងផ្ទះ ហើយទៅធ្វើក្តារមឈូសទៀត ។ កូនសេដ្ឋី ក៏ទៅដេកនឹងនាងប៉ិចទៀត ។ ដល់ពាក់កណ្តាលអធ្រាត្រ ចៅសុក្រ និងចៅសៅរ៍មកផ្ទះវិញ ។ ចៅសុក្រ ខំដើរប្រញាប់មកមុន ស្រែកហៅប្រពន្ធចៅសៅរ៍ ឲ្យបើកទ្វារ ។ ឯកូនសេដ្ឋី ក៏ភិតភ័យ រត់ពុំរួច នាងប៉ិច ប្រា

១– ច្បាប់សរសេរដៃលេខ C.20.B របស់លោក E–Aymonier ទំព័រ ៣៨ ផ្នែកខាងភាសាខ្មែរ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ និង កម្ពុជសុរិយា លេខ ១-២-៣ ឆ្នាំ ១៩៣៦ ទំព័រ ៧៩ គ្មានឈ្មោះអ្នករៀបរៀងទេ ។

សហាយឲ្យចូលដេកក្នុងក្ដារមឈូស ហើយទៅបើកទ្វារ ឲ្យចៅសុក្រចៅសៅរ៍



ចូលទៅក្នុងផ្ទះ ។ នាងប៉ិច សួរថា "ដូចម្ដេច ក៏បានជាវិលមកវិញ? " ចៅសៅរ៍ ប្រាប់ថា "ចៅសុក្រ ឈឺក្បាលហៅវិលមកវិញ" ហើយចៅសៅរ៍ ប្រាប់ទៅនាងប៉ិចឲ្យដណ្ដាំបាយស៊ី, ស៊ីបាយរួចហើយ ដោយចៅសុក្រ ដឹងថា សហាយនាងប៉ិច ដេកនៅក្នុងក្ដារមឈូស ក៏ប្រាប់ទៅចៅសៅរ៍ថា "រកផ្ដៅមក ចងក្ដារមឈូសទុកក្រែងចោរលួច", ចៅសៅរ៍ ក៏យកផ្ដៅទៅចងរួចស្រេច ហើយយកដែកគោលបោះថែមទៀត ។ ឯចៅសៅរ៍ពុំដឹងជាប្រពន្ធមានសហាយ ក៏ធ្វើតាមពាក្យចៅសុក្របង្គាប់ ។ លុះព្រឹកឡើងចៅសៅរ៍ ប្រើនាងប៉ិចជាប្រពន្ធ ឲ្យទៅទិញអីវ៉ាន់, នាងប៉ិច ក៏ហួសទៅប្រាប់សេដ្ឋីថា "ឲ្យសេដ្ឋីចាំទិញមឈូស ត្បិតកូនសេដ្ឋី ទៅដេកនឹងខ្ញុំ ប្ដីខ្ញុំមកទាន់ បានរត់ចូលដេកក្នុងមឈូស, ឥឡូវនេះ

ប្ដីខ្ញុំសែងយកមកដល់ព្រឹកនេះហើយ ,, ។ ប្រាប់ហើយ នាងប៉ិច ក៏ត្រឡប់ទៅផ្ទះវិញ ។ លុះចៅសុក្រ និង ចៅសៅរ៍ ស៊ីបាយរួច ក៏សែងមឈូស យកទៅលក់ ។ សេដ្ឋីឲ្យខ្ញុំមួយនាក់ ចាំមើលផ្លូវ ផ្ដាំថា ,, បើឃើញអ្នកណាសែងក្ដារមឈូសមកដល់ ឲ្យរត់ទៅហៅយើង ,, ។ ចៅសុក្រ និងចៅសៅរ៍ សែងក្ដារមឈូសមកដល់ផ្ទះសេដ្ឋី ស្រែកពពាយនាយថា " អ្នកណាទិញក្ដារមឈូសទេ "។ សេដ្ឋីឮ សួរថា " លក់តម្លៃប៉ុន្មាន ? " ។ ចៅសុក្រប្រាប់ថា " ឲ្យចាក់ប្រាក់ពីដីឡើង ស្មើនឹងមឈូស " ។ សេដ្ឋីសុំតថ្លៃ ក៏ចៅសុក្រមិនព្រម ។ សេដ្ឋីក៏ប្រើខ្ញុំកំដរឲ្យយកប្រាក់មកចាក់ ស្មើនឹងមឈូស ហើយចៅសុក្រ និង ចៅសៅរ៍ យកប្រាក់ទៅចែកគ្នា ។ សេដ្ឋី គាស់មឈូសយកកូនចេញ ។ ក្រោយមក ចៅសៅរ៍ យកនាងប៉ិចជា ប្រពន្ធដូចដែលវិញ ។

**អួសឧទ្ធកមិនឱ្យល្អាន ចាប់ត្រីបាន មិនឱ្យល្អក់ទឹក**

---

# ១២- រឿងគ្រូ និង សិស្ស(១)

មានរឿងមួយ ដំណាលថា: មានភិក្ខុមួយអង្គ គង់នៅវត្តមួយ មានកូនសិស្សតែម្នាក់ ឈ្មោះអាថ្លូញ ។ អាថ្លូញ ខិលណាស់ គ្រូក៏ល្ងង់ណាស់ ឆោតណាស់ គ្មានឧបាសកឧបាសិកាណារាប់អាន យកចង្ហាន់ ស្លា បារីទៅប្រគេន ឬនិមន្តលោកនោះ ទៅឆាន់ឯផ្ទះដល់ម្ដងឡើយ, លោកនោះ ក្រលំបាកពន់ពេក តែលោកមានដំរីមួយ ។

ថ្ងៃមួយ លោកនោះ ពិចារណាថា " សព្វថ្ងៃនេះ គ្មានឧបាសកគេប្រគេនវត្ថុអ្វីសោះ, បើដូច្នេះ គួរតែអញទិញវត្ថុផ្សេងៗ យកមកទុកឆាន់ កុំឲ្យលំបាក ។ គិតដូច្នោះហើយ ក៏ប្រាប់កូនសិស្សថា " អាថ្លូញ ឯងចាប់ដំរីមក ហើយឯងទៅផ្សារនឹងអញ រកទិញវត្ថុផ្សេងៗ យកមកទុកឆាន់ " ។ កូនសិស្សទៅចាប់ដំរីបានមក, គ្រូនិងកូនសិស្ស ក៏ឡើងជិះដំរីបរទៅផ្សារ ។ លុះទៅដល់ គ្រូប្រាប់កូនសិស្សថា " ឯងទិញវត្ថុអ្វីដែលគេទុកស៊ីបានយូរ មិនខូច" ។ អាថ្លូញជាសិស្ស ក៏ទិញអំបិលមួយចុង ច្រកការុងស្រេច ។ គ្រូឃើញ សួរថា ហេតុម្ដេច ក៏ឯងទិញតែអំបិល មិនទិញត្រីឆ្អើរ ត្រីងៀតផង? " ។ កូនសិស្សទូលថា អំបិលទុកបានយូរ មិនចេះខូច បានជាខ្ញុំព្រះករុណាទិញ ។ គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម ។

គ្រូឡើងបរដំរីមកវិញ សិស្សវែកអំបិលពីក្រោយ, ដល់ពាក់កណ្ដាលផ្លូវ

---

១ កម្ពុជសុរិយា លេខ ៤-៥-៦ ឆ្នាំ ១៩៣៩ ទំព័រ ៣១ គ្មានឈ្មោះអ្នករៀបរៀងទេ ។

គ្រូមើលទៅសិស្ស ឮសួរដងរែកដូចជាស្រួល ក៏សួរថា « អាផ្លូញ! អញមើលទៅឯងរែកអំបិល ដូចជាស្រួល ឬ យ៉ាងណា? » ។ សិស្សទូលថា « ព្រះករុណា! ស្រួលណាស់ ហើយស្រាលផង » ។ លោកគ្រូប្រាប់សិស្សថា « ឯងជិះដំរី វិញចុះ អញរែកអំបិលដើរក្រោយ » ។ លោកគ្រូថាហើយ ចុះពីលើដំរីមក, សិស្សក៏ឡើងជិះដំរីទៅ ។ លោកគ្រូប្រាប់ថា « ឯងបរដំរីទៅចាំអញនៅមូប់ឈើឯមុខ » ។ សិស្សបរដើរទៅដល់មូប់ឈើ ក៏មិនឈប់ចាំគ្រូ បរហួតទៅវត្ត ។

លោកគ្រូ រែកអំបិលដើរតាមក្រោយ, ដោយអំបិលនោះ ធ្ងន់ណាស់, លោកគ្រូរែកឈប់ ៗ រកមើលទៅសិស្សមិនឃើញ ក៏គិតថា « ចាំក្រោយ សឹមនាំសិស្សមកយក » ហើយយកអំបិលទៅលាក់ក្នុងព្រៃមុននឹងលាក់ លោកគិតថា « មីនេះប្រសិនជាមានគេដើរមកចំឃើញ គេនឹងយកអំបិលនេះអស់មិនខាន គួរតែរកទីណាដែលកំបាំងភ្នែកអ្នកទាំងពួង គឺមានក្នុងទឹក ទើបគេមើលមិនឃើញ » ហើយក៏យកអំបិលទាំងពីរការុងទៅលាក់ទុកក្នុងទឹក ហើយដើរទៅ ។ លុះដល់វត្តសួរសិស្សថា « ហេតុអ្វេចក៏ឯងមិនចាំអញ? » ។ សិស្សទូលថា ខ្ញុំព្រះករុណាបរដំរីមក ប្រុងចាំលោកគ្រូដែរ តែដំរីមិនព្រមចាំសោះ អង្វរដូចម្តេច ក៏វាមិនព្រម វាប្រឹងតែដើរដល់វត្ត ទើបឈប់ ។ សិស្សសួរគ្រូថា « លោកគ្រូ ទុកអំបិលឯណា? » ។ គ្រូប្រាប់ថា អញលាក់ទុក នៅទីឯណោះ អញកាត់ដើមឈូកដោតជាសំគាល់ » ។ លុះព្រឹកឡើងលោកក៏នាំកូនសិស្ស ទៅយកអំបិលវិញ លុះដល់ ប្រាប់សិស្សថា « អញលាក់ក្នុងទឹកត្រពាំងនេះ » ។ សិស្សលាន់មាត់ថា « ម៉ែអើយ វារលាយអស់ទៅហើយ » ។ អាផ្លូញជាសិស្ស ក៏ចុះទៅយកអំបិល ចាប់លើកការុងទាំងពីរឡើងគ្មានឃើញអំបិលសល់សោះ ព្រោះវារលាយអស់ហើយ, ឯចំណងដែលចងមាត់ការុង ក៏ឃើញដាច់អស់ ប្រទះឃើញ ឯត្រីកញ្ចុះមួយនៅក្នុងការុងនោះ ។ សិស្សទូលលោកគ្រូថា « មានត្រីកញ្ចុះមួយ នៅក្នុងការុង វាស៊ីអំបិលអស់ទៅហើយ » ហើយយកត្រី និង ការុងមកប្រគេនគ្រូមើល ។ លោកគ្រូឃើញត្រី ខឹងណាស់ ក៏ទះ

កំភ្លៀងត្រី មុតដៃនឹងធ្នុងត្រីជាប់ ។ ពិសត្រី ចាប់ពើតឈឺខ្លាំងពេក លោកគ្រូថា « ឯងចាប់ដកធ្នុងត្រីចេញឲ្យឆាប់ ត្បិតឈឺអញណាស់ » ។ សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច ។ លុះដករួច ឈាមហូរខ្លាំង ពិសត្រីក៏រឹតតែបណ្ដាលឲ្យលោកឈឺខ្លាំងឡើង, លោកគ្រូ នាំកូនសិស្សទៅវត្តវិញ យកទាំងការុងត្រីកញ្ចុះទៅផង, ទៅដល់វត្ត ប្រាប់សិស្សថា « អាផ្លូញ ឯងដាំបាយមួយឆ្នាំង រវាងត្រីកញ្ចុះនេះឲ្យឆ្អិនជាឆាប់ អញនឹងឆាន់ » ។ លុះពិសអន់ចាប់ពើត លោកគ្រូ ក៏សម្ងំសឹងលក់ទៅ ។

ឯអាផ្លូញ ក៏ដាំបាយ អាំងត្រីឆ្អិនហើយ បរិភោគអស់ ទុកតែបាយមួយពំនូត និងឆ្អឹងត្រីក្នុងចានគ្រប តែវាគ្របមិនឲ្យជិត ។ លោកគ្រូភ្ញាក់ឡើង ប្រាប់សិស្សថា « ឯងយកបាយនឹងត្រីមកឆាន់ » ។ អាផ្លូញក៏ធ្វើកិរិយាដូចជាចូលទៅយកបាយប្រគេន ចេញមកវិញ ទូលថា បាយនិងត្រី រុយស៊ីអស់ទៅហើយ នៅសល់តែមួយពំនូត និងឆ្អឹងត្រី » លោកគ្រូជឿឥតសង្ស័យ ដោយភោគលួង់ ក៏ហុចរំពាត់ផ្ដៅមួយឲ្យមកសិស្សហើយថា « ឯងវាយរុយ កុំឲ្យវានៅលើកុដិ » ។ អាផ្លូញជាសិស្សក៏វាយរុយមិនឈប់ ។ គ្រានោះ មានរុយមួយ ទំចុងច្រមុះគ្រូ ។ ប្រាប់ថា « រុយវាទំច្រមុះអញ ឯងវាយឲ្យឆាប់ » ។ កូនសិស្សក៏វាយតាមពាក្យគ្រូ វាយទៅ ។ មិនត្រូវរុយ ត្រូវឯច្រមុះគ្រូ បែកឈាមហូរខ្លាយ ។ សិស្ស ភ័យណាស់ រត់ទៅដល់ផ្ទះ និយាយប្រាប់ឪពុកម្ដាយតាមរឿង ។ ឪពុកម្ដាយប្រាប់កូនឲ្យមកវត្តវិញ កូនប្រកែកមិនព្រមមក ។ លោកគ្រូទៅតាម ក៏វាមិនហ៊ានមកដោយខ្លាចគ្រូវាយ ។

ថ្ងៃក្រោយ លោកគ្រូតាំងពិធីសូត្រមន្តអាគមស្នេហ៍ បន្ទន់ចិត្តសិស្សឲ្យមក ។ អាផ្លូញជាសិស្ស បានដឹងថា គ្រូតាំងពិធីមន្តអាគមស្នេហ៍ដូច្នោះ ក៏មកវត្តវិញ ដើម្បីឲ្យគ្រូជឿថា ស្នេហ៍ពូកែ, លុះដល់វត្តដើរលប ៗ ចូលទៅ ឃើញគ្រូកំពុងតែអង្គុយសូត្រមន្តអាគមស្នេហ៍ ក៏សួរលោកថា « លោកគ្រូធ្វើអ្វី ? » គ្រូកុហកថា «អញសូត្រមន្តអាគមបំបាំងខ្លួន ព្រោះអញទើបរៀនពីគេ » ។ ជាបន្ទាន់នោះ លោក

គ្រូគិតថា « ស្នេហ៍អញពូកែមែន បានសិស្សអញវាមក » ។ លុះព្រឹកឡើង សិស្សដាំបាយ ធ្វើម្ហូបស្រេច ទូលថា « ចង្ហាន់ឆ្អិនហើយ » ។ លោកគ្រូថា « បើដូច្នេះ ឯងលើកមកឲ្យអញឆាន់ » ។ អាផ្លូញ ក៏លើកមកប្រគេន ធ្វើជាមើលមិនឃើញ ដាក់ចាសទៅលើក្បាលគ្រូ ។ ស្រែកថា « អាផ្លូញ ! ហេតុម្ដេចក៏យកចាសមកដាក់លើក្បាលអញ ? » ។ សិស្សទូលថា « ខ្ញុំព្រះករុណាមើលមិនឃើញ » ។ លោកគ្រូងាកចេញ អាផ្លូញ ក៏ដាក់ចាសលើក្បាលគ្រូទៀត ។ លោកគ្រូថា « អាឯងដាក់ចាសលើក្បាលអញទៀតហើយ » ។ សិស្សថា « ខ្ញុំព្រះករុណាសុំទោស ព្រោះមើលមិនឃើញ ។ លោកគ្រូជឿថា អញរៀនស្នេហ៍ ។ ពូកែប្រាកដ, ឥឡូវ អញកុហកវាថា តាំងពិធីមន្តអាគមបំបាំងខ្លួនវិញ ក៏ទៅជាពូកែ គេមើលមិនឃើញប្រាកដមែន, គួរទន្ទេញឲ្យចាំ កុំឲ្យភ្លេច » ។

ឯអាផ្លូញ លុះប្រគេនចង្ហាន់គ្រូ គ្រូឆាន់រួចហើយ វាក៏លើកមកបរិភោគខ្លួនវា ។

ថ្ងៃក្រោយ មានឧបាសក គេនិមន្តលោកទៅឆាន់ឯផ្ទះ ។ អាផ្លូញទូលថា « បើលោកគ្រូ និមន្តទៅឆាន់ឯផ្ទះគេ សូមកុំស្លៀកស្បង់ ព្រោះធាំតែចាស់ស្បង់ខូចឥតអំពើ ឃ្លុំតែចីពរបានហើយ គេមើលមិនឃើញទេ ត្បិតលោកគ្រូចេះមន្តអាគមបំបាំងខ្លួន ពូកែណាស់ អ្នកណានឹងមើលឃើញ » ។ គ្រូជឿក៏ធ្វើតាមពាក្យសិស្ស ។

លុះព្រឹកឡើង លោកគ្រូប្រាប់សិស្សថា « ឯងតាមអញទៅឆាន់ឯផ្ទះឧបាសក » រួចលោកឃ្លុំតែចីពរ មិនស្លៀកស្បង់ ដោយគិតថា « ឃ្លុំតែចីពរបានហើយ ព្រោះមន្តអាគមអញ ពូកែណាស់ នរណានឹងមើលកេរ្តិ៍ខ្មាស់ឃើញ » រួចក៏នាំកូនសិស្សទៅ ។

លុះទៅដល់ ឧបាសកនិមន្តឡើងលើផ្ទះហើយ គេលើកចង្ហាន់មកដើម្បីប្រគេនលោកឆាន់, ដោយលោកមិនបានស្លៀកស្បង់ អង្គុយមិនស្រួលងាកឆ្វេងងាកស្តាំ ក៏លេចកេរ្តិ៍ខ្មាស់(១) កណ្តាលវាល ។ ឧបាសកឃើញដូច្នោះ គេនាំគ្នាសើចហើលាន់ ។ លោកគ្រូ ពុំទាន់បានឆាន់ចង្ហាន់ មានចិត្តខ្មាស់ណាស់ ក៏ចុះពី-ផ្ទះត្រឡប់មកវត្តវិញ ដេរបន្ទោសសិស្សថា «អាឯង មិនឲ្យអញស្លៀកស្បង់ ឥឡូវអញខ្មាស់គេណាស់ » ។ អាផ្លូញទូលថា « លោកគ្រូ កុំខ្ញាល់នឹងខ្ញុំព្រះករុណា រឿងនេះប្រហែលខុសត្រណមទេឬ ? » ។ លោកគ្រូសួរថា « ឯងឃើញអញធ្វើខុសត្រណមដូចម្តេច ? ។ អាផ្លូញសួរថា « កាលលោកគ្រូ និមន្តទៅឆាន់ឯផ្ទះឧបាសក និមន្តទៅផ្លូវខាងណា ? » ។ លោកគ្រូប្រាប់ថា « កាលអញទៅ អញចេញផ្លូវខាងកើត » ។ សិស្សថា « ឱ ! ច្បាស់ជាលោកគ្រូខុសត្រ-ណមហើយ ។ ថ្ងៃមុនលោកគ្រូប្រាប់ខ្ញុំព្រះករុណាថា បើរៀនមន្តអាគមទាំងពួងត្រូវតមស៊ីផ្លែស្ពឺ សូម្បីមុជក្រោមដើមស្ពឺ ក៏មិនបាន វាសាបមន្តអាគម, ឥឡូវលោកគ្រូមុជក្រោមដើមស្ពឺ បានជាខុសត្រណម សាបអាគមរបស់ ហេតុនេះបានជាគេឃើញកេរ្តិ៍ខ្មាស់លោកគ្រូ » ។ លោកគ្រូ បានស្តាប់ដូច្នោះ ក៏ថា «ឱ-អាផ្លូញ ! អញភ្លេចតម បានជាយ៉ាងហ្នឹង, នេះថានោះពិតប្រាកដហើយ » ។ លោកគ្រូនោះ ដោយឆោតល្ងង់ ក៏ជឿជាក់ឥតសង្ស័យ ។ តាំងពីកាលនោះមក អាផ្លូញ ជាសិស្ស នៅបម្រើដោយសុខសប្បាយទៅ ។

ស្លូតស្លាប់ ទៀចទេរមានគំព អាយុយឺនយូរ

---

១ ហៅតែ ( ខ្មាស់ ) ទះទក់មាន ។

# ១៣-រឿង កម្លោះពីរនាក់ ចង់បានប្រពន្ធគេ

មានរឿងមួយថា មានបុរសម្នាក់ មានប្រពន្ធល្អ ទើបតែរៀបការថ្មី ៗ បណ្ដើរគ្នាទៅសួរញាតិ មានកម្លោះពីរនាក់ បានឃើញ ក៏ស្រឡាញ់ចង់បាន វាគិតថា " យើងធ្វើដូចម្ដេចនឹងបានអេះ? " ។ ចៅម្នាក់ ឆ្លើយថា ងាយទេ ឯងគិតទៅរកខ្ចីរទេះគោមកបរ ប៉ុន្តែឯងធ្វើមិនស្គាល់អញ បើអញសួរឯង ៗ កុំប្រាប់ថារទេះ ចូរឯងប្រាប់ថាចន្ទោល ថា នឹម ទៅវិញ ។ ទើបកម្លោះម្នាក់ ទៅខ្ចីរទេះគេមកបរឲ្យជួបនឹងបុរសបណ្ដើរប្រពន្ធនោះដើរមកដល់, ក៏កម្លោះម្នាក់នោះវាសួរថា " នែ អ្នក! អញ្ជើញមកអាយ ឈប់និយាយគ្នាលេងបន្តិចសិន " ។ បុរសការប្រពន្ធថ្មី ក៏ចូលទៅអង្គុយលេង ។ លុះកម្លោះម្នាក់ បររទេះមកដល់ វាធ្វើជាសួរថា " នេះហៅអ្វី? អ្នក! ,, ។ បុរសប្ដីប្រពន្ធ ឆ្លើយប្រាប់ថា ‹‹ គេហៅរទេះ ,, ។ ‹‹ មែនឬអ្នក? ,, ។ បុរសនោះថា ‹‹ មែន ,, ។ ‹‹ បើមែនអ្នកហ៊ានភ្នាល់នឹងខ្ញុំទេ ,, ។ បុរសនោះសួរថា ‹‹ អ្នកឯង មានទ្រព្យអ្វីភ្នាល់នឹងយើង? ,, ។ កម្លោះនោះថា ‹‹ បើខ្ញុំចាញ់ ខ្ញុំនៅជាខ្ញុំអ្នក បើខ្ញុំឈ្នះ ‹‹ សុំតែប្រពន្ធអ្នក ,, ។ បុរសនោះ គិតថា ប្រាកដជាគេហៅរទេះមែននឹងខ្លាចអ្វី ក៏ព្រមភ្នាល់នឹងគេទៅ ។ ទើបកម្លោះដែលឈរ សួរទៅអ្នកបររទេះចង្អុលទៅសួរទៅចន្ទោល, កម្លោះអ្នកបររទេះប្រាប់ថា ‹‹ នេះគេហៅចន្ទោល ,, ។ ចង្អុលសួរទៅនឹមថា « នេះគេហៅនឹម » ‚ « នេះ គេហៅទូក» «នេះ គេហៅទ្រាយ » «នេះ គេហៅប្រែក » « នេះ គេហៅកង់ » « នេះគេហៅ

ខ្នងកង់ » « នេះ គេហៅត្រពង » ដល់ឆ្លើយរួចសព្វគ្រប់ កម្លោះនោះ សួរទៅបុរសជាប្ដីថា « ឥឡូវ គេមិនហៅរទេះទេ បើដូច្នោះ តើអ្នកឯងព្រមចាញ់យើងឲ្យប្រពន្ធមកយើងឬម្ដេច ? » ។ បុរសជាប្ដីនោះ មិនព្រម, ដល់ប្រកែកទៅមិនឈ្នះគេ ។ ដណ្ដើមយកប្រពន្ធទៅបាន ។ បុរសនោះមិនសុខចិត្តទៅប្ដឹងចៅក្រម ។ ឲ្យទៅកោះចៅទាំងពីរនោះមកជុំនុំ, កម្លោះទាំងពីរនាក់នោះវាសូកចៅក្រម។ កាត់សេចក្ដីថា « ត្រូវចាញ់គេហើយ ត្រូវឲ្យប្រពន្ធទៅគេហើយ » ។ បុរសនោះខឹងណាស់ ត្បិតគេយកប្រពន្ធទៅបាន ដើរផង យំផង, ដើរបន្តិចទៅ ប្រទះសុភាទន្សាយ ។ សួរថា « ថ្វីបានជាយំបង ? » ។ បុរសនោះប្រាប់តាមដំណើរសព្វគ្រប់ ។ សុភាទន្សាយថា « បើដូច្នោះបងឯងកុំភ័យ រកតែចេកមកឲ្យយើងស៊ីសិន យើងទៅជួយជុំនុំឲ្យបានប្រពន្ធមកវិញ » ។ បុរសនោះអរណាស់ ខំទៅរកចេកយកមកឲ្យសុភាទន្សាយ ។ ស៊ីចេករួចហើយ ដើរទៅជាមួយបុរសនោះទៅដល់សួរចៅក្រមថា « លោកកាត់សេចក្ដីគេនោះ តើដូចម្ដេចខ្លះ ? » ។ ចៅក្រម ឆ្លើយប្រាប់តាមដំណើរសព្វគ្រប់ ។ សុភាទន្សាយថា « លោកកាត់សេចក្ដី មិនទាន់អស់ទេ បើដូច្នេះ ខ្ញុំសូមកាត់សេចក្ដីនេះផងឲ្យសុខចិត្តទាំងពីរខាង » ។ សុភាទន្សាយ សួរកម្លោះដែលយកប្រពន្ធគេមកនោះថា « អ្នកទាំងពីរនាក់ កាលភ្នាល់គ្នា ថាដាក់អ្វី ? » ។ បុរសនោះ ឆ្លើយថា « ដាក់ប្រពន្ធ» ។ សុភាទន្សាយ សួរទៅកម្លោះនោះថា « ត្រង់ណាហៅប្រពន្ធ » បើអ្នករកឃើញយកទៅចុះ បើរកមិនឃើញទេ ឲ្យប្រពន្ធទៅគេវិញទៅ » ។ កម្លោះនោះ ចាប់ត្រង់ដៃ, សុភាទន្សាយប្រាប់ថា នេះគេហៅថាដៃទេ វាចាប់ត្រង់ជើង សុភាទន្សាយថា « នេះគេហៅជើងទេ » វាចាប់ត្រង់នេះ ក៏ថា មិនមែន, ត្រង់នោះក៏ថាមិនមែន ហើយប្រាប់ថារួមទាំងអស់គ្នាទៅទើបគេហៅ « ប្រពន្ធ » ឯរទេះក៏ដូចគ្នា គឺគេហៅចន្ទោល នឹម ទូក ទ្រាយ ប្រែក ធ្នង់ ត្រពង រួមទាំងអស់នេះមៅ ទើបហៅថា « រទេះ » បើដូច្នេះ ឯងយកប្រពន្ធគេ មិនបានទេ ឲ្យ

មកគេវិញ » ។ សុភាទន្សាយ ឲ្យកម្ទោះនោះ យកប្រពន្ធមកវិញ ។ សុភាទន្សាយស្ដីឲ្យលោកចៅក្រម ថា « បងកាត់សេចក្ដីនេះស៊ីតែសំណូកគេ គ្មានត្រង់តាមព្រះច្បាប់សោះ » ។ បុរសនោះបានប្រពន្ធមកវិញ ក៏អរណាស់ លើកដៃសំពះសុភាទន្សាយថា « លោកបងកាត់សេចក្ដីនេះ ពេញហោត្រង់ហើយ ឲ្យលោកបានសម្បត្តិសួគ៌និព្វាន » ។

## ប្រាជ្ញឯង ឱ្យត្រែងប្រាជ្ញគេ

# ១៤– រឿងជាតិខ្លាធំ(១)

កាលពីព្រេងនាយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គ សោយរាជសម្បត្តិនៅនគរមួយ មានអគ្គមហេសី ជាចមស្ត្រី មានបន្ត្រីចតុស្តម្ភ ៤ នាក់ មានហោរាមួយនាក់ ជាតំណាងព្រះនេត្រ ព្រះកាណ៌ព្រះអង្គ មានមន្ត្រី និងស្រីស្នំជារាជបរិពារ ពេញកិត្តិយសជាម្ចាស់ផែនដី តាមព្រះរាជប្រពៃណីអំពីបុរាណរៀងមក ប៉ុន្តែ ព្រះមហាក្សត្រិយ៍និងចតុស្តម្ភ ទាំង ៤ នាក់ ពុំបានរៀនវេទមន្ត ខាងការពិជ័យសង្គ្រាម ដូចព្រះរាជាមុនៗមកឡើយ ព្រះអង្គតែងទ្រង់ព្រួយបារម្ភនឹងព្រះមហានគរជាអនេក ។ ដោយព្រះរាជានុភាពរបស់ព្រះអង្គ ចេះតែទន់ទាបចុះ ទ្រង់ក៏រំពឹងថា " បើប្រសិនជាមានសឹកសត្រូវ ចូលមកលុកលុយដណ្តើមព្រះនគរ អញមុខជាព្រះនគរ នឹងបានទៅក្នុងកណ្តាប់ដៃ នៃបច្ចាមិត្រ ដោយងាយពុំខានឡើយ " ។

ថ្ងៃមួយ វេលាម៉ោង ៨ ព្រឹក ព្រះអង្គ ទ្រង់យាងចេញកាន់ចុងព្រះរាជរោង ដោយមានព្រះអគ្គមហេសី គង់អែបនែបជិតព្រះអង្គ ហើយដោយមានហោរា ចតុស្តម្ភទាំង ៤ នាក់ និងមន្ត្រីឯទៀត ក្រាបបង្គំគាល់តាមធម្មតា ។ ពេលនោះ ទ្រង់ភ្នកព្រះទ័យ ចង់ទៅរៀនសិល្បសាស្ត្រ ក្នុងសំណាក់អាចារ្យទិសាបាមោក្ខឯនគរតក្កសិលា ។ ទ្រង់ក៏ជំនុំជាមួយព្រះអគ្គមហេសី ក៏សុំតាមទៅផង ។ ឯ-

---

១ ច្បាប់សរសេរដៃ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យលេខ G 20 B របស់លោក E. Aymonier ទំព័រ ៣៤ ផ្នែកភាសាខ្មែរ និង ក្នុងកម្ពុជសុរិយា លេខ ១០-១១-១២ ឆ្នាំ ១៩៣៧ ទំព័រ ៤៣ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ហោរា និងចតុស្តម្ភទាំង ៤ នាក់ ក៏សុំតាមហែព្រះអង្គទៅដែរ ដើម្បីនឹងរៀនមន្តវិជ្ជាឲ្យជំនាញ ដើម្បីរក្សាព្រះនគរ ។ ព្រះអង្គ ក៏ទ្រង់ព្រះរាជានុញ្ញាត ។ ជំនុំស្រេចហើយ មានថ្ងៃមួយ ព្រះអង្គនាំអគ្គមហេសី ហោរា និងចតុស្តម្ភទាំង ៤ នាក់ ចេញចាកព្រះនគរ ។ គម្រប់ ៧ ថ្ងៃ ដល់នគរតក្កសិលា បានជួបនឹងអាចារ្យទិសាបាមោក្ខ ក៏សុំរៀនសិល្បវេទ ។ អាចារ្យទិសាបាមោក្ខ ទទួលភារៈបង្រៀនព្រះអង្គ ។ ព្រះអគ្គមហេសី និងហោរា ព្រមទាំងចតុស្តម្ភ បានរៀនចេះចប់សព្វគ្រប់ ទោះនឹងចង់ក្លែងខ្លួនជាសត្វតិរច្ឆាន ឬជាយក្ស គន្ធព្វ សុបណ្ណា ក៏បានដោយងាយ ។ រៀនចេះចប់ស្រេច ស្តេចសុំលាលោកអាចារ្យ វិលត្រឡប់មកព្រះនគរវិញ ។ អាចារ្យ ក៏អនុញ្ញាត ព្រះរាជា និងព្រះអគ្គមហេសី បានធ្វើព្រះរាជដំណើរ ត្រឡប់មកវិញ ព្រមដោយហោរា នូវចតុស្តម្ភទាំងបួននាក់ ។ ទ្រង់ចេញចាកក្រុងតក្កសិលាមក បាន ៣ ថ្ងៃ ហេតុតែផលកម្មនាំឲ្យវង្វេងផ្លូវ ទ្រង់យាងត្រាច់កាត់ព្រៃ រស់ស្បៀងអាហារ សោយតែមើមឈើ និងផ្លែឈើ ។ ព្រះរាជាទ្រង់ស្តាយព្រះជន្ម ទ្រង់ក៏ជំនុំគិតជាមួយហោរា ចតុស្តម្ភទាំង ៤ នាក់ ព្រមទាំងព្រះអគ្គមហេសីថា ‹‹ ឥឡូវនេះ យើងជិតដល់នូវការរស់អាយុសង្ខារគ្រប់គ្នាហើយ ព្រោះគ្មានអាហារនឹងចិញ្ចឹមជីវិត តើអស់លោកយល់ឃើញដូចម្តេច ?›› ។ ហោរាទូលព្រះអង្គថា ‹‹ ទូលព្រះបង្គំជាខ្ញុំ យល់ឃើញថា មន្តវិជ្ជាដែលយើងបានរៀនមក សឹងចេះសព្វគ្រប់ដូចគ្នា ហេតុនេះ បើកាឡាខ្លួនជាសត្វខ្លាធំ ហើយនឹងចាប់សត្វឯទៀត ធ្វើជាអាហារទំរាំតែទៅដល់ព្រះនគរ សឹបកាឡាខ្លួនជាមនុស្សវិញ ក៏បាន ›› ។ ព្រះរាជា ព្រះមហេសី នូវចតុស្តម្ភ ក៏ព្រមតាមហោរា ។ ទ្រង់មានព្រះបន្ទូលសួរថា ‹‹ ឥឡូវរូបខ្លាទាំងមូលនេះ លោកណាត្រូវកាឡាខ្លួនធ្វើជាអ្វី ?›› ។ ចតុស្តម្ភ សុំធ្វើជាជើងខ្លាទាំងបួន ។ ហោរា សុំធ្វើជាកន្ទុយ ។ ព្រះអគ្គមហេសី សុំធ្វើជាខ្លួនខ្លា ។ រូបខ្លាទាំងមូលនេះឃើញនៅសល់តែក្បាល គឺត្រូវព្រះមហាក្សត្រិយ៍ ។ ជំនុំរួចស្រេចក៏សូត្រមន្តវិជ្ជាកាឡាខ្លួន

កើតជាព្យគ្ឃរាជ ( ស្តេចខ្លា ) បានដូចសេចក្តីប្រាថ្នា ស្ទុះបោលដេញចាប់សត្វ-ប្រើស ក្តាន់ជាអាហារ ។ លុះអំឡុងទៅ ក៏កើតមានសេចក្តីសប្បាយ ភ្លេចរាជសម្បត្តិ និងព្រះមហានគរ ពុំស្តាយសោះ ។

ហេតុនេះ បានជាសត្វខ្លា មានកម្លាំងជាងសត្វឯទៀត ហើយសត្វខ្លានេះកាលនឹងចាប់សត្វជាអាហារ គឺដឹងដោយសារកន្ទុយជាមុន ព្រោះជាហោរា ។ ដងខ្លួនដែលទន់ភ្លន់គឺព្រះអគ្គមហេសី ជាស្ត្រីភាព ។ ឯក្បាលដែលមើលឃើញសម្បើមអស្ចារ្យ គឺតួអង្គព្រះមហាក្សត្រិយ៍ ដែលមានមហិទ្ធិឫទ្ធិជាងគេទាំងអស់ ។ ឯជើងទាំង ៤ ដែលមានកម្លាំងខ្លាំង ហើយមានក្រចកមុត គឺចតុស្តម្ភទាំង ៤ ។

## ប្រហែសបាត់ប្រយ័ត្នគង់

# ១៥– រឿងចោរចិត្តជា[១]

កិរ ដូចបានឮតៗ មកថា: កាលនោះ មានក្មេងប្រុសម្នាក់ នៅស្រុកមួយ, អ្នកស្រុក គេហៅថា « អាចោរចិត្តជា » ។ លុះក្មេងនោះ ចម្រើនធំឡើង ឪពុក ស្លាប់ទៅ នៅតែម្ដាយ ។ ចៅនោះ មិនគិតធ្វើការរកស៊ីអ្វីសោះ តែវេលាយប់កាលណា ដើររកលួចទ្រព្យសម្បត្តិ អ្នកស្រុកទាំងពួង ។ មាតាទូន្មានប្រដៅដូចម្ដេច ក៏មិនព្រមធ្វើតាម ទើបមាតាយកទៅឲ្យនៅវត្ត រៀនអក្សរ។ ចៅនោះ ក៏មិនខំរៀនសូត្រឡើយ ប្រព្រឹត្តតែដើរលួចទ្រព្យគេ យកមកចិញ្ចឹមមាតានិងអាត្មា ។ គ្រូរំលឹកប្រដៅដូចម្ដេចម្ដា ក៏មិនព្រមស្ដាប់ ។

ថ្ងៃមួយ ស្ដេចក្នុងនគរនោះទ្រង់ចេញប្រថាប់ចុងព្រះរាជរោងឲ្យសេនាបតី នាហ្មឺនសព្វមុខមន្ត្រីចូលគាល់ ទ្រង់មានព្រះរាជឱង្ការថា « មានខេត្តមួយនៅទំនេរពុំទាន់មានឈ្មោះណាទៅឈររក្សា បើអ្នកណាយកប្រាក់ ៤០ កហាបណៈមកដាក់ឃ្លាំងយើងនឹងឲ្យទៅឈរជាចៅហ្វាយស្រុកក្នុងខេត្តនោះ ។ ត្រាស់ហើយស្ដេចយាងចូលព្រះបរមរាជវាំងវិញ ។ គ្រានោះ មន្ត្រីតូចម្នាក់ វិលមកផ្ទះ ដេកកើតទុក្ខ ចង់ធ្វើចៅហ្វាយស្រុកពន់ពេក ។ លុះដល់វេលាយប់ ចូលដំណេកនិយាយនឹងភរិយាថា « នាងអើយ ឥឡូវនេះ ស្ដេចមានព្រះរាជឱង្ការថា បើឈ្មោះណាមានប្រាក់ ៤០ កហាបណៈ ថ្វាយព្រះអង្គដាក់ឃ្លាំង ទ្រង់នឹងឲ្យធ្វើចៅហ្វាយស្រុកនៅរក្សាស្រុកក្នុងខេត្តមួយ ដែលនៅទំនេរ » ។ ភរិយាឆ្លើយថា

---

១ កម្ពុជសុរិយាលេខ ១-២-៣ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៦២ រៀបរៀងដោយឧកញ៉ាបញ្ញាធិបតី យិន ជាងហ្វាងព្រះរាជនិពន្ធ ។

« ឱ ! អ្នកអើយ ! ចិត្តខ្ញុំ ចង់ឲ្យអ្នកធ្វើចៅហ្វាយស្រុកណាស់ តែសព្វថ្ងៃ យើងក្រលំបាកគោកយ៉ាកពេក នឹងរកប្រាក់ថ្វាយស្ដេចពុំបានទេ » និយាយហើយ បន់ទេវតាថា « សូមទេវតា ជួយខ្ញុំឲ្យបានប្រាក់ ៤០ កហាបណៈថ្វាយស្ដេច ខ្ញុំនឹងបានធ្វើជាចៅហ្វាយស្រុកគ្រានេះ » ។

ពេលនោះ អាចោរចិត្តជា វាដើរលួចគេ ហើយមកអង្គុយក្រោមផ្ទះមន្ត្រីនោះ វាបានឮដូច្នោះ មានចិត្តអាណិត ក៏យកប្រាក់ ៤០ កហាបណៈពីផ្ទះវា វេចនឹងកំណាត់សំពត់ជាតី មកលូកដៃតាមប្រហោងជញ្ជាំងទៅទុកឲ្យមន្ត្រីនោះ រួចត្រឡប់មកវិញ ។ លុះភ្លឺច្បាស់ មន្ត្រីនោះភ្ញាក់ឡើងក្រឡេកទៅឃើញបង្វេចសំពត់ជាតី ក៏ចាប់លើក ស្រាយមើលឃើញប្រាក់ ៤០ កហាបណៈ អរណាស់ ប្រាប់ប្រពន្ធថា « យើងបានប្រាក់ ៤០ កហាបណៈហើយ គឺទេវតាឲ្យ » ។ ប្រពន្ធ ស្ទុះមកមើលឃើញច្បាស់ ក៏មានចិត្តត្រេកអរពន់ពេក ។



លុះដល់ថ្ងៃរសៀល មន្ត្រីនោះយកប្រាក់ ៤០ កហាបណៈ ទៅថ្វាយស្តេច ដាក់ឃ្លាំង ។ ព្រះរាជា ក៏តាំងមន្ត្រីនោះ ឲ្យធ្វើជាចៅហ្វាយស្រុកនៅរក្សាក្នុងខេត្តនោះតទៅ ។

ឯអាចោរចិត្តជា កាលបានដឹងថា មន្ត្រីនោះ បានធ្វើចៅហ្វាយស្រុកហើយ ក៏ដើរស្វែងរកលួចអ្នកស្រុកក្នុងខេត្តនោះ ធ្វើដំណើរឲ្យគេចាប់ខ្លួនវាបាន, ឯពួកម្ចាស់ទ្រព្យ ក៏នាំអាចោរចិត្តជានោះទៅជូនចៅហ្វាយស្រុក ។ បង្គាប់មេគុកឲ្យដាក់ច្រវាក់ ឃុំទុកក្រោមផ្ទះលោក ។ វេលាយប់ស្ងាត់ អាចោរចិត្តជា និយាយរអ៊ូតែម្នាក់ឯងថា « ឱ ! ហេតុតែឯងមានចិត្តអាណិតគេ, កាលគេចង់ធ្វើចៅហ្វាយស្រុក ខ្លួនឯង ប្រឹងយកប្រាក់ ៤០ កហាបណៈវេចនឹងកំណាត់ផាតិ មកឲ្យគេទាំងយប់, ឥឡូវគេបានធ្វើចៅហ្វាយស្រុកហើយ គេមិនមេត្តាករុណាឯងបន្តិចសោះ គេដាក់ច្រវាក់ ឃុំឯងទុកឲ្យវេទនា » ។ អាចោរចិត្តជា និយាយតែពាក្យដដែលៗ ម្នាក់ឯងមិនឈប់ ។

ឯចៅហ្វាយស្រុក និងប្រពន្ធ បាឮចោរនិយាយដូច្នោះ ក៏ប្រឹក្សាគ្នាថា « គួរឲ្យឆ្ងល់ណាស់ ចោរវានិយាយនេះត្រូវដូចរឿងខ្លួនយើង គួរតែយើងចុះទៅសួរវាឲ្យជាក់មើល » ។ ទើបចៅហ្វាយស្រុក ចុះពីផ្ទះទៅសួរចោរនោះថា « ចុះឯងនិយាយរឿងអ្វី យើងឮតែស្តាប់បានខ្លះ មិនបានខ្លះ ចូរឯងនិយាយរឿងនោះ ឲ្យយើងស្តាប់ក្នុងវេលានេះ តាមពិតមកមើល » ។ ទើបអាចោរចិត្តជានិយាយថា « ខ្លួនខ្ញុំនេះ ជាមនុស្សប្រព្រឹត្តចោរកម្ម ដើរតែលួចទ្រព្យគេរាល់យប់ យកមកចិញ្ចឹមជីវិត, កាលដែលលោកនៅជាមន្ត្រីតូច ពុំទាន់បានធ្វើចៅ-ហ្វាយស្រុកនៅឡើយ, វេលាយប់មួយនោះ ខ្ញុំដើរលួចគេ ហើយមកអង្គុយក្រោមផ្ទះលោក ឮលោកនិងប្រពន្ធនិយាយថា « យើងនឹងរកប្រាក់ ៤០ កហាបណៈពីណាបានយកទៅថ្វាយស្តេច ដើម្បីឲ្យបានធ្វើចៅហ្វាយស្រុកក្នុងខេត្តមួយ » ។ ប្រពន្ធលោកថា « យើងក្រីក្រម្ល៉េះ នឹងបានប្រាក់ពីណា ? » ។ ខ្ញុំឮដូច្នោះមាន

ចិត្តអាណិតលោក ក៏ទៅយកប្រាក់ ៤០ កហាបណៈពីផ្ទះ រេចនឹងកំណាត់សំពត់ ជាតិ មកដាក់ជិតក្បាលដំណេក ទុកជូនលោក រួចខ្ញុំត្រឡប់ទៅវិញ, ថ្ងៃក្រោយ ឮគេនិយាយថា « លោកបានធ្វើចៅហ្វាយស្រុក ខ្ញុំក៏មកលួចគេក្នុងខែត្រនេះ គេ ចាប់ខ្លួនខ្ញុំបាន នាំមកជូនលោក ។ ក៏ធ្វើទោសខ្ញុំ មិនប្រណី » ។

ចៅហ្វាយស្រុក បានស្តាប់ ក៏ជឿជាក់ឥតសង្ស័យ ហើយថា ឱ ! អាសម្លាញ់ អើយ ឯងនិយាយនេះ ពិតប្រាកដមែន, ដែលអញបានធ្វើចៅហ្វាយស្រុក ពី ព្រោះតែឯងជួយ, វេលានេះ ឯងកុំភ័យ កុំតូចចិត្ត, អញនឹងដោះឯងឲ្យរួចចេញ ពីទោស, មួយទៀតឯងនិងអញ ត្រូវយកគ្នាជាសម្លាញ់តទៅ ។

ចៅហ្វាយស្រុកសួរថា « ឯងឈ្មោះអី ? » ។ បុរសនោះជម្រាបថា « ខ្ញុំ ឈ្មោះអាចោរចិត្តជា » ។ សួររួចហើយ លោកចៅហ្វាយស្រុកក៏ឡើងទៅលើ-ផ្ទះវិញ ។

លុះភ្លឺឡើង ចៅហ្វាយស្រុក បង្គាប់មេគុកឲ្យដោះអាចោរចិត្តជារួចពីទោស ហើយនិយាយថា « អាសម្លាញ់ឯងនៅនឹងអញចុះ អញចិញ្ចឹមឯងពីថ្ងៃនេះតទៅ ឯងកុំលួចគេទៀត » ។ អាចោរចិត្តជា ឆ្លើយថា « រឿងលួចនោះ អញ មិនឈប់ទេ ដែលអញលួចទ្រព្យគេនេះ គ្រាន់យកទៅចិញ្ចឹមមាតាមេម៉ាយ » ។ ចៅហ្វាយស្រុក ក៏ឲ្យប្រាក់ ៣០ កហាបណៈឲ្យទៅឲ្យមាតា ។ អាចោរចិត្ត ជា មិនព្រមយក ។ ចៅហ្វាយស្រុក សួរថា ផ្ទះសម្លាញ់ឯង នៅឯណា? ចូរឯងប្រាប់អញឲ្យត្រង់ » ។ អាចោរចិត្តជាប្រាប់ថា « អញនៅផ្ទះនោះ » ហើយលាចៅហ្វាយស្រុកទៅផ្ទះវិញ ។

គ្រានោះ លោកយមរាជ និងមន្ត្រីតូចម្នាក់ កើតក្តីវិវាទទាស់ទែងគ្នា ជា យូរខែហើយ, មន្ត្រីតូចនោះ គុំគិតសម្លាប់លោកយមរាជនោះឲ្យបាន ។ មន្ត្រីតូច នោះ មានស្រីបម្រើម្នាក់ជាទីទុកចិត្ត ប្រើដូចម្តេចបានទាំងអស់ ។ ស្រីបំរើនោះ ខំផ្គាប់ផ្គុនចៅហ្វាយ មិនឲ្យទាស់ចិត្ត ។ វេលាយប់ស្ងាត់ មន្ត្រីនោះ និយាយនឹង

ស្រីបម្រើថា « វេលានេះ ចូរឯងអាណិតអញ ពីព្រោះអញស្អប់លោកយមរាជណាស់ អញចង់សម្លាប់ចោល តែមិនដឹងរកអ្នកណាជួយរឿងនេះ, សព្វថ្ងៃ អញឃើញតែឯងមានប្រាជ្ញា ហើយមន្ត្រីនោះ បង្គាប់ស្រីបំរើថា « ចូរឯងចេញពីអញទៅយកប្រាក់លោកយមរាជ នៅនឹងគេចុះ រួចឯងខំផ្គាប់ផ្គុនគេ ឲ្យដូចកាលនៅ-នឹងអញ, បើឯងបម្រើខាងក្រៅ ដល់លោកយមរាជនោះគេទុកចិត្តស្និទ្ធស្នាល ត្រូវឯងចូលបំរើខាងក្នុង, លុះបានហើយ ឯងចាំមើលរាល់វេលាយប់ស្ងាត់កាលណាយម-រាជនោះដេកលក់ ចូរឯងរំលាយសំណឲ្យក្តៅពុះ រួចយកទៅចាក់ក្នុងមាត់ទៅ លោកយមរាជ នឹងស្លាប់មិនខានគ្មានអ្នកណាដឹងឡើយ បើឯងធ្វើបានដូចគំនិតនេះ អញនឹងចេញប្រាក់លោះឯងមកវិញឲ្យ រួចពីខ្ញុំគេ » ។ ស្រីបំរើនោះ ទទួលការសព្វគ្រប់ ។

វេលាយប់នោះ អាចោរចិត្តជា ដើរលួចគេ ហើយវាមកអង្គុយក្រោមផ្ទះមន្ត្រីនោះ, កាលមន្ត្រីនោះកំពុងនិយាយបង្គាប់ស្រីបម្រើ ឲ្យសម្លាប់យមរាជដូចម្តេចៗ ក៏វាស្តាប់ការណ៍បានទាំងអស់ ។

ថ្ងៃក្រោយ ស្រីបំរើនោះ លាម្ចាស់ទៅរកប្រាក់លោកយមរាជ ហើយសុំ-នៅផង លោកយមរាជ ក៏ទទួលចេញប្រាក់ លោះឲ្យទៅបម្រើរៀងមក ។ នាងនោះខំបម្រើផ្គាប់ផ្គុនលោកយមរាជ និងលោកជំទាវ មិនឲ្យទាស់ចិត្ត ។ លោកយមរាជនិងជំទាវ ក៏ទុកចិត្តស្និទ្ធស្នាល ឲ្យចេញចូលក្នុងក្រៅ បម្រើជិតដិតរៀងមក ។ វេលាមួយនោះ ពេលយប់ស្ងាត់ ស្រីបំរើនោះវាដឹងថា លោកយមរាជ និងលោកជំទាវសម្រាន្តលក់ហើយ វាដុតភ្លើងរំលាយសំណឲ្យក្តៅពុះ ហើយវាលើកសំណនោះចាក់ក្នុងមាត់លោកយមរាជ ៗ ស្លាប់ទៅ រួចត្រឡប់ទៅដេកតាមកន្លែងវិញ ។

លុះព្រឹកឡើង លោកជំទាវភ្ញាក់ បានដឹងថា ប្តីខ្លួនស្លាប់ ក៏ស្រែកទ្រហោយំ។ មនុស្សផ្អើលមកមើល ឃើញលោកយមរាជស្លាប់មែន តែមិនដឹងជាស្លាប់ដោយរោគអ្វី ព្រោះគ្មានស្លាកស្នាមបន្តិចសោះ ។ លោកជំទាវនោះ ទៅក្រាបថ្វាយបង្គំទូល

ស្តេច តាមរឿងដែលស្លាប់ ។ ព្រះរាជា ទ្រង់ចាត់ឲ្យមន្ត្រីមកមើល តែមិនដឹងជាស្លាប់ដោយរោគអ្វី ព្រោះគ្មានហេតុស្នាកស្នាម ក៏ទៅក្រាបបង្គំទូលតាមរឿង។ ព្រះរាជា ទ្រង់ឲ្យយកសពទៅបញ្ចុះទុកតាមសមគួរ ។

ក្រោយនោះ ជាវដូវបុណ្យទ្វាទសមាស នាហ្មឺនសព្វមុខមន្ត្រី ចូលគាល់ព្រះមហាក្សត្រ ។ ទ្រង់មានព្រះរាជឱង្ការថា បើអ្នកឯណា រកឈ្មោះមនុស្សដែលសម្លាប់យមរាជ បានដឹងច្បាស់ប្រាកដ យើងឲ្យធ្វើទីជាយមរាជ, រួចទ្រង់ស្តេចយាងចូលទៅខាងក្នុងវិញ ។ សេនាបតី នាហ្មឺនសព្វមុខមន្ត្រី ក៏ទៅផ្ទះរៀងខ្លួន។

គ្រានោះ ចៅហ្វាយស្រុក ដែលជាសម្លាញ់នឹងអាចោរចិត្តជា ចង់ធ្វើយមរាជណាស់ បានទៅរកអាចោរចិត្តជា ។ សួរថា « អាសម្លាញ់ឯង មករកអ្វី ? »។ ចៅហ្វាយស្រុកប្រាប់ថា « អញបក បានការសួរឯងបន្តិច ត្បិតលោកយមរាជស្លាប់ ដោយឥតមាននរណាដឹងថាជា ស្លាប់ព្រោះរោគអ្វី, ឥឡូវ ស្តេចមានព្រះរាជឱង្ការថា : បើអ្នកឯណារកឈ្មោះមនុស្ស ដែលសម្លាប់លោកយមរាជឃើញពិតប្រាកដ ទ្រង់នឹងឲ្យធ្វើទីយមរាជ, រឿងនេះ អាសម្លាញ់ឯងបានដឹងឬទេ ? ត្បិតអញចង់ធ្វើយមរាជណាស់ » ។ អាចោរចិត្តជា ឆ្លើយថា « រឿងនេះអញបានដឹងច្បាស់ ព្រោះនៅវេលារាត្រីមួយនោះ អញដើរលួចគេហើយអញ មកអង្គុយក្រោមផ្ទះមន្ត្រីតូចម្នាក់ នៅខាងជើងផ្ទះលោកយមរាជ ក្លាយពីគ្នាបន្តិច, មន្ត្រីនោះ ប្រាប់ស្រីបម្រើម្នាក់ ថា « អញស្អប់លោកយមរាជពេក ចង់សម្លាប់ចោលព្រោះជាសត្រូវនឹងអញ, ក្នុងគ្រានេះ ត្រូវឯងជួយអញជាប្រាកដ ដូច្នេះ ត្រូវឯងចេញពីផ្ទះអញ ទៅរកផ្ទះលោកយមរាជនៅ បើគេព្រមទទួលឲ្យនៅ ត្រូវឯងខំបម្រើ ឲ្យត្រូវចិត្តគេ បើគេទុកចិត្តស្និទ្ធស្នាល ប្រើចេញចូលខាងក្នុងវេលាណា លុះដល់យប់ស្ងាត់ ឯងត្រូវដុតភ្លើងរំលាយសំណឲ្យក្តៅពុះ ហើយយកទៅចាក់ក្នុងមាត់លោកយមរាជកំពុងដេកលក់ គង់ស្លាប់មិនខាន ។ រឿងនេះអញលបស្តាប់បានចាំប្រាកដ, ចូរសម្លាញ់ឯងទៅទូលស្តេចតាមរឿងនេះចុះ តែត្រូវឲ្យគាស់ខ្មោចលោក-

យមរាជនោះយកមកវះមើល បើឃើញសំណនៅក្នុងពោះខ្មោចនោះមែន អាសម្លាញ់ឯង នឹងបានធ្វើយមរាជមិនខាន» ។ ចៅហ្វាយស្រុកស្ដាប់យកការណ៍បានហើយត្រឡប់ទៅផ្ទះវិញ ។

ថ្ងៃក្រោយ ចៅហ្វាយស្រុក ទៅទូលស្ដេចតាមរឿង; ស្ដេចទ្រង់ឲ្យភ្នាក់ងារទៅចាប់មន្ត្រី និងស្រីនោះ យកមកឃុំទុកហើយទ្រង់ឲ្យគាស់ខ្មោចលោកយមរាជយកមកវះមើល ឃើញសំណនៅក្នុងពោះមែន ទើបទ្រង់ឲ្យជំនុំជំរះរឿងនោះ ឯមេស្រីនោះ ឆ្លើយថា «ខ្ញុំសម្លាប់លោកយមរាជពិតប្រាកដ» ទ្រង់ឲ្យប្រហារជីវិតទាំងពីរនាក់ចោលទៅ ហើយទ្រង់ក៏តាំងចៅហ្វាយស្រុកនោះ ឲ្យធ្វើទីយមរាជ ។

ឯចៅហ្វាយស្រុក កាលបើបានធ្វើទីយមរាជហើយ ឲ្យបម្រើទៅហៅអាចោរ-ចិត្តជា ជាសម្លាញ់, លុះវាមកដល់ ប្រាប់ថា អាសម្លាញ់អើយ ! ឯងបានគុណនឹងអញច្រើនណាស់ ឥឡូវនេះ អញបានធ្វើយមរាជហើយ; ដែលអញបានធ្វើយមរាជនេះ គឺដោយសារឯងជួយអញពីថ្ងៃនេះទៅ ឯងកុំលួចទៀត អញចិញ្ចឹមបាតាឯង និងសម្លាញ់ឯង លុះអស់ជីវិត » ។

អាចោរចិត្តជាឆ្លើយថា " អញសុំលួចតែម្ដងទៀត " ។ ថាតែប៉ុណ្ណោះវាក៏-ត្រឡប់ទៅផ្ទះវិញ, លុះយប់ អាចោរចិត្តជា ទៅលួចដង្វៅម្នាក់ បានប្រាក់និងសំពត់អាវជាច្រើន យកមកជូនបាតា ។ លុះព្រឹកឡើង អាចោរចិត្តជា មកប្រាប់លោកយមរាជថា " អាសម្លាញ់ យប់មិញ អញលួចគេ បានប្រាក់និងសំ-ពត់អាវច្រើនណាស់; ពីថ្ងៃនេះទៅ អញលះចោលរឿងរកស៊ីលួចគេហើយ អាសម្លាញ់ឯងជឿចុះ " ។ លោកយមរាជតបថា " បើឯងឈប់រកស៊ីលួចគេនោះ អញអរណាស់ បើខ្វះខាតអ្វីបកករកអញ ៗ ឲ្យឯងកុំទើសទាល់ អញចិញ្ចឹម

ឯងលុះអស់ជីវិត ” ។

អាចោរចិត្តជា ក៏លាលោកយមរាជទៅផ្ទះវិញ ទៅនោរក្សាមាតាជាសុខសប្បាយ ។

លោកយមរាជ និងអាចោរចិត្តជា ស្រឡាញ់រាប់រានគ្នា ចិញ្ចឹមគ្នាដរាបអស់ជីវិត ដូចបានសន្យាគ្នាមក ។

## មនុស្សចិត្តជា តែងមានគ្នាជានិច្ច

# ១៦ – រឿង ឪពុកក្មេករើសកូនប្រសា(១)

កាលពីព្រេងនាយ មានតាចាស់ម្នាក់ និងដូនចាស់ម្នាក់ នៅស្រុកមួយ ។ តាចាស់យាយចាស់នោះ មានកូនក្រមុំម្នាក់ រូបល្អណាស់ អ្នកណាទៅដណ្ដឹង ក៏គាត់មិនព្រមឲ្យ គាត់ថា " អ្នកណាតមមិនដេរម្ដាយគេបាន ទើបគាត់ឲ្យកូនជាប្រពន្ធអ្នកនោះ " ។

ដូនជាថ្ងៃមួយនោះ មានកម្លោះម្នាក់ រូបរាងស្អាតបាត ចូលទៅដណ្ដឹងកូនគាត់ ៗ ថា " អើ អញឲ្យឯង ៗ កុំព្រួយចិត្ត ប៉ុន្តែ ឯងត្រូវតមដេរម្ដាយគេ ហើយទទួលបម្រើអញ តាមពាក្យអញ ទើបបានអញឲ្យឯង បើតមមិនបាន អញផ្ដាច់មិនឲ្យឯងទេ អញប្រាប់ឯងឲ្យដឹងជាមុន, លុះក្រោយទៅ ឯងកុំថា អញកាចណាំ " ។

កម្លោះនោះថា " ខ្ញុំបាទតមដេរម្ដាយគេបាន ហើយធ្វើការអ្វី ៗ ក៏បានទាំងអស់ ខ្ញុំបាទទទួលសព្វគ្រប់ប្រការ តាមប្រសាសន៍លោកឪពុក " ។ តានោះថា « អើ បើឯងតមដេរម្ដាយគេបានមែន ឯងទៅសិនចុះ ព្រឹកត្រូវឯងមកវិញពីព្រលឹម » ។ កម្លោះនោះ ក៏លាវិលទៅផ្ទះវិញ ។

ព្រឹកឡើង កម្លោះនោះមកវិញ ចូលទៅបម្រើឪពុកម្ដាយក្មេក ៗ នោះ ប្រើកូនក្រមុំគាត់ឲ្យរៀបបាយទឹក ឲ្យអ្នកកម្លោះនោះស៊ី ៗ រួចហើយតានោះ ក៏ប្រាប់ទៅកូនប្រសាថា « នែកូន ! ចូរកូនទៅចាប់ក្របីទៅភ្ជួរស្រែ, កូនឯងភ្ជួររាបដល់ថ្ម

១ ច្បាប់សរសេរដៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ G 20 B របស់លោក E. Aymnier ទំព័រ ៤១ ខាងភាសាខ្មែរ និង ក្នុងកម្ពុជសុរិយាលេខ ១-២-៣ ឆ្នាំ ១៩៣៩ ទំព័រ ១២៧ គ្មានឈ្មោះអ្នករៀបរៀងទេ ។

នៅឯស្រែនោះ យំតេរ ។ ហើយសឹមឯងដោះក្របី ” ។ អ្នកកម្លោះ នៅចាប់ក្របីមកទឹម ហើយទៅភ្ជួរស្រែ តាំងពីព្រលឹមដល់ថ្ងៃត្រង់ ក៏ថ្មពុំយំ, ក្របីដើរពុំរួច ក៏ថ្មចេះតែឈឹង ពុំយំសោះ ។ អ្នកកម្លោះឃ្លានបាយណាស់ ទ្រាំពុំបាន ដេរម្ដាយថា “ ម្ដាយអាថ្មនេះ កាលណានឹងយំឡើង ” ។ ។ កម្លោះនោះ ដេរតែប៉ុណ្ណោះ តានោះក៏ស្ទុះចេញពីក្រោយថ្មមកថា “ ណ្ហើយចុះ ! ឯងដោះក្របីលែង ហើយទៅផ្ទះឯងចុះ អញផ្ដាច់កូនហើយ ត្បិតឯងតមដេរម្ដាយមិនបាន ” ។ កម្លោះនោះ ក៏ដោះក្របីលែង ហើយទៅផ្ទះវិញ ។

ថ្ងៃក្រោយមក មានកម្លោះម្នាក់ ចូលទៅដណ្ដឹងកូនតានោះទៀត គាត់ក៏បង្គាប់ដូចកម្លោះមុន, តែអ្នកកម្លោះក្រោយគេបានប្រាជ្ញា គេទៅភ្ជួរស្រែ វេចបាយទៅស៊ីផង លុះភ្ជួរដល់ថ្ងៃខ្ពស់ ឃ្លានបាយ ក៏បញ្ឈប់ក្របីស៊ីបាយ, រួចហើយ ក៏ភ្ជួរទៀតទល់ថ្ងៃជ្រេពីត្រង់ ក៏ថ្មពុំយំ ក្របីក៏អស់ជើងដើរពុំរួច ។ កាលបើអ្នកកម្លោះបរក្របីទៅដល់ជិតថ្មនោះអ្នកធ្វើជាស្ដីថា “ ឱ ! លោកថ្មអើយ យំឡើង, ក្របីដើរពុំរួចទេ អាណាពិតក្របីផងទៅ, ខ្លួនខ្ញុំឥតបើរីទេ ខ្ញុំមានបាយស៊ីហើយ ភ្ជួរដល់យប់ក៏បានដែរ, បើមិនអាណិតខ្ញុំ អាណិតតែក្របីទៅចុះ ត្បិតវាជាសត្វ ” ។ កម្លោះនោះ អង្វរដូចម្ដេច ក៏ថ្មពុំយំ, អ្នកកម្លោះនោះ ក៏ពុំដេរ ត្បិតវាដឹងថាតានោះទៅពួនក្រោយថ្ម លុះនិយាយយូរ ។ ទៅ តានោះមើលមកឃើញក្របីដើរពុំរួចមែន គាត់នឹកអាណិតក្របីគាត់ ក៏យំក្រោយថ្មនោះ ឮតែតេរ ។, អ្នកកម្លោះនោះ ក៏ដោះក្របីឲ្យស៊ីស្មៅ ហើយមកផ្ទះឪពុកក្មេកវិញ ។ តានោះក៏ឲ្យកូនគាត់លើកបាយបក ឲ្យអ្នកកម្លោះនោះស៊ី ។ លុះល្ងាច តានោះប្រាប់ថា “កូនអើយ ! ទៅផ្ទះឯងចុះ, ព្រឹក សឹមឯងមកវិញ ” ។ កម្លោះនោះ ក៏លាទៅផ្ទះ លុះយប់ មកលបចាំស្ដាប់យកការណ៍ នៅក្រោមដំណេកតានោះ ព្រោះគាត់និយាយគិតគូរនឹងប្រពន្ធគាត់ ទាល់តែដេកលក់ ។

វេលាយប់ តាចាស់ចូលដេក ក៏និយាយនឹងយាយថា “ ដូន ! អានេះ វាតមដេរម្ដាយបាន ប៉ុន្តែរូបរាងវាអាក្រក់ មិនសមនឹងកូនយើងដូច្នេះ យើងរកឧបាយយ៉ាងណា ឲ្យវាខឹងដេរម្ដាយ ហើយយើងនឹងផ្ដាច់វាទៅ ? ” ។ ដូនឆ្លើយថា “ ងាយទេ, បើដូច្នេះចូរតាឯងចូលក្នុងការុងមួយ ការុងមួយទៀតដាក់អង្ករ, ព្រឹកឡើងវាមក ខ្ញុំប្រាប់វាថា តាទៅកាប់ឧសលើភ្នំមុន ហើយខ្ញុំឲ្យវាវែកតាឯងនិងអង្កទៅលើភ្នំ, បើវាធ្ងន់ វាខឹងវាជេរនោះ តាឯងនៅក្នុងការុងស្រាប់នឹងឮ ហើយមកវិញផ្ដាច់វាបានដោយងាយ ” ។ តាយាយគិតគ្នាដូច្នោះហើយ ក៏ដេកទៅ ។ ឯអ្នកកម្លោះ ល បស្ដាប់ក្រោមផ្ទះ ឮដឹងការណ៍ហើយ ក៏វិលទៅដេកឯផ្ទះ ។ ព្រឹកឡើងអ្នកកម្លោះនោះ ទៅបម្រើម្ដាយក្មេកឪពុកក្មេក ក៏ស្រាប់តែឃើញយាយចាស់បង្គាញអម្រែកហើយប្រាប់ថា “ កូនអើយ ! ឪឯងទៅកាប់ឧសលើភ្នំហើយ គាត់ផ្ដាំថាឲ្យកូនឯងវែកអង្ករនេះ ឡើងទៅតាមឲ្យឆាប់ ត្បិតគាត់ទៅតាំងតែពីព្រឹក មិនទាន់ទាំងហូបបាយផង មានតែកូនឯងវែកទៅឲ្យឆាប់ នឹងអាលដណ្ដាំបាយឲ្យឪឯងហូប”។ កម្លោះនោះ ទទួលអម្រែកហើយ ក៏វែកទៅតាមជើងភ្នំ, ដល់វែកឡើងបន្តិចទៅធ្ងន់ណាស់ ក៏វែកចុះមកវិញ ហើយស្ដីថា ឱ!ឪអើយ, ខ្ញុំឃ្លានបាយណាស់ ខ្ញុំវែកឡើងទៅឲ្យឆាប់មិនបានទេ បើវាធ្ងន់ម្ល៉េះ នរណានឹងវែកឡើងទៅរួច បើឪមិនអាណិត គាត់ជេរបន្ទោសដូចម្ដេច ក៏ទទួល ” ។ និយាយហើយវែកចុះមកវាលវិញ, លុះវែកទៅដល់កន្លែងមួយ ឃើញស្បូវស្ងួតល្អ ក៏វែកទៅដាក់ឈប់កណ្ដាលស្បូវនោះ ហើយដើរទៅបាត់មួយស្របក់ ទើបដើរត្រឡប់មកវិញ យកភ្លើងដុតអម្រែក, លុះភ្លើងឆេះស្បូវជុំវិញ ហើយក្ដៅដល់តាចាស់ ដែលនៅក្នុងអម្រែកនោះ គាត់ក៏បម្រះញ័ររង្គើទាំងការុង ភ័យក្រែងភ្លើងឆេះស្លាប់ ប៉ុន្តែចេញមិនរួច ។ អ្នកកម្លោះធ្វើជារត់មកពីណាស្រែកថា «ដើ! នរណាដុតភ្លើង ឆេះអម្រែកអញអស់ ធ្វើដូចម្ដេចអញនឹងចូលទៅបាន បើភ្លើងឆេះជុំវិញដូច្នេះ ចូលមិនចុះទេ” ថាហើយឈរ

ស្រែកទៅក្រៅ, លុះភ្លើងឆេះដល់ការុង ដឹងថា តាចាស់ក្ដៅណាស់ហើយ ទើបស្ទុះចូលទៅរូសអម្រែកចេញពីភ្លើង រួចហើយ ភ្លើងក៏ឆេះដាច់ខ្សែការុង លោកតាចាស់បម្រះញ័រ ។ ទើបអ្នកកម្លោះ ស្រាយការុងចេញ ឃើញតាឪពុកក្មេករលាកភ្លើង ឆេះទាំងសក់ក្បាល ក៏ជំរាបថា " ដើ ! លោកឪម្ដេចក៏មិនប្រាប់កូន កុំអីភ្លើងឆេះស្លាប់ ចោលម៉ែឲ្យនៅមេម៉ាយ " ។ តាចាស់ ខឹងណាស់ តែពុំដឹងជាធ្វើដូចម្ដេច ឡើងដើរតយង៉យមកផ្ទះវិញ ទ្រមខ្លួនមួយថ្ងៃ ណាមួយ ដោយវារូសចេញពីភ្លើង ណាមួយ ដោយរលាកភ្លើង ។ មកដល់ផ្ទះវិញ គ្មានស្ដីមួយម៉ាត់, ដល់ផ្ទះហើយ ប្រាប់កូនប្រសាថា " ទៅផ្ទះចុះ, ព្រឹក សឹមមក " ។ ឯកូនប្រសាលាទៅផ្ទះ, ដល់យប់ ក៏មកពួនក្រោមផ្ទះលបចាំស្ដាប់ទៀត ។

លុះយប់ តាចាស់ដូនចាស់ ចូលដេក ក៏និយាយគិតគ្នាទៀត ។ តាថា " គិតដូចម្ដេច នឹងផ្ដាច់វាបាន ? អានេះ មានប្រាជ្ញាណាស់ តែបើឲ្យកូនយើងទៅវា វាបិទសមនឹងកូនយើង, ពីថ្ងៃមិញ វាដឹងថាឯងនៅក្នុងការុង វារែកទៅដល់កណ្ដាលផ្លូវ វាថា ធ្ងន់ណាស់ តែវាមិនដេរម្ដាយទេ វារកទីណាមានស្បូវស្ងួត វារែកអម្រែកទៅដាក់កណ្ដាលស្បូវ ហើយវាដើរទៅរកភ្លើងមកដុតជុំវិញ, លុះដល់ភ្លើងឆេះ វាធ្វើជាស្រែកថា " នរណា ដុតភ្លើងនេះ ឆេះអម្រែកវាអស់ " ហើយវាឈរតែស្រែក មិនចូលយក ទុកទាល់តែភ្លើងឆេះ ក្ដៅដល់ រលាកឯងទៅហើយទើបបានវារត់ចូលទៅរូសចេញមក, អញភ័យណាស់ ប៉ុន្តែចេញមិនរួចព្រោះវាចងបាត់ការុងជាប់ អញរលាកអស់ទាំងខ្លួន, ឥឡូវនេះយើងគិតដូចម្ដេច នឹងផ្ដាច់វាបាន ? " ។ យាយថា " ឥឡូវនេះ យើងគិតថា តាឯងធ្វើម្ចាស់ ឲ្យវាធ្វើផ្កែ នាំទៅបណ្ដើររកអណ្ដើក ឲ្យវារារដូចផ្កែ, បើវារកអណ្ដើកមិនបាន ឬវាបោលមិនទាន់ទេ នោះយើងផ្ដាច់វាបាន " ។ តាចាស់ថា " អើ ! ដូនគិត

ដូច្នេះត្រូវ, ព្រឹកអញធ្វើដូចជាឯងថា ” ។ តាយាយគិតគ្នាហើយ ដេកទៅ ។ ឯអ្នកកម្លោះនោះ ស្តាប់ដឹងការណ៍អស់ហើយ វិលទៅដេកឯផ្ទះវិញ, ដល់មាន់រងាវ ទើបពុនអណ្តើកយកទៅចងទុក ក្នុងគម្ពោតស្មៅវាល ឯនេះ ឯនោះ ពាសពេញ តែវាល ដែលតាចាស់គាត់គិតទៅរកអណ្តើកនោះ ហើយវិលមកផ្ទះ ដេកធ្វើព្រងើយទៀត ។

លុះព្រឹកព្រហាមឡើង ចៅនោះ ទៅដល់ផ្ទះឪពុកក្មេកម្តាយក្មេក ។ ក៏ឲ្យកូនក្រមុំគាត់រៀបបាយ លើកយកមកឲ្យចៅស៊ី ។ រួចហើយ ក៏ប្រាប់ថា “ កូន ! ឥឡូវនេះ យើងទៅបណ្តើរអណ្តើក ប៉ុន្តែយើងគ្មានផ្លែ កូនឯងធ្វើក្លែ ឪធ្វើម្ចាស់ យើងទៅរក ក្រែងបានមួយពីរ យកមកស៊ី ” ។ ចៅនោះ ឆ្លើយបាទ ! ហើយតាចាស់ ពុនបាយសំណុំ ទឹកបំពង់ ដើរចេញពីផ្ទះទៅ ។ ចៅនោះក៏បោល ជើង ៤ តាមក្រោយ ទៅដល់វាលកន្លែងវាចងអណ្តើកនោះ វាក៏បោលទៅមុខ ចូលគម្ពោតស្មៅមួយ ធ្វើជាកោះង៉ុង ៗ ។ តាចាស់ រត់ទៅដល់ វាខាំបាន អណ្តើកមួយ ហើយទៅទៀត ខាំបានអណ្តើកប្រាំមួយប្រាំពីរ, ដល់ថ្ងៃត្រង់ តាចាស់ឃ្លានពេកណាស់ ក៏អង្គុយគិតនឹងស្រាយបាយស៊ី ។ ផ្លែមើលទៅខាង ឃើញក្របីចូលហ្វូង ក៏បោលទៅដេញខាំក្របី ៗ បោលចូលស៊ីស្រូវស្រែអ្នកស្រុក ។ តាចាស់ឃើញហើយ រត់ទៅដេញក្របីចេញពីស្រែ, ផ្លែបោលមកស៊ីបាយអស់ ហើយបោលទៅបាត់ ។ ឯឪពុកក្មេកជាម្ចាស់ផ្លែ វិលមកវិញ រកបាយស៊ីគ្មាន ព្រោះផ្លែស៊ីអស់ខឹងណាស់ ដេញវាយវាពុំទាន់ ណាអស់កម្លាំងឃ្លានបាយ ណាផ្លូវឆ្ងាយ ក៏ខំដើរមកផ្ទះវិញទាំងអត់បាយ ដើរពុំចង់រួច បន្ទោសផ្លែមិនបាន ត្បិតវាចំណាំអីចឹង ។ ដល់ផ្ទះស៊ីបាយរួចហើយ ប្រាប់កូនប្រសាថា “ ទៅផ្ទះចុះ ព្រឹកសឹមមកវិញ ” ដល់យប់ កូនប្រសា មកស្តាប់តាយាយគិតគ្នាទៀត ។

លុះដល់យប់ តាយាយចូលដេក, តាប្រាប់យាយ ពីរឿងដែលកូនប្រសានោះ

ធ្វើសព្វគ្រប់ ហើយតាឲ្យយាយជួយគិតទៀត ។ ដូនចាស់ប្រាប់ថា " ពីមុនវាធ្វើផ្តែ តាឯងធ្វើម្ចាស់ បានជាវាធ្វើបាបតាឯងបាន ដូច្នោះព្រឹកនេះ តាឯងឲ្យវាធ្វើម្ចាស់ម្តង ឯតាឯងធ្វើផ្តែវិញ " ។ តាយាយគិតគ្នា ហើយដេកទៅ ។ ចៅនោះ លបស្តាប់បានកាណ៍ហើយ ក៏ទៅដេកឯផ្ទះវាហ៎ី ។

ព្រឹកឡើង ចៅនោះ ទៅបម្រើឪពុកក្មេកម្តាយក្មេកទៀត ។ តាយាយ ឲ្យកូនក្រមុំលើកបាយមកឲ្យវាស៊ី ។ រួចហើយ តាក៏ប្រាប់ថា " កូនអើយ ! ពីម្សិលមិញ ឯងធ្វើផ្តែ, ថ្ងៃនេះ ឯងធ្វើម្ចាស់អញម្តង អញធ្វើផ្តែវិញ " ។ ចៅនោះ ឆ្លើយបាទ ! ហើយពុនបាយនឹងទឹកទៅ ឯតាវារធ្វើជាផ្តែ បោលតាមក្រោយ ។ លុះហួសពីផ្ទះបន្តិច វាខំដើរយ៉ាងលឿន កុំឲ្យឪពុកក្មេកវារបោលទាន់ ។

តាបោលពុំទាន់ ត្បិតខ្លួនចាស់ ដើរគ្រុក ៗ តាមក្រោយវា, ឯវាក៏បែរមកថា " ផ្តែអីស៊ីតែបាយបង្អស់ ទៅមុខមិនទៅ ដើរតែក្រោយម្ចាស់ រកអណ្តើកម្តេចបាន ? " ថាហើយ វាយផ្តែឲ្យបោលទៅមុខ ។ តាបោលក្នុងស្មៅមិនរួចចេះតែដើរតាមក្រោយ រកអណ្តើកក៏មិនបាន, កូនប្រសាវាយ ស្ទើរស្លាប់ ហត់ស្ទើរដាច់ខ្យល់ តែពុំហ៊ានស្តី ព្រោះខ្មាស់កូនប្រសា ។

លុះទៅឆ្ងាយ ដល់ថ្ងៃត្រង់ វាស្រាយបាយស៊ី ហើយវាថា " ផ្តែអីរកអណ្តើកមិន បាន ដើរតែក្រោយមនុស្ស ស៊ីតែបាយបង្អស់ " ហើយវាបង្អត់មិនឲ្យបាយស៊ី វាឲ្យតែឆ្អឹងឆ្អែង, ផ្តែចាស់អង្គៀមក៏មិនបែក ត្បិតគ្មានធ្មេញ ឃ្លានណាស់ អង្គុយមើលតែមុខវា ទាល់តែវាស៊ីហើយ វាវាយមួយព្រនង់ទៀត វាថា " ណ្ហើយ ! ទៅផ្ទះចុះ បើមិនដេះទេ ផ្តែអីឆ្អែងយ៉ាងហ្នឹង " ហើយវាឡើងដើរវិលទៅផ្ទះវិញ ។

តាចាស់ ហត់ណាស់ វារមិនរួច ឡើងដើរទៅតាមក្រោយកូនប្រសា ធ្វើ-

មុខស្រមេះ ។ លុះទៅដល់ ចៅកម្សោះ ប្រាប់ម្ដាយក្មេកថា “ ម៉ែ ! រកអណ្ដើក មិនបានទេ ព្រោះក្អែមិនស្វាក់ ” ។

តាចាស់ ខឹងណាស់ ប្រាប់កូនប្រសាថា “ ឯងទៅផ្ទះចុះ, ព្រឹកសឹមមកវិញ ” ។ ចៅនោះ ក៏លាទៅ, ដល់យប់ មកពួនលបស្ដាប់ក្រោមផ្ទះទៀត ។

លុះដល់យប់ តាយាយចូលដេក, តានិយាយប្រាប់យាយ ពីរឿងកូនប្រសាធ្វើបាប ហើយបង្អត់ទាំងបាយផង ។ ជូនថា “ ណ្ហើយ ! ឲ្យកូនទៅវាទៅ ផ្ដាច់វាមិនបានទេ, អានេះ មានប្រាជ្ញាណាស់ ឯងគិតអី ក៏វាដឹងមុនទាំងអស់, វាធ្វើបាបស្ទើរតែស្លាប់ ម្ដេចក៏មិនរាង ” ។ តាចាស់ ឆ្លើយថា “ នឹងឲ្យវាទៅមើលទៅរូបរាងវា មិនសមនឹងកូនយើងសោះ, ប៉ុន្តែ យើងធ្វើកលឲ្យវាខឹង ឲ្យវាដេរម្ដាយ វាមិនដេរ ដូច្នេះជូនជួយគិតអញម្ដងទៀត បើវាធ្វើតាមមិនបាន សឹមផ្ដាច់វា ” ។ ជូនចាស់ថា “ អើ ! ឥឡូវនេះ មានតែដល់ពេលមាន់រងាវ តាឯងលុបមុខ ស៊ុស្លា ហុបបាយ ចូលទៅក្នុងការុងមួយ ការុងមួយទៀត ច្រកអង្ករ បើព្រឹកឡើង វាមក ខ្ញុំនឹងប្រាប់វាថា តាឯងទៅផ្សារទិញអីវ៉ាន់, ហើយខ្ញុំប្រាប់ឲ្យវារែកទៅតាមឲ្យទាន់ នៅវេលាស៊ីបាយព្រឹក ត្បិតផ្លូវផ្សារ ក៏ឆ្ងាយដែរ, បើវារែកទៅមិនទាន់ទេនោះ លុះមកវិញនឹងផ្ដាច់កូនពីវាបានងាយ មួយទៀត តែទៅដល់ពាក់កណ្ដាលផ្លូវ វាមុខជាធ្ងន់វាប្រហែលជាវាគិតឃើញថាស្លាក់ហើយ វាដេរមិនខាន ” ។ តាចាស់ និងយាយគិតគ្នាហើយ ក៏ដេកទៅ ។ ឯកូនប្រសាលបស្ដាប់នៅ ក្រោមផ្ទះដឹងការណ៍ហើយ ក៏ទៅដេកផ្ទះ ។

លុះព្រឹកឡើង ចៅនោះ រៀបខ្លួន ដើរចេញទៅបម្រើឪពុកក្មេកទៀត, ដល់ហើយ ម្ដាយក្មេកឲ្យកូនក្រមុំលើកបាយ យកមកឲ្យចៅនោះស៊ីទៀត, ស៊ីហើយ ក៏ប្រគល់អម្រែកឲ្យកូនប្រសា រែកទៅតាមឪពុកក្មេកឯផ្សារ ដូចគិតគ្នាពីល្ងាចនោះ ។

ចៅនោះ វែកដើរទៅហើយ គិតថា " ម្ដងនេះ អញធ្វើឲ្យឪពុកក្មេកអញនេះ ឲ្យកូនមកអញ កុំឲ្យគាត់រកកលធ្វើបញ្ឆោតអញក្រោយទៀត " ហើយគិតតែវែកដើរទៅ ដល់កណ្ដាលផ្លូវ ដាក់អម្រែកចុះ ហើយថា ការុងនេះចងមាត់មិនជាប់ " វាយកខ្សែចងថែមទៀត, លុះវែកទៅដល់កន្លែងមានព្រែក មានស្ពាន ក៏ដាក់អម្រែកលើស្ពាន ឲ្យប្របេះត្រង់ចុងក្ដារ នៅតែបន្ដិចនឹងធ្លាក់ពីស្ពាន ហើយថា " អញអើយ ថ្ងៃណាស់ហើយ ម៉្លេះសមឪអញដេរមិនខាន អម្រែកធ្ងន់ វែកម្ដេចឲ្យទាន់ ! ណ្ហើយ ឪដេរក៏ដេរចុះ អញដាក់នៅនេះ ទៅវាលសិន រួចសឹមទៅទៀត " និយាយបណ្ដើរដើរបណ្ដើរ ។ មួយស្របក់ ក៏កាន់ឈើមួយធំ ដើរមកពីនាយ បុកក្ដារស្ពានឮគ្រាំ ។ ធ្វើហាក់ដូចជាដំរីឆ្លងស្ពាន ហើយស្រែកថា " នរណា ដាក់អម្រែកនៅលើស្ពាន ដំរីអញវាជាន់ខ្ទេចអស់ហើយ យកចេញឲ្យឆាប់ ស្រែកហើយបុកក្ដារគ្រាំង ។ ដើរចូលមក ។



ឯតាចាស់ នៅក្នុងការុង គិតស្មានថាជាដំរីមែន ភ័យក្រែងជាន់ស្លាប់ ក៏ខំបម្រះជៀសផ្លូវដំរី ហួសពីក្តារ ធ្លាក់ទៅក្នុងទឹក ៗ ចូលការុងគាត់ឈ្លក់ទឹកត្រដរញ៉ររទាំងការុង ស្ទើតែនឹងស្លាប់ ។ ឯកូនប្រសា ឃើញដូច្នោះ ក៏ទុកឲ្យផឹកទឹកបន្តិច ឲ្យរស់ខ្លួចទៀត ហើយធ្វើជាដើរមកពីវាល ស្រែកថា " ទរណាហ៊ានបរដំរីឆាយអម្រែកអញ ឲ្យធ្លាក់ក្នុងទឹក ទទឹកអង្ករអញអស់ ! ឱអញអើយ ! ឪដេរថែមទៀតហើយ ថ្ងៃក៏កាន់តែខ្ពស់ហើយ អង្ករទទឹកថែមទៀត " ។ អ្នកកម្លោះ ឃើញឪពុកក្មេកបម្រះញ៉រក្នុងការុង ក៏ថា " ឱ ! មានត្រីមកប្របេះផង, ណ្ហើយ ! អញចុះទៅស្រង់មកមើល " ថាហើយ ក៏លោតទៅស្រង់ឡើងបក មើល ហើយថា " អើយ ! បើវាទទឹក នឹងស្រាយហាលថ្ងៃ ហើយវែកយកទៅឲ្យម៉ែធ្វើនំបញ្ចុកទុកឲ្យឪ " ។ ថាហើយ ស្រាយមើល ឃើញតានៅក្នុងការុង ក៏ថា ឪអើយ ! ម្តេចមិនស្រែកប្រាប់ខ្ញុំ កុំអីស្លាប់ទៅហើយ គេបរដំរីមកពីណាមិនដឹង គេឲ្យដំរីឆាយធ្លាក់ទៅក្នុងទឹក " ។ តាឮហើយ ឡើងឈរ ដើរវិលមកផ្ទះវិញមិនមានស្តីមួយម៉ាត់ ដល់ទៅផ្ទះ រវល់ចំណោះ ពុំហ៊ានគិតទៀត ក៏រៀបការកូនក្រមុំឲ្យទៅអ្នកកម្លោះនោះទៅ ។

## និយាយយប់ ឆ្មប់ព្រៃ និយាយថ្ងៃ ព្រៃមានត្រចៀក

# ១៨- រឿង អាសុខស្ងួត អាសុខកាច(១)

កាលពីព្រេងនាយ មានក្មេងប្រុស ២ នាក់ នៅភូមិជាមួយគ្នា មួយឈ្មោះអាសុខស្ងួត មួយឈ្មោះអាសុខកាច ។ ឯអាសុខកាច ចិត្តអាក្រក់ បើលេងល្បែងអ្វី ៗ នឹងក្មេងផងគ្នា រកតែរៀងឈ្មោះ ជេរ វាយគេមិនដែលខាន ។ ម្ដាយឪពុកអាសុខកាចនោះ ជាអ្នកគ្រាន់បើ មានស៊ី មានចាយ កាន់ជើងអាសុខកាចណាស់ បណ្ដាជនក្នុងភូមិនោះ ខឹង ស្អប់អាសុខកាចពន់ពេក ។ ឯអាសុខស្ងួត កំព្រាឥតមានមាតាបិតា មានតែជីដូន ។ ក៏ចាស់ជរា ក្រលំបាកពេកក្រៃ ។ អាសុខស្ងួតនោះ បើលេងល្បែងអ្វី ៗ នឹងក្មេងផងគ្នា ក្នុងភូមិនោះពុំដែលឈ្លោះប្រកែកដល់ម្ដងឡើយ ។ បណ្ដាជនក្នុងភូមិនោះ អាណិតស្រឡាញ់ ឲ្យចំណីស៊ី ខុសអ្នកនេះ អ្នកនោះឲ្យ មិនដែលសល់ខាន, ម្ល៉ោះហើយ អាសុខកាចនោះ ច្រណែន ទាំងម្ដាយម៉ែក្ដៅចិត្ត រឹតតែកាចឡើង ជេរ វាយកូនគេ ឥតកោតញញើត, ចាស់នឹងចាស់ឈ្លោះគ្នា ព្រោះតែកាន់ជើងកូនរៀងខ្លួន ។ លុះអាសុខស្ងួត នឹងអាសុខកាច ចំរើនអាយុធំឡើង. អាសុខកាចបបួលអាសុខស្ងួត ថា «វ៉ឺ យើងចង់នាំគ្នាទៅកាប់ឫស្សី លួសរនាប ត្បិតផ្ទះអាសុខស្ងួតឯង បាក់ពុកអស់ហើយ»។

---

១ កម្ពុជសុរិយាលេខ ១-២-៣ ឆ្នាំ១៩៣៣-៤ ទំព័រ ១៧៤ រៀបរៀងដោយព្រះអគ្គរលេខាណុប នៅក្រុមព្រះរាជនិពន្ធ និងឯកសារទំនៀមទម្លាប់ លេខ ២៧-០៣៩ រៀបរៀងដោយភិក្ខុ គង់_ស៊ីគួន សិក្សាសាលាបាលីជាន់ខ្ពស់ថ្នាក់ទី ២ ។

អាសុខស្លូត ថា « អញគ្មានប្រដាប់កាំបិត ឲ្យជាមុតមាំទេ ទាំងអង្ករ ត្រីសាច់ ថ្មដែក ក៏គ្មានផង សព្វថ្ងៃ រកបានព្រឹក ខ្វះល្ងាច» ។ អាសុខកាច ថា«កុំ បាច់យកម្ហូបចំណី ថ្មដែក កាំបិត គ្រប់ប្រដាប់ទៅឡើយ ធានាលើអញទាំងអស់ ឯងមានតែខ្លួនចុះ » ថាហើយ ក៏បណ្ដើរគ្នាទៅដល់ផ្ទះអាសុខស្លូត ហើយអាសុខ ស្លូត ក៏និយាយប្រាប់ជីដូន ថា « បងសុខ គេបបួលខ្ញុំទៅកាប់ឫស្សីលួសរនាប ប្រដាប់ប្រដា អាហារភោជន៍ នៅលើគេទាំងអស់ ខ្ញុំមានតែខ្លួនទេ» ។ ជីដូន យាត់ ថា « ចៅកុំទៅ ! ព្រៃឫស្សីនោះ ស្ងាត់ណាស់ » ។ អាសុខ ថា « មិនអីទេ យាយ ! ផ្ទះយាយ ពុកបាក់អស់ហើយ បានរនាបមក គ្រាន់នឹង ជួសជុល កុំឲ្យផុងយាយ ! » ។ ឯយាយផ្ដាំថា « ចៅទៅ ក៏ទៅចុះ តែ ចៅមើលថែទាំប្អូនផង » ។ អាសុខស្លូតអាសុខកាច រៀបចាយសំណុំគ្រប់ប្រដាប់ សម្រាប់កាប់ឫស្សី លួសរនាប ចេញទាំងពីរនាក់ទៅ ដល់ព្រៃឫស្សីកាប់បាន ហើយ លួសរនាប ។ អាសុខកាច បានរនាបតិច អាសុខស្លូត បានរនាប ច្រើន ហើយឈប់សម្រាក ស៊ីបាយទាំងពីនាក់ អង្គុយទល់មុខគ្នា, អាសុខកាច គិត ថា « ជីវិតអាឯង មុខជាស្លាប់នឹងដៃអញឥឡូវនេះ » គិតហើយ ក៏ចាប់យកកាំ បិតបន្ទោះ ចាក់ចំភ្នែកអាសុខស្លូតដែលកំពុងស៊ីបាយ ។ អាសុខស្លូតស្រែកយំ ថា « ហេតុដូចម្ដេច ក៏មកចាក់ខ្ញុំ ? » ។ អាសុខកាច ឆ្លើយថា «អាឯងរក របររបស់ឯង ហើយមកស៊ីបាយអញ ទាំងរនាប ក៏បានច្រើនជាងអញទៀត » ។ អាសុខស្លូតឆ្លើយថា «កាលបងឯងបបួលខ្ញុំមកកាប់ឫស្សី លួសរនាប ខ្ញុំប្រកែក ថា ខ្ញុំគ្មានអ្វីទេ, បងឯងធានា ថា បាយម្ហូបគ្រប់ប្រដាប់ នៅលើបងឯងទាំង អស់ បានជាខ្ញុំមក, ឥឡូវ បងឯង ចង់យករនាបទាំងអស់ ក៏យកចុះ កុំតែសម្លាប់ ខ្ញុំ » ។ អាសុខកាច ឆ្លើយថា «អាឯងនេះ បាត់រឹងណាស់ អាភាវទៅទៅ»។

ថាហើយ អាសុខកាច ក៏ចាប់កាំបិតបន្ទោះ ចាក់ភ្នែកអាសុខស្លូតម្ខាងទៀត ឈាមបាញ់ហូរស្រក់ជោកមុខ ជោកដើមទ្រូង ខ្វាក់ភ្នែកទាំងពីរ ឈឺចាប់ខ្លាំង ណាស្តាយជីវិតខ្លួន ណាគិតដល់ជីដូនចាស់ជរា កំព្រានៅផ្ទះតែម្នាក់ឯង ។

អាសុខកាចថា « អាឯងទៅ ឲ្យត្រីវាស៊ីទៅ » ថាហើយ ច្រានអាសុខស្លូតទៅជិតមាត់ស្ទឹង ហើយធាក់ទម្លាក់ទៅក្នុងទឹកស្ទឹងកំពុងហូរ ដោយគិតថា «អាសុខស្លូត មុខជាស្លាប់ហើយ » ក៏ប្រមូលរនាបទាំងអស់ ចងបាច់វិលមកផ្ទះ, ដាក់រនាបហើយ ហួសទៅនិយាយថ្លែងកុហក ប្រាប់ជីដូនអាសុខស្លូត ថា « ចៅយាយឯង ខ្លាខាំស្លាប់ទៅហើយ » ។

យាយ ឮអាសុខកាចប្រាប់ថា ខ្លាខាំចៅស្លាប់ ក៏ទួញយំសោកបោកខ្លួន ហៀបនឹងក្ស័យជីវិត ។ ឯអាសុខកាច រីករាយសប្បាយចិត្ត ហើយក៏ដើរលេងជិត ៗ ផ្ទះដូចធម្មតា ដោយចិត្តក្លាហាន រកតែរឿងឈ្លោះនឹងគេ ។

តពីនេះ ដំណាលពីអាសុខស្លូត គ្រាដែលអាសុខកាច ចាក់ធ្លៀលភ្នែកទាំងពីរខាង ហើយវាធាក់ទម្លាក់ទឹកស្ទឹងកំពុងហូរទៅនោះ, អាសុខស្លូត ហែលបណ្តែតខ្លួន តាមខ្សែទឹកហូទៅ ក៏ភាវនារកពុទ្ធោ ។ ពុំដាច់ពីមាត់ ។ គ្រានោះ អ្នកតាមួយ មានមហិទ្ធិរិទ្ធិខ្លាំងពូកែណាស់ ដែលមានអាស្រម នៅក្នុងព្រៃរំលោង ជិតមាត់ស្ទឹងនោះ, អ្នកតា មានក្រពើធំមួយ ដេកនៅក្រោមអាស្រម អាចតំណែងជាមនុស្សបាន ។ ដល់ពេលឃ្លានអាហារ ក្រពើនោះ ក៏វាចុះមកក្នុងស្ទឹង ស្វែងរកអាហារ វាហែលច្រាសទឹក, ហែលទៅ ។ ប្រទះនឹងអាសុខស្លូត ដែលកំពុងហែលបណ្តែតខ្លួនតាមខ្សែទឹក ក្រពើលាន់មាត់ថា «អៃយ៉ា លាភធំណាស់តើ ! អញមក់រកអាហាថ្ងៃនេះ ប្រទះបានមនុស្សស៊ី » ហើយប្រឹងស្ទុះហែលទៅជិត ឮមាត់ថា ពុទ្ធោ ។ ក៏សង្ស័យក្នុងចិត្ត មើលទៅភ្នែកទាំងពីរ ឃើញធ្លុះរកប្រស្រីគ្មាន, ក្រពើ គិតថា « គួរអញយកទៅថ្វាយលោកតាអញ ។ កុំស៊ីមនុស្សនេះ» ហើយ

ក៏មុជកៀងអាសុខស្លូតឲ្យទៅពីលើខ្នង ហែលត្រឡប់មកដល់អាស្រមវិញ ហើយតំណែងខ្លួនជាមនុស្ស ដឹកដៃ នាំខ្លួនអាសុខស្លូតទៅថ្វាយអ្នកតា ។ សួរ, អាសុខស្លូតនោះ ក៏ថ្វាយបង្គំ រាយរឿងតាមដំណើរគ្រប់ប្រការ, អ្នកតា ស្ដាប់សព្វគ្រប់ហើយ មានចិត្តមេត្តាអាសុខស្លូតនោះពន់ពេក លោកថា " ឱ! អាសុខកាចអើយចិត្តអី អាក្រក់ម៉្លេះ ? ណ្ហើយ! ចៅសុខស្លូត ឯងកុំភ័យ សឹមតាជួយសង្គ្រោះឲ្យចៅរស់ជីវិត ភ្នែកក៏ឲ្យភ្លឺដូចដើម បានទៅជួបនឹងជីដូនឯផ្ទះវិញ " ថាហើយក៏ផ្សំថ្នាំដាក់ភ្នែក សូត្រទិព្វមន្តផ្លុំភ្នែកឲ្យ, ចៅសុខស្លូតនោះ ក៏បានភ្លឺភ្នែកដូចដើម ទើបអ្នកតាក្ដាប់ដីខ្សាច់មួយដៃ សែកទិព្វមន្តផ្លុំដីខ្សាច់ដាក់ដៃឲ្យចៅសុខ ផ្ដាំថា "ចៅ! ចូរឯងក្ដាប់ឲ្យជាប់ ពុំលាដៃ បើទៅដល់ផ្ទះចៅ ៗ ប្រាប់ជីដូនឲ្យក្រាលកន្ទេលក្នុងផ្ទះ ហើយសឹមចៅដាក់ដីខ្សាច់នេះទៅលើកន្ទេល " អ្នកតាផ្ដាំហើយ ហៅក្រពើមកឲ្យចៅសុខស្លូតជិះលើខ្នង ហែលតាមស្ទឹងទៅ ។ បានទៅដល់កន្លែងដែលអាសុខកាចផាក់ទម្លាក់ក្នុងទឹកនោះ ចៅសុខ ឃើញព្រៃឫស្សីដែលកាប់ ល្អសរនាប ក៏ចាំជាក់, ក្រពើ ដាក់ចៅសុខឲ្យឡើងលើគោក, ចៅសុខ ក៏លាក្រពើ ដើរដរាបទៅដល់ផ្ទះ , ហើយចូលទៅយំសំពះជីដូន ៗ ឃើញចៅហើយ ស្ទុះមកយំឱ្យកខ្សឹកខ្សួល និយាយប្រាប់ចៅ ថា « គេប្រាប់យាយថា ខ្មោចចៅស្លាប់ទៅហើយ ម្ចាស់ជីវិតអើយ! ជីដូនយំសោកបោកខ្លួនអាសូរចៅ ហៀបនឹងក្ស័យជីវិត , ចៅមិនស្លាប់ជីដូនអរណាស់ រកអ្វីមកប្រៀបផ្ទឹមពុំបាន » ។

ឯចៅសុខនិយាយប្រាប់ជីដូន តាំងពីទៅកាប់ឫស្សី ល្អសរនាប ត្រូវអាសុខកាច វាចាក់ភ្នែកផាក់ទម្លាក់ទឹក ហើយបានក្រពើនាំទៅថ្វាយអ្នកតា, លុះរៀបរាប់រឿងប្រាប់ជីដូនគ្រប់ប្រការ ជីដូនរឹងរឹតតែអាណិតចៅពេក ហើយវាប្រាប់ជីដូនថា « យាយ ! ក្រាលកន្ទេលក្នុងផ្ទះទៅ » ជីដូនក្រាលតាមពាក្យចៅ ៗ សុខស្លូត ក៏លាដៃ ដាក់ដីខ្សាច់លើកន្ទេល កើតជាប្រាក់គរក្នុងផ្ទះ អរណាស់ តែពីរនាក់ជីដូននិងចៅ បានចាត់ចែងទិញសំលៀកបំពាក់គ្រប់ប្រដាប់ ប្រើប្រាស់ សង់ផ្ទះថ្មី ល្បីបាន

ដាច់គេក្នុងភូមិនោះ ។

អាសុខកាច ឃើញអាសុខស្លូត ក៏នឹកឆ្ងល់ក្នុងចិត្តថា « អញចាក់ភ្នែកវាទាំងពីរខាង ធាក់ទម្លាក់ទឹក ស្មានថាវាស្លាប់ ឥឡូវ វារស់ឡើងវិញ ភ្នែកក៏ភ្លឺដូចដើម មានទាំងសម្បត្តិសប្បុរណ៍ប្រើប្រាស់ គ្មានខ្វះអ្វី ប្លែកអំពីដើម » ។ លុះដល់វេលាស្ងាត់ប្រយោ វាបានជួបនឹងអាសុខស្លូត ក៏សួរថា « កាលឯងនិងអញ ទៅកាប់ឫស្សី លួសរនាបនោះ បិសាចមកបណ្ដាលចិត្តអញ ឲ្យចាក់ភ្នែកទាំងពីរខាង ធាក់ទម្លាក់ទៅក្នុងចិកស្ទឹង អញស្មានថាឯងស្លាប់ ហេតុម្ដេច ក៏ឯងរស់ឡើងវិញ ហើយមានទាំងទ្រព្យច្រើនជាងគេផង » ។

អាសុខស្លូត ឆ្លើយថា « បានគុណបង កុំអីខ្ញុំក្រីក្រលំបាកតោកយ៉ាក ដូចបង ឯងដឹងស្រាប់ » ហើយនិយាយប្រាប់អាសុខកាច តាមត្រង់ថា « កាលដែលបងចាក់ភ្នែកខ្ញុំទាំងពីរខាង ធាក់ទម្លាក់ក្នុងស្ទឹងទៅនោះ ខ្ញុំភាវនារកតែពុទ្ធោ ៗ ក៏បានជួបនឹងក្រពើ ៗ នាំទៅថ្វាយអ្នកតា ៗ ជប់ភ្នែកជប់ដីខ្សាច់ឲ្យខ្ញុំ, លុះខ្ញុំមកដល់ផ្ទះ ដាក់ដីខ្សាច់ កើតជាប្រាក់មាស បានជាខ្ញុំមានសព្វថ្ងៃនេះ » ។

អាសុខកាច ឮអាសុខស្លូត រាយរឿងដូច្នោះ ក៏បណ្ដាលចិត្តលោភលន់ពន់ប្រមាណ គិតថា « អញនឹងធ្វើឲ្យបានដូចអាសុខស្លូត » ថ្ងៃក្រោយ ជួបនឹងអាសុខស្លូត ក៏និយាយថា « អាសម្លាញ់អើយ ! អញចង់ទៅកាប់ឫស្សី លួសរនាបនៅព្រៃដែលយើងទៅកាប់ត្រង់កន្លែងមុននោះ, ឯបាយទឹកអាហារភោជន ថ្នាំជក់ កាំបិតតូចធំ ប្រដាប់កាប់ឫស្សី លួសរនាប ស្រេចនៅលើអញទាំងអស់ ឯងមានតែខ្លួនទៅបានហើយ » ។ អាសុខស្លូតថា « ក្រែងសម្លាប់អញទៀត » ។ អាសុខកាច ថា “មុននោះខ្មោចកំរោលវាចូលឲ្យអញងងឹតមុខ អញចាក់ឯង ដោយមិនដឹងខ្លួនសោះ ឯងកុំប្រកាន់ខឹងនឹងអញ ” ។ អាសុខស្លូត ថា “ ចាំខ្ញុំជូនទៅ ក្បែតបងសុខឯង មានគុណលើខ្ញុំច្រើន ខ្ញុំមានសម្បត្តិទ្រព្យក៏ព្រោះបង” ។ លុះ

ព្រឹកឡើង អាសុខកាច ស្ពាយបាយសំណុំ មានគ្រប់ប្រដាប់ដូចមុន ហើយបណ្ដើរគ្នាដល់ព្រៃឫស្សី, លុះកាប់បាន ពុះល្ងួសរនាបហើយ នាំគ្នាអង្គុយស៊ីបាយ។ អាសុខកាច ហុចកាំបិតបន្ទោះទៅអាសុខស្លូត ប្រាប់ថា " ឯងចាក់ភ្នែកអញម្ខាងទៅ " ។ អាសុខស្លូតប្រកែកពុំព្រមចាក់ ។ អាសុខកាចថា " ពើ ! ចាក់មក ៗ, ហ៊ឺ ! ម្ដេចមិនអាណិតគ្នាផងសោះ " ។ អាសុខស្លូតក៏ចាក់ឆ្កៀលដូចគេឆ្កៀលក្រសាំង ឲ្យខ្ទាក់ភ្នែកម្ខាងទៅ ។ អាសុខកាចឈឺពើតខ្លាំងណាស់ តែចិត្តចង់ប្រញាប់ឲ្យបានប្រាក់ ដូចអាសុខស្លូត ក៏ឲ្យអាសុខស្លូតចាក់ភ្នែកម្ខាងទៀត ហើយបង្គាប់ឲ្យអាសុខស្លូតច្រានទៅជិតមាត់ស្ទឹង ទាំងបង្គាប់ឲ្យធាក់ផង ។ អាសុខស្លូត ក៏ធាក់ទម្លាក់ក្នុងទឹកស្ទឹង ។ អាសុខកាច សួរថា " កាលដែលអញចាក់ឯងមុននោះ ឯងធ្វើម្ដេចខ្លះ ? " ។ អាសុខស្លូតថា " អញរកតែពុទ្ធោ ជាប់នៅមាត់" ។ អាសុខកាចប្រឹងស្រែករកតែពុទ្ធោមិនឈប់ ព្ធរំពងព្រៃមាត់ស្ទឹង ទន្ទឹងរកក្រពើ ក៏ពុំជួបសោះ ណាមួយវាឈឺចាប់ ហែលបណ្ដែតខ្លួនយូរបន្តិចទៅ អស់កម្លាំង ឈ្លក់ទឹកស្លាប់ទៅ ហើយរលួយរលេះ ត្រីស៊ីនៅតែលលាដ៍ក្បាល ។ ខ្មោចអាសុខកាច ក៏អណ្ដែតតាមខ្សែទឹក លងគេឮតែពុទ្ធោ ៗ ជរាបដល់កំពង់ទឹកមហាសេដ្ឋី ។ វេលានោះ កូនក្រមុំមហាសេដ្ឋី នាំខ្ញុំប្រុសស្រីចុះទៅងូតទឹកកំពង់, កំពុងតែកញ្ជ្រោកទឹកលេងសប្បាយ ស្រាប់តែឃើញលលាដ៍ក្បាលអាសុខកាចនោះ អណ្ដែតមកជិត លងស្រែកថា " ពុទ្ធោ ៗ ! " ។ កូនក្រមុំមហាសេដ្ឋី ឈប់លេងទាំងអស់គ្នាទឹកសង្ស័យ ក៏ប្រើខ្ញុំប្រុសម្នាក់ ឲ្យទៅស្រង់យកលលាដ៍ក្បាលខ្មោចនោះមកដាក់លើគោក នៅមាត់កំពង់នោះ, លលាដ៍ក្បាលខ្មោចនោះ វាមិនបាត់ស្ងាត់សោះ ចេះតែលងគេរកតែពុទ្ធោ ៗ ។

កូនក្រមុំមហាសេដ្ឋី ក៏នាំខ្ញុំប្រុសស្រីឡើងពីងូតទឹកមក ប្រើឲ្យខ្ញុំប្រុស កាន់យកក្បាលខ្មោចអាសុខកាចនោះមកផ្ទះ ហើយនាង ជំរាបមហាសេដ្ឋីជាឪពុកនាងថា

« លោកឪពុក ! ខ្ញុំរើសលលាដ៍ក្បាលខ្មោចមួយអណ្តែតទឹកនៅកំពង់យើង វាលង់ស្រែករកពុទ្ធោ ។ » ។ សេដ្ឋីជាមាតាបិតាស្តាប់ហើយ ក៏ស្ទុះមកមើល ឃើញក្បាលខ្មោចនោះ កំពុងស្រែករកពុទ្ធោ ។ បែនអស្ចារ្យណាស់ ក៏ឲ្យលាងជុះខាត់ដាក់លើតោក លលាដ៍ក្បាលនោះ ក៏នៅតែស្រែករកពុទ្ធោ ។ ជានិច្ច គ្មានឈប់ ។

ព្រឹកៗសេដ្ឋីនោះតែងទៅគាល់ព្រះមហាក្សត្រនៅទីចុងព្រះរាជវាំងជួបជុំអស់មន្ត្រីចតុស្តម្ភ រាល់ពេលពុំដែលខាន ។ សេដ្ឋីជំរាបអស់លោកថា « ខ្ញុំបានលលាដ៍ក្បាលខ្មោចមួយ ចេះស្រែករកពុទ្ធោ ។ ជានិច្ច » ។ អស់លោកចតុស្តម្ភស្តាប់ហើយ ឆ្លើយថា « សេដ្ឋីកុហកទេ មិនដែលមានលលាដ៍ក្បាលខ្មោចណា ចេះស្រែករកពុទ្ធោទេ យើងមិនជឿឡើយ » ។ សេដ្ឋីថា « ពិតប្រាកដណាស់ បើអស់លោកមិនជឿខ្ញុំ ។ ហ៊ានភ្នាល់ដោយមាសមួយរយតម្លឹង » ។ អស់លោកចតុស្តម្ភទាំង ៤ ថា « យើងហ៊ានភ្នាល់ » ហើយធ្វើសំបុត្រចុះកិច្ចសន្យា ។ សេដ្ឋីទៅដល់ផ្ទះ ឮលលាដ៍ក្បាលខ្មោចស្រែករកពុទ្ធោគោក ។ នឹកថា « អស់លោកមុខជាចាញ់អញហើយ » ។ សេដ្ឋីយកមាសមួយរយតម្លឹងឲ្យខ្ញុំទូលយកកាន់តោកដែលដាក់លលាដ៍ក្បាលខ្មោចនោះរហ៊ាររហ័សទៅ, លុះចូលទៅដល់ទ្វារកំពែងខាងក្រៅ លលាដ៍ក្បាលខ្មោចបាត់សម្លេងឈឹង ពុំឮស្រែករកពុទ្ធោសោះ, កាលចូលដល់ចុងព្រះរាជវាំង ដាក់លលាដ៍ក្បាលខ្មោច ចំពោះមុខអស់លោកចតុស្តម្ភទាំង ៤ នោះហើយ សេដ្ឋីបង្គាប់ថា « ចាំអីទៀតក៏មិនស្រែករកពុទ្ធោៗទៅ » ។ លលាដ៍ក្បាលខ្មោច បាត់ស្ងាត់ឈឹង មិនឮរកពុទ្ធោសោះ ។ មហាសេដ្ឋីចាញ់ ក៏ជូនមាសមួយរយតម្លឹងទៅអស់លោក. ឯអស់លោក ចំអកថា « សេដ្ឋីយកក្បាលខ្មោចមក វារកពុទ្ធោ ជូនយើងរាល់គ្នា » ហើយទះដៃសើចលាន់នៅទីព្រះរាជវាំង ។ សេដ្ឋីខឹងនឹងក្បាលខ្មោចណាស់ លាអស់លោកចេញមកក្រៅដល់កំពែង ស្រាប់តែលលាដ៍ក្បាលខ្មោច ស្រែកថា ពុទ្ធោ ។ ។ សេដ្ឋីរឹតតែខឹងណាស់,

ដល់ផ្ទះ ប្រើបាវឲ្យយកពូថៅ នាំយកលលាដ៍ក្បាលខ្មោច ទៅសំពងចោលឯកំពង់ទឹក ។ បាវយកទៅមិនសំពងឲ្យល្អិត គ្រឡប់ជាបោះលលាដ៍ខ្មោចទាំងមូល ចោលទៅក្នុងទឹក ។ ឯលលាដ៍ក្បាលខ្មោចអាសុខកាចនោះ អណ្តែតតាមទឹកស្ទឹង ហូររសាត់ទៅក្រោម វាលង រកពុំឡោ ។ រៀងទៅដល់កំពង់វត្ត ។ វេលានោះ លោកសង្ឃនិមន្តទៅស្រង់ទឹក បានឃើញលលាដ៍ក្បាលខ្មោច លងរកពុំឡោ ៗ, លោកក៏ស្រង់យកទៅកុដិ និមន្តលោកសង្ឃផងគ្នាបង្សុកូល រួចដុតក្បាលខ្មោចនោះសុសហើយលោកពិចារណាថា « គួរយកកំទេចឆ្អឹងនេះ លាយនឹងម្រ័ក្សណ៍ ខ្នុកសសរព្រះវិហារ បញ្ជូនផលឲ្យបានដល់អ្នកដែលស្លាប់ ហើយលោកក៏យកខ្នុកលាបតាមសព្វព្រះទ័យលោកទៅ, សល់បន្តិចបន្តួច យកទៅលាបលនរទេះលោក, កាលដែលម្រ័ក្សណ៍ខ្នុករទេះនោះស្ងួតហើយ លោកភ្នកព្រះទ័យចង់ទឹមរទេះបរទៅសួរញាតិញោម, លោកក៏ឲ្យសិស្សដឹកគោមកទឹមរទេះឡើងគង់ បរចេញពីកុដិទៅ ។ វេលាស្ទាត់ពីមនុស្ស រទេះនោះ លាន់ភ្ញៀនឹងដុំសង្កៀតគ្នា, ដូចរទេះធម្មតា តែដល់ជួបនឹងឧបាសកឧបាសិកា រទេះនោះលាន់ឮដូចលោកជេរបញ្ចោរគេ ថា «មេចោរៗ» ញាប់ញ៉ិញ ។ ឧបាសក-ឧបាសិកាឮ ខឹងនឹងលោក ព្រោះថា លោកជេរបញ្ចោរប្រពន្ធកូនគេ ក៏ជៀលគ្នះជាពាក្យទម្ងន់ ៗ, លោកប្រកែកដូចម្តេច ក៏ពុំស្តាប់រឹតតែប្រមាថលោក ឥតកោតញញើត, លោកបរហួសទៅទៀត ជួបនឹងនាហ្មឺនគេកំពុងដើរ មានគ្នាច្រើន, ឯរទេះលាន់ឮទៀត ដូចជាលោកជេរម្តាយនាហ្មឺនទាំងនោះ ថា «ចោរម្តាយនាហ្មឺន» នាហ្មឺន ខឹងនឹងលោក ក៏នាំគ្នាដេញវាយលោក ។ ភ័យវាយគោបំបោលរួចទៅ ។

លោកនេះ គិតថា «ពីដើម រទេះអញ បរមក មិនដែលឮស្អូរជេរបញ្ចោរគេទេ, រៀងនេះ ឃើញតែកំទេចឆ្អឹងក្បាលខ្មោចដែលខ្នុកបិទសសរព្រះ

វិហារ សល់ពីនោះ អញយកមកលាបលនរទេះនេះ » ។ លុះគ្រឡប់មកពីស្ថានញាតិញោម មកដល់វត្តវិញ លោកកាប់រទេះដុតនៅកន្លែងដែលដុតលលាដ៍ក្បាលខ្មោចអាសុខកាច ក្រោះជាផេះ, កន្លែងនោះ ដោយមានជាតិអាសុខកាច ក៏ផុះកើតជាស្មៅកន្ត្រើយ ដែលជាប់សំពត់ ទោបនុស្សសព្វថ្ងៃនេះឯង ។

## ចិត្តមិនអប់រំ នាំឱ្យវិនាស

## ១៨- រឿង សម្លាញ់ពីរនាក់(១)

កាលពីព្រេងនាយ មានបុរសពីរនាក់ ជាសម្លាញ់នឹងគ្នា និយាយសន្យាគ្នាថា « កាលបើយើងមានប្រពន្ធហើយ ឯងក្ដី អញក្ដី បើមានទ្រព្យសម្បត្តិ ត្រូវយើងចិញ្ចឹមគ្នាទៅវិញទៅមក » ។ សន្យាគ្នាហើយ យូរបន្តិចទៅ សម្លាញ់មួយ មានប្រពន្ធគ្រប់លក្ខណ៍ សម្លាញ់មួយទៀតមានប្រពន្ធខាតលក្ខណ៍ ។

វេលាយប់ចូលដំណេក សម្លាញ់ ដែលមានប្រពន្ធគ្រប់លក្ខណ៍នោះ និយាយគិតគ្នាប្ដីប្រពន្ធថា « យើងរកស៊ីអីឲ្យមានឆាប់ ? » ប្រពន្ធថា « អ្នកចង់រកស៊ីអីឬប្រើខ្ញុំឲ្យត្បាញរវៃលក់ដូរ ខ្ញុំទទួលតាម មិនហ៊ានទទឹងទាស់ចិត្តអ្នកទេ » ។

លុះកន្លងមកពេលចូលដំណេកយប់ក្រោយទៀត ប្ដីនិយាយនឹងប្រពន្ធថា « នាងអើយបើគិតឃើញរបរមួយមុខ បើបានដូចគំនិតនឹងបានមាសប្រាក់ផ្ដិល. តុ ថាសដោយងាយ » ។ ប្រពន្ធសួរប្ដីថា « គិតធ្វើម្ដេចក៏បានងាយម៉្លេះ ? » ។ ប្ដីប្រាប់ប្រពន្ធថា « ជាច្រើនឆ្នាំមកហើយនៅក្នុងសមុទ្រ មានសំពៅអ្នកជំនួញគ្រប់ប្រទេស ខ្លះសុខសប្បាយ ខ្លះលិចលង់របស់ទ្រព្យសព្វសារពើ មាសប្រាក់ កប់នៅបាតសមុទ្រនោះច្រើន យើងគិតនាំគ្នាទៅបាចទឹកសមុទ្រនោះឲ្យរីង ក្រអ្វី មាស-ប្រាក់ របស់គ្រប់មុខនោះ, បើបានត្រីធំតូចយើងធ្វើងៀត ធ្វើផ្អកប្រហុក, ព្រឹក

---

១ កម្ពុជសុរិយា លេខ ១-២-៣ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៦២ រៀបរៀងដោយព្រះអក្ខរលេខា ណុប នៅក្រុមព្រះរាជនិពន្ធ ។

ព្រះរាជស្រវាងនេះ នាងឯងដាំបាយដួសដាក់កញ្ជើ ឲ្យមានម្ហូបនិងស្លាម្ហូរផង យើងទៅបាចទឹកសមុទ្រឲ្យរីង » ។ ប្រពន្ធឮប្តីប្រាប់ហើយ ក៏ធ្វើតាមបង្គាប់ ។ លុះព្រឹកឡើង រៀបគ្រប់ប្រដាប់រួចក៏នាំទៅមាត់សមុទ្រ ហើយទុកដាក់បាយម្ហូបចំណីដោយស្រួល ទើបប្តីកាន់កញ្ជើ ១ ខំបាចទឹកទៅលើគោក បាចទាល់តែដល់ពេលបាយ ទើបឈប់បរិភោគ លុះបរិភោគបាយរួច នាំប្តីប្រពន្ធបាចទៀតដល់ល្ងាចទើបទៅផ្ទះ, ព្រឹកឡើងនាំគ្នាទៅបាចទៀតទាល់ល្ងាចទើបនាំគ្នាមកផ្ទះវិញ ។ បាចបានចំនួន ៥ ថ្ងៃប្តីក៏ឈរបាំងដៃមើលទឹកសមុទ្រ ហើយប្រាប់ប្រពន្ធថា « ទឹកស្រកសណ្តកហើយនាង » ។ ប្រពន្ធឆ្លើយថា « បើដូច្នោះ យើងខំបាចទៅបើប្រហែលជាអស់ត្រឹមកន្លះខែទៀតមុខជារីងហើយ យើងចាប់យកត្រីធំតូចវះធ្វើងៀតផ្អកប្រហុកផ្សំលក់យកប្រាក់, មួយទៀត យើងត្រូវកកាយយកប្រាក់មាស ត្បូង ថាស ចានក្បាន ដ៏មាននៅក្នុងសំពៅទាំងប៉ុន្មាន ដែលលិចលង់មកយូរឆ្នាំនោះ មិនដឹងបើយកទៅណារស់ទេ » ថាហើយ ដល់ល្ងាចនាំគ្នាត្រឡប់មកផ្ទះវិញ ។ ព្រឹកឡើង នាំគ្នាទៅបាចទៀត ហើយនិយាយតែពាក្យដដែល ៗ ដូចថ្ងៃមុន ។ ហ្វូងមច្ឆាក្នុងសមុទ្រ ស្តាប់ឮពាក្យពំពេកីរសព្វគ្រប់ ភ័យបារម្ភណាស់ ជំនុំគ្នាថា « យើងមុខជាស្លាប់ប្រលងនិងបៀបៀន គួរតែយើងនាំគ្នាទៅទូលស្តេចត្រីអន្ទ្យាសមុទ្រទើបរស់ជីវិត» គិតហើយបាននាំគ្នាមុជហែលទៅដល់ស្តេចត្រី ទូលតាមដំណើរ ដែលបុរសប្តីប្រពន្ធមកបាចទឹកសមុទ្រនោះ ។ ស្តេចត្រីដឹងហើយ បង្គាប់ត្រីទាំងប៉ុន្មានដែលទៅទូលនោះថា « ឯងរាល់គ្នាពាំយកបាស ៥ ក្រឡ ប្រាក់ ៥ ក្រឡ និង ត្បូង ថាសផ្តិលចានទៅឲ្យបុរសប្តីប្រពន្ធ អង្វរគេឲ្យលែងបាចទឹកសមុទ្រទៅ » ។ ត្រីទាំងនោះក៏យករត្នគ្រប់ចំនួនតាមស្តេចត្រីបង្គាប់ រួចនាំគ្នាពាំហែលមកដល់បុរសប្តីប្រពន្ធ អង្វរសូមឲ្យលែងបាចទឹកសមុទ្រ ត្រីទាំងនោះក៏ហាមាត់ខ្ជាក់ក្រឡមាសប្រាក់ ត្បូង ថាសផ្តិលចានឲ្យបុរសប្តីប្រពន្ធ ។ បុរសប្តីប្រពន្ធ មានសេចក្តីត្រេកអរពន់ពេក ក៏ឈប់លែងបាចទឹកពីថ្ងៃនោះ នាំប្តីប្រពន្ធរែកទូលជញ្ជូនទៅទុកផ្ទះគ្រាតែអស់ ។ បុរស

ប្ដីប្រពន្ធក៏មានទ្រព្យសម្បត្តិច្រើនថ្កើងរុងរឿង បានសេចក្ដីសុខរៀងទៅ ។

ពណ៌នាពីសម្លាញ់ដែលមានប្រពន្ធខាតលក្ខណ៍ គាត់ភ្ញាក់ពីកព្រឹកដល់សំឡាញ់ ហើយនាំប្រពន្ធទៅលេងផ្ទះសំឡាញ់ ដែលមានប្រពន្ធគ្រប់លក្ខណ៍, លុះឡើងដល់លើផ្ទះ ឃើញគេនៅរាប់អានចាំចិត្តស្និទ្ធស្នាលដូចពីដើម, គាត់គន់មើលរបស់ទ្រព្យប្រដាប់ប្រដាក្នុងផ្ទះគេ ហើយនឹកក្នុងចិត្តថា « ពីដើម សំឡាញ់គេមានទ្រព្យសម្បត្តិល្មមគួរសមទេ, ឥឡូវនេះគេរករបរអ្វី ក៏មានទ្រព្យសម្បត្តិច្រើនម៉្លេះ » គិតហើយ ត្អូញប្រាប់សម្លាញ់ដែលមានទ្រព្យសម្បត្តិថា « សំឡាញ់អើយ ! អញសព្វថ្ងៃនេះក្រលំបាកណាស់, ចុះសម្លាញ់ឯង រកស៊ីជំនួញអ្វី ក៏មានទ្រព្យសម្បត្តិច្រើនម៉្លេះ » ។ សម្លាញ់ដែលមានប្រពន្ធគ្រប់លក្ខណ៍ ថា « សំឡាញ់អើយ !-អញរកស៊ីបាចទឹកសមុទ្រ តែពីរនាក់នឹងប្រពន្ធអញ, ពេលព្រឹកទៀបភ្លឺប្រពន្ធអញដាំបាយគ្រប់ប្រដាប់ លុះភ្លឺឡើង នាំគ្នាទៅបាចទឹកសមុទ្រ, ល្ងាច ត្រឡប់មកផ្ទះវិញ ស្ដេចត្រីភ័យបង្គាប់ត្រីជាបរិវារឲ្យនាំមាសប្រាក់ នឹងរបស់គ្រប់មុខឲ្យអញ »។

ឯសំឡាញ់ មានប្រពន្ធខាតលក្ខណ៍ ដឹងហើយ ក៏លាសំឡាញ់ដែលមានប្រពន្ធគ្រប់លក្ខណ៍ ។ គេក៏ឲ្យប្រាក់យកទៅចិញ្ចឹមជីវិត ។ លុះត្រឡប់ទៅផ្ទះវិញ ពេលចូលដំណេក បុរសនោះ និយាយនឹងប្រពន្ធថា « ព្រឹកនេះឯងដាំបាយពីយប់រៀបប្រដាប់ឲ្យមានសព្វគ្រប់, ភ្លឺឡើង យើងនឹងនាំគ្នាទៅបាចទឹកសមុទ្រ ឲ្យបានមាសប្រាក់របស់ទ្រព្យដូចសំឡាញ់យើង ។

លុះភ្លឺច្បាស់ មេខាតលក្ខណ៍ជាប្រពន្ធ បានក្រោកបង្កាត់ភ្លើងឆេះហើយ បានបើកខាប់រាល់អង្ករ ។ កំពប់ម្ដងមួយទូកដៃ យកអង្ករទៅលាងកំពប់មួយទូកដៃទៀត ច្រកអង្ករទៅក្នុងឆ្នាំងកំពប់ទៀត ដល់ពុះជាត់បាយកំពប់ទៀត ច្រកអង្ករចំនួនល្មមឆ្អិនពេញឆ្នាំង បាយនៅតែកន្លះឆ្នាំង, ទាល់តែថ្ងៃណាស់ហើយ ទើបដួសដាក់កញ្ជើ ហើយបណ្ដើរប្ដីប្រពន្ធទៅបាចទឹកសមុទ្រ បាចទាំងខឹងទាំងជា ។ បាចចំ-

ទួន ៥ ថ្ងៃ អស់ហ្វូងមច្ឆាតូចធំ ផ្អើលភិតភ័យ និយាយគ្នាថា « បុរសប្តីប្រពន្ធពីណា មកបាចទឹកសមុទ្រទៀតហើយ » ពួកត្រី ក៏សម្លឹងទាំងហ្វូងចាំមើលចាំស្តាប់ ។ ប្រពន្ធខាតលក្ខណ៍ បោកល្អីដែលបាចទឹកនោះ ហើយថា « បាចយូរថ្ងៃហើយ មិនបានឃើញរបស់អ្វី អញមិនខ្វល់ទេ អញលែងបាចហើយ » ឈ្លោះប្តីប្រពន្ធជេរម្តាយប្តី ប្តីបញ្ចោរប្រពន្ធ ប្រកាច់ចំបាប់គ្នា ប្រទាញសំពត់គ្នាទៅវិញទៅមក ទាល់តែអាស្រាតទាំងប្តី ប្រពន្ធ លេចកេរ្តិ៍ខ្មាស់នៅមាត់សមុទ្រ ហើយអ្នកទាំងពីរនាក់ថា «ខ្ញុំគេក៏ខ្ញុំចុះ លែងបាចហើយ » ។ ត្រីទាំងនោះ ឮថា លែងបាច ក៏ត្រេកអរធូរចិត្ត លែងស្ងួតឲ្យមាសប្រាក់របស់ទាំងពួង ។ ត្រីទាំងនោះ បានឃើញកេរ្តិ៍ខ្មាស់បុរសប្តីប្រពន្ធ ក៏លោតសើចទាំងហ្វូង ។ ឯត្រីសណ្តាយ សើចទាល់តែរយះមាត់បានជាមាត់ធំ ដូចគេហែក រហូតដល់បច្ចុប្បន្ននេះ ។

បុរសប្តីប្រពន្ធ គ្មានបានអ្វីសោះ ក៏លែងឈ្លោះ នាំគ្នាដកសាររាយ ។ ប្តីមួយអង្រែក ប្រពន្ធ មួយទ្រនូល ត្រឡប់មកផ្ទះវិញ ចាក់សាររាយចោលនៅកៀនជញ្ជាំង ឲ្យរលួយខូចអស់ទៅ ។

## នាងរត់រកអ្នក មេខាតលក្ខណ៍ រត់រកអាបាក់ធន្យា

# ១៩- រឿង សួស្តី និង អពមង្គល(១)

សម័យមួយ សិរីសួស្តី និងអពមង្គល ជួបនិយាយគ្នា ។ អពមង្គលសួរទៅសិរីសួស្តីថា « លោកមានឫទ្ធិអំណាច ដូចម្តេចខ្លះ? » ។ សិរីសួស្តី ប្រាប់ទៅអពមង្គល ថា « ឫទ្ធិអំណាចអញជាសិរីសួស្តីនេះ ខ្លាំងពូកែណាស់ សូម្បីតែមនុស្សខ្ញុំគេ ទោះគេស្អប់ គេមិនមេត្តា តែអញទៅសណ្ឋិតកាលណា ចឹងបណ្តាលឲ្យគេស្នេហាទំនុកបម្រុងដរាបដល់បានរាជសម្បត្តិ » ។

ឯសិរីសួស្តី សួរទៅអពមង្គលវិញ ថា « ឫទ្ធិអំណាច ដូចម្តេចខ្លះ? » ។ អពមង្គល ឆ្លើយថា « ឫទ្ធិអំណាចខ្ញុំនេះ បើខ្ញុំទៅសណ្ឋិតនៅឈ្មោះណាបណ្តាលឲ្យគេស្អប់គេខឹង ខូចខាតសម្បត្តិទ្រព្យវិនាសអន្តរាយ សូម្បីតែបានរាជសម្បត្តិហើយក៏គង់ថ្លោះធ្លោយ ធ្លាក់ខ្លួនទៅជាខ្ញុំគេបាន » ។ អពមង្គល ចង់ដឹងឫទ្ធិសិរីសួស្តី ក៏ប្រាប់ថា « ខ្ញុំឃើញខ្ញុំសេដ្ឋីម្នាក់ឈ្មោះ អាគុល សព្វថ្ងៃនេះ សេដ្ឋីប្រើឲ្យឃ្វាលគោក្របី សេដ្ឋីខឹងនឹងអាគុល ជេរវាយតែសព្វថ្ងៃ ថា ពុំមើលថែរក្សាគោក្របី ឲ្យស្គមអស់ ខ្ញុំចង់ឲ្យលោកសិរីសួស្តី ទៅសណ្ឋិតនៅលើរូបអាគុលខ្ញុំសេដ្ឋីនោះ, បើវាបានរាជសម្បត្តិ ខ្ញុំក៏ជឿថា លោកមានឫទ្ធិខ្លាំងពូកែប្រាកដមែន » ។ សិរីសួស្តី ប្រាប់អពមង្គលវិញថា « ឯងចាំមកគន់មើលចុះ ថ្ងៃស្អែកនេះ អញចូលទៅសណ្ឋិត នៅលើរូបអាគុល ខ្ញុំសេដ្ឋីហើយ, តែកាលណា អញចូលទៅនៅហើយ មិនយូរប៉ុន្មាន

---

១ កម្ពុជសុរិយាលេខ ១-២-៣ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៩៤ រៀបរៀងដោយ ព្រះអក្សរលេខា ណុប នៅក្រុមព្រះរាជនិពន្ធ ។

មុខជាអាគុលខ្ញុំសេដ្ឋីនោះ វាបានសោយរាជសម្បត្តិមិនខាន » ។

លុះព្រឹកឡើង ដល់ពេលអាគុលបញ្ចេញគោក្របីពីក្រោល យកទៅឃ្វាល, សិរីសួស្តី ចូលទៅសណ្ឋិតនៅលើរូបអាគុល ។ ក៏រីករាយ សប្បាយក្នុងចិត្តប្លែកពីថ្ងៃមុន ។

ដល់ពេលល្ងាច អាគុល កៀងគោក្របី ត្រឡប់មកបញ្ចូលក្រោលឯផ្ទះវិញ ។ សេដ្ឋីទាំងប្ដីប្រពន្ធឈរមើលគោក្របី ឃើញអាគុលរាំងទ្វារក្រោលគោក្របីខ្ទាប់ហើយ ទើបឡើងទៅអង្គុយលើផ្ទះសេដ្ឋីជាចៅហ្វាយ នៅត្រង់កន្លែងខ្លួន ដូចសព្វដង ។ កាលសេដ្ឋីទាំងប្ដីប្រពន្ធ ឃើញអាគុលហើយ ក៏នឹកក្នុងចិត្តអាណិត ថា “ឱ អាគុលអើយ ! ទៅឃ្វាលគោក្របី អត់បាយក្រហាយទឹកទាល់ល្ងាច ទើបបានបាយបរិភោគម៉្លេះសមវាឃ្លានយ៉ាងណាទៅ ? ” គិតហើយ ក៏ដាស់តឿនខ្ញុំកំដរស្រី ។ ឲ្យដោះដួសបាយស៊ីរាល់គ្នា ។ ខ្ញុំស្រី ។ ក៏ដោះដួសភោជនាហារណាដែលមានឱជារស យកទៅដាក់ជូនសេដ្ឋី ហើយប្រជុំគ្នាបរិភោគ ។ សេដ្ឋីប្ដីប្រពន្ធ ហៅអាគុលឲ្យមកជិត ចាប់ម្ហូបដែលមានឱជារសឲ្យបរិភោគ ។ រួច សេដ្ឋីប្ដីប្រពន្ធ គន់មើលកិរិយាឫករូបអាគុលនោះ ក៏ឃើញថាសមរម្យឥតខ្ចោះ រកទាស់ចិត្តត្រង់ណាគ្មាន ។ បណ្ដាជនទាំងស្រីប្រុស ឲ្យតែឃើញរូបអាគុលនោះកាលណា ក៏មានចិត្តស្នេហាមេត្តាពន់ប្រមាណ ។ ឯសេដ្ឋីប្ដីប្រពន្ធ ជាចៅហ្វាយអាគុលនោះ និយាយគិតគ្នាថា « សព្វថ្ងៃនេះ យើងឥតកូន, ទ្រព្យសម្បត្តិ ក៏មានច្រើន, អំណើះតទៅបើឥតពីយើង ទ្រព្យសម្បត្តិនឹងអន្តរាយអសារឥតការ, គួរលើកអាគុលឡើង តម្កើងធ្វើជាកូន កុំឲ្យវាឃ្វាលគោក្របីទៀត ត្បិតអាគុលនេះ សាច់ឈាមឫកពាល្អណាស់ ល្មមសមគួរជាកូនយើងបាន » ។

ដល់ពេលល្ងាច អាគុលត្រឡប់មកពីឃ្វាលគោក្របីវិញ សេដ្ឋីទាំងប្ដីប្រពន្ធ ឃើញអាគុល រឹតតែស្នេហាមេត្តាពន់ពេក ក៏ហៅឲ្យបរិភោគបាយជាមួយ មិន

ឃ្លាតឆ្ងាយពីខ្លួន ឈប់ឲ្យឃ្វាលគោក្របី ចាប់តាំងពីថ្ងៃនោះតទៅ ។

សេដ្ឋីទាំងប្ដីប្រពន្ធ យកសម្លៀកបំពាក់ គ្រឿងមាសប្រាក់មកតុបតែងឲ្យអាគុល ហើយប្រាប់ថា " ពីថ្ងៃនេះទៅ អញទុកឯងជាកូន; អំណើរ៉ះពីអញទៅ ទ្រព្យ-សម្បត្តិអញទាំងប៉ុន្មាន នៅលើដៃកូនឯងទាំងអស់ " ។ អាគុល ក៏រីករាយសប្បាយជាទីបំផុត ។

ដោយអំណាចសិរីសួស្តី សណ្ឋិតលើខ្លួន លុះអាគុល ចំរើនអាយុពេញរូបរាងឡើង ក៏រឹតតែល្អ រកបុរសឯណា នឹងប្រៀបផ្ទឹមស្មើពុំបាន ។

រាល់ព្រឹកល្ងាច សេដ្ឋីតែងចូលគាល់ព្រះមហាក្សត្រ ពុំដែលលស់ខាន ក៏នាំយកអាគុល ជាកូនទៅគាល់ផង ។ ព្រះរាជា ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ, ស្ដេចចេញប្រថាប់នៅក្រឡាព្រះនៅធ្វល់; ព្រះរាជបុត្រី ក៏ជិតដោយក្រោយព្រះអង្គមក ។ កាលមហាសេដ្ឋី នាំកូនចូលក្រាបបង្គំគាល់ ព្រះមហាក្សត្រ ទ្រង់-ឆ្មៀងព្រះនេត្រ ឃើញសេដ្ឋីនិងកូន អង្គុយគាល់ទន្ទឹមគ្នា ទ្រង់ត្រាស់សួរថា "កូនសេដ្ឋីឬ ? " ។ សេដ្ឋីទូលថា " កូនទូលព្រះបង្គំជាខ្ញុំ " ។ ស្ដេចទ្រង់សរសើរថា « កូនសេដ្ឋីមានរូបមានពុកល្អណាស់ » ។ ព្រះរាជបុត្រី ក៏នឹកក្នុងព្រះទ័យថា " កូនសេដ្ឋីនោះមានលំអនឹងរកបុរសណាផ្ទឹមពុំបាន ធ្វើម្ដេចនឹងបានជាស្វាមីអញ?"។

ដល់ពេលគួរ ស្ដេចនិងព្រះរាជបុត្រីនោះ យាងចូលទៅខាងក្នុងវិញ, សេដ្ឋីក្រាបថ្វាយបង្គំលា នាំកូនត្រឡប់មកផ្ទះ, ដល់ផ្ទះ កូននិយាយនឹងសេដ្ឋីថា " សូមលោកឪលោកម៉ែមេត្តាកូន ទៅដណ្ដឹងព្រះរាជបុត្រីស្ដេចឲ្យខ្ញុំ ត្បិតកាលខ្ញុំចូលទៅ-គាល់ ជាមួយលោកឪពុកនោះ, ខ្ញុំបានឃើញច្បាស់ ព្រះរាជបុត្រីនោះ ល្អណាស់ បើមិនដណ្ដឹងឲ្យខ្ញុំទេ ខ្ញុំមុខជាស្លាប់មិនខាន " ។ ដោយស្នេហាកូនពេក សេដ្ឋីប្ដីប្រពន្ធ ក៏ប្រជុំយខ្លួនរៀបៗគុមាសប្រាក់ ដាក់គ្រឿងបណ្ណាការ ជាតង្វាយ សុទ្ធ-តែពេជ្រនិងមាស ពោរពាសច្រើនគុ, លុះព្រឹកឡើង នាំតង្វាយនោះ ទៅរៀបចំ

ក្នុងទីព្រះរាជវាំង ។ ព្រះមហាក្សត្រ ស្ដេចចេញមកឲ្យនាហ្មឺនធំតូចគាល់ ។ សេដ្ឋីទាំងប្ដីប្រពន្ធ ក៏គាល់នៅជិតគ្រឿងបណ្ណាការតង្វាយនោះ ។ ស្ដេចត្រាស់សួរថា « សេដ្ឋី ! តង្វាយនេះ ប្លែកណាស់ មានការអ្វី? » ។ សេដ្ឋីប្ដីប្រពន្ធ ក្រាបបង្គំទូលថា " សូមព្រះរាជតេជះតម្កល់លើត្បូង សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ សូមទ្រង់ប្រោសព្រះរាជទានព្រះរាជបុត្រី ផ្សំនឹងកូនទូលព្រះបង្គំជាខ្ញុំ " ។ ស្ដេចទ្រង់ជ្រាប ទ្រង់ព្រះរាជអនុញ្ញាត ទ្រង់ចាត់មុខក្រសួង ឲ្យរៀបព្រះរាជពិធីសមោស, ហោរាថ្វាយឫក្ស ទ្រង់ផ្សំព្រះរាជបុត្រីនឹងកូនសេដ្ឋី ហើយផ្ទេរទាំងរាជសម្បត្តិឲ្យគ្រប់គ្រងផង ។

លុះបានរាជសម្បត្តិហើយ ស្ដេចគុលនិងព្រះនាងមហេសី ក៏បានប្រកបដោយសេក្ដីសុខឥតទុក្ខា មហាប្រសើររៀងទៅ ។

និយាយពីរឿងអពមង្គលវិញ កាលជួបនឹងសិរីសួស្ដី ក៏ថា " លោកសិរីសួស្ដី ខ្ញុំដៀហើយ ឃើញថា លោកមានរិទ្ធិ ជួយស្ដេចគុលឲ្យបានរាជសម្បត្តិមែន, ដូច្នេះ លោកចាំមើលរិទ្ធិខ្ញុំវិញម្ដង សូមលោកលែងសណ្ឋិតនៅលើរូបស្ដេចគុលទៅ " ។ សិរីសួស្ដី ក៏ថយចេញពីរូបស្ដេចគុល, អពមង្គល ក៏ចូលទៅសណ្ឋិតលើរូបស្ដេចគុលម្ដង ។ ឯស្ដេចគុលចេះតែម្សួរម៉ៅ ក្ដៅក្រហាយ, ព្រះនាងមហេសី ស្រីបរិវារ ក៏ពុំសូវយកចិត្តទុកដាក់គោរពប្រណិប័តន៍ បណ្ដាលចិត្តឲ្យតែខឹងស្អប់ស្ដេចគុល អស់លោកចតុស្ដម្ភទាំងប៉ុន្មាន ។ ក៏ពុំសូវចូលចិត្ត គិតចង់ឲ្យតែព្រះវររាជបិតាក្មេក យករាជសម្បត្តិទៅវិញ ។

ចំណែកស្ដេចគុល ចេះតែក្ដៅក្រហាយ អន្ទះអន្ទែង ចង់ទៅក្រសាលទីទំនាបមាត់បឹងព្រៃពេក ក៏នាំព្រះនាងមហេសី ស្រីបរិវារចេញទៅ, លុះទៅដល់ ក៏ឲ្យធ្វើព្រះពន្លាស្នាក់ក្រសាល ។ នៅទីមាត់បឹងនោះ ឮតែសព្ទសូរត្រដោកគោត្រដោកក្របី, ស្ដេចគុល ក៏នឹកអាណិតខ្លួនកាលនៅជាខ្ញុំមហាសេដ្ឋីដែលគេប្រើ

ឲ្យឃ្វាលក្របី ហើយក៏ទ្រង់ព្រះកន្សែងខ្សឹកខ្សួល ។ ព្រះនាងមហេសី សួរថា "ព្រះអង្គ ! ហេតុអ្វីក៏ទ្រង់ខ្សឹកខ្សួលម្ល៉េះ? " ។ ស្តេចគុលប្រាប់ព្រះនាងមហេសី តាមត្រង់ថា "លាក់បាំងអី ម្ចាស់អូនអើយ / ខ្លួនបងនេះ មិនមែនកូនសេដ្ឋីទេ, ពីដើមបងជាខ្ញុំសេដ្ឋី ។ គេប្រើឲ្យឃ្វាលគោក្របី, ឥឡូវ ឮគ្រដោកក្របីគោបងនឹក ស្រងេះស្រងោច អាណិតខ្លួន បានជាបងយំ " ។ ព្រះនាងមហេសីបានឮថា ជាខ្ញុំសេដ្ឋី ក៏មានចិត្តទោមនស្សក្នុងព្រះទ័យពន់ពេកថា "ឱព្រះវរបិតា ពុំគួរផ្សំផ្គុំកូន ផ្ដេរទាំងរាជសម្បត្តិឲ្យទៅខ្ញុំគេសោះ " ខ្វាល់ហើយ ក៏នាំស្តេចគុល នឹងស្រីបរិវារដែលតាមហែរទៅទាំងប៉ុន្មាន ត្រឡប់ចូលព្រះរាជវាំងវិញ ចូលក្រាបទូលវរាជបិតាមាតា តាមរឿងដែលស្តេចគុលយំគ្រប់ប្រការ ។ ស្តេចជាព្រះវររាជបិតាមាតាទ្រង់ជ្រាបហើយ ទ្រង់កោធពន់ប្រមាណ ទ្រង់ត្រាស់ឲ្យហៅសេដ្ឋីទាំងប្តីប្រពន្ធមកដៀលត្មះជាទម្ងន់ ហើយប្រគល់ស្តេចគុល ឲ្យទៅសេដ្ឋីប្តីប្រពន្ធ នាំយកទៅផ្ទះវិញ ។

ឯរាជសម្បត្តិ ស្តេចទ្រង់គ្រប់គ្រងវិញ ។ សេដ្ឋីប្តីប្រពន្ធ នាំអាគុលទៅដល់ផ្ទះហើយ ជេរវាយ ត្មះតិះដៀល លែងរាប់អានជាកូន ឲ្យអាគុលឃ្វាលគោក្របីទុកជាខ្ញុំដូចដើម ។

## មាយានថ្លៃឱ្យយក មាយានថោកឱ្យទៀវ

## ២០–រឿង ខ្លាចាញ់ប្រាជ្ញាគីង្គក់ និងអណ្ដើក(១)

មានសត្វខ្លាមួយ ដើរស្វែងរកស៊ីតាមទម្លាប់វា, លុះដើរទៅប្រទះនឹងសត្វគីង្គក់មួយ កំពុងលោតផ្លោត ៗ ក៏ស្រែកសួរទៅ ថា « យើ ! បងមាំងកាយេ ( ខ្លះហៅថាមាំងកាជា ) ឯងដើររកស៊ីអ្វីហ្នឹង ? » ។ គីង្គក់ តបថា « ចុះបងខ្លាឯង ដើរមករកអ្វីដែរ ? » ។ ខ្លាថា « យើងដើររកស៊ី » ។ គីង្គក់តបថា យើងក៏ដើររកស៊ី ដូចបងឯងដែរ » ។ ខ្លាថា « ចុះដើររកស៊ីអ្វីនឹងបាន បើបងឯង លោតម្ដងបានមួយសុញដូច្នេះ តើចាប់សត្វអ្វីនឹងបាន ? » ។ គីង្គក់ ក៏អួតអាត្មា ប្រាជ្ញាឲ្យខ្លាកោតខ្លាចថា " យើ ! ថ្វីបើឃើញយើងលោតតិច ៗ ដូច្នេះ បើចង់លោតយ៉ាងណាក៏បាន ចង់ចាប់សត្វតូចក្ដី ធំប៉ុន្មានក្ដី ក៏បានទាំងអស់ មិនចាញ់បងឯងទេ " ។ ខ្លាថា " បើបងឯង ពូកែដូចសំដីថានេះ យើងលោតប្រឡងគ្នា ពីត្រើយព្រែកម្ខាងទៅត្រើយម្ខាងមើល, បើបងឯងលោតឆ្លងដល់ យើងជឿថា ពូកែមែន ។ គីង្គក់ ជាសត្វមានប្រាជ្ញា គិតឃើញថា " សត្វខ្លានេះ តែកាលណាវារៀបនឹងលោតរមែងចោលកន្ទុយទៅខាងក្រោយ, បើដូច្នេះ អញចាំខាំកន្ទុយវា កាលមុនវានឹងលោតទៅនោះ " ទើបគីង្គក់ តបទៅ ថា "ខ្លាចអ្វីបងខ្លាឯង ! យើងចង់លោត ពីត្រឹមណាទៅត្រឹមណា ក៏បានដែរ ហើយយើងហ៊ានឲ្យបងឯងទៅឈរពីមុខយើងទៀតផង, តែកាលណាយើងស្រែកថា ហឺ ! ត្រូវបងឯង

---

១ កម្ពុជសុរិយា លេខ ៤-៥-៦ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៩១ រៀបរៀងដោយ ព្រះមេត្រីតេជោ សុគតោ ក្រមការដើមខ្សែថ្នាក់លេខ ២ ។

លោតទៅចុះ ” ។ ខ្លាផាសត្វឆោត មិនអាចគិតដឹងគំនិតគីង្គក់ វានឹងខាំកន្ទុយខ្លួននោះសោះ, ឯខ្លួនទៀត ក៏មិនបានគិតឃើញពីរបៀបខ្លួន ដែលរៀបនឹងលោតទៅនោះ ធ្វើកិរិយាយ៉ាងណា ៗ ដែរ ក៏ព្រមសន្យាទៅឈរនៅពីមុខគីង្គក់ ។ ឯគីង្គក់ កាលខ្លាមកឈរពីមុខ ឃើញពេលល្អហើយ ក៏ប្រាប់ថា “ បងឯងប្រុងស្តាប់ ” ។ រីឯខ្លា រវល់តែប្រុងត្រចៀកស្តាប់ ចោលឯកន្ទុយនោះ ទៅត្រង់ពីមុខគីង្គក់ ៗ ស្រែកថា ហ៏ ! ហើយខាំកន្ទុយផាប់ ។ ខ្លាលោតផ្លោតទៅភ្លាមដល់ត្រើយម្ខាងមួយរំពេច ។ អំណាចកន្ទុយខ្លាវាត់ទៅមុខនោះ ដោយទាំងគីង្គក់ទៅផង ដូចជាដុំដីដែលគេចោលនឹងឈើដង្គក់ ធ្លាក់ហួសទៅមុខខ្លាស្ទើរតែនឹងស្លាប់។ ខ្លាក៏មិនអាចដឹងបាន ប្រែប្រាណទៅខាងក្រោយវិញ ស្រែកហៅថា “ បងមាំងកាយេអើយ ! មក ” ។ គីង្គក់ ឆ្លើយ “ គូក ! នៅឯនេះហើយ ” ។ ខ្លា ឮគីង្គក់ឆ្លើយពីមុខដូចច្នោះ ក៏ថា “ បងមាំងកាយេ ' ពូកែមែនហើយ ប៉ុន្តែ



ខាងការចាប់សត្វនោះ យើងមិនទាន់ឃើញរឹទ្ធិបងឯងនៅឡើយ, បើដូច្នេះ យើងនឹងចាប់សត្វល្បងគ្នាទៀត " ។ តឹង្កក់ ព្រម ក៏តបវិញថា បងទៅចាប់សត្វចុះ បានសត្វប៉ុន្មាន ។ មកជួបគ្នានៅកន្លែងនេះ យើងនឹងរើសាច់នោះល្បងគ្នាមើល តើអ្នកណាច្រើនជាង ? " ។ ខ្លាព្រម ក៏ចេញទៅរកចាប់សត្វផ្សេង ៗ បានច្រើន ។

ឯតឹង្កក់ ក្រោយខ្លាចេញទៅនោះ ខំសង្វាតលោតទៅ មិនដឹងនឹងទៅចាប់សត្វណាបានទេ ព្រោះធ្លាប់តែចាប់ជន្លេននឹងស្រមោចសង្ការ, លោតបន្តិចទៅ ឃើញមានធ្យូងមួយដុំ ប៉ុនគ្រាប់សណ្តែក ក៏លេបធ្យូងនោះចូលទៅ, លោតបន្តិចទៅទៀត ឃើញឆ្អឹងត្រីស្លាតមួយតូចនៅកណ្តាលផ្លូវ លេបថែមទៅទៀត, លោតបន្តិចទៅ-ទៀត ឃើញគ្រាប់អង្ក្រែមអង្ក្រមមួយ ក៏លេបទៅទៀត, បានជា ៣ មុខ ល្មមតែពេញនោះ រួចក៏ត្រឡប់វិលមកចាំខ្លាខាងទីដដែលវិញ ។

ឯខ្លា កាលបើស្វែងរកសត្វបានសព្វគ្រប់ហើយ ក៏ត្រឡប់មកឯកន្លែងដើមតាមសន្យា, លុះមកដល់ ឃើញតឹង្កក់អង្គុយចាំ ច្រប៉ុកប៉ុក ក៏សួរថា " យើ ! បងមាំងការយេ បកដល់ហើយហះ " ។ តឹង្កក់តបថា " យើងមកចាំឯងយូរណាស់ហើយ, មើល៍ ! បងខ្លាឯងបានប៉ុន្មានមុខ ? បងឯងរើចេញមកមើល ! យើងនឹងកត់ត្រា " ។ ខ្លារើសសាច់នានាជាច្រើនមុខ ប្រាប់តឹង្កក់, រើសចេញអស់ ទើប-ប្រាប់ថា " អស់តែប៉ុណ្ណោះហើយ " ។ តឹង្កក់ តាំងរើចំណែករបស់ខ្លួនវិញឲ្យខ្លាមើលម្តង ។

ទី ១ រើបញ្ចេញធ្យូងមកមុន ។ ខ្លាសួរថា " សត្វអ្វីបង ! " ។ តឹង្កក់ថា : " ហ្នឹង គេហៅថា គាស រម៉ុយ " ខ្លាស្តាប់មិនបានអង្វរថា កុំនិយាយបាលីបាតូបង ! សូមប្រាប់ជាសម្រាយមកចុះ ។ តឹង្កក់ប្រាប់ថា " នេះកុយរ-មាស " ។ ខ្លាក៏កោតថា " យើ ! ខាំដល់ទៅរមាសផង " ។

ទី ២ រើឆ្អឹងត្រីស្លាតចេញមកទៀត ។ ខ្លា សួរថា " សត្វអ្វីសស្គុះដូច្នេះ

បង ? " ។ គីង្គក់ប្រាប់ថា " ផ្ដំរីស៊ុក " ។ ខ្លាថា " អាណិតទៅ កុំនិយាយបាលីបាតូអ្វី " ។ គីង្គក់ថា " ហ្នឹងគេហៅភ្លុកដំរីស " ។ ខ្លារឹតតែកោតថា " អៃយ៉ា ! លេងដល់ភ្លុកដំរីសទៀតផង, ចុះអស់ប៉ុណ្ណឹងហើយឬនៅទៀតបង ?" ។ គីង្គក់ថា « យើ ! អស់ប៉ុណ្ណឹងអ្នកម៉ែ ! នៅច្រើនមុខណាស់ បងឯងចាំតែរាប់ចុះ » ។

ទី ៣ រើទម្លាក់គ្រាប់អង្គ្រែមអង្គ្រែមចេញមក ។ ខ្លាសួរថា « សត្វអ្វីក្រហមផង ខ្មៅផងដូច្នេះ ? » ។ គីង្គក់តបថា « ផ្ការាអាឃ្មែក » ។ ខ្លាថា " សុំនិយាយជាសម្រាយទៅវិញមើល ! " គីង្គក់តបថា " ហ្នឹងហើយ គេហៅថា " ភ្នែកអាខ្លាឯង " ។

ខ្លាឮថា ភ្នែករបស់ខ្លួន ក៏ស្ទុះរត់ភ្លាម មិនហ៊ាននៅ ។ គីង្គក់ស្រែកថា " ឈប់សិន ឯងទៅណា ចាំអញយកភ្នែកឯងស៊ីសិន " ។ ខ្លារឹតភ័យខ្លាំងឡើងទៀត ចេះតែរត់ទៅ ។ គីង្គក់ ខំដេញតាមពីក្រោយ, លុះឆ្ងាយបន្តិចទៅ ស្រាប់តែប្រទះនឹងអណ្ដើក ។ សួរថា " បងមាំងកាយេ រត់ទៅណា ? " គីង្គក់ថា " បងជាប៉ុរិល ! ខ្ញុំដេញតាមខ្លារត់ទៅមិញ ។ បងប្រទះដែរឬ ? " ។ អណ្ដើក ថា " ឃើញវារត់ទៅហើយ បើដូច្នេះ ខ្ញុំជួយតាម " ។ គីង្គក់ និង អណ្ដើក ក៏នាំគ្នាតាម, ដើរបន្តិចទៅ ឃើញខ្លាសម្ងំពួនលើគុម្ពឫស្សី ។

អណ្ដើក ឃើញ ស្រែកប្រាប់ទៅគីង្គក់ ថា " វានៅ ។ នេះទេ " ។ គីង្គក់ថា " បងឯង ចាំនៅត្រង់ទីនេះចុះ ខ្ញុំនឹងឡើងទៅចាប់វា " ។ គីង្គក់ខំឡើងតាមវល្លិ៍ និង មែកឈើទៅបានពាក់កណ្ដាលគុម្ពឫស្សី ស្រាប់តែរបូតដៃធ្លាក់មកដីឮស្នូរប្រោក ។ អណ្ដើក ថា « អើបង ? » ។ គីង្គក់ថា «ខ្ញុំចុះមកប៉ោចវល្លិ៍យកទៅចងវាតែម្ដង » ។ ខ្លា ឮដូច្នោះស្ទុះលោតចុះ រត់ទៅទៀត ទៅឃើញដើមឈើមួយដើមធំ ក៏គ្រេកអរខំឡើងទៅនៅសម្ងំ មិនឲ្យសត្វទាំងពីរដឹង ។ ឯគីង្គក់

និង អណ្តើក ខំតាមដានទៅ បាត់ដានត្រង់ដើមឈើនោះ មើលលើ ឃើញឯខ្លា ពួនក្រាបនៅលើមែកឈើគ្រមាម ។ ទើបស្រែកប្រាប់គ្នា ថា «កនយើង ! វានៅ។ នេះទេ » ។ គីង្គក់ប្រាប់ថា « បងជាបរិលឯង ចាំនៅគល់នេះចុះ ខ្ញុំនឹង ឡើងទៅចាប់វាឯលើ » ។ គីង្គក់ ខំប្រវេប្រវាឡើងទៅជិតប្រគាបមែកឈើ ស្រាប់ តែសម្បកឈើ របេះធ្លាក់ចុះមក ដោយទាំងខ្លួនរាមកដល់ដី ។ អណ្តើកឃើញ សួរ-ថា « ម្តេចដូច្នេះ ? » ។ គីង្គក់ ថា « យើងគិតរំលំឈើនេះវិញ ឲ្យដួលមក នឹងចាប់ » ។ អណ្តើកបោលទង្គិចគល់ឈើនោះ ឮសូរប៉ូក ។ រួចគីង្គក់ ធ្វើ បញ្ចេញសម្លេងឮតែ ក្រុក ។ ហើយស្រែកបន្ថែរទៀត ថា « ហ៎ ! រលំឈើ ហើយ » ។ ខ្លា ឮថា វារលំ ទទួលក្រឡេកមើលទៅលើ ឃើញពពក រសាត់លឿនស្មោស្មានថា រលំមែន ក៏ស្ទុះរត់ចុះទៅទៀត ។ សត្វទាំងពីរ ចេះ តែដេញតាមទៅ ។

ឯខ្លា រត់កាន់តែឆ្ងាយ បានប្រទះនឹងតាចាស់ម្នាក់ ធ្វើជាងដែកខ្លាចូលទៅ សំពះតាចាស់នោះថា «សូមឲ្យជួយយកអាយុខ្ញុំផង ត្បិតគីង្គក់និងអណ្តើក វាដេញ ចាប់ខ្ញុំនឹងប្រហារជីវិត » ។ តាចាស់តបទៅនឹងខ្លាថា « នៅចុះ សឹមអញជួយ ឯងឲ្យរួចពីស្លាប់ កុំឲ្យអាគីង្គក់អណ្តើកធ្វើអ្វីបាន » ។ យូរបន្តិចឃើញអណ្តើក ទៅដល់មុន ។ ខ្លាប្រាប់តាចាស់ថា " អញហ្នឹ៎ មកទៀតហើយតា " ។ តាចាស់ថា " មិនអីទេ បើខ្លាចណាស់ត្រូវខំសប់ខ្លាំង ៗ ទៅ " ។ ខ្លារឹតតែសប់ខ្លាំងឡើង ៗ ។ តាចាស់ចាប់អណ្តើកនោះបាន យកទ្រាប់គូថអង្គុយ ហើយថា " ជាហើយ ចាំតែ ធ្វើដែករួចសឹមស្ងោរ " ។ បន្តិចឃើញគីង្គក់ទៅដល់ទៀត ខ្លាថា " អាហ្នឹង ហើយ វាប្រាថ្នាតែភ្នែកខ្ញុំទេ " ។ តាចាស់ប្រាប់ថា " បើឯងខ្លាចណាស់ ត្រូវយកខ្សែចងស្នប់ផ្ទាប់នឹងចង្កេះទៅ ។ ខ្លាធ្វើតាម ។ ឯតាចាស់នោះ គាត់ ស្លៀកខោជើងធំ ៗ ពេក អង្គុយលើអណ្តើក កំពុងតែពីតរួសកោសកាំបិត ភ្លេចគិតវា

ប្រដាប់របស់ខ្លួនខាងក្រោម ធ្លាក់ស្តោកនៅកណ្តាលវាល ។ គីង្គក់ក្រឡេកឃើញ ប្រាប់ទៅអណ្តើក ថា " បងជាបុរិលឯង មើលខាងក្រោម ។ អណ្តើកក្រឡេក ទៅ ឃើញប្រដាប់តាចាស់នោះទាំងអស់ ក៏មានចិត្តអរព្រួច ហើយអើតក្បាល ចូលទៅក្នុងជើងខោ ខាំគ្រិប ដោយចង្កូម ដាច់ត្រឹមគល់ទៅទាំងអស់ ។ តា ចាស់ដួលបះជើងប្រោង ។ គីង្គក់ក៏ស្រែកថា « ទៅ ! កនយើង ដួលមួយ ហើយ »។ ខ្លាឃើញតាចាស់ដួល ក៏ស្ទុះរត់ទៅ ដោយទាំងស្អប់នោះទៅផង ។ គីង្គក់ដេញតាមទៅដល់ជិតមាត់ស្ទឹងមួយ មានទឹកជ្រៅ គីង្គក់ស្រែកឲ្យអណ្តើកថា « បងប្រយ័ត្ន ! ខំស្ទាក់កុំឲ្យវាលោតទឹក ក្រែងបាត់ដាន » ។ ខ្លាញ ក៏លោត ទៅក្នុងទឹក ។ ចូលក្នុងស្អប់, ទឹកហូរខ្លាំង ក៏នាំខ្លាលិចស្លាប់ទៅ ។

**ផ្ចាញ់កម្លាំងកាយ ដោយកម្លាំងប្រាជ្ញា**
**ផ្ចាញ់មនុស្សក្លៀវក្លា ដោយការអង់អាច**

# ២១– រឿង ខ្លា ស្វា និង ទន្សាយ(១)

មានសត្វខ្លាមួយ វាផាច់សង្វែង ដើររកចាប់អ្វីមិនបានសោះ ខំដើរស្វែងណាស់ ៗ ទៅ ប្រទះនឹងសត្វអកមួយ កំពុងតែយំឮស្វរអកអ្វ ៗ ទំលើដើមព្រឹក្សាមួយនៅមាត់ត្រពាំង ។ ខ្លាក្រឡេកមើលទៅឃើញគិតក្នុងចិត្តថា " ធ្វើម្តេចនឹងចាប់អានេះបានហ្ន៎! បើវានៅខ្ពស់ម៉្លេះ ? បើអញឡើងទៅ មុខជាវាឃើញ ហើយហើរទៅ កាលណានឹងចាប់វាបាន ? " ។ ខ្លា អង្គុយចាំមើលកិច្ចកលសត្វអកនោះ ។ ឯសត្វអកនោះ កាលណាទំហើយ ភ្នែកវាតែងរំពៃមើលទៅបង្អែត្រីប្រែងបាចត្រីបន្ទៀកខ្លួនឡើង នឹងចាប់ ។ យូរបន្តិច មានត្រីមួយផុសឡើងពីក្នុងទឹក, អកស្ទុះទៅចាប់បានត្រីនោះ យកមកធ្វើជាចំណីវាទៅ ។

ខ្លា ឃើញអកធ្វើដូច្នោះ ក៏គិតក្នុងចិត្តថា " ឃើ ! អាអកនេះវាអង្គុយតែស្ងៀមសោះ ស្រាប់តែមានត្រីហែលក្នុងត្រពាំងនោះ វាស្ទុះទៅចាប់បានមួយរំពេចយកមកក្រអែះ មិននឿយហត់ប៉ុន្មានសោះ មិនព្រួយដូចជាខ្លួនអញ ខំដើរស្វែងរកស្ទើរស្លាប់មិនងាយបាន, អានេះអង្គុយធ្វើច្រងុក ៗ ចាប់បានភ្លាម ៗ ហើយវាមិនលំបាកលបលំបាកឱន ក្រាបទៀតផង, បើដូច្នេះ អញគិតធ្វើដូចសត្វអកនេះវិញ ស្រួលជាង" ។

ខ្លា គិតដូច្នោះហើយ ក៏ដើរទៅទៀត ដើម្បីស្វែងរកបឹង ឬត្រពាំងជាទីស្ងាត់ហើយដែលមានត្រីច្រើននោះ ។ វាដើរទៅដល់បឹងមួយ ជាទីស្ងាត់; នៅមាត់បឹងនោះ បានដើមឈើធំ ៗ ដុះច្រូងច្រាង ដ៏មានមែកត្រឈៃល្មមវាពឹងពួនខ្លួនវាបាន ។

---

១ កម្ពុជសុរិយាលេខ ៤-៥-៦ ឆ្នាំ ១៩៣៣-៤ ទំព័រ ២០១ រៀបរៀង ដោយព្រះមេត្រីគេដោ សុគតោ ក្រុមការដើមខ្សែលេខ ២ ។

ពេលនោះ មានបុរសម្នាក់នៅចងសន្ទូចក្នុងបឹងនោះ មុនខ្លាទៅដល់ ។ ដោយចង់មើលទៅឲ្យឃើញសន្ទូចខ្លួន ដែលរាយនៅឯនាយឆ្ងាយ បានស្រួល បុរសនោះវាយសន្ទូចហើយ មិនឈរនៅនឹងដីទេ ទៅឡើងលើដើមព្រឹក្សាមួយធំខ្ពស់ នៅសម្ងំតែម្នាក់ឯង មិនមាត់កឡើយ ។ ឯខ្លានោះ កាលបានទៅដល់ហើយ ក៏ដើរផ្ទួកចុះផ្ទួកឡើង រកដើមឈើនឹងឡើង ធ្វើដូចជាសត្វអក ។ បុរសឮសូរ មើលទៅឃើញខ្លាកំពុងតែដើរ រួចទៅឡើងអង្គុយជ្រហម ។ លើចុងឈើ ហើយធ្វើសំឡេងត្រាប់តាមសត្វអក ថា « អកអូរ ។ » គាត់មិនហ៊ានមាត់ថាអ្វីទេ ចាំតែមើលហើយគិត ថា « ខ្លានេះ វាឡើងចុងឈើនៅក្នុងបឹងដូច្នេះ តើវាគិតធ្វើអ្វីអេះ ? » ។ យូរបន្តិច មានត្រីងើបឡើង ស្រាប់តែខ្លានោះ ស្ទុះលោតប្រូង រួចផុសឡើងវិញឈ្លក់ទឹកឮសូរខក់ ។ ។ បុរសនោះ ឃើញហើយ សើច រួចស្រែកថា « ស្លាប់ទៅ! អាខ្មោច ធ្វើអ្វីដូច្នោះ » ។ ខ្លាឮ មើលទៅឃើញបុរសនៅលើចុងឈើ ក៏មានសេចក្តីអៀនខ្មាសខ្លាំងណាស់ ស្ទើរនឹងស្លាប់ខ្លួន ព្រោះមិនដែលបង់គំនិតដល់ម្ល៉ឹងសោះ រួចខ្លានឹកថា « ឥឡូវ បុរសនេះ ឃើញអញតែម្នាក់ឯង បើគាត់ទៅដល់ផ្ទះសមគាត់នឹងនិយាយប្រាប់គេថែមទៀត គេនឹងកាន់តែដឹងច្រើនឡើងកើតមានកេរ្តិ៍ឈ្មោះអាក្រក់ណាស់ បើដូច្នោះ អញសូកគាត់ កុំនិយាយប្រាប់នរណាគេទៅទៀតឡើយ »។ ខ្លាបាននិយាយអង្វរបុរសនោះ ជាពាក្យទនលំទោនថា « ឱ! អ្នកអើយ ! ខ្ញុំបានជាចាប់ត្រីធ្វើដូចជាសត្វអកទៅ វាមិនបានឯត្រី ទៅបានឯលង់ទឹក ស្ទើរនឹងស្លាប់ ខ្ញុំមានសេចក្តីខ្មាសអៀនច្រើនណាស់ បើដូច្នេះ សុំអ្នកអាណិតខ្ញុំ កុំនិយាយទៅណាមកណាទៅទៀត ខ្ញុំនឹងតបគុណឧបការៈអ្នក » ។ បុរសតបវិញថា " ខ្លាឯងឲ្យអ្វីអញ " ។ ខ្លាថា " ខ្ញុំសន្យារកសត្វ មួយព្រឹកមួយ ។ យកមកជូនអ្នក នៅទីនេះរាល់តែថ្ងៃ " ។ បុរសនោះ ក៏ព្រមព្រៀងទទួលពាក្យខ្លា រួចហើយវិលទៅផ្ទះអាត្មាវិញ; លុះព្រឹកឡើង មកទទួលយកសត្វអំពីខ្លា នៅកន្លែងសន្យា ។ ខ្លាក៏ខំរកសត្វ

យកមកឲ្យបុរសនោះ ជាប្រក្រតី មិនហ៊ានខាន ។ កាលបើបុរសនោះបានសត្វនាំយកទៅផ្ទះអាត្មា ច្រើនថ្ងៃពេកណាស់ នាងភរិយាឆ្ងល់ លុះវេលាយប់ ក៏សួរដោយស្ងាត់ ថា « អ្នកឯង ធ្វើដូចម្ដេច ក៏បានសត្វរាល់ថ្ងៃម៉្លេះ ? ម្ដងសត្វនេះម្ដងសត្វនោះ ជ្រូកក៏មាន ក្ដាន់ក៏មាន ល្មួសក៏មាន » ។ ប្ដីថា “ អញដាក់អន្ទាក់ ” ។ ប្រពន្ធថា “ អន្ទាក់អ្វីក៏បាន មិនដែលខានដូច្នេះ ? អ្នកអើយ ! ប្អូនឲ្យត្រង់ទៅបើបេ ” ។ បុរសនោះ ក៏ភ្លេចពាក្យសន្យា ដោយស្មានថា ខ្លាកាលណាវានឹងមក ក៏ប្រាប់ប្រពន្ធ តាមរឿងហេតុ ពីដើមដល់ចុង ។ ប្រពន្ធនោះក៏ជឿ ។ លុះព្រឹកឡើង បុរស ទៅយកសត្វអំពីខ្លាដូចសព្វដង លុះទៅដល់ ស្រាប់តែឃើញខ្លាអង្គុយព្រហម ៗ ចាំនៅកន្លែងនោះ ។ លុះបុរស ដើរទៅដល់ ខ្លាប្រាប់ថា « អើ ! បុរសឯងមកហើយ អញនៅចាំទេតើ ! អញនឹងស៊ីឯង ត្បិតកាលនិយាយគ្នាមុននោះ អញហាមថា កុំឲ្យនិយាយប្រាប់គេតទៅទៀត អញសូកឲ្យសត្វមួយ ៗ រាល់តែថ្ងៃ, ឥឡូវ ម្ដេចក៏និយាយប្រាប់គេ ? » ។

បុរសនោះ ក៏ភ័យភ្ញាក់ស្លោ ឥតប្រកែកថាអ្វីទេ គ្រាន់តែអង្វរទៅខ្លាវិញថា “ បងខ្លាឯង ស៊ីក៏ស៊ីចុះ ខ្ញុំមិនប្រកែកទេ បានជានិយាយទៅហើយ តែបើម៉្វើនឹងស្លាប់រស់ ខ្ញុំសូមទៅជួបប្រពន្ធសិន នឹងបានប្រាប់ឲ្យគេដឹងផង ” ។ ខ្លាក៏ព្រម ថា “ អើ ទៅក៏ទៅចុះ តែឲ្យឆាប់ត្រឡប់មកវិញ អញស្ដោះទឹកមាត់ចាំ តែស្ងួតទឹកមាត់អញតាមទៅស៊ីទាំងប្ដីទាំងប្រពន្ធ, ទុកធ្វើអី មនុស្សនិយាយមិនទៀង ” ។ បុរសនោះ ក៏នៅទាំងសោកសៅក្នុងចិត្ត ព្រោះតែមាត់មិនជិត បានជាខ្លាវាស៊ី, ទៅដល់ក៏ប្រាប់ប្រពន្ធ តាមរឿងហេតុនោះ ហើយថា “ ឥឡូវ នៅមិនបានទេ ត្បិតខ្លាវាចាំតែយូរ វានឹងមកស៊ីទាំងអស់គ្នា ” ។ ប្រពន្ធក៏យំសោកស្រណោះគ្នាទៅវិញទៅមកស្ដាយគំនិត ។ ប្ដីក៏លាភរិយាចេញចាកគ្រឹះស្ថាន ដើរមកតាមផ្លូវ យំចណ្ដើរផង,

ដល់ពាក់កណ្ដាលផ្លូវ ប្រទះនឹងទន្សាយ ។ សួរថា « បុរសឯង ដើរទៅណា យំផង ដូច្នេះ មានទោសទុក្ខដូចម្ដេច ? ។ បុរសនោះ ថ្លែងឲ្យទន្សាយស្ដាប់ សព្វគ្រប់ ប្រការតាមហេតុនោះ ។ ទន្សាយឆ្លើយថា " ឱ ! បើដូច្នោះ ភ័យអ្វី បុរសឯងទៅ រកតែចេក ១ ស្និតមក ទៅខ្លាចអ្វី អាខ្លាកំព្រើលនោះ " ។ បុរសនោះ ត្រេកអរ ក៏ម្នីម្នារត់ទៅរកបានចេកមួយស្និត ហើយជូនទៅលោកសុភទន្សាយថា « ខ្ញុំជូន លោក ! សុំឲ្យតែលោកសុភា ជួយខ្ញុំឲ្យរស់ជីវិតផងចុះ តែបន្ដិច ខ្លាវាតាមមកស៊ីខ្ញុំ ហើយ » ។ សុភាទន្សាយ ថា « អើ ! អ្នកឯងទៅជាមួយនឹងយើង ចាំមើលខ្លា នោះឲ្យជាក់ » រួចសុភាទន្សាយ រកដំបូកមួយយ៉ាងខ្ពស់ ឡើងទៅអង្គុយលើដំបូក នោះ ដើម្បីមើលទៅឲ្យបានឆ្ងាយ ។

ឯខ្លា កាលចាំបុរសនោះយូរពេក ក៏តាមមក ប្រាថ្នានឹងខាំស៊ីទាំងពីរនាក់ ព្រោះ ខុសសន្យាគ្នាពីរលើកហើយ, វាដើរម្នាក់ឯងតាមផ្លូវ រលេះរលាំងបកដល់ទៀបដំបូក ។ បុរសនោះឃើញ ក៏ប្ដឹងសុភាទន្សាយថា " ហ្ន៎ ! មកហើយលោក " ។ សុភា ទន្សាយ ប្រាប់ថា « កុំមាត់ ! ចាំវាមកជិតសិន » ។ ខ្លាដើរបកកាត់តែជិត សុភាទន្សាយ ពមចេកមួយក្នុងមាត់ ហើយស្រែកគ្រហែមឡើងថា « អើម ។ ស៊ីខ្លា ៥ មិនស្កាំផ្ទៃ ស៊ីគ្រប់ខាប៉ុនកូនដៃ ស្អុះ-កស្អើរបែក អើម ។ » ។ ខ្លាឮសម្លេងតំ ក្រអួនថា « ស៊ីខ្លា ៥ មិនស្កាំផ្ទៃ » ក៏ស្ទុះថយក្រោក ។ សុភាទន្សាយគ្រហែមថែប ម្ដងហើយម្ដងទៀត យ៉ាងផ្ទួន ៗ ។ ខ្លា ស្ទុះរត់លែងទាំងមើលក្រោយ រត់ឆ្ងាយទៅ ប្រទះស្វាមួយនៅលើចុងឈើ ស្វាឃើញខ្លារត់ ស្រែកសួរថា " បងខ្លា រត់មានការណ៍ អ្វី ? " ។ ខ្លាឮហើយឈប់ ឆ្លើយតបទៅវិញ « ទេ ! ទេ ! វុំអើយ ! អាណា ក៏ធំម្ល៉េះ ស៊ីខ្លាដល់ទៅ ៥ មិនឆ្អែត បានជាអញភ័យ រត់មក ក្រែងវាស៊ី » ។ ស្វា សួរថា « បងឯងឃើញដែរឬអ្វី ? » ។ ខ្លាថា « ទេ ! ឮតែមាត់ » ។ ស្វា-សួរថា " មាត់ត្រង់ណា ? " ។ ខ្លាតបថា " នៅទៀតដំបូកឯដើមពង្រនោះណ៎ា " ។ ស្វាថា " ក្រែងបងសុភាទេដឹង ? ចំណាំតែឃើញនៅត្រង់ហ្នឹង " ។ ខ្លា តបថា

" មិនមែនទេ សម្ដីសុភាណាដូច្នោះ " ។ ស្វាថា " ទេ ! ប្រាកដជាសុភាហើយ, បើដូច្នោះ ទៅម្ដងទៀតមើល ខ្ញុំជូនទៅ " ។ ខ្លាមិនព្រមទៅ ថា " ក្រែងបងស្វាឯងរត់ចោលអញ តែឯងភ័យរត់ឡើងចុងឈើទៅ, នៅតែអញម្នាក់ឯង ស្លាប់អញហើយ " ។ ស្វានិយាយម្ដងទៀតថា បើបងឯងខ្លាចខ្ញុំរត់ចោល យើងចងកន្ទុយភ្ជាប់គ្នា ខ្ញុំឡើងទៅចុងឈើឯណារួច បើបងជាប់នឹងខ្ញុំហើយ » ។ ខ្លាថា អើ ! បើដូច្នោះ ទៅក៏ទៅ កុំរត់ចោលគ្នាវុំ ! " ។ ខ្លា និងស្វា ចងកន្ទុយជាប់គ្នាហើយ ដើរតម្រង់ទៅដំបូកនោះ ។ បុរសនោះឃើញប្ដីងសុភាទន្សាយទៀតថា " លោកអើយ! មកទៀតហើយ ម្ដងនេះ មានស្វាមកផង ខ្ញុំខ្លាចណាស់លោក ! ,, ។ សុភាទន្សាយថា " កុំបារម្ភអ្វី ! នៅមាត់ឲ្យស្ងៀម ចាំវាមកជិតបន្តិច នឹងមើលវា " ។ សុភាទន្សាយ ក៏ប្រុងបកចេកមួយ នឹងពមឲ្យមាំ ។ ដល់មកជិត ស្វាសួរថា ត្រង់ណាបងខ្លា? ។ ខ្លាថា " ហ្នុំ ត្រង់ហ្នឹង, ហ្ន ! មាត់ស្រែកពីត្រង់នោះ " ។ សុភាទន្សាយពមចេកនៅក្នុងមាត់ ស្រែកថា " យើ អាស្វាក្រញាំ ជំពាក់បំណុលអញ ៤-៥ ឆ្នាំ ដឹកអាខ្លាសំគមមួយឲ្យអញ អ៊ែម ! មើលមារយាទអាស្វានេះ ! " ។ ខ្លាឮដូច្នោះ ក៏ស្ទុះរត់ភីងទៅ ស្វាយារ៉ពុំស្ដាប់ ហើយគិតក្នុងចិត្តថា " យើអាស្វានេះ វានាំអញមកផាត់បំណុលទេតើ ! " ។ ស្វាស្រែកថា " បងខ្លា ឈប់សិន ។ ខ្លាក៏មិនព្រម ដោយចូលចិត្តថា ច្បាស់ជាស្វាយកខ្លួនមកផាត់ឲ្យគេ " ហើយរត់ទៅឆ្ងាយ ទាល់តែស្វានោះរណ្ដំនឹងឈើ នឹងដី ស្លាប់ខ្លួនខ្ទេចអសារឥតការ ។

## មាត់មានគ្រប ឪមានឆ្នុក

# ២២ – រឿង អណ្តើក និង ស្វា(១)

មានរឿងនិទានមួយ ថា អណ្តើក និង ស្វា វាសុំធ្វើជន្លងគ្នា តែគ្មានកូនចៅទៅចងពន្ធអ្វីទេ គ្រាន់តែនិយាយថា សុំគ្នាធ្វើជន្លង ។ សត្វទាំងពីរ ស្រឡាញ់រាប់អានគ្នា ដូចជន្លងអ្នកទាំងពួងនោះដែរ ។ លុះចំណេរយូរទៅ ជន្លងខាងស្វានោះ គេមានកូនត្រូវរៀបការ គេហៅភ្ញៀវពួកស្វា សន្មតថ្ងៃនឹងស៊ីការ ទើបនឹកឃើញអណ្តើកជាជន្លងថា « យើងការកូននេះ ហៅភ្ញៀវអស់ហើយ នៅតែអណ្តើកជា-ជន្លង មិនទាន់បានទៅប្រាប់ ឥឡូវ ជិតថ្ងៃការណាស់ទៅហើយ បើដូច្នោះ ឲ្យបំរើ ទៅអញ្ជើញគាត់ផង បំណាច់យើងរាប់អានគ្នា យូរឆ្នាំណាស់មកហើយ » គិតហើយ ក៏ចាត់បំរើឲ្យទៅអញ្ជើញ ។ ថ្ងៃដែលគេប្រជុំញាតិស៊ីការនោះ អណ្តើកក៏ទៅដល់ដែរ តែនឹងឡើងទៅស៊ីផឹកនឹងគេ មិនរួច ។ ពួកស្វាបានឃើញ ក៏ទៅប្រាប់ជន្លងស្វាថា « ត្បិតជន្លងអណ្តើក មកដល់ហើយ នៅឯក្រោមដើមឈើ»។ ជន្លងស្វាចុះមក ឃើញអណ្តើកក៏ប្រាប់ថា ជន្លងឯង ឡើងមិនរួចនឹងគេ មានតែជន្លងឯងខាំវល្លិ៍នេះចុះ យើងនឹងស្រាវឡើង ប៉ុន្តែ បើមិនទាន់ដល់ទៅកន្លែង ដែលយើងអង្គុយទេ ជន្លងឯង កុំនិយាយឲ្យសោះ ទោះបីឃើញអ្វី ឬគេថាអ្វីក៏ដោយ, តែនិយាយ ធ្លាក់មកស្លាប់ហើយ ។ អណ្តើកទទួលបណ្តាំជន្លងនោះសព្វគ្រប់ហើយ ក៏ទទួលខាំវល្លិ៍ ។ ពួកស្វាទាំងប៉ុន្មាន ក៏ស្រាវវល្លិ៍នោះឡើង នាំអណ្តើកទៅឯថ្នាក់លើ។

---

១ រឿងជា អណ្តើក និង កំប្រុក ។ កម្ពុជសុរិយាលេខ ៧-៨-៩ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៥២ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

លុះទៅជិតដល់កន្ទែង ដែលគេនឹងដាក់នោះ ជួនជាជន្ទូងស្រីស្វា ឃើញអណ្តើក ក៏សួរដោយរាប់អានថា « ជន្ទូង ! សុខសប្បាយទេឬ ? » ។ អណ្តើក ភ្លេចពាក្យបណ្តាំ ហាមាត់ស្តីទៅនឹងជន្ទូង ក៏របូតមាត់ ធ្លាក់ខ្លួនដល់ដីបែកស្នូកដូចគេបោកនឹងថ្ម ស្លាប់នៅវេលានោះ ខានស៊ីការនោះទៅ ។

## មាត់អណ្តើក

## ២៣– រឿង ដង្កូវ និង ក្អែក(១)

មាននិទានមួយ ថា សត្វដង្កូវ កំពុងស៊ីស្លឹកឈើ មានសត្វក្អែកមួយហើររកចំណី ទៅប្រទះនឹងដង្កូវនោះ ។ ក្អែក ថា « ពេលនេះ មានលាភ បានដង្កូវស៊ី » ក៏ហើរទៅជិតដង្កូវ ។ ដង្កូវ ក្រឡេកឃើញក្អែកក៏ទឹកថា « ខ្ញុំអាក្អែកនេះ ចិត្តឃោឃៅ នឹងចឹកអញស៊ីឥឡូវហើយ» ។ ដង្កូវ សួរក្អែក ថា «បករកអ្វី ? » ។ ក្អែក ប្រាប់ទៅដង្កូវវិញ ថា « អញមកស៊ីដង្កូវឯង » ។ ដង្កូវ ថា « លុះតែក្អែកឯង រកប្រស្នាអញឃើញទើបស៊ីអញបាន, បើរកប្រស្នាអញមិនឃើញ ស៊ីអញមិនបានទេ » ។ ក្អែក សួរថា « ប្រស្នាដង្កូវឯង យ៉ាងដូចម្ដេចសួរមកចុះ អញនឹងរកឲ្យឃើញ » ។ ដង្កូវ សួរទៅក្អែក ដូចមានតទៅនេះ :

១– ដូចម្ដេច ដែលគេហៅថា ផ្អែមជាងគេបំផុត ?

២– ដូចម្ដេច ដែលគេហៅថា ជូរចត់ជាងគេបំផុត ?

៣– ដូចម្ដេច ដែលគេហៅថា ស្អុយជាងគេបំផុត ?

៤– ដូចម្ដេច ដែលគេហៅថា ក្រអូបជាងគេបំផុត ?

កាលបើក្អែក បានឮដង្កូវសួរប្រស្នាទាំង ៤ បទនេះហើយ មានសេចក្ដីត្រេកអរជាទីបំផុត ក៏ស្រែកហោកញ្ជៀវលេង ដោយគិតថា « ប្រស្នាដង្កូវទាំង ៤ បទនេះ អញមុខជារកឃើញឥឡូវហើយ នឹងបានស៊ីដង្កូវនេះ មិនខាន » ទើបក្អែក ឆ្លើយដោះស្រាយប្រស្នាដូចមានតទៅនេះ :

---

១ កម្ពុជសុរិយា លេខ ១-២ ឆ្នាំ ១៩៣៥ ទំព័រ ៦៣ គ្មានឈ្មោះអ្នករៀបរៀងទេ ។

១- ដែលគេហៅថា ផ្អែមនោះ គឺមានស្ករ និង ទឹកឃ្មុំ ផ្អែមជាងផ្អែមអ្វីទាំងពួង ។

២- ដែលគេហៅថា ជូរចត់នោះ គឺមានម្ទេះក្រូចឆ្មារ, អម្ពិល, ម្លូរសណ្ដាន់, ម្ទូរក្រសាំង, និង ទឹកខ្មេះ ។

៣- ដែលគេហៅថា ស្អុយជាងគេនោះ គឺអាចម៍ និង គម្រង់ខ្មោចសត្វ-ទាំងពួង ។

៤- ដែលគេហៅថា ក្រអូបជាងគេនោះ គឺ ផ្ការំដួល ផ្កាម្លិះ និង ទឹកអប់ ។

ក្អែក បានដោះស្រាយប្រស្នាទាំង ៤ បទនេះ ប្រាប់ទៅជង្គ្រួ ។ ជង្គ្រួ ថា « ក្អែក ដោះប្រស្នានេះ មិនត្រូវទេ » ។ ក្អែក ក៏ដាក់មុខស្រងូត និយាយទៅជង្គ្រួវិញ ថា « បើជង្គ្រួឯង ថាខុស សុំឲ្យជង្គ្រួ ប្រាប់ប្រស្នានេះមកអញឲ្យបានដឹងផង » ។ ជង្គ្រួ ប្រាប់ទៅក្អែកវិញថា « ប្រាប់បាន តែក្អែកឯងកុំស៊ីអញ ទើបអញប្រាប់ » ។ ក្អែក ថា « ឲ្យតែប្រាប់ចុះ អញមិនស៊ីជង្គ្រួឯងទេ » ។ លុះបានខសន្យាព្រមព្រៀងគ្នាយ៉ាងហ្នឹងហើយ, ជង្គ្រួ ក៏ដោះស្រាយប្រស្នាប្រាប់ទៅក្អែក ដូចមានពាក្យតទៅនេះ :

១- ដែលគេហៅថា ផ្អែមនោះ មិនមែនផ្អែមស្ករទឹកឃ្មុំនោះទេ គឺផ្អែមពាក្យសម្ដី ដែលនិយាយទៅមករកគ្នា ដោយពាក្យពិរោះស្មោះត្រង់រកគ្នា, នេះហើយហៅថា ផ្អែមជាទីបំផុត, ។

២- ដែលគេហៅថា ជូរចត់នោះ មិនមែនជូរចត់ អម្ពិល សណ្ដាន់ ក្រូចឆ្មារ ទឹកខ្មេះនោះទេ គឺពាក្យផរុសវាទ យោយោ ឥតគួរ ឥតសម ដែលនិយាយកាន់គ្នាទៅវិញទៅមក, នេះហើយ ហៅថា « ជូរចត់លើសជូរចត់អ្វីទាំងពួង ។

៣- ដែលគេហៅថា ស្អុយនោះ មិនមែនស្អុយអាចម៍ ឬ ស្អុយគម្រង់នោះទេ

គឺស្អុយកេរ្តិ៍ ស្អុយឈ្មោះ ដែលប្រព្រឹត្តអាក្រក់ក្នុងលោក. នេះហើយហៅថា « ស្អុយច្រាស់ខ្យល់ » ។

៤- ដែលគេហៅថា ក្រអូបនោះ គឺមិនមែនក្រអូបក្លិនផ្កាឬទឹកអប់នោះទេ គឺក្រអូបកេរ្តិ៍ឈ្មោះដែលប្រតិបត្តិល្អ, នេះហើយហៅថា " ក្រអូបជាងគ្រឿងក្រអូបទាំងពួង " ។

ក្អែកបានស្តាប់ប្រស្នាទាំងនេះហើយ ឈប់ស៊ីដង្កូវទៅ ។

## តូចមែនពិត ដូចពេជពណ្ណរាយ

# ២៤- រឿង បងថ្លៃ និង ប្អូនថ្លៃ

មានមនុស្សពីរនាក់ ជាបងថ្លៃប្អូនថ្លៃនឹងគ្នា, បងថ្លៃ ជាអ្នកក្រ ប្អូនថ្លៃ ជាអ្នកមានទ្រព្យសម្បត្តិ ។ ថ្ងៃមួយ ឪពុកក្មេក មានកិច្ចរវល់ត្រូវប្រាប់បងប្អូន កូនចៅឲ្យទៅស៊ីផឹកនៅផ្ទះគាត់, ប្អូនថ្លៃនោះ បានមកជួបនឹងបង បបួលទៅស៊ីឯផ្ទះឪពុកក្មេក, បងថ្លៃ និយាយប្រាប់តាមត្រង់ ថា « មិនហ៊ានទៅស៊ីទេ » ព្រោះខ្លួនជាអ្នកក្រ មិនធ្លាប់ស៊ីម្ហូបចំណីល្អ ក្រែងមិនត្រូវរបៀបទេ ខ្មាសគេ, ប្អូនថ្លៃនោះ ជាមនុស្សចិត្តសប្បុរសនឹងបង ក៏ប្រាប់ទៅវិញ ថា « មិនអីទេ ទៅពីរនាក់ចុះ បើមិនដឹង ឲ្យតែធ្វើតាមខ្ញុំ ៗ ស៊ីអី ស៊ីហ្នឹងទៅ មិនក្រប៉ុន្មានទេ បងទៅជាមួយនឹងខ្ញុំចុះ » ។ បង ក៏ព្រមទៅ, លុះទៅបរិភោគនៅទីនោះ បបួលគ្នាស៊ីបាយតាមធម្មតាទៅ, ដល់គេលើកសម្លខ្ទោមក ប្អូនក៏យកចង្កឹះចាប់មួយមកពម រួចជញ្ជក់អស់ ខ្ជាក់សំបកខ្ទោនោះដាក់នឹងកន្ទ្រង ហើយគេចោលសំបកនោះទៅ ។

ឯបងនោះ មិនដឹង ដោយមិនបានឃើញគេធ្វើដូច្នោះ ក៏ខំជញ្ជក់ហើយខំទំាំងទំពាសំបកខ្ទោនោះទាល់តែល្អិត ខំលេបទៅ ។ ប្អូនឃើញដូច្នេះ ក៏លែងស៊ីខ្ទោនោះទៅចាប់យកឯអំពៅ ដែលគេឡៀទុកនៅចាននោះ មកស៊ី ៗ រួច គេយកកន្ទ្រងខ្ជាប់ដាក់ ហើយចោលទៅទៀត ។ បងឃើញគេស៊ីអំពៅ ក៏យកអំពៅនោះ មកស៊ីនឹងគេទៀត ខំទំពាអំពៅទាល់តែល្អិតកាក លេបទៅទៀត, ប្អូនលែងស៊ីអំពៅ វាទៅស៊ីសម្លមីសួរទៀតទើបតែនឹងពបចូលក្នុងមាត់ នឹកឃើញបងស៊ីអំពៅ

ទាំងកាកនោះ ហើយអស់សំណើចទប់មិនឈ្នះ ក៏ចេញសំឡេងរេកញ្ចតែយឹក ។ ដោយហេតុខ្យល់ទប់យឹកនោះ មីស្លូវរាស្ទុះឡើងទៅចូលឯរន្ធច្រមុះទាំងពីរ ចេញមីស្លូវនោះមកក្រៅដោយអំណាចខ្យល់ ។ បងថ្លៃឃើញដូច្នោះ ក៏ចោលចង្កឹះទៅក្នុងថាស ថា « ទេ ! លែងស៊ីហើយ ស៊ីឯទៀត ធ្វើតាមបាន សូម្បីខ្ទាគិងអំពៅទាំងសំបក ទាំងកាក ក៏ស៊ីបានទាំងអស់ ដល់មីស្លូវ ខ្ទុះនឹងច្រមុះដូច្នេះ ធ្វើតាមមិនបានទេ ប្អូនឯងស៊ីតែឯងចុះ បងលែងស៊ីហើយ ស៊ីទៅទៀតមិនកើតទេ»។

## ពុតគ្រូគុំគ្រាប់ ច្បាប់គ្រូឱ្យយក

# ២៥- រឿង បុរសកុហក ៤ នាក់(១)

កាលពីព្រេងនាយ មានបុរសកុហក ៤ នាក់ មកជួបជុំគ្នា រួមគំនិត គិតដើរទៅរកឆបោកបញ្ឆោត យកទ្រព្យសម្បត្តិគេ នៅគេហដ្ឋាន ឆ្ងាយពីលំនៅរបស់ខ្លួន, ព្រមព្រៀងគ្នាស្រេចហើយ ក៏នាំគ្នាដើរទៅ, លុះទៅឃ្លាបន្តិច បានជួបប្រទះនឹងតាចាស់ដូនចាស់ពីរនាក់ ជាអ្នកធ្វើចម្ការកប្បាស នៅក្បែរមាត់ទន្លេមួយ ដាច់ឆ្ងាយពីស្រុកភូមិគេ ។ បុរសកុហក ៤ នាក់នោះ បានដឹងដំណឹង ថា តាចាស់ដូនចាស់ ជាអ្នកបានទ្រព្យសម្បត្តិច្រើនគ្រាន់បើ ក៏គិតគ្នា ថា « យើងត្រូវនាំគ្នាឈប់ទៅទីនេះ ដើម្បីភូតកុហក យកទ្រព្យសម្បត្តិតាចាស់ដូនចាស់នេះឲ្យបាន » បុរស ៤ នាក់នោះ ទៅដល់សួរតាចាស់ដូនចាស់ថា“ ឱ ! តាយាយអើយ ! យើងខ្ញុំទាំង ៤ នាក់នោះ មកពីស្រុកឆ្ងាយណាស់ ខំត្រាច់ដើររកអ្នកឯណា ដែលចេះដឹង ព្រោះយើងខ្ញុំ ចង់ដឹងរឿងព្រេងពីបុរាណនាយបក, តែវេលានេះ បានមកជួបនឹងតាយាយ ។ ប្រហែលជាចេះដឹងរឿងបុរាណមកខ្លះមិនខាន បើដូច្នេះ សូមតាយាយមេត្តានិទានរឿងព្រេងអ្វីមួយ ឲ្យចៅស្តាប់បន្តិច » ។ តាចាស់ដូនចាស់ ក៏ឆ្លើយតបទៅបុរសទាំង ៤ នាក់វិញ ថា « ចៅអើយ ចៅ ! តាំងពីក្មេងដល់ចំណាស់ប៉ុណ្ណេះហើយ តាយាយ គ្មានចេះរឿងព្រេងអ្វីទេ សូមចៅអញ្ជើញទៅរកសួរអ្នកឯទៀតចុះ » ។ បុរសទាំង ៤ នាក់ ក៏ជម្រាបទៅតា–

---

១- កម្ពុជសុរិយា លេខ ៧-៨-៩ ឆ្នាំ ១៩៣៧ ទំព័រ ១២២ គ្មានឈ្មោះអ្នករៀបរៀងទេ ។

យាយវិញ ថា « ឱ ! តាយាយអើយ ! បើប្រសិនជាមានគេចេះរៀងព្រេងនោះ តាយាយ ចង់ស្តាប់ឬទេ ? » ។ « ឱ ! ចៅអើយ ! តាយាយ ចង់ស្តាប់ណាស់ តែរករអ្នកណាចេះគ្មាន» ។ បុរសទាំង ៤ នាក់ ក៏ជម្រាបទៅតាយាយវិញ ដោយកិច្ចកល បំងនឹងបោកយកទ្រព្យសម្បត្តិតាចាស់ជូនចាស់នោះ ឲ្យបានដោយងាយ ថា « យើងខ្ញុំទាំង ៤ នាក់នេះ ចេះខ្លះដែរ ព្រោះបានដឹងពីជីតាខ្ញុំ គាត់និទានប្រាប់, តែរឿងនេះ បើនិយាយទៅកាលណា តាយាយ ត្រូវតែជឿ ទើបខ្ញុំនិទានប្រាប់បាន » ។ តាយាយ ក៏ព្រមព្រៀងឲ្យបុរសទាំង ៤ នាក់នោះនិយាយ ។

បុរសទី ១ ចាប់អធិប្បាយរឿងកុហកជាដំបូងឡើងថា : កាលខ្ញុំនៅក្នុងផ្ទៃម្តាយខ្ញុំបានចំនួន ៣ ខែ ម្តាយខ្ញុំ គាត់ចង់ពិសាផ្លែទុរេននៅមុខផ្ទះខ្ញុំ ដើមវា មានកំ-ពស់ប្រហែល ៨ ព្យាម ហើយមានផ្លែតែមួយផង គាត់មិនដឹងជាគិតដូចម្តេច នឹងបានផ្លែឈើនោះមកពិសា ។ លុះខ្ញុំបានដឹងថា គាត់ចង់ពិសាផ្លែនោះ ខ្ញុំក៏ចេញពីផ្ទៃគាត់ តាមទ្វារបាស ទៅឡើងបេះទុរេននោះ យកមកជូនគាត់ពិសា, រួចស្រេច ខ្ញុំត្រឡប់ចូលទៅក្នុងផ្ទៃគាត់វិញ ។

បុរសទី ២ ថា: កាលខ្ញុំនៅក្នុងផ្ទៃម្តាយខ្ញុំ បានចំនួន ៦ ខែ ឃើញគាត់នឿយហត់លំបាកនឹងធ្វើស្រែ ចម្ការ ច្បារដំណាំពេក ខ្ញុំចេញពីផ្ទៃគាត់មក នៅធ្វើស្រែចម្ការ ឃ្វាលគោ ក្របី ដណ្តាំបាយ ដងទឹក ជំនួសគាត់ ពីព្រឹកព្រហាម លុះល្ងាច, អស់ការធ្វើ ខ្ញុំចូលទៅក្នុងផ្ទៃម្តាយខ្ញុំវិញ ជារៀងរាបដរាបមក ។

បុរសទី ៣ ថា "ឱ! តាយាយអើយ ខ្លួនខ្ញុំនេះ ជាទេវបុត្រ ច្បុតចុះមកចាប់បដិសន្ធិនឹងម្តាយខ្ញុំសព្វថ្ងៃនេះ ខ្ញុំចេញពីទ្វារបាសវេលាណា បានមកបនៅម្រើគាត់ សព្វសារពើ, ដល់ខ្ញុំចាស់ទៀបនឹងស្លាប់ ខ្ញុំសុំចូលទៅក្នុងផ្ទៃម្តាយខ្ញុំវិញ ដើម្បីកុំឲ្យស្លាប់ទាន់ហើយកើតម្តងទៀតឲ្យបានជាក្មេងឡើងវិញ ។

បុរសទី ៤ ថា : ខ្លួនខ្ញុំនេះ ចាប់តាំងតែចេញពីផ្ទៃម្តាយកាលណាមក ខ្ញុំរក្សា

សីល ៥ ចាំសីល ៨ តែសីលខ្ញុំ ប្លែកពីសីលអ្នកទាំងពួងចង់ផឹកស្រា ជក់អាភៀន សម្លាប់ជីវិតគេ ក៏បាន, លុះដល់ខ្ញុំស្លាប់ទៅ ៗ កើតជាទេវតា សោយរាជសម្បត្តិនៅឋានសួគ៌ ។

បុរសទាំង ៤ នាក់នោះ និយាយភូតកុហកគ្រប់គ្នាហើយ ក៏សួរទៅតាចាស់ដូនចាស់ ថា « រឿងខ្ញុំនិទានជំរាបទាំងប៉ុន្មាននេះ តើតាយាយជឿឬទេ ? » ។ តាយាយ ឆ្លើយតបទៅវិញ ថា « រឿងនោះ តាយាយ ជឿហើយចៅ ! » តែក្នុងគំនិតគាត់ទាំង ២ នាក់ គិតឃើញជាស្រេចថា « បុរសទាំងនេះ សុទ្ធតែនិយាយកុហកទាំងអស់ » ។

ដល់បុរសទាំង ៤ នាក់នោះ ទាល់ប្រាជ្ញា ក៏ឲ្យតានោះ និយាយរឿងប្រាប់ម្តងវិញ, ប៉ុន្តែ មុននឹងនិយាយរឿង តាចាស់នោះ គាត់បានសន្យាដូចបុរសទាំង ៤ នាក់នោះដែរ; លុះព្រមព្រៀងទាំងអស់គ្នាទើបតាចាស់និយាយ ។

តាថា « ឱ ! ចៅអើយ ! កាលតានិងយាយ មកធ្វើចម្ការកប្បាសនេះបាន ៥-៦ ឆ្នាំ មានទ្រព្យសម្បត្តិ ប្រាក់ មាស ល្មមនឹងចិញ្ចឹមចៅទាំង ៤ នាក់នេះបាន; តែនៅឆ្នាំមួយមុននោះ កប្បាសមិនផ្លែសោះ មិនដឹងជារឿងហេតុអ្វី, មានមួយថ្ងៃ តាដើររុកក្នុងចម្ការទៅ ឃើញដើមកប្បាស ១ ដើម ទំហំប៉ុនដើមត្នោត មានផ្លែមួយធំ គាត់ឡើងបេះយកមកផ្ទះ, ដល់តានិងយាយនាំគ្នាបកមើល ឃើញមានគ្រាប់ ៤ ក្នុងមួយគ្រាប់ ៗ មានកុមារម្នាក់ ៗ គ្រប់គ្រាប់ទាំង ៤, តាបានឲ្យយាយគាត់បំបៅបីបាច់រក្សា, លុះដល់កុមារទាំង ៤ នាក់នោះ ធំវេលាណាឡើង ក៏នាំគ្នារត់ចោលតានិងយាយទាំងអស់ទៅ, ឥឡូវ តាឃើញចៅទាំង ៤ នាក់នេះត្រឡប់មកវិញហើយ ។

បុរសទាំង ៤ នាក់ ភិតភ័យខ្លាំង ក៏នាំគ្នាឆ្លើយប្រកែកទៅនឹងតាចាស់ដូនចាស់វិញ ថា « មិនមែនទេ » ។ តាយាយសួរទៅវិញ ថា " ហេតុអ្វី ក៏ចៅថា មិនមែន, បើចៅ ចេះតែប្រកែកយ៉ាងនេះ នុះឃើញថា ទាស់ខុសនឹងកិច្ចសន្យាហើយ, បើដូច្នេះ ត្រូវចៅទាំង ៤ នាក់ មកនៅបម្រើតា ទើបត្រូវនឹងពាក្យសន្យា " ។ បុរសកុហក ៤ នាក់ គេចមិនរួច ក៏នៅបម្រើតាយាយទៅ។

**ពាក្យច្រើនតួត ចាញ់អាត្មា**

## ២៦– រឿង បុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍(១)

មានរឿងព្រេងមួយ ដំណាលថា៖ មានបុរសកំជិលម្នាក់ មានប្រពន្ធគ្រប់លក្ខណ៍ មានកិរិយាមារយាទល្អ ចេះគោរពប្រណិប័តន៍ប្ដី ។ តាំងពីបានគ្នាជាប្ដីប្រពន្ធមក, បុរសកំជិល ចេះតែពីដេក ដល់ឃ្លានបាយ ទើបក្រោកឡើងស៊ី ។ រួចដេកទៅវិញ ស្វម្បីថ្នាំជក់ ក៏ប្រពន្ធមូរឲ្យដែរ ។ ប្រពន្ធ ជាមនុស្សគោរពប្រណិប័តន៍ប្ដី មិនមានពាក្យអាក្រក់ ទៅលើប្ដីសោះ លើកបាយទឹកនិងរបស់អ្វីឲ្យប្ដី សុទ្ធតែសំពះ, ដល់ទៅយូរទៅ មានសេចក្ដីក្រីក្រខ្លាំងណាស់ នាងនោះ រកអ្វីចិញ្ចឹមពុំបានសោះឡើយ, ថ្ងៃមួយ នាងរៀបស្លា ៥ ម៉ាត់ បារី ៥ ចូលទៅក្រាបសំពះប្ដី ហើយថា « ខ្ញុំសុំទោសអ្នកប្ដី ត្បិតយើងសព្វថ្ងៃ ក្រណាស់ យើងមិនបានរកស៊ី គ្មានទទួលទានទេ សុំឲ្យអ្នកទៅកាប់ឈើ ធ្វើនង្គ័ល រនាស់ធ្វើ ស្រែនឹងគេ ត្បិតដល់រដូវធ្វើស្រែហើយ » ។ ប្ដីថា "បើដូច្នោះ ឲ្យនាងដាំបាយ វេចជាសំណុំចុះ ប្ដីនឹងទៅរកកាប់ឈើ ធ្វើនង្គ័ល រនាស់ " ។ ប្រពន្ធ ក្រោកពីយប់ ដាំបាយ វេចជាកញ្ចប់មានទាំងដឹង ពូថៅទៅផង ។ បុរសកំជិល ដេកទាល់ថ្ងៃរះ ប្រពន្ធពុំហ៊ានដាស់ចាំឲ្យក្រោកខ្លួនឯង, ដល់ក្រោកហើយ ប្រពន្ធដងទឹក ទៅលប់មុខឲ្យ រួចស្រេចនាងក៏ហុចស្លាបារី នឹងបាយកញ្ចប់ ព្រមទាំងគ្រឿងប្រដាប់ទៅឲ្យប្ដី ។ បុរសនោះក៏ចុះពីលើផ្ទះទៅ ចូលក្នុងព្រៃរកឈើ, បានឃើញឈើមួយដើម មានមែកសាខាមូលត្រជាក់ ក៏ដាក់បាយសំណុំ ដឹង ពូថៅ ហើយដេកគងអន្ទាក់ខ្លា មើលទៅលើនិយាយតែម្នាក់ឯង ថា " មែកឈើនេះ ត្រូវធ្វើជាភ្លៀងនង្គ័ល, មែកនេះត្រូវធ្វើជាយាម, មែកនេះ ត្រូវធ្វើជាផង មែកនេះ ត្រូវជានឹម មែកនេះ ត្រូវធ្វើជារនាស់ ។ គ្រាន់តែដេកថាប៉ុណ្ណឹង ពេលឃ្លានបាយក្រោកឡើងស្រាយបាយសំណុំស៊ី ។ រួច

---

១ កម្ពុជសុរិយា លេខ ៨-៩ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៣៦ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

ដេកថាដូចមុនទៀត, ថ្ងៃរសៀលត្រឡប់មកផ្ទះវិញ ។ ប្រពន្ធឃើញ រត់ទទួលយកគ្រឿងប្រដាប់ នាំប្ដីឡើងទៅលើផ្ទះ យកទឹកលាងជើងឲ្យប្ដី ហើយសួរថា "អ្នកទៅបានការដូចម្ដេចខ្លះ ? " ។ ប្ដីថា "មិនទាន់បានទេ នាង ! ចាំស្អែកសឹមទៅទៀត ជប់កន្លែងដើមឈើនោះហើយ, រុក្ខទេវតាដែលអាស្រ័យនៅទីនោះ ឮបុរសកំជិល ថាដូច្នោះ ក៏ភ័យ ខ្លាចរកកន្លែងនៅគ្មាន ក៏គិតគ្នា នឹងតាមទៅវាយសម្លាប់បុរសកំជិលនោះ ឲ្យស្លាប់នៅមាត់ជណ្ដើរផ្ទះ កុំឲ្យវាមកកាប់ឈើនេះបាន ។ បុរសនោះ ក៏ត្រឡប់មកផ្ទះវិញ ។ រុក្ខទេវតា តាមមកដល់មាត់របង ឃើញប្រពន្ធរត់ទៅទទួលប្ដីដល់មាត់ជណ្ដើរ យកទឹកលាងជើងប្ដី ។ ដោយសិរីសួស្ដីប្រពន្ធនោះ ទេវតាចូលមិនចុះ មិនហ៊ានវាយ ។ បុរសនោះ រួចពីអន្ដរាយ ក៏ឡើងទៅលើផ្ទះ ប្រពន្ធសួរ និយាយដូចមុនទៀតថា "បានសព្វគ្រប់អស់ហើយព្រឹកនឹងទៅកាប់" ។ ទេវតាភ័យណាស់ថា "បុរសនោះ មុខជាកាប់ហើយព្រឹកនេះ " ក៏ទាំគ្នាបកនិយាយអង្វរថា "សុំកុំកាប់ឈើនោះ » ។ បុរសថា " អញមិនព្រមទេ ព្រឹកនេះ អញទៅកាប់ហើយ " ។ ទេវតាភ័យណាស់ ក៏នាំគ្នានិយាយស្តូក ដោយប្រាប់ទីកន្លែងកំណប់មាសប្រាក់ ឲ្យបុរស ។ សួរថា " ឲ្យកំណប់ប៉ុន្មានកន្លែង? "។ ទេវតាថា ពីរកន្លែង បុរសថា " មិនព្រមទេ, បើ ៤ កន្លែងទើបព្រម ហើយឲ្យដាក់ឈើសក្ដាល់ឲ្យផង " ។ ទេវតា ក៏ព្រមធ្វើតាម កុំឲ្យតែកាប់ដើមឈើនោះ ។ បុរសថា " បើដូច្នោះ ខ្ញុំលែងកាប់, តែថា ព្រឹកនេះ ខ្ញុំទៅគាស់កំណប់នោះហើយ " ។ ទេវតា ថា "ទៅចុះខ្ញុំដោតឈើសក្ដាល់ទុកឲ្យ " ។ ព្រឹកឡើង ប្ដីប្រពន្ធ នាំគ្នាទៅគាស់កំណប់ដែលទេវតាឲ្យ, ក្នុងកំណប់មួយ ៗ ទាំងពីរនាក់ប្ដីប្រពន្ធ ត្រូវជញ្ជូនបីថ្ងៃ បានសុទ្ធតែមាសនិងប្រាក់ ចាក់គរពេញផ្ទះ ។ នាងនោះ ក៏រៀបចំដាក់ហិប ដាក់ឡាំង មិនឲ្យអ្នកណាឃើញ ហើយក៏ជួលជាងឲ្យធ្វើគ្រឿងប្រដាប់ លក់ជាជំនួញរឹតតែមានឡើង ៗ បានជាសេដ្ឋី បានបន្ទុស្សកុះករប្រូលបកនៅពឹងពាក់ជាច្រើន រាប់មិនអស់ ។

**ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក**

**ផ្ទះធំស្រណុក ត្បិតលំភ្នំស្រីជា**

## ២៧ _ រឿងបុរសមានកូន ៤ នាក់ រៀនវិជ្ជា ៤ បទ[១]

មានបុរសម្នាក់ មានកូនប្រុស ៤ នាក់ បានសិក្សាវិជ្ជា ៤ បទ ស្ទាត់ជំនាញរៀងខ្លួន គឺម្នាក់ ចេះស៊ី, ម្នាក់ ចេះដេក, ម្នាក់ ចេះកាត់ក្តី ម្នាក់ទៀត ចេះចង់ស្រី។ ឪពុក ក៏យកកូនទាំង ៤ នាក់ ទៅថ្វាយស្តេច ក្រាបអំពីវិជ្ជានីមួយ ៗ ក្នុងខណៈដែលថ្វាយនោះ ។ ស្តេចទ្រង់រក្សាទទួលទុក ។ ថ្ងៃមួយ ស្តេចទ្រង់ពិសោធបុរសម្នាក់ ដែលចេះស៊ីជាមុន, ឲ្យគេរៀបភោជនាហារជាច្រើនមុខ ស្តេចជួសទឹកឆៅមួយក្រចក ដាក់ទៅក្នុងចានសម្លមួយ ហើយទ្រង់ប្រាប់ទៅបុរសនោះថា "ឲ្យស៊ីភោជនាហារគ្រប់មុខ " ។ បុរសនោះ ក៏បរិភោគ តាមព្រះរាជបញ្ជា, ដល់ទៅសម្លមួយមុខ ដែលស្តេចបានដាក់ទឹកឆៅមួយក្រចក ចូលនោះ បុរសនោះ មិនបរិភោគ ។ ស្តេចសួរបុរសនោះថា " ហេតុអ្វេចបានជាចៅឯង មិនបរិភោគសម្លនេះ ? " ។ បុរសនោះក្រាបទូលថា « សម្លនេះ មានទឹកឆៅមួយក្រចកនៅក្នុងនោះ បានជាទូលព្រះបង្គំជាខ្ញុំ មិនទទួលព្រះរាជទាន » ។ ស្តេចនឹកក្នុងព្រះទ័យថា « បុរសនេះ ចេះវិជ្ជាខាងស៊ីស្ទាត់មែន » ។ អំពីនោះទៅ ស្តេចទ្រង់ពិសោធបុរសចេះដេកទៀត ទ្រង់ឲ្យរៀបទីកន្លែងយ៉ាងស្អាត បានពូកកប្រាលក្រាលពីលើ ។ ស្តេចយកសក់មួយសរសៃ ទៅដាក់ក្រោមកប្រាលពូកនោះ, ដល់ពេលយប់ ទ្រង់ហៅបុរសនោះ ឲ្យទៅដេក ។ បុរស ប្រះដេកទៅក្រោក

---

១-កម្ពុជសុរិយា លេខ ១០-១១-១២ ឆ្នាំ ១៩៣៣-៤ ទំព័រ ១១៨-២០ គ្មានឈ្មោះអ្នករៀបរៀងទេ ។

ឡើងវិញភ្លាម ។ ស្ដេចទ្រង់សួរថា « ហេតុម្ដេច បានជាដេកហើយក្រោកឡើងវិញ ? » ។ បុរសនោះ ក្រាបទូលថា « មានសក់មួយសរសៃនៅក្នុងដំណេកនោះ បានជាទូលព្រះបង្គំជាខ្ញុំក្រោក » ។ ស្ដេចទ្រង់នឹកសរសើរក្នុងព្រះទ័យ ថា « បុរសនោះ ស្ទាត់ខាងវិជ្ជាដេកប្រាកដមែន » ។ ថ្ងៃមួយ មានបុរសម្នាក់ស្លាប់ នៅកណ្ដាលវាល គ្មានភិនភាគស្លាកស្នាមអ្វី នៅរូបកាយនោះសោះ ។ ស្ដេចទ្រង់បង្គាប់ឲ្យតុលាការមុខក្រសួង ស៊ើបសួររកហេតុនោះ ក៏ពុំឃើញ, ទ្រង់ព្រះវិតក្កក្នុងព្រះរាជហឫទ័យ ទ្រង់នឹកឃើញបុរសដែលចេះវិជ្ជា ខាងផ្លូវតុលាការនោះ ក៏បានព្រះរាជឱង្ការ ឲ្យហៅចូលមក ហើយទ្រង់ចាត់ប្រើឲ្យទៅស៊ើបរករឿងពិរុទ្ធនោះ ។ បុរសនោះ សូមព្រះរាជអនុញ្ញាតអំណាច ក្នុងវេលាដែលស៊ើបសួរយកការណ៍នោះ។ ស្ដេច ក៏ព្រះរាជទានពរតាមសុំ ។បុរសនោះចេញទៅដល់ទីកន្លែងមនុស្សស្លាប់នោះ ចាត់ការហៅអ្នកស្រុកមកប្រជុំ មិនឲ្យមានសល់ម្នាក់, ហើយបុរសនោះហាមប្រាមថា «ក្នុងវេលាថ្ងៃស្អែកនេះ មិនឲ្យអ្នកណាទៅណាមកណាក្រៅពីភូមិខ្លួនទេ ឲ្យទាំងអស់គ្នា ទាំងប្រុសទាំងស្រី ចាស់ក្មេងចូលទៅមើលគេធ្វើបុណ្យរំលាយសពបុរសអនាថា ដែលស្លាប់នៅកណ្ដាលវាលស្រែ លើកតែមនុស្សខ្វាក់ខ្វិនចេញ។ ខណៈដែលរៀបចំរំលាយសពនោះ បុរសជាអ្នកស៊ើបសួរ បានចាត់មនុស្សជាច្រើននាក់ ដែលបាន ពន្យល់ពីកិច្ចហេតុ ដែលយកការណ៍ក្នុងរឿងនោះ បើឃើញឈ្មោះណាប្រកបនឹងកិច្ចដែលបានពន្យល់នោះ ឲ្យយកឈ្មោះនោះមកប្រគល់ឲ្យខ្លួនជានាយមួយរំពេច ។ ពេលភ្លើងឆេះពេញកម្លាំង មានស្រីក្មេងម្នាក់ស្រក់ទឹកភ្នែកច្រោក ។ បុរសជាអ្នកគយគន់មើលហេតុ ក៏នាំយកខ្លួននាងនោះ ទៅប្រគល់ឲ្យនាយខ្លួន ។ បុរសជានាយ យកខ្លួននាងទៅស៊ើបសួរដំណើរ ដែលនាងយំនោះ ដោយយោបល់ដ៏ល្អិត ។ នាងនោះ រកផ្លូវគេចកែដោះសាទៅពុំបាន

ក៏ប្រាប់បុរសនោះ តាមត្រង់ថា «ខ្លួននាង បានសេហាហាយនឹងបុរសដែលស្លាប់ ទើប នឹងបានគ្នាក្នុងយប់ដែលស្លាប់នោះ, ហើយថា ដំណើរដែលស្លាប់នោះ គ្មានអ្នកណា វាយដំធ្វើបាបអ្វីទេ គឺវេលាចូលដំណេក បុរសនោះប្រើនាងឲ្យទៅរកទឹកមកឲ្យផឹក នាង មិនហ៊ានចេញទៅដងទឹកឯក្រៅ ដោយខ្លាចឪពុកដឹង ក៏យកផ្តិលត្រងទឹកភ្លៀង ដែលហូរធ្លាក់ តាមរងស្បូវប្រក់ផ្ទះនោះឲ្យផឹក, លុះផឹកហើយ ក៏បណ្តាលឲ្យដល់ មរណៈ ក្នុងខណៈនោះទៅ ។ បុរសដែលជាអ្នកស៊ើបសួរ ក៏យល់ច្បាស់ក្នុងចិត្តថា « នាងនេះ មិនមានសន្តានចិត្តជាទុច្ចរិត នឹងបុរសដែលស្លាប់នោះទេ ព្រោះទើប ស្រឡាញ់គ្នា បានជួបគ្នាក្នុងខណៈនេះ, ការណ៍នេះ ប្រាកដជាមានសត្វអាសិរ-ពិសអ្វី នៅលើដំបូលផ្ទះនោះ បានជាបណ្តាលឲ្យបុរសនោះស្លាប់ » ។ ទើប បុរសជានាយ ចាត់ឲ្យទៅមើលលើដំបូលផ្ទះនោះ ឃើញពស់នាគរាជមួយ នៅចំពី លើល្វែង ដែលនាងនោះដេក ។ បុរសជានាយ ក៏ឲ្យវាយពស់នាគរាជនោះ យក មកថ្វាយស្តេច ក្រាបទូលតាមដំណើរ ហើយដោះលែងនាងនោះទៅ ដោយវិនិ-ច្ឆ័យថា « ហេតុដែលបណ្តាលឲ្យបុរសនោះស្លាប់ មកអំពីផឹកទឹកភ្លៀង លាយដោយ ពិសពស់នាគរាជ ដែលនាងនោះ ត្រងមកឲ្យផឹក ដោយឥតចេតនា ។ ស្តេច ក៏ទ្រង់ សរសើរថា បុរសជានាយ ចេះស្ទាត់ក្នុងការស៊ើបសួរ ខាងផ្លូវតុលាការមែន ។

ថ្ងៃមួយក្រោយមក មានសេដ្ឋីម្នាក់ស្លាប់ សេដ្ឋីនោះ មានប្រពន្ធក្មេងល្អ ។ នាង នោះ ប្តេជ្ញាថា « មិនយកប្តីទៀតទេ » ។ ដំណឹងនោះ ជ្រាបដល់ស្តេច ។ ទ្រង់ ឲ្យនាហ្មឺនសព្វមុខមន្ត្រី ទៅចង់នាងមេម៉ាយជាប្រពន្ធខ្មោចសេដ្ឋីនោះ ។ នាហ្មឺនទាំង អស់ ទៅចង់មិនបាន ស្តេចទ្រង់គិត ថា « នាងនេះ ប្រហែលជាមិនយកប្តី ដូចដំ-ណើរដែលទ្រង់ជ្រាបនោះមែន » តែទ្រង់គិតក្នុងព្រះរាជហឫទ័យ ថា « នាហ្មឺនសព្វ មុខមន្ត្រីទាំងនោះ ប្រហែលជាមិនពេញសេចក្តីប្រាថ្នានាងមេម៉ាយទេ បើអង្គអញ ប្រ ហែលជានាងនេះព្រម » ក៏ទ្រង់យាងទៅផ្ទះនាងមេម៉ាយនោះ ហើយទ្រង់ឲ្យប្រាប់

នាងថា «ល្ងាចនេះ ទ្រង់នឹងមកផ្ទំនឹងនាង ឲ្យនាងរៀបចំទីកន្លែងចាំទទួល» ។ នាងមេម៉ាយ ក៏ទទួលព្រះរាជឧង្ការ ។ ពេលល្ងាច នាងរៀបក្រឡាព្រះបន្ទំ ហើយតែងស្រីបម្រើម្នាក់ ដែលមានកើតស្រែងនៅខ្លួន រចនាដោយគ្រឿងប្រដាប់ សម្រាប់តាក់តែងរូបកាយស្រី គឺគ្រឿងមាសពេជ្រ និងគ្រឿងក្រអូបគ្រប់ប្រដាប់ ហើយឲ្យនាងនោះចូលទៅក្នុងទីក្រឡាព្រះបន្ទំ ដែលរៀបចំទទួលស្ដេច តាមព្រះរាជឧង្ការ ។ ដល់ស្ដេចយាងមក ដោយទ្រង់មិនបានគិតពិនិត្យសព្វគ្រប់ ទ្រង់ក៏យល់ថា« ទីនេះ ជាទីសម្រាប់នាងមេម៉ាយមែន បានជាមនុស្សទាំងឡាយ មិនហ៊ានមកនៅទីនេះ » ទ្រង់ក៏ដាក់ព្រះអង្គគង់អែប ដោយសំគាល់ថា « នាងមេម៉ាយ » ទ្រង់ផ្ទំជាមួយនាងនោះ រួចហើយទ្រង់កំណត់ព្រះចិន្ដាថា « អញ មកចង់នាងនេះបានហើយ » ។ ដើម្បីឲ្យបានជាភស្តុតាងដល់ភ្នែកអ្នកផងទាំងពួង, ស្ដេច ក៏ទ្រង់ខាំថ្ពាល់នាងនោះជាសំគាល់ រួចទ្រង់យាងមកព្រះបរមរាជវាំងវិញ ទ្រង់មានព្រះរាជឧង្ការផ្ដាំ ថា « ព្រឹកស្អែកនេះឲ្យនាងចូលទៅគាល់ស្ដេចកុំខាន » ។ ទ្រង់យាងទៅដល់ព្រះបរមរាជវាំង ទ្រង់ក៏មានព្រះរាជឧង្ការ ប្រាប់អស់នាហ្មឺនសព្វមុខមន្ត្រីថា ព្រះអង្គយាងទៅចង់នាងនោះបាន មានទាំងសម្គាល់ស្នាមព្រះទន្តនៅថ្ពាល់នាងនោះផង ហើយទ្រង់បាន ប្រាប់ឲ្យចូលមកគាល់ ក្នុងវេលាព្រឹកនេះផង ឲ្យនាហ្មឺនសព្វមុខមន្ត្រីទាំងអស់ ចាំមើល ។ ដល់នាងមេម៉ាយ ចូលមកគាល់ យកទាំងស្រីបម្រើដែលតាក់តែងកាយ ទទួលស្ដេចពីយប់នោះ មកជាមួយផង, លុះចូលមកគាល់ ក៏អង្គុយតាមមុខក្រោយ, នាងមេម៉ាយអង្គុយមុខ ស្រីបំរើ អង្គុយក្រោយ ។ ស្ដេចឲ្យនាហ្មឺនទៅពិនិត្យមើល នៅកន្លែងសំគាល់ ដែលទ្រង់បានប្រាប់ហើយនោះ ។ លុះភ្នាក់ងារដែល ទទួលព្រះរាជឧង្ការ ទៅពិនិត្យ ត្រឡប់មកក្រាបទូលស្ដេចវិញ ថា « នាងអង្គុយក្រោយ មានស្នាមនៅថ្ពាល់ជាសម្គាល់ដោយធ្មេញ ឯនាងមេម៉ាយ គ្មានស្នាមអ្វីជាសម្គាល់ទេ » ។ ស្ដេច ក៏តូចព្រះរាជហឫទ័យ ដោយសេចក្ដី មិនបានពិនិត្យជាមុន ក៏ព្រះអង្គទ្រង់ចិន្ដាត្រិះរិះ

ទៅឃើញថា « នាងនេះ ជាស្រីមានប្រាជ្ញា នឹងរកអ្នកណាទៅចង់នាងពុំបាន » ទ្រង់នឹកដល់បុរស ដែលជាអ្នកស្ទាត់ខាងវិជ្ជាចង់ស្រី ក៏បានព្រះរាជឱង្ការឲ្យចូលទៅគាល់ ។ ស្ដេច ក៏មានព្រះរាជឱង្ការ សួរទៅបុរសនោះ ថា " ឯងទៅចង់នាងមេម៉ាយ ជាប្រពន្ធខ្មោចសេដ្ឋីបានឬទេ ? បើឯងត្រូវការវត្ថុអ្វី យើងឲ្យឯងទាំងអស់ "។ បុរសនោះ ក្រាបទូល " ទទួលតាបបន្ទាល់ ដោយមិនបាច់យកវត្ថុជាឧត្ដមទៅទេ សុំតែសំពត់ជាឪបសចាស់ យកទៅស្លៀកពាក់ ហើយនឹងឆ្អឹងគោមួយចោរវេចខ្ចប់ជាប់នឹងខ្លួនប៉ុណ្ណោះ បានហើយ " ។

ឯនាងមេម៉ាយ ជាប្រពន្ធខ្មោចសេដ្ឋី វេលាដែលត្រឡប់ពីគាល់ស្ដេចទៅវិញ ក៏រៀបសាលាធ្វើបុណ្យខ្មោចសេដ្ឋីជាប្ដី រំលាយសពជាស្រេច រើសធាតុយកមកខ្ចប់តម្កល់លើសាលា ធ្វើបុណ្យឆ្លង ។ វេលាយប់នោះ បុរស ដែលទទួលព្រះរាជឱង្ការ បានទៅដល់លើសាលា ដែលនាងមេម៉ាយធ្វើបុណ្យខ្មោចប្ដី ដែលនឹងហើយស្រេចនៅវេលាព្រឹកស្អែកនោះ ដេកហើយ ធ្វើជាយំសោកនឹងខ្មោចប្រពន្ធខ្លួនស្លាប់ បានសេក្ដីទុក្ខយ៉ាងខ្លាំង ដោយបានទាំងធាតុស្ពាយជាប់នឹងខ្លួន ជាសំគាល់ផង, បណ្ដាលឲ្យអស់អ្នកជាពួកក្រុមនាងមេម៉ាយ ដែលទៅលើសាលានោះទាំងប៉ុន្មានបានសេចក្ដីភ្ញាក់ផ្អើលគ្រប់គ្នា សួរទៅបុរសនោះថា ហេតុអ្វី ក៏អ្នកមកយំសោក ឡោកខ្លួនប្រាណលើទីនេះ ខ្លាំងម្ល៉េះ?" ។ បុរសនោះប្រាប់ទៅអ្នករក្សាសាលានោះ ថា« ខ្ញុំឃើញគេធ្វើបុណ្យខ្មោចលោកសេដ្ឋីនោះ ខ្ញុំនឹកដល់ខ្មោចប្រពន្ធខ្ញុំ ដែលស្លាប់ជាយូរហើយនោះភ្លាម ក៏បណ្ដាលឲ្យសង្វេគនឹងទុក្ខវេទនានិងការព្រាត់ប្រាស ជាថ្មីមួយជាន់ទៀត, តាំងពីប្រពន្ធស្លាប់ទៅនោះ ខ្លួនខ្ញុំ លះបង់ការងារចោលអស់ ស្ពាយតែធាតុប្រពន្ធដើរ ដោយសេចក្ដីអាឡោះអាល័យ » ហើយបុរសនោះ សុំអ្នកចាំសាលាអ្នកស្នាក់មួយយប់ ។ បុរសដែលចាំសាលា មិនហ៊ានសម្រេចដោយខ្លួនឯង ក៏យកសេចក្ដីនោះ ទៅជំរាបនាងមេម៉ាយ ជារចាបព្វាយ តាមដំណើរ ដែលបុរសនោះ

អធិប្បាយអំពីសេចក្ដីកំសត់របស់ខ្លួន ហើយសុំសាលាស្នាក់ ។ នាងមេម៉ាយ មានចិត្តអាណិត ដល់បុរសកំសត់ ដែលមានទុក្ខព្រាត់ប្រាសប្រពន្ធនោះ ក៏យល់ព្រមឲ្យស្នាក់ ហើយបង្គាប់ទៅមនុស្សបម្រើ ឲ្យរៀបអាហារភោជន ឲ្យទានបុរសនោះផង។ លុះយប់ នាងមេម៉ាយ ទៅស្ដាប់ធម៌ទេសនា ឆ្លងបុណ្យខ្មោចប្ដី នៅលើសាលាដែលតម្កល់ធាតុនៅនោះ ។ ឯបុរសចង់ស្រី ក៏សម្ងំធ្វើជាដេកលក់ទៅ ។ នាងមេម៉ាយនោះ ស្ដាប់ធម៌ទេសនាចប់ ត្រឡប់មកផ្ទះវិញ ។ បុរសជាអ្នកចង់ស្រី ឃើញឱកាសស្ងាត់ល្អ ក៏លួចយកធាតុប្រពន្ធខ្លួន ទៅដាក់ប្របធាតុសេដ្ឋីជាប្ដីនាងមេម៉ាយ ។ លុះដល់ព្រឹកឡើង នាងមេម៉ាយ ចូលដល់សាលា, បុរសនោះក៏ស្រែកយំយ៉ាងខ្លាំងថា “អ្នកណា លួចធាតុប្រពន្ធខ្ញុំបាត់ ? » ។ នាងមេម៉ាយឆ្ងល់ ក៏សួរបុរសនោះថា « ហេតុអ្វី ក៏អ្នកឯងយំខ្លាំងម្ល៉េះ ? » ។ បុរសនោះ ប្រាប់ទៅនាងមេម៉ាយវិញ ថា «អ្នកឯណាលួចធាតុប្រពន្ធខ្ញុំទៅបាត់ » ហើយចោទប្រកាន់ ទៅលើរូបនាងមេម៉ាយថា « ខ្មោចប្ដីនាងមេម៉ាយ លួចធាតុប្រពន្ធទៅ » ។ នាងមេម៉ាយ មានសេចក្ដីអន់ចិត្តនឹងបុរសចោទប្រកាន់ខ្មោចប្ដីថា “ លួចធាតុប្រពន្ធខ្លួនដូច្នោះ,, ក៏នាំបុរសនោះឲ្យទៅមើល ឃើញនៅជិតគ្នាមែន។ បុរស ក៏ចោទប្រកាន់ ចំពោះខ្លួននាងមេម៉ាយថា “ប្ដីនាង យកប្រពន្ធគាត់ទៅធ្វើជាប្រពន្ធខ្លួនហើយ លុះតែនាងព្រមទទួលធ្វើជាប្រពន្ធគាត់វិញទើបព្រមសុខចិត្ត ,,។សេចក្ដីចោទចំពោះខ្លួននាងមេម៉ាយនោះ ជាដំណំច្រើនខណាស់ដោយឧបាយយ៉ាងល្អិត ។ នាងមេម៉ាយ រកផ្លូវដោះសាគ្មាន ក៏ចាញ់កលនោះជាទម្ងន់ ថែមទាំងមានសេចក្ដីអន់ចិត្ត នឹងខ្មោចប្ដីខ្លួនដែលស្លាប់នោះ ថា ជាមនុស្សគ្មានចិត្តសប្បុរសចំពោះប្រពន្ធ បន្តិចបន្តួចសោះ គ្នាកំពុងកើតទុក្ខនឹងខ្លួន ។ ហ៊ានទៅលួចប្រពន្ធគេ យកមកបញ្ចៀនៅមុខ នាងជាអ្នកជាទុក្ខតិតសព្វ ។ ទៅ ក៏ទទួលព្រមយកបុរសនោះធ្វើជាប្ដី ជាសេចក្ដីផ្ដើន តបឲ្យទល់ពុត ទៅនឹងខ្មោចប្ដីខ្លួនវិញ ដែលហ៊ានខូច លួប្រពន្ធបុរសនោះ ។ ចំណែកបុរសនោះ ដល់បាននាងមេម៉ាយជាប្រពន្ធ ៣-៤ ថ្ងៃក៏បបួលគ្នាទៅគាល់ស្ដេច ។ ឯស្ដេច នឹងនាហ្មឺនសព្វមុខមន្ត្រីបានទតបានឃើញ ក៏មានសេចក្ដីសរសើរ ចំពោះបុរសនោះ ថា ជាអ្នកមានវិជ្ជាចេះចង់ស្រីប្រាកដមែន ។

**ម្ល៉ៃនឹងចេះ ឱ្យគេគោត ម្ល៉ៃនឹងឆោត ឱ្យគេអាណិត**

## ២៨ — រឿង ចោរអាចម៍សេះ(១)

មានបុរសម្នាក់ អ្នកស្រុកគេហៅថា « ចោរអាចម៍សេះ » ព្រោះនៅខ្ញុំសេដ្ឋី គេឲ្យឃ្វាលសេះ ប្រហែលជា ៥០ ក្បាល គេឲ្យទៅសង់ខ្ទមនៅបៀតមាត់ទន្លេ ។ បុរសនោះ ព្យាយាមរំឭកគុណព្រះពុទ្ធ ទោះឃ្វាលសេះក្តី ធ្វើការអ្វីក្តី តែងទន្ទេញជាប់ «អញទៅដេញសេះ សម្មាសម្ពុទ្ធោ អញទៅលើកអាចម៍សេះ សម្មាសម្ពុទ្ធោ» ធ្វើការអ្វី ។ ក៏ទន្ទេញថា សម្មាសម្ពុទ្ធោ ដូច្នេះ ដរាបទៅ ។ ឯអាចម៍សេះនោះទៀត បុរស មិនលើកចោលទេ តែងកើបច្រកការុងទុក បានជាច្រើន ។ ថ្ងៃមួយមានសំពៅ ៥០០ មកពីស្រុកចិន នាំទំនិញមកលក់ ។ បុរស ស្រែកហៅថា « ឲ្យចូលមកនេះសិន » ។ លុះសំពៅចូលមក សួរថា « អ្នករាល់គ្នា បើកសំពៅមកពីណា ? » ។ នាយសំពៅ ថា « មកពីស្រុកចិន » ។ បុរស ថា « អ្នកស្គាល់ស្តេចក្រុងចិនទេ ? » ។ នាយសំពៅ ថា « ស្គាល់ ព្រោះខ្ញុំនៅជិតព្រះរាជវាំងដែរ » ។ បុរស ថា « ស្តេចក្រុងចិននោះ ជាក្សៀវអញ ហើយជាមិត្រសម្លាញ់ថ្ងៃមុនរៀងមក បើអ្នកត្រឡប់ទៅស្រុកចិនវិញ អញផ្ញើរបស់ទៅក្សៀវអញផង " ។ នាយសំពៅនោះ ឆ្លើយថា បាទ ! ហើយនាំគ្នាចេញសំពៅទៅលក់ដូរ, មិនយូរប៉ុន្មាន នាយសំពៅត្រឡប់មកវិញ ចូលទៅរកបុរសនោះ សួរ ថា " អ្នកឯង បានអ្វីផ្ញើទៅ ? យកមកខ្ញុំទៅឥឡូវហើយ " ។ បុរស ថា ខ្វះអ្វី ខ្ញុំ

---

១ កម្ពុជសុរិយា លេខ ១០-១១-១២ ឆ្នាំ ១៩៣៣-៤ ទំព័រ ១៤៩ មិនមានឈ្មោះអ្នករៀបរៀងទេ ។

រៀបដាក់ក្នុងការុងបម្រុងផ្ញើទៅ " ។ នាយសំពៅ ក៏ប្រើជើងឈ្នួលឲ្យជញ្ជូនដាក់សំពៅ នូវរបស់ប្រហែល ៤០០ ការុង ដែលសុទ្ធតែការុងពេញដោយអាចម៍សេះ ហើយក៏លាបុរសនោះ ចេញសំពៅទៅស្រុកចិន, ដល់ទៅដំណាក់ផែស្ដេចក្រុងចិន ហើយ ក៏បោះយុថ្កា ឡើងទៅក្រាបទូលថា "បានក្មើព្រះអង្គ ផ្ញើរបស់ពីស្រុកខ្មែរមកថ្វាយ ដាក់នឹងការុងច្រើនណាស់ " ។ ស្ដេចក្រុងចិនឆ្លល់ថា " អញមិនដែលទៅស្រុកខ្មែរទេ អញមានក្មើងណានៅស្រុកខ្មែរ ? " ក៏មានព្រះបន្ទូល ឲ្យទៅជញ្ជូនការុងអាចម៍សេះនោះ មកដាក់គរនៅមុខព្រះលាន ទ្រង់ឲ្យស្រាយមាត់ការុងចាក់មើល តើជារបស់អ្វីខ្លះ " ដល់ស្រាយទៅ ឃើញសុទ្ធតែដុំមាសគ្រប់ការុង ។ ស្ដេចមានព្រះទ័យត្រេកអររកទីបំផុតគ្មា ក៏ទ្រង់គិតក្នុងព្រះចិន្តាថា " នឹងបានអ្វីផ្ញើទៅគេវិញ, មានតែព្រះរាជបុត្រីមួយ ព្រះជន្ម ១៨ ឆ្នាំ ព្រះរូបព្រះឆោមល្អលើសស្រីទាំងអស់ គិតផ្ញើទៅឲ្យគេ, ហើយក៏ទ្រង់ចាត់ឲ្យជាងធ្វើស្គរមួយយ៉ាងធំ ពាសស្បែកសត្វទាំងសងខាង តែឲ្យមានកន្លែងបើកចេញចូលម្ខាងបាន ហើយក៏ដាក់ព្រះរាជបុត្រីនោះ ទៅក្នុងស្គរ មានទាំងកន្សែងបក់ បោយមួយផង ហើយចាត់បម្រើ ឲ្យបើកសំពៅយកទៅឲ្យចៅអាចម៍សេះ, បម្រើទៅដល់ហើយ ក៏ស្រែកហៅបុរសនោះថា « ស្ដេចក្រុងចិនជាក្មើ ផ្ញើស្គរមួយមកឲ្យអ្នកឯងវាយលេង"។បុរសឮដូច្នោះក៏ត្រេកអរណាស់ ។ អ្នកបម្រើ យកស្គរទៅចង ក្នុងរោងសេះនោះ ។ បុរសនោះក៏ចេះតែវាយលេងទាំងនិយាយផង ថា "ក្មើអញ ស្រឡាញ់អញផ្ញើស្គរនេះមកឲ្យអញវាយលេង " ។ ថ្ងៃមួយ បុរសនោះ វាយស្គរ ហើយចេញទៅឃ្វាលសេះ ។ នាងដែលនៅក្នុងស្គរ ចេញមក រៀបបាយទឹកទុកបម្រុងឲ្យបុរសនោះ ហើយចូលទៅក្នុងស្គរ ចេញមក រៀបបាយទឹក មកវិញឃើញបាយ គិតថា " នរណាអេះ មករៀបបាយឲ្យអញ ។ ឃ្លានបាយ អញស៊ីហើយ " ។ ឯនាងនោះ ធ្វើដូច្នេះ ជាច្រើនថ្ងៃ ។ បុរសនោះ សង្ស័យ នឹកថា " នរណា យកបាយឲ្យអញស៊ីរាល់ថ្ងៃម្ល៉េះ?"ចាំលបមើល ក៏ឃើញនាងដ៏មានរូបល្អឯក ចេញពីក្នុងស្គរមក ហើយបក់បោយកន្សែង ឲ្យកើតជាអាហារឡើងមួយរំពេច ។ បុរសនោះក៏ភ័យស្រែកថា " សម្មា

សម្តុទ្ធោ មកពីណាល្អម៉្លេះ ? ហើយក៏រត់ទៅ ។ នាងនោះ ចេញតាម ។ បុរសនោះ ស្រែកថា " សម្មាសម្តុទ្ធោ កុំចាប់រញ អាណិតអញ លែងអញទៅ " ។ នាងថា " ខ្ញុំមិនលែងទេ អ្នកឯងជាប្តីខ្ញុំហើយ ឪពុកខ្ញុំ ឲ្យខ្ញុំមកនៅធ្វើជាប្រពន្ធអ្នកឯង ព្រោះអ្នកឯងបានធ្វើមាសប្រាក់ទៅឲ្យឪពុកខ្ញុំច្រើនណាស់ " ។ បុរសថា« ទេ ! ខ្ញុំមិនយកទេ" ។ នាងនោះ និយាយល្ងួងលោមច្រើនផង បុរសក៏ស្ងៀប, នាងដឹកដៃបុរសនោះ មករោងសេះវិញ ។ ក្នុងវេលាយប់នោះ នាងអធិដ្ឋានកន្សែងបក់បោយហើយបក់ទៅ កើតជាប្រាសាទរាជវាំង មានមនុស្សគឹកកងរំពងនៅក្នុងនោះ ។ ចៅអាចម៍សេះ ហើយនិងនាងនោះ ក៏នៅលើប្រាសាទ មានមនុស្សបម្រើឆ្វេងស្តាំ ។ អ្នកស្រុកទាំងពួង ឃើញហើយ ភ្ញាក់ផ្អើលគ្រប់គ្នា ក៏រត់ទៅប្រាប់សេដ្ឋីជាចៅហ្វាយបុរសនោះថា«មានកើតប្រាសាទរាជវាំង ត្រង់ខ្ទមចៅអាចម៍សេះនោះច្រើនណាស់"។ សេដ្ឋីសង្ស័យ រត់ទៅមើល ឃើញហើយ ក៏ភិតភ័យ រត់ទៅទូលស្តេចតាមរឿង ។

ស្តេចទ្រង់ជ្រាប ទ្រង់ចាត់បម្រើ ឲ្យទៅពិនិត្យមើល ឃើញពិតដូច្នោះមែន ក៏មានព្រះទ័យទោមនស្សជាខ្លាំង ថា " ឈ្មោះណា ហ៊ានបកសាងប្រាសាទរាជវាំងក្នុងនគរអញ មានតែអញទេ ជាស្តេចក្នុងនគរនេះ " ទើបទ្រង់ប្រជុំនាហ្មឺនសព្វមុខមន្ត្រី មានព្រះបន្ទូលចាត់ឲ្យរៀបរេហ៍ពល លើកទៅចាប់ ទាំងព្រះអគ្គក៏ស្តេចយាងជាមួយផង ។ វេលានោះ មានបម្រើទៅប្រាប់ ចៅអាចម៍សេះហើយនឹងប្រពន្ធចៅអាចម៍សេះបានឮ ក៏មានសេចក្តីភិតភ័យណាស់ ។ នាងប្រាប់ប្តី ថា " កុំឲ្យភ័យទុកងារឲ្យខ្ញុំច្បាំងនឹងស្តេចនេះវិញនាងក៏រៀបខ្លួនចេញទៅ ហើយអធិដ្ឋានកន្សែងបក់កន្សែងបោយឲ្យស្តេចបរាជ័យ ព្រមទាំងរេហ៍ពល ។

ចៅអាចម៍សេះនិងនាងនោះ បានសោយរាជ្យជាស្តេច ដោយអំណាចដឹងគុណព្រះពុទ្ធ ។

**ការខំប្រឹងប្រែង តែងមានផលច្រើន**

# ២៩. រឿង ស្រីក្អែកមាស(១)

ដើមឡើយ មានបុរសម្នាក់ បានទទួលបណ្ដាំពីឪពុកប្រដៅថា « កុំឲ្យយកស្រីប្ដីលែង និងស្រីសោកែ ឲ្យយកតែស្រីក្រមុំព្រហ្មចារី និងមេម៉ាយប្ដីស្លាប់ ធ្វើជាប្រពន្ធ ហើយកុំឲ្យយកក្លើនឹងមនុស្សគ្រូបី » តែមិនដូច្នោះ បុរសនោះ បានយកស្រីទាំង ៤ នាក់នោះជាប្រពន្ធ និងយកមនុស្សគ្រូបីជាក្លើ ដើម្បីល្បងមើល ។ ថ្ងៃមួយ ក្អែកមាសរបស់ស្ដេច ទៅរកស៊ីក្បែរផ្ទះបុរសនោះ, ឯបុរសនោះ គិតពិសោធមើល ក៏ចាប់ក្អែកមាសនោះយកទៅចងលាក់ទុកក្នុងទ្រុងមួយ ហើយដាក់ចំណី បាយទឹកឲ្យក្អែកនោះស៊ី រួចបុរសយកមាន់គកមួយ ទៅកាប់ធ្វើម្ហូបបរិភោគ ។ ពេលនឹងបរិភោគ បុរសនោះ បានយកប្រពន្ធទាំង ៤ និងក្លើនោះ ទៅបរិភោគទាំងអស់គ្នា ។ កំពុងតែស៊ី ក៏ធ្វើជាភ្លក្ស និយាយថា « នេះគឺជាសាច់ក្អែកមាសស្ដេច ដែលអញបានលួចកាប់យកមកស៊ី » ។

ក្រោយពីនោះ ដល់បាត់ក្អែក ស្ដេចឲ្យបាំរគងសួររកក្អែកនោះ ។ នាងស្រីប្ដីលែង និងនាងស្រីសោកែ និយាយទៅនាងក្រមុំ និង នាងប្ដីស្លាប់ថា " ឲ្យប្រាប់ទៅពួកអ្នកបាំរគងទៅ ! ថា ប្ដីយើងបានលួចកាប់ក្អែករបស់ស្ដេច យកសាច់ស៊ី កុំទៅជួយបិទបាំងថ្វី ឲ្យវាងាប់ទៅចុះ ព្រោះវាធ្វើបាប វាយ ជេ យើងខ្លាំងណាស់ "។ ស្រីក្រមុំនិងស្រីប្ដីស្លាប់ អង្វរទៅវិញ ថា « កុំធ្វើបាបប្ដីរបស់ខ្លួនដូច្នោះមិនល្អទេ»។ ស្រីសោកែ និងស្រីប្ដីលែងថា « ទោះបីនាងឯងមិនចូលគំនិតនឹងយើង ក៏គង់តែយើងប្ដឹងអ្នកបាំរគងដែរ » ថាហើយ ស្រីទាំងពីរនាក់នោះ ប្ដឹងអ្នកបាំរគងតាមដំណើរ ថា

---

១- កម្ពុជសុរិយា លេខ ១-២-៣ ឆ្នាំ ១៩៣៥ ទំព័រ ៧៩ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

“ ប្តីខ្ញុំលួចក្អែកស្តេចយកសាច់ស៊ី » គ្រាន់តែឮដូច្នោះភ្លាម ពួកអ្នកយាមវាំង ក៏ចាប់យកបុរសនោះ ទៅថ្វាយស្តេច ទូលតាមដំណើរ ។ ស្តេចឲ្យនាំបុរសនោះទៅពិឃាត, លុះនាំទៅដល់មាត់ទ្វារវាំង អ្នកចាំទ្វារ ពុំព្រមបើកទ្វារ សួរថា « អ្នកនាំមនុស្សទោសនេះមក តើបានជំនុំជម្រះហើយឬនៅ ?» ហើយបាននិយាយរឿងមួយ ប្រាប់អ្នកនាំ ថា៖

កាលនោះមានសេដ្ឋីម្នាក់ ចិញ្ចឹមឆ្កែ ៥០០, វេលាយប់មួយ មានចោរជីកឧម្មង្គចូលទៅលួចយកទ្រព្យសម្បត្តិរបស់សេដ្ឋីនោះ ហើយចូលទៅក្នុងឧម្មង្គវិញទាំងអស់ ។ ឆ្កែរបស់សេដ្ឋីដឹង បាននាំគ្នាវាទៅខាំចោរក្នុងឧម្មង្គនោះ ស្លាប់ទាំងអស់, លុះព្រឹកឡើង មហាសេដ្ឋី ឃើញបាត់ទ្រព្យសម្បត្តិដូច្នោះ ខឹងនឹងឆ្កែ ថា “ មិនចេះចាំរបស់ ក៏ឲ្យគេសម្លាប់ឆ្កែទាំងនោះចោលអស់ទៅ, លុះធំអរសោចខ្មោចចោរឡើងទៅមើលឃើញចោរស្លាប់ដូច្នោះ ក៏នឹកស្តាយក្រោយ . . . ។

កំពុងតែនិយាយ ឃើញចម្រើស្តេច ដែលទ្រង់ព្រះរាជបញ្ជា ឲ្យទៅយកបុរសនោះ មកជំនុំជម្រះវិញ ។ លុះស្តេចសួរបុរសនោះ ពីរឿងសម្លាប់ក្អែកមាស, បុរសក្រាបទូល ថា ក្អែកនោះ ទូលព្រះបង្គំ មិនបានសម្លាប់ទេ គឺបានទុកកៅកន្លែងមួយដោយល្អ, ឯសត្វដែលទូលព្រះបង្គំជាខ្ញុំសម្លាប់ ទទួលព្រះរាជទាននោះ គឺមាន់គកទេ » ។ ស្តេចទ្រង់ឲ្យទៅយកក្អែកនោះមកវិញ ហើយទ្រង់លើកលែងទោសបុរសនោះ ។ ឯស្រីទាំងពីរនាក់ ដែលប្តឹងពីបុរសជាប្តី ថាសម្លាប់ក្អែកនោះ ត្រូវបុរសជាប្តីនោះ លែងចោលទៅ ។

**ចប់ជីវផលពិត ត្រូវពិនិត្យរកហេតុ**

# ៣០ — រឿង បុរសកាស៣០(១)

កាលពីព្រេងនាយ មានបុរសម្នាក់ នៅស្រុកមួយ អាពុកម្ដាយស្លាប់ទៅ នៅកំព្រាតែម្នាក់ឯង ហើយក្រលំបាកណាស់ គ្មានទ្រព្យសម្បត្តិអ្វីទេ មានតែកាស ៣០ ច្រកក្នុងថៃ ក្រវាត់ជាប់នៅចង្កេះជានិច្ច ។ បុរសនោះ ពិចារណាថា "អញទៅទីពឹងអ្នកណានឹងបានសុខ" គិតទៅឃើញថា "គួរអញទៅជ្រកកោន នឹងលោកក្រឡាហោមចុះ" ហើយក៏ដើរចេញពីផ្ទះទៅ, ទៅដល់ ក្រាបសំពះតាមសមគួរ ។ លោកក្រឡាហោម សួរថា "ជីឯង មកពីស្រុកណា មានការអ្វី ?" ។ បុរសនោះ ជំរាបថា "ខ្ញុំបាទ មកពីស្រុកឆ្ងាយ អាពុកម្ដាយស្លាប់ចោលអស់ហើយ នៅកំព្រាតែម្នាក់ឯង, ខ្ញុំបាទមកនេះ នឹងសូមជ្រកកោននៅបម្រើ ជាកូនក្មួយតទៅ សូមព្រះតេជព្រះគុណមេត្តា" ។ លោកនោះ សួរថា "ជីឯង ចេះអក្សរល្មមធ្វើជាស្មៀនបានឬទេ ?" ។ បុរសជំរាបថា "អក្សរខ្ញុំបាទមិនចេះទេ" ។ លោកក្រឡាហោម ប្រាប់ថា "យើងទទួលឲ្យនៅបាន តែត្រូវឲ្យជីឯង បោសសម្រាមក្រោមផ្ទះយើង រៀងរាល់ថ្ងៃកុំខាន" ។

បុរសនោះ ក៏នៅបម្រើ បោសក្រោមផ្ទះរាល់ថ្ងៃ ដល់ចំនួន ៣ ឆ្នាំ ។ ថ្ងៃមួយនោះ បុរសកាស ៣០ សួរមាតាលោកក្រឡាហោមថា "លោកយាយ ! តើលោកក្រឡាហោម ជាកូនលោកយាយ កើតឆ្នាំខែថ្ងៃអ្វី បានជាលោកមានបុណ្យមានទ្រព្យសម្បត្តិច្រើនម្ល៉េះ ?" ។ យាយនោះប្រាប់ឆ្នាំខែថ្ងៃ និងពេលដែលកើតសព្វគ្រប់ ។ បុរសនោះ បានស្ដាប់ចាំប្រាកដ ពិចារណាថា "គួរអញកត់ឆ្នាំខែ

១ កម្ពុជសុរិយា លេខ ១០-១១-១២ ឆ្នាំ ១៩៣៩ ទំព័រ ១១៧ រៀបរៀងដោយឧកញ៉ាប្រាជ្ញាធិបតី ជាងហ្វាង យិន ។

ថ្ងៃនិងពេលរបស់លោកនេះដាក់ក្នុងដៃឲ្យដាប់ ” គិតហើយ ក៏យកកំណាត់សំពត់ចាស់ កត់ឆ្នាំខែថ្ងៃនិងពេលដែលលោកនោះកើត ហើយដាក់ក្នុងដៃ មិនឲ្យអ្នកឯណាដឹង ឬ ឃើញឡើយ ។

ថ្ងៃក្រោយ លោកក្រឡាហោម, សួរ បុរសកាស ៣០ « ពីឯងមកនៅនឹងយើងយូរឆ្នាំហើយ ពុំទាន់បានធ្វើរាជការនឹងគេ, ចុះខ្លួនពីឯង កើតឆ្នាំខែថ្ងៃអ្វី » ។ បុរសនោះ ជំរាបថា«ខ្ញុំបាទមិនចាំ តែកាលឪពុកម្ដាយខ្ញុំបាទរស់នៅឡើយបានឲ្យកំណត់កត់នឹងកំណាត់សំពត់សមួយ មកខ្ញុំបាទ។ក៏ទុកនៅសព្វថ្ងៃ តែមិនដឹងជារឿងអ្វី ពីព្រោះខ្ញុំមិនចេះអក្សរ » ។ លោកក្រឡាហោមថា « បើដូច្នេះ ដឹងឯងឲ្យកំណត់នោះមកអញមើល ! » ។ បុរសនោះ ក៏ជូនកំណាត់ទៅលោក ។ មើលឃើញ កើតថ្ងៃខែឆ្នាំនិងពេលដូចជាលោកដែរ ក៏គិតក្នុងចិត្តថា « ចៅនេះ កើតឆ្នាំខែថ្ងៃដូចអញដែរ គន់មើលទៅរូបរាងឫកពារា ក៏សមសួន, ចៅនេះ នឹងបានធ្វើជានាហ្មឺនធំដូចអញមិនខាន » ហើយកាន់កំណត់នោះចូលទៅក្នុង បន្ទាញរួចខ្សឹបប្រាប់ភរិយា ថា “ គេហ៍អើយ ! បុរសជាកូនក្មួយយើង ដែលបោសសម្រាមក្រោមផ្ទះសព្វថ្ងៃនេះ វាកើតឆ្នាំខែថ្ងៃដូចអញ មើលទៅឫកពាសាច់ឈាមវា ក៏សមសួនផង, ទៅមុខ វានឹងបានធ្វើជាសេនាបតីដូចយើង ” ហើយលោកនោះ ប្រឹក្សានឹងប្រពន្ធថា “កូនស្រីយើងមួយនេះគួរឲ្យទៅវាធ្វើជាភរិយាចុះ ខ្លួនវានឹងបានធ្វើជានាហ្មឺនធំ តវង្សយើង ” ។ ភរិយា ក៏យល់ព្រម ។ លោកនោះ ចេញមកវិញ ប្រាប់បុរសនោះ ថា “ ពីថ្ងៃនេះតទៅ ឯងឈប់បោសសម្រាមក្រោមផ្ទះចុះ ត្រូវឯងឡើងមកបោសខាងលើផ្ទះវិញ ” ។

កន្លងមកមួយខែ លោកក្រឡាហោម រៀបវិវាហមង្គលការ ផ្សំផ្គុំកូនស្រីនឹងបុរសកាស ៣០ ជាស្វាមីភរិយា, រួចស្រេច លោកក្រឡាហោមក៏បង្ហាត់បង្ហាញកូនប្រសា ឲ្យធ្វើរាជការជាមួយ តែងចូលគាល់បម្រើស្ដេចរៀងរាល់ថ្ងៃ ដរាបមក ។

លុះកន្លងមកបានបីខែ មានគេជំរាបថា « កូនប្រសាលោក មិនមែនកើតឆ្នាំខែ

ថ្ងៃដូចលោកទេ, រឿងនេះ គឺបុរសនោះ សួរឆ្នាំខែថ្ងៃរបស់លោកអំពីសំណាក់លោកយាយជាមាតា ឯលោកយាយក៏បានប្រាប់ដោយសព្វគ្រប់, កូនប្រសាលោកបានស្តាប់ដឹងអស់ហើយ ក៏សរសេរចុះក្នុងកំណាត់សំពត់សទុក លុះដល់លោកសួរឆ្នាំខែថ្ងៃខ្លួន ក៏ជូនកំណត់នោះមកលោក ។ មើលទៅឃើញថា កើតឆ្នាំខែថ្ងៃដូចលោក ។ ក៏ឲ្យកូនក្រមុំធ្វើជាភរិយា រឿងនេះ មិនមែនដូច្នោះទេ គឺក្លែងសរសេរទុកជាប្រាកដ » ។ លោកក្រឡាហោម ក៏ជឿជាក់ឥតសង្ស័យ ហើយមានចិត្តទោមនស្សជាខ្លាំង គិតថា « មិនគួរនឹងចាញ់ប្រាជ្ញាអាមនុស្សកំសត់នេះសោះ » ក៏រកឧបាយនឹងផ្តាច់កូន បណ្តេញចោលចេញ ។

ក្រោយនោះ មានទ័ពចោរ បះបោរនៅខេត្តក្រៅជាច្រើន ។ ស្តេចទ្រង់ជ្រាបទ្រង់ត្រាស់ប្រើលោកក្រឡាហោម ឲ្យនាំសេនាទាហានទៅបង្ក្រាប ប៉ុន្តែពួកទ័ពចោរ មិនបានរាបទេ, កាលបើដូច្នោះ លោកក្រឡាហោម ក៏លើកទ័ពត្រឡប់មកក្រាបបង្គំទូលស្តេចវិញ ។ ស្តេច ត្រាស់ប្រើឲ្យនាំសេនាទាហានទៅបង្ក្រាបទ័ពចោរទៀត ក៏នៅតែមិនរាបទាបទៀត, លោកក្រឡាហោម ក៏លើកទ័ពត្រឡប់យកសេចក្តីមកក្រាបបង្គំទូលថា « ទូលព្រះបង្គំជាខ្ញុំ លើកទ័ពទៅបង្ក្រាបទ័ពចោរពីរដងហើយនៅតែមិនឈ្នះវា ព្រោះពួកវាមានសេនាទាហានច្រើន ហើយពូកែផង ទូលព្រះបង្គំជាខ្ញុំ នឹងនាំសេនាទាហានទៅទៀតពុំបាន ត្បិតមានជម្ងឺក្នុងខ្លួនច្រើន សូមទ្រង់ចាត់មន្ត្រីណាមួយ ដែលមានស្វាហាប់ ឲ្យនាំសេនាទាហាន ទៅបង្ក្រាបទ័ពចោរទាំងនោះឲ្យទាប់, ឯកូនប្រសាប្រុសម្នាក់របស់ទូលព្រះបង្គំជាខ្ញុំ ជាមនុស្សមានចិត្តទាហានហានក្លាដែរ ចំណេះវិជ្ជាក្នុងខ្លួនវា ក៏មានច្រើន, បើទ្រង់ចាត់ឲ្យវាទៅវានឹងហ៊ានទៅមិនខ្លាច » ។ ការដែលលោកក្រឡាហោមទូលដូច្នេះ គឺជាឧបាយដោយស្អប់កូនប្រសានោះណាស់ ព្រោះយល់ថា បើវាលើកទ័ពទៅហើយ ទ័ពចោរទាំងនោះ នឹងសម្លាប់វាមិនខាន ។ ស្តេចទ្រង់ព្រះសណ្តាប់ ក៏ឲ្យហៅកូនប្រសានោះមក ទ្រង់មានព្រះរាជឱង្ការប្រាប់ ថា « នៅខេត្តក្រៅ មានទ័ពចោរបះបោរ-

ច្រើន, ឥឡូវ យើងប្រើអ្នកឯងឲ្យនាំសេនាទាហាន ទៅបង្ក្រាបទ័ពចោរទាំងនោះ អ្នកឯងហ៊ានទៅឬទេ? បើហ៊ានទៅ ហើយឈ្នះចោរផង យើងនឹងឲ្យរង្វាន់»។

បុរសនោះ ទូលថា «ទូលព្រះបង្គំជាខ្ញុំ ហ៊ានទទួលទៅធ្វើរាជការថ្វាយ»។ ទ្រង់មានព្រះរាជឱង្ការ ថា «បើដូច្នោះ ចូលអ្នកឯង នាំសេនាទាហានទៅជាឆាប់»។ បុរស ថ្វាយបង្គំលាមកផ្ទះជំរាបលោកក្រឡាហោមជាបិតាក្មេក តាមរឿងគ្រប់ប្រការ រួចលើកទ័ពចេញទៅ ទ័ពចោរបានដឹង ក៏លើកទ័ពមកតតាំងច្បាំងគ្នាជាខ្លាំងក្លា ។ ទ័ពចោរទ្រាំពុំបាន ក៏បរាជ័យ បាក់បបខ្ចបខ្ចាចរត់ខ្ចាត់ខ្ចាយវិនាសអស់ទៅ ។ បុរស លើកទ័ពបង្ក្រាបរាបគ្រប់អន្លើ រួចនាំសេនាទាហានត្រឡប់មកវិញ ក្រាបបង្គំគាល់ ទូលរឿងច្បាំងនឹងទ័ពចោរគ្រប់សេចក្តី ។ ស្តេចជ្រាបទ្រង់ព្រះអំណរពន់ប្រមាណ ។

ឯលោកក្រឡាហោម ដឹងថា «កូនប្រសា លើកទ័ពទៅបង្ក្រាបចោររាបទាបអស់ដូច្នោះ ក៏មានចិត្តទោមនស្សរឹតតែខ្លាំងឡើង ពីព្រោះគិតថា ដែលឲ្យវាទៅបង្ក្រាបទ័ពចោរនោះ ដើម្បីឲ្យពួកចោរសម្លាប់វា ឥឡូវទៅជាវាមានជ័យជំនះវិញ»។ ឯរោគលោកក្រឡាហោម រឹងរឹតតែរើខ្លាំងឡើងលើសដើម ពេទ្យមើលពុំជា ក៏ទទួលមរណភាពទៅ ។ ស្តេចជ្រាបទ្រង់ព្រះចិន្តា ថា «នឹងឲ្យឈ្មោះណាធ្វើក្រឡាហោម ? » ទ្រង់ព្រះចិន្តាទៅឃើញតែបុរសដែលវាយទ័ពចោររាបទាបនោះឯងមានគុណបំណាច់នឹងរាជការ គួរតែឲ្យធ្វើជាក្រឡាហោមបាន» ទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏ត្រាស់ឲ្យហៅបុរសនោះមកគាល់ ហើយទ្រង់ព្រះមេត្តាប្រោស តាំងឲ្យធ្វើទីក្រឡាហោម តំណាងបិតាក្មេកទៅ ។

**មនុស្ស កុំមើលងាយមនុស្ស**

# ៣១– រឿង បុរសជីកក្ដាម(១)

និទាន ១ ថា: មានបុរសប្ដីប្រពន្ធ មានកូនប្រុសមួយ កូនរនោះអាយុបាន ១២ ឆ្នាំ មាតាស្លាប់ទៅ នៅតែឪពុកពោះម៉ាយ ។ ឪពុកក៏ធ្វើរបរលក់ដូវតែពីរនាក់នឹងកូន លក់មិនដាច់ រឹតតែក្រទៅ ៗ, ក្រោយមក ឪពុកអនិច្ចកម្មទៅទៀត នៅតែកូនម្នាក់ឯង រក្សាផ្ទះសំបែង ។ ឪពុកស្លាប់ទៅបាន ៥ ថ្ងៃ ក៏មកពន្យល់សប្ដិ ថា "កូនឯងក្រលំបាកណាស់ យើងជាឪពុក គ្មានរបស់អ្វីនឹងឲ្យទេ, ដូច្នេះ ឲ្យកូនទៅជីកក្ដាមនៅក្រោមខ្ទមរនូកតា ទាទិសព្ឋិសានផ្ទះយើង យកទៅលក់ចិញ្ចឹមជីវិត រៀងរាល់ថ្ងៃចុះ, វេលាព្រឹក ថ្ងៃរះឡើងកាលណា ឲ្យកូនទៅជីកយករាល់ថ្ងៃកុំខាន " ។

លុះភ្លឺច្បាស់ កូននោះភ្ញាក់ឡើង ចាំជាក់នូវនិមិត្តសព្វគ្រប់ ក៏ចាប់យកចបដើរតម្រង់ទៅខ្ទមរនូកតា ជីកទៅឃើញក្ដាមមួយប្រាកដមែន រួចយកក្ដាមនោះទៅលក់ឲ្យអ្នកផ្សារ ។ ក៏ទិញយក ។ បុរសនោះបានប្រាក់ហើយត្រឡប់មកវិញ ។

ថ្ងៃក្រោយ វេលាព្រឹក បុរស ទៅជីកក្ដាមនៅកន្លែងដដែលនោះ បានក្ដាមមួយយកទៅលក់ឲ្យអ្នកផ្សារ គេក៏ទិញយកទៅទៀត ។ បុរសនោះ ត្រឡប់មកផ្ទះវិញ ។

នៅទីនោះ មានមហាសេដ្ឋីម្នាក់ មានកូនស្រីក្រមុំច្រើន កូនស្រីបង ៗ ទាំងប៉ុន្មានមហាសេដ្ឋីរៀបឲ្យមានប្ដីអស់ នៅតែកូនស្រីពៅម្នាក់ ឈ្មោះនាងពៅ ប្រកែកមិនព្រមយកប្ដី, សូម្បីមហាសេដ្ឋីជាឪពុកម្ដាយ បង្ខំឲ្យមានប្ដីម្ដេចម្ដា ក៏នាងមិនព្រម ។

---

១– កម្ពុជសុរិយា លេខ ៧-៨-៩- ឆ្នាំ ១៩៣៩ ទំព័រ ២៥៧ រៀបរៀងដោយ ឧកញ៉ាប្រាជ្ញាធិបតី ជាងហ៊្វាង ឃឹម ។

រីឯបុរសនោះ លុះថ្ងៃក្រោយ ទៅដីកក្ដាមនៅទឹកខ្នែងដដែល បានមួយទៀត ហើយកាន់បកទៅលក់ ។ នាងពៅ កូនក្រមុំមហាសេដ្ឋីបានឃើញ ក៏ហៅមក សួរថា « អ្នកកំឡោះ យួរក្ដាមទៅណា ? » ។ បុរសនោះ ជំរាបថា " ខ្ញុំយក ទៅលក់ " ។ នាងពៅ ក៏ទិញយក ហើយនាងប្រាប់ថា « ពីថ្ងៃនេះទៅ បើអ្នក បានក្ដាម កុំលក់ឲ្យអ្នកណា ត្រូវអ្នកយកមកលក់ឲ្យខ្ញុំ រាល់ថ្ងៃកុំខាន » ។ ដែល ទៅជាយ៉ាងនេះ ដោយនាងនោះ មានចិត្តប្រតិពទ្ធនឹងបុរសនោះណាស់ តែអ្នកនោះ មិនដឹងខ្លួនទេ ។ បុរសនោះ បានប្រាក់ហើយត្រឡប់មកផ្ទះវិញ ។ ថ្ងៃក្រោយ បុរសនោះ ទៅដីកក្ដាមនៅទឹកខ្នែងដដែលបានទៀត រួចយកមកលក់ឲ្យតែនាងពៅ នោះរាល់ ៗ ថ្ងៃ ។ នាងពៅ ក៏ចេះតែទទួលទិញយកក្ដាមមិនដែលខាន ហើយមាន ចិត្តរឹតតែស្រឡាញ់បុរសនោះខ្លាំងឡើង ក៏ធ្វើឫកពាកិរិយាឲ្យបុរសនោះដឹង ។ បុរសនោះដឹងជាក់ថា " នាងនោះ ស្រឡាញ់ខ្លួនប្រាកដ " តែដោយពិចារណាថា សព្វថ្ងៃនេះ ខ្លួនជាអ្នកក្រីក្រលំបាកណាស់ ហើយកំព្រាផង ក៏មិនហ៊ាននិយាយថា ម្ដេចឡើយ ។

ចំណែកបងស្រី ៗ ប៉ុន្មាននាក់ បានឃើញនាងពៅជាប្អូន ធ្វើឫកពាកិរិយា ស្រឡាញ់បុរសលក់ក្ដាមនោះពន់ពេក ក៏នាំគ្នាទៅជំរាបមហាសេដ្ឋី ជាមាតាបិតា « នាងពៅជាប្អូន ធ្វើឫកពាស្រឡាញ់បុរសដីកក្ដាមនោះក្រៃពេក, បុរសនោះ បាន ក្ដាម យកមកលក់ឲ្យតែនាងពៅ, ឯនាងពៅ ចេះតែទទួលទិញរាល់តែថ្ងៃ រួចធ្វើឫក ពាកិរិយាស្រឡាញ់បុរសនោះណាស់ ទោះបីខ្ញុំទាំងអស់គ្នា និយាយទូន្មានដូចម្ដេច ក៏មិនស្ដាប់មិនតាម រឹតតែធ្វើខ្លាំង » ។ សេដ្ឋីជាបិតាមាតា ឮដូច្នោះ ខឹងច្រឡោត ឲ្យហៅនាងពៅមក ជេរបន្ទោស ត្មះតិះដៀល ថា « ហងនេះ ជាមនុស្សរឹងត្អឹង ទទឹងនឹងចិត្តមាតាបិតា, អញឲ្យមានប្ដី ទៅមនុស្សមានទ្រព្យសម្បត្តិ ហងឯង ប្រកែកមិនព្រមយក, ឥឡូវហងស្រឡាញ់អាមនុស្សកំសត់លក់តែក្ដាមវិញ ហងឯង នេះ អាក្រក់ណាស់ ចុះចេញពីផ្ទះអញឲ្យឆាប់ ទៅយកអាកំសត់លក់ក្ដាមនោះចុះ,

ចាប់ពីថ្ងៃនេះទៅ ហែងឯង កុំបកទៀងផ្ទះអញ សូម្បីតែក្នុងភូមិ ក៏ចូលមិនបាន អញកាត់ចោលហើយ » ។ ចំណែកមាតា កាត់ចិត្តមិនដាច់ពីកូនពៅ ក៏លបវេចរបស់ស្រាល ៗ ដែលមានតម្លៃ ឲ្យនាងពៅជាកូន ។ នាងពៅ ក៏សំពះលាមាតា យកបង្វេចដែលមាតាឲ្យនោះចុះ ចេញពីផ្ទះ សំដៅទៅផ្ទះបុរសលក់ក្តាម និយាយពីរឿងដែលបិតាខឹងបណ្តេញសព្វគ្រប់ ប្រាប់បុរសនោះ ។ បានស្តាប់ហើយ ឆ្លើយតបថា « សព្វថ្ងៃ ខ្លួនខ្ញុំនេះ ក្រីក្រជាទីបំផុត ហើយកំព្រាតែម្នាក់ឯងផង នាងត្រឡប់ទៅវិញចុះ ខ្ញុំមិនហ៊ានទទួលយកនាងទេ ខ្ញុំខ្លាចមហាសេដ្ឋីជាបិតានាងចាប់ទោស យកខ្ញុំទោសម្លាប់ » ។ នាងពៅ តបថា « ខ្ញុំមិនទៅវិញទេ ស៊ូស្លាប់នឹងអ្នកហើយ ! » ។ បុរសនោះ សួរថា " បើដូច្នេះ យើងគិតដូចម្តេច ? " ។ នាងពៅ ឆ្លើយថា " បើអ្នកគិតឃើញយ៉ាងណា ខ្ញុំទទួលធ្វើតាមយ៉ាងនោះទាំងរស់ " ។

បុរសនោះ នាំនាងពៅចេញចោលផ្ទះ ទៅនៅស្រុកក្រៅ ហើយធ្វើផ្ទះ ១ ខ្នងសម្រាប់, លុះព្រឹកឡើងមកជីកក្តាម នៅទីដដែល យកទៅលក់ដូចថ្ងៃមុនទៀត, បានប្រាក់ហើយ ទិញវត្ថុផ្សេង ៗ ផ្ញើប្រពន្ធ ហើយប្រព្រឹតយ៉ាងនេះ ជាច្រើនថ្ងៃ ។ ហេតុតែជាស្រីគ្រប់លក្ខណ៍ នាងពៅនោះ ក៏បម្រើប័តន៍ប្តីមិនឲ្យទាស់ចិត្ត, វេលាយប់ចូលដំណេក នាងពៅ និយាយនឹងប្តី ថា « ខ្ញុំសូមចិត្តប្តី ! តាំងពីថ្ងៃនេះតទៅ សូមអ្នកកុំទៅជីកក្តាមទៀតឡើយ ព្រោះប្រាក់កាសយើង មានច្រើនហើយ, បើអ្នកចង់ទិញរបស់អ្វី ៗ ក៏ទិញតាមចិត្តអ្នកចុះ ។ ប្តីមិនព្រមតាម ។

លុះព្រឹកឡើង ប្តីកាន់ចបទៅជីកក្តាមទៀត ។ ប្រពន្ធឃើញដូច្នោះ ក៏លបដើរតាមទៅមើលដល់ទីកន្លែង ឲ្យឃើញច្បាស់ មិនឲ្យដឹង, លុះឃើញច្បាស់ហើយ ក៏ត្រឡប់មកផ្ទះវិញ ។ ចំណែកប្តី ជីកបានក្តាមហើយ, យកទៅលក់ រួចទិញម្ហូបចំណីផ្ញើប្រពន្ធ ។

ថ្ងៃក្រោយ ប្តីទៅកាប់ឧសក្នុងព្រៃឆ្ងាយ នាងពៅ បានឃើញប្តីទៅរកឧស ក៏កាន់ចបទៅជីករំលើង នៅទីកន្លែងដែលប្តីជីកក្តាមនោះអស់ រួចត្រឡប់មកផ្ទះវិញ

ធ្វើម្ហូបចំណីទុកឲ្យប្ដីបរិភោគ, ថ្ងៃល្ងាចត្រជាក់ ប្ដីមកពីព្រៃ ក៏បរិភោគបាយជាមួយគ្នា។

លុះព្រឹកឡើង ប្ដីកាន់ចបទៅជីកក្ដាមទៀត ឃើញទឹកន្លែងដីនោះធ្លុះធ្លាយរលើង



រលុះខ្វាត់ខ្វាយអស់ ហើយបានឃើញសំបកក្ដាមមួយធំប្លែកស្អួតស្អាត ដូចជាហាលថ្ងៃយូរហើយ, អ្នកនោះ ក៏កាន់សំបកក្ដាមយកមកទុកក្រោមផ្ទះ មិនបានប្រាប់ភរិយាឲ្យដឹងទេ, ភរិយា ក៏សួរប្ដីថាដូចម្ដេចឡើយ ។ ដល់វេលាយប់ចូលដំណេក នាងពៅកាន់ប្រាក់របូតពីដៃជ្រុះមួយណែនទៅក្រោមផ្ទះ ធ្លាក់ទៅលើសំបកក្ដាមនោះ នាងមិនហ៊ានប្រាប់ឲ្យប្ដីដឹង ដោយគិតថា " ចាំព្រឹកភ្លឺច្បាស់ឡើង សឹមចុះទៅយកប្រាក់មកទុកវិញ " ។ លុះព្រឹកឡើង នាងចុះពីផ្ទះទៅយកប្រាក់មួយណែនដែលធ្លាក់នោះស្រាប់តែឃើញប្រាក់ណែនពេញសំបកក្ដាម នាងអរណាស់ យកមកឲ្យប្ដី ៗ សួរថា " នាងបានប្រាក់ពីណាច្រើនម្ល៉េះ ? ។ នាងពៅជំរាបប្ដីថា " កាលពីយប់មិញ ខ្ញុំកាន់ប្រាក់ ដើម្បីយកទៅទុកខាងក្នុង ក៏របូតមួយណែនពីដៃ ធ្លាក់ទៅក្រោមផ្ទះ ខ្ញុំពុំបានចុះទៅយក ពីព្រោះគិតឃើញថា " ផ្ទះនៅឆ្ងាយពីគេ គ្មាននរណាដឹង ឬឃើញ

ចាំព្រឹកភ្លឺច្បាស់សឹមចុះទៅយកមកទុក, លុះព្រឹកឡើង ខ្ញុំចុះទៅយក ស្រាប់តែឃើញប្រាក់ណែនពេញសំបកក្តាម ខ្ញុំក៏យកមកជូនអ្នក » ។ ប្តី មានអំណរពន់ប្រមាណ ហើយនិយាយប្រាប់ប្រពន្ធថា « ពីថ្ងៃនេះតទៅ បងឈប់ជីកក្តាមហើយ » ។ ប្រពន្ធអរណាស់ ។ រាល់តែវេលាយប់ អ្នកទាំងពីរនាក់ប្តីប្រពន្ធ នាំគ្នាទំលាក់ប្រាក់ទៅចំសំបកក្តាមធំ ព្រឹកឡើង ចុះទៅមើល ឃើញប្រាក់ពេញសំបកក្តាមនោះ ក៏យកមកទុករៀងរាល់ថ្ងៃ, ទើបទម្លាក់ប្រាក់រៀល ព្រឹកឡើង ឃើញប្រាក់រៀល ទើបទម្លាក់ប្រាក់ណែន ព្រឹកឡើង ឃើញប្រាក់ណែន ទើបទម្លាក់គ្រឿងមាសពេជ្រ ព្រឹកឡើង ឃើញគ្រឿងមាសពេជ្រ ពេញសំបកក្តាម ។ អ្នកទាំងពីរប្រព្រឹត្តយ៉ាងនេះចំនួនមួយឆ្នាំ មានប្រាក់មាសនិងគ្រឿងប្រដាប់ប្រើប្រាស់ច្រើនណាស់រាប់មិនអស់ ទើបប្រឹក្សាគ្នាថា « យើងមានប្រាក់មាស និងគ្រឿងប្រដាប់ច្រើនម្ល៉េះ តើយើងបានអ្វីនឹងទុករបស់ទាំងអស់នេះ ? » លុះគិតឃើញ ក៏នាំគ្នាយកប្រាក់ និងគ្រឿងមាសពេជ្រទាំងអស់ ទៅជីកកប់ទុកច្រើនអន្លើ ។

ក្រោយពីនោះមក ទាំងពីរនាក់ប្តីប្រពន្ធ នាំគ្នាទៅសួរមហាសេដ្ឋីជាមាតាបិតា, ទៅដល់ បងស្រីទាំងអស់បានឃើញ ជេរថា « មេចោរចង្រៃឯង នាំប្តីកំសត់លក់តែក្តាម មករកអ្វី ? ហងឯង បានឮឬទេ លោកឪពុក បណ្តេញកាត់កាល់ចោលហើយ សូម្បីតែក្នុងភូមិ ក៏លោកហាមមិនឲ្យចូលដែរ ? មេចង្រៃឯង ចេញពីភូមិឲ្យឆាប់ » ។ នាងពៅឆ្លើយថា « បងទាំងអស់ កុំមើលងាយខ្ញុំ ៗ មកនេះដើម្បីសួរមាតាបិតា ព្រោះលោកមានគុណលើខ្ញុំ ។ មិនមកសុំទ្រព្យសម្បត្តិលោកទេ, សម្បត្តិបងឯងទាំងអស់ ក៏ខ្ញុំមិនសុំដែរ ខ្ញុំមើលទៅទ្រព្យសម្បត្តិបងទាំងអស់ មានប៉ុណ្ណោះ ខ្ញុំមិនកោត មិនព្រឺឡើយ សូម្បីតែរោមជើងខ្ញុំ ក៏វាមិនព្រឺផង » ។

បងទាំងអស់ ខឹងណាស់ ជេរប្រទេចថា « ហងឯងនេះ អួតណាស់ អញមិនជឿទេ » ។ នាងពៅ ថា « បើមិនជឿ ភ្នាល់គ្នាចុះ » ។ បងទាំងនោះ ថា « ភ្នាល់ដូចម្តេច ? » ។ នាងពៅ ថា « ឲ្យបងទាំងអស់ រាប់ប្រាក់ខ្ញុំមើល ឲ្យអស់

ក្នុងមួយថ្ងៃ បើរាប់អស់ ខ្ញុំបែងចែកឲ្យរាល់គ្នា បើរាប់មិនអស់ ខ្ញុំមិនឲ្យទេ តែខ្ញុំយល់ថា កុំថាឡើយរាប់មួយថ្ងៃ ទោះជារាប់ពីរ ឬ បីថ្ងៃ ក៏មិនអស់ដែរ » ។ បងទាំងនោះ ឆ្លើយថា « អញព្រមទៅរាប់ តែហាងកុហក អញវាយហាងសម្លាប់ »។ នាងពៅប្រាប់ថា « តាមចិត្ត » ។ បង ៗ នាំគ្នាទៅរាប់ប្រាក់នាងពៅ រាប់តាំងពីព្រឹកទល់ល្ងាច ក៏មិនអស់ នាំគ្នាត្រឡប់មកផ្ទះវិញ ជំរាបសេដ្ឋីជាមាតាបិតាថា «នាងពៅជាប្អូន វាអួតថា ខ្លួនវាមានប្រាក់ច្រើន ខ្ញុំទាំងអស់គ្នាមិនជឿ ហើយវាថា បើមិនជឿទេ ឲ្យទៅមើលឯផ្ទះវាចុះ ខ្ញុំទាំងអស់គ្នាក៏ទៅមើល ឃើញវាមានប្រាក់ច្រើនមែន ក៏ភ្នាល់នឹងវា ៗ ថា បើខ្ញុំទាំងអស់គ្នា រាប់ប្រាក់វាអស់ក្នុងមួយថ្ងៃ វានឹងឲ្យខ្ញុំយកចែកគ្នាចុះ បើរាប់មិនអស់ វាមិនឲ្យទេ, ទោះខ្ញុំទាំងអស់គ្នា ចាប់រាប់តាំងពីព្រឹកទាល់ល្ងាច ក៏មិនអស់ប្រាក់វា បានជាត្រឡប់មកជំរាបមាតាបិតា សូមជ្រាប » ។ មហាសេដ្ឋីបានស្តាប់ ក៏ចាត់ក្រមការឲ្យទៅមើលប្រាក់នាងពៅ ឲ្យជាក់ច្បាស់ ។ នាងពៅ ក៏នាំទៅមើលគ្រប់កន្លែង ។ ក្រមការទាំងនោះ បានឃើញប្រាក់នាងពៅ មានច្រើនប្រាដកមែន ក៏ត្រឡប់មកជំរាបមហាសេដ្ឋីតាមដំណើរសព្វគ្រប់ ។ មហាសេដ្ឋី បានជ្រាប មានចិត្តត្រេកអរណាស់ ក៏ចាត់បំរើឲ្យទៅហៅនាងពៅ និងកូនប្រសាមក ប្រាប់ថា « កូនឯង បកទៅជាមួយនឹងមាតាបិតាវិញចុះ » ទើបមហាសេដ្ឋី បង្គាប់ក្រមការឲ្យកេណ្ឌរទេះក្របីគោជាច្រើន ទៅដឹកជញ្ជូនប្រាក់និងទ្រព្យសម្បត្តិនាងពៅ យកមកទាំងអស់ ដាក់លើផ្ទះពាសពេញល្វែង ។ មហាសេដ្ឋី ឃើញប្រាក់នាងពៅច្រើនមែន បានអំណរពន់ប្រមាណ ក៏សរសើរថា « កូនអញនេះ ពេញជាមានបុណ្យ អំណើះតទៅកូនទាំងពីរនឹងបានធ្វើជាសេដ្ឋីដំណ-វង្សពុំខាន, ឯការណ៍ដែលបិតាខឹង បណ្តេញកូននោះ អ្នកកុំប្រកាន់ខឹងនឹងបិតា »។ នាងពៅ និងប្តី ក៏នៅផ្ទះជាមួយមាតាបិតាដូចដើមវិញ ។ ចំណែកបងស្រីទាំងប៉ុន្មានក៏កោតខ្លាចនាងពៅ និងប្អូនថ្លៃនោះណាស់ ។ លុះមហាសេដ្ឋីជាបិតា ទទួលមរណ-ភាពទៅវេលាណា ប្តីនោះនិងនាងពៅភរិយា ក៏បានឡើងធ្វើជាសេដ្ឋី ជំនួសបិតាតទៅ ។

## ឈើពុក កុំដាក់គូថអង្គុយ

## ៣២– រឿង ស្រីមាយាដកខ្វី(១)

មានបុរសម្នាក់និងស្រីម្នាក់ ជាប្តីប្រពន្ធ នៅក្នុងស្រុកមួយ ប្តីជាមនុស្សចិត្តត្រង់ តែគ្មានប្រាជ្ញា ឯនាងប្រពន្ធនោះ ជាស្រីចិត្តមិនត្រង់នឹងប្តី តែចេះមាយាច្រើន ។

ថ្ងៃមួយ នាងប្រពន្ធ មានចិត្តប្រាថ្នាចង់ជួបនឹងសហាយណាស់ ដោយឃ្លាតគ្នាយូរហើយ តែមិនដឹងជាធ្វើម្តេចនឹងទៅជួបបាន ព្រោះភូមិនោះ នៅឆ្ងាយពីគ្នាបើដើរទៅ ខ្វាចខ្មោចលង ។ នាងប្រពន្ធ ក៏និយាយនឹងប្តីខ្លួនថា « អ្នក ! ល្ងាចនេះ យើងគិតទៅរកទិញមាន់មួយ មកធ្វើស៊ីបាយម្តង អ្នកចង់ស៊ីទេ ? » ។ ប្តីតបវិញថា « ចង់ស៊ីដែរ » ។ ប្រពន្ធថា « ខ្ញុំចង់ស៊ីខ្វះខ្វី » ។ ប្តីថា « អើ ! អញ ក៏ចង់ស៊ីខ្វះខ្វីដែរ » ថាហើយ ក៏បបួលគ្នាចុះដើរទៅទិញមាន់អ្នកស្រុក នៅភូមិជិតផ្ទះសហាយនោះ ។ ប្តីនិងប្រពន្ធ បបួលគ្នាសួររកទិញគ្រប់តែផ្ទះ ។ នាងប្រពន្ធ ដើរបែកពីប្តី ទៅជួបសហាយ វានិយាយកិច្ចកលផ្សេង ។ រួចមកជួបនឹងប្តីវិញ ហើយប្រាប់ប្តី ថា «អ្នក ! ផ្ទះឯណោះ គេមានមាន់លក់ គេប្រាប់ខ្ញុំអម្បាញមិញ » ។ ប្តី ព្រមទៅតាមប្រពន្ធប្រាប់ ក៏ទិញបានមេមាន់មួយ យួរត្រឡប់មកផ្ទះវិញ ពេលនោះ ជាពេលពន់ព្រលប់ ទៅដល់ពាក់កណ្តាលផ្លូវ ស្រាប់តែនាងប្រពន្ធ ធ្វើមាយាគក់ដើមទ្រូងហើយ ថា « ឱ អ្នកអើយ ! ភ្លេចដូចគេលត់ទៅហើយ » ។ ប្តី សួរថា « ភ្លេចអី ? » ។ ប្រពន្ធ ថា " ភ្លេចខ្វីទៅហើយ អ្នក ! បើដូច្នោះអ្នកឯងនៅ ។ នេះសិនចុះ ខ្ញុំរត់ទៅ វាឆាប់ " ហើយ

១ កម្ពុជសុរិយា លេខ ១-២ ឆ្នំ ឆ្នាំ ១៩៣៨ ទំព័រ ១៣។ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

នាងនោះ វត់ទៅ ។ ប្ដី ក៏ឈរចាំប្រពន្ធ ។ ឯនាងប្រពន្ធ កាលឃ្លាតពីប្ដីហើយ ក៏គេចទៅជួបនឹងប្រុសសហាយខ្លួន ហេតុតែរឭកសហាយខ្លាំងណាស់ ក៏ប្រះដេកទៅ ដី មិនរកផ្ទះសម្បែងទេ ដោយប្រញាប់ទៅជួបប្ដីវិញ ។

ឯបុរសសហាយនោះ ក៏ទទួលភារៈនាងនោះទៅ រួចនាងនោះយកខ្ទីពីសហាយ ហើយផ្ដាំ ថា « ល្ងាចនេះ ឲ្យអ្នកបងចាំមើល បើមានពេលស្រួល ចូលទៅដេក ម្ដងទៀតចុះ » និយាយកិច្ចការសព្វគ្រប់ហើយ នាងនោះ ក៏ត្រឡប់មកឯប្ដីដើម វិញ ។ ដីដែលប្រះដេកនោះ ក៏នៅជាប់នឹងខ្នង មិនទាន់បោសនៅឡើយ ព្រោះ ដើរមកដោយប្រញាប់ លុះដើរមកដល់ប្ដីខ្លួនហើយ ក៏សើចក្អាកក្អាយ និយាយ ទៅកាន់ប្ដី ថា " បើអ្នកឃើញអំមិញប្រហែលជាសើចដាច់ខ្យល់ស្លាប់ហើយ " ។ ប្ដីសួរថា « សើចអី ? » ។ ប្រពន្ធ តបថា " នែ ! អ្នកមើលខ្នងខ្ញុំ បោស ឲ្យបន្តិចមក ! ហ្នឹងហើយខ្ញុំដកខ្ទី វារបូតដៃទាំងអស់ ខ្ញុំដួលផ្ងារទៅក្រោយ បះ ជើងច្រោង បានជាដីប្រឡាក់ខ្នងខ្ញុំអស់ " ។ ប្ដី មិនដឹង ក៏បោសខ្នងឲ្យប្រ- ពន្ធទៅ រួចហើយនាំគ្នាដើរទៅផ្ទះ ធ្វើបាយនិងមាន់ស៊ុ ធ្វើរួចហើយ ពេលងងឹត ស៊ីបាយរួច ប្រពន្ធនិយាយនឹងប្ដី ថា " អ្នក ! ផ្លុំប៉ីទៅ ខ្ញុំនឹងស្ដាប់ " ប្ដី ក៏យក ប៉ីមកផ្លុំ ។ ប្រពន្ធ ដេកស្ដាប់ ។ បន្តិចទៅ ក៏កិលបកដេកលើភ្លៅប្ដី ហើយថា " ពីរោះណាស់ អ្នក ! អ្នកផ្លុំប៉ី ភ្នែកមើលរន្ធដែរឬទេ ? បើអ្នកមិនមើលរន្ធ ធ្វើ ម្ដេចនឹងចាប់បើកបទឲ្យត្រូវទំនុក? " ។ ប្ដី តបថា ទេ ! « មិនបាច់មើលរន្ធទេ ព្រោះដៃចាំស្ទាត់ ហើយចំណាំរន្ធផង » ។ ប្រពន្ធ ថា " បើដូច្នេះ ខ្ញុំបិទភ្នែក អ្នកទាំងពីរមើល អ្នកនៅតែផ្លុំពីរោះដូចដែលឬទេ ? " ។ ប្ដីតបថា " បិទចុះ ក៏ នៅតែផ្លុំពីរោះដូចមុនដែរ " ។ ប្រពន្ធ យកដៃបិទភ្នែកប្ដីខ្លួនទាំង ២ រួចហើយក៏ កន្ទែកជើងឲ្យសហាយនោះឃើញ ។ បុរសសហាយ ឃើញស្រីសហាយខ្លួនបិទភ្នែក ប្ដីបាន ហើយកន្ទែកជើងឲ្យសញ្ញាដូច្នោះ ក៏ចូលទៅរួមសំវាសនឹងនាងនោះទៅ ។

លុះសហាយនោះ ថយចេញ ទើបប្រពន្ធលែងបិទភ្នែកប្ដី ។ ប្ដីនាង ក៏មិន អាចដឹងដល់កិច្ចកលនោះឡើយ ។

ព្រោះហេតុនេះ បានជាមានពាក្យបុរាណ ថា « មាយាដកខ្វិ » មានទាំងទំនុកច្រៀងផង ថា :

ស្រីទោដកខ្វិ ស្រីអើយនាងស្រី
ស្រីទោដកខ្វិ ដកដួលទាំងខ្លួន ។
កាលដកលើកមុន តូចតន់លាក់ពួន
ដកក្រោយសំនួន ផ្ទួនឲ្យប្ដីស្លាប់ ។
ប្ដីនាងអ្នកផ្ទុំ នាងសុំធ្វើគ្រាប់
បន្ទរអើងអាប់ ចប់បទអុំទូក ។

**កុំពត់ស្រឡៅ កុំប្រដៅស្រីខូច**

# ៣៣– រឿង តាចន្ទរំលៀក(១)

មានរឿងមួយ ដំណាលថា ៖ កាលនោះ មានព្រៃមួយធំ មានខ្លាសាហាវ តែងខាំមនុស្សជាច្រើន នឹងចូលទៅរកបោចផ្តៅរល្លីពុំបាន ។ គ្រាដែលតាចន្ទ គាត់ចូលទៅបោចរល្លីក្នុងព្រៃនោះ ខ្លា វាលបចេញពីក្នុងព្រៃ ចង់នឹងខាំតាចន្ទ ដែលចូលទៅបោចរល្លី ។ តាចន្ទ ឃើញវាមុន ហើយគាត់រកពុទ្ធោ ថា ៖

ឱ ! ពុទ្ធោ ៗ អើយ !

ឆ្នាំនេះឆ្នាំខាល ទឹកបែកពាសវាល ស្លាប់ខ្លាដំរី
ស្លាប់អស់បក្សា ម្រឹគាបក្សី ស្លាប់ខ្លាដំរី
គ្មានគង់តូចមួយ ។

ផ្តៅអញនេះ អាណាវែង ៗ អញព្យួរកូនចៅ អាណាខ្លី ៗ អញព្យួរត្បាល់អង្រែ ឧសត្វទាំងឡាយអើយ ! ក្នុងឆ្នាំខាលនេះ នឹងស្លាប់អស់ហើយ គ្មានគង់ទេ " ។

តាចន្ទ និយាយរកពុទ្ធោយ៉ាងនេះ ជាច្រើនដង ខ្លា ស្តាប់បានឮច្បាស់ គិតថា « គួរអញសួរតានេះចង់ដឹងមើល » ។ ទើបខ្លា សួរទៅតាចន្ទវិញថា " តាអើយតា ! ក្នុងឆ្នាំខាលនេះ ទឹកធំមែនឬ ? " ។ តាចន្ទ ធ្វើភ្ញាក់និយាយទៅនឹងខ្លា ថា « ឱចៅ ! ឆ្នាំនេះ ទឹកធំណាស់ បានជាតាភ័យនឹងកូនចៅ ទើបតារកផ្តៅ ដើម្បីចងព្យួរកូនចៅ ឲ្យផុតពីទឹក » ។ ខ្លា ក៏មានចិត្តភិតភ័យនឹងពាក្យតាចន្ទ , គិតខ្លាចស្លាប់ ក៏ចូលមកជិត ហើយនិយាយនឹងតាចន្ទថា « តាអើយ អាណិតចងព្យួរខ្ញុំ ឲ្យផុតពីទឹកផង

១ កម្ពុជសុរិយា លេខ ៤-៥-៦ ឆ្នាំ ១៩៣៤-៥ ទំព័រ ៥៣ រៀបរៀងដោយ ឃុន អក្ខរាឯក ។

បានឬទេ ? » ។ តាចន្ទឆ្លើយថា « បាន មិនអីទេ ចៅ ! អង្គុយមក ចាំតានៅទីនេះសិនចុះ » ។ ខ្លា ក៏ចូលមកអង្គុយចាំ ។ លុះតាចន្ទបោចវល្លិ៍ផ្ដៅបាន ក៏ត្រកួញធ្វើជារង្វង់ ហើយចូលទៅចងចង្កេះខ្លា ។ តាចន្ទ កាន់គល់ផ្ដៅឡើងទៅលើដើមឈើខ្ពស់ ហើយបង្គាប់ខ្លាឲ្យលោតឡើង ។ តាចន្ទ ក៏ស្រាវទាញឡើងឲ្យផុតជើងខ្លាពីដី រួចគាត់ចុះមកវិញ ។ ខ្លា សួរថា « តា ! ប៉ុណ្ណេះផុតពីទឹកហើយឬអ្វី ? » ។ តាចន្ទ ឆ្លើយថា « ផុតហើយចៅ ! ។ តាចន្ទ ក៏កាន់កាំបិតទៅកាប់ឈើជាដំបង ។ ខ្លាឃើញ សួរថា " តា ! តាកាប់ដំបងធ្វើអ្វី ? " ។ តាចន្ទថា « កាប់យកទៅផ្ទះ ក្រែងប្រទះនឹងសត្វឯទៀត វាប្រមាទតា » ។ ខ្លាឆ្លើយថា " គ្មានខ្លាឯណាទេ តា ! មានតែខ្ញុំនេះឯង. តែងតែខាំគេរាល់ថ្ងៃ " ។ តាចន្ទ ដឹងថា « ឱ ! អានេះជាសត្វកាច បើដូច្នេះ អញនឹងវាយឲ្យអស់ចិត្ត ក្នុងគ្រានេះ " ។ ទើបតាចន្ទ កាន់ដំបងចូលទៅដល់ខ្លា ថា " ចៅនៅឲ្យស្ងៀម តានឹងមើលចំណងឲ្យ ក្រែងវារបូតលង់ទឹកស្លាប់ " ។ ខ្លា ក៏នៅស្ងៀម ។ ទើបតាចន្ទលើកដំបងវាយខ្លា ។ ក៏ប្រឹងរើបម្រះ ស្រែករោទិ៍ រលាករលួតស្បែកហើមខ្លួនជាខ្លាំង មុខគួរវេទនា ហើយខ្លាក៏ប្រឹងរើបម្រះ ក្រឡុះខាំខ្សែផ្ដៅដាច់ គេចរត់ទៅ ។ តាចន្ទ ក៏វិលទៅខ្ទមចាំស្រែវិញ ។

និយាយពីខ្លាដែលរត់រួចទៅនោះ បានទៅជួបនឹងដំរីមួយ ដំរីឃើញខ្លាបោល ក៏ស្រែកសួរថា " បងខ្លាឯង ភ័យនឹងអ្វី ក៏បានជាបោលមិនមើលក្រោយសោះ " ។ ខ្លាប្រាប់ទៅដំរីវិញ ថា " បងអើយ ! អាចន្ទរំលៀក បញ្ឆោតវាយខ្ញុំហើមខ្លួនអស់ "។ ដំរី សួរថា អាចន្ទរំលៀកនោះ " នៅឯណា ? " ។ ខ្លាប្រាប់ថា " វាធ្វើស្រែនៅមាត់បឹងឯនោះ ។ ដំរី ថា « អញនឹងព្រួចឲ្យវាល្អិត កុំឲ្យវាធ្វើបាបគេ " ។ ខ្លាបោលហួសទៅ, ដំរីក៏ដើររកតាចន្ទនឹងព្រួច ជួបនឹងតាចន្ទហើយ តែដំរីមិនស្គាល់ សួរថា « តា ។ ស្គាល់អាចន្ទរំលៀកដែរឬ ? " ។ តាចន្ទ សួរដំរីថា "ចៅឯងសួររកគាត់ធ្វើអ្វី ? " ។ ដំរីថា " ខ្ញុំខឹងណាស់ វាបញ្ឆោតវាយខ្លាហើមខ្លួនអស់ "។ តាចន្ទឆ្លើយថា " តាចន្ទ គាត់នៅខ្ទមស្រែត្រើយខាងកើតមាត់បឹង, ហ្នឹ ! ខ្ទមគាត់ស។

នុះឯង » ។ ដំរីថា « តាអាណិតជូនខ្ញុំទៅ បើខ្ញុំព្រេចរាស្លាប់ បានរបស់អ្វីប៉ុន្មាន ខ្ញុំជូនតាទាំងអស់ » ។ តាចន្ទ ឆ្លើយថា « តាអរណាស់ ចៅអើយ ! ប៉ុន្តែ ទឹក បឹងនេះជ្រៅណាស់ តាទៅមិនរួចទេ » ។ ដំរី ថា « បើទឹកជ្រៅ តាជិះលើ ក្បាលខ្ញុំមក » ។ តាចន្ទ ឆ្លើយថា « អើ បើដូច្នោះ ទៅក៏ទៅ » ។ តាចន្ទ ក៏កាន់កាំបិតព្រាមួយទៅផង, លុះទៅបានចម្ងាយមួយស្រែ តាចន្ទ ក៏កាប់ក្បាលដំរី ៣-៤ កាំបិត មុតចេញឈាម ។ ដំរី ក៏គេចបោលមកវិញ ដល់គោក រលាស់ ទម្លាក់តាចន្ទ ហើយដំរីក៏បោលទៅ ជួបនឹងខ្លាឃ្មុំ ។ ស្រែកសួរ ថា « បងដំរីបោល អ្វីក៏គ្មានមើលក្រោយសោះ » ។ ដំរីប្រាប់ថា : « បងខ្លាឃ្មុំអើយ ! អាចន្ទរំលៀក បញ្ឆោតកាប់ក្បាលខ្ញុំឈាមអស់» ។ ឯខ្លាឃ្មុំ ក៏ជួយខឹងដំរី ហើយសួរទៅដំរីវិញថា « អាចន្ទនោះ វានៅឯណា ? » ។ ដំរីប្រាប់ថា « វានៅធ្វើស្រែនៅមាត់បឹងធំឯ នោះ » ។ ដំរី ក៏បោលបាត់ទៅ ។ ខ្លាឃ្មុំ ក៏មានចិត្តខឹងគុំគួន ប្រមាថ នឹងខំបំ បែកក្បាលតាចន្ទឲ្យស្លាប់ ។ លុះថ្ងៃក្រោយ ខ្លាឃ្មុំដើរ ៗ ទៅ ឃើញតាចន្ទភ្ជួរ ស្រែពេលព្រឹក ។ ខ្លាឃ្មុំ នឹកថា " នេះហើយ តើ អាចន្ទរំលៀកនោះ ដូច្នេះអញ ពួនចាំនៅនេះចុះ ចាំវាមកជិត អញលោតទៅខាំវាឲ្យបាន " ។ ខ្លាឃ្មុំ ក៏ក្រាប ចាំនៅសំយាបព្រៃ ។ តាចន្ទ មិនដឹងខ្លួន ។ តាចន្ទ ភ្ជួរស្រែយូរ គ្រទៅ ខ្លា ឃ្មុំក្រោកអើតមើលមក តាចន្ទ ឃើញខ្លាឃ្មុំអើតដូច្នោះ គាត់គិតថា " សត្វនេះ វា ចង់មកប្រមាថធ្វើទុក្ខអញទៀតហើយ " ។ តាចន្ទ ប្រុងខ្លួន ហើយវាយដេញក្រ បី ថា " ហ៎ ! អានាងខំទាញឡើង តាយកឃ្មុំឲ្យស៊ី ឃ្មុំតែពីរសម្បុក កំពុងពេញទឹក ផ្អែម " ។ តាចន្ទ គាត់ថាយ៉ាងនេះជាច្រើនផង ។ ខ្លាឃ្មុំឮច្បាស់ ក៏មានចិត្តចង់ ស៊ីឃ្មុំ ហើយឆ្លើយមកកឹងតាថា " តា ៗ ! ចែកខ្ញុំស៊ីផង " ។ តាចន្ទឆ្លើយប្រាប់ ទៅខ្លាឃ្មុំវិញថា "ចៅអើយ ឃ្មុំតាតែពីរសម្បុកទេ ទុកឲ្យក្របីវាស៊ីមួយម្នាក់ សោះញ៉រ ខ្លួន បើចៅចង់ស៊ី ចូលមកនិយាយគ្នាសិន " ។ ខ្លាឃ្មុំ ក៏ចូលមកអង្គុយ ។ តាចន្ទថា " បើចៅចូលចិត្តស៊ីដែរ នឹងឲ្យស៊ីទាំងអស់តែម្ដងទៅ ខ្លាចក្រែងក្របីវា

ខឹង ព្រោះវាធ្លាប់ស៊ីដែរ តែតាគិតថា ចៅឯង ឲ្យតាទឹមក្ដួរស្រែ បានមួយព្យាម ចុះ តានឹងឲ្យចៅស៊ីទាំងពីរសម្បកតែម្ដង ឯក្របីតា ឲ្យវារត់សិនទៅចុះ សឹមរក ទៀត » ។ ខ្លាឃ្មុំ ស្ដាប់ ត្រូវចិត្តនឹងចំណីនោះ ព្រោះត្រូវចំណង់របស់ខ្លួន ក៏អរ ណាស់ ថា « បើដូច្នេះ ឲ្យតាដោះក្របីចេញចុះ » ។ តាចន្ទ ក៏ដោះក្របីចេញ មួយរំពេច ។ ខ្លាឃ្មុំ ក៏ចូលទៅឲ្យតាចន្ទទឹម ដាក់ខ្សែទាមចងរឹតរួចស្រេច ។ តាចន្ទ គាត់ស្ទុះទៅកាន់កន្ទុយយាមនង្គ័ល ហើយដេញថា ហី ! អានាង ខំទៀង តាយកឃ្មុំឲ្យស៊ី ឃ្មុំតែពីរសម្បក កំពុងពេញទឹក » ។ ខ្លាឃ្មុំ ខំប្រឹងទាញនង្គ័លពុំ រកក្រើកឡើយ ។ តាចន្ទ គាត់ខឹង ក៏លែងកន្ទុយយាមនង្គ័លបែរទៅវាយខ្លាឃ្មុំ ។ ក៏ខំប្រឹងរើបម្រះ តាចន្ទ វាយខ្លាំងណាស់ ដល់ទៅបែកហើមខ្លួនទាំងមូល ។ លុះ ខ្លាឃ្មុំរើរួច បោលទៅជួបនឹងចចក ។ សួរខ្លាឃ្មុំ ថា : បងខ្លាឃ្មុំ ពោលអីគ្មាន មើលក្រោយម្ល៉េះ ? ។ ខ្លាឃ្មុំប្រាប់ទៅវិញថា « បងចចកអើយ ! អាចន្ទរំលៀក វាបញ្ឆោតវាយខ្ញុំ ហើមខ្លួនអស់ » ហើយខ្លាឃ្មុំបោលទៅ ។ ចចក ក៏រួតថា « បើដូច្នោះ ទុកឲ្យអញទៅហែកលបតាចន្ទ យកត្រីចែកគ្នាស៊ី ឲ្យអស់ កុំទុកឲ្យ វាឡើយ » ។ លុះព្រឹកឡើង តាចន្ទ គាត់កាន់កាបិតព្រាមួយនិងច្រវាប្រួយ ទៅ លើកលបគាត់ក្នុងបឹង ។ និយាយពីចចក បកដល់កណ្ដាលផ្លូវជួបនឹងខ្លាត្រីមួយ ។ ចចក ក៏បបួលខ្លាត្រី ថា « បងខ្លាត្រី ទៅស៊ីត្រីនឹងអញ » ។ ខ្លាត្រីតបថា«បង ចចកឯង បានត្រីពីណា ? » ។ ចចកថា « អញទៅហែកលបអាចន្ទរំលៀក ចែកគ្នាស៊ី » ។ ខ្លាព្រមតាមចចក ក៏មកអង្គុយនៅមាត់បឹង យូរបន្តិច ឃើញតា ចន្ទអុំទូកមក ចចក សួរថា « តាស្គាល់អាចន្ទរំលៀកដែរ» ។ តាចន្ទ ថា «ស្គាល់ ដែរ តែអាចន្ទនោះ វានៅត្រើយបឹងខាងណោះទេ » ។ ចចក ថា បើដូច្នេះ អាណិតជូនខ្ញុំទៅ បើខ្ញុំហែកលបវាបានត្រី ខ្ញុំចែកតាពាក់កណ្ដាល» ។ តាចន្ទ ថា « ទៅក៏ទៅ ក្បែតលបតា ក៏វាពុំត្រូវផង » ថាហើយចចកក៏លោតទំក្បាលទូក ។ តាចន្ទ ថា « ចៅកុំទៅអង្គុយក្បាលទូក វាលិចណា៎ ! បករអង្គុយខ្លង់មុខតាឯណោះ ទើបវាមិនលិច » ។ ចចក ក៏មកអង្គុយនៅមុខតាចន្ទ ហើយហៅខ្លាត្រី ថា «មក បង ប្រញាប់នឹងអាលទៅ » ។ ខ្លាត្រីថា « បងចចក អញមិនបានទៅទេ អញ ក្រែងតាចន្ទហើយនេះ »។ ចចក បែរមើលក្រោយ ថា « មិនមែនទេ » ។ តា

ចន្ទ គាត់នៅស្ងៀម ។ ខ្លាត្រី ក៏ឡើងមកអង្គុយទឹមគ្នានឹងចចក ។ តាចន្ទ គាត់អ៊ុំទូកទៅប្រមាណជា ១០ ព្យាមពីច្រាំង គាត់កាប់ក្បាលចចកមួយករបិត ។ ចចកលោតធ្លាក់ទឹក ខ្លាត្រី ក៏លោតធ្លាក់ទឹកទាំងអស់គ្នា, ខ្លាត្រី បន្ទោសចចកថា "អញថា តាចន្ទហើយ ឯងថា មិនមែនតាចន្ទទេ" ។ ចចកថា "កុំមាត់ ខំតែហែលទៅ» ។ សត្វទាំងពីរ ក៏ហែលដល់គោក ហើយបោលទៅ ។ តាចន្ទ នៅធ្វើស្រែស្រួវរួចហើយ ក៏ទៅផ្ទះ បានសេចក្ដីសុខសប្បាយ ។

ក្រោយមក តាចន្ទ មានចិត្តសង្ស័យ ថា « ឱ ! សត្វទាំង ៤ នេះនឹងចងពៀរានឹងអញតទៅមុខពុំលែង ហើយវានឹងធ្វើបាបអញនេះមិនខាន ដូច្នេះ គួរអញទិញដែកឲ្យច្រើន ធ្វើករបិតកោរដងដែកឲ្យបាន ៥០ ឬ ៦០ ទុកបំរុងការពារខ្លួនដែលស្លាប់ទៅ ។ តាចន្ទ ធ្វើករបិតបានស្រេចហើយ គាត់ ក៏ហៅកូនចៅមកផ្ដាំ ថា « បើអញស្លាប់ទៅហើយ យកអញទៅកប់ ឲ្យយកករបិតទាំងអស់នេះ ទៅដាក់លើផ្នូរកុំខាន ចូកដីលប់ឲ្យជិត លុះដល់ ៥-៦ ថ្ងៃ ឲ្យកូនចៅមើលផ្នូរអញកុំខាន»។ តាចន្ទ ផ្ដាំកូនចៅរួចហើយ គាត់ក៏មានជម្ងឺឈឺក្សិយទៅ កូនចៅ ក៏យកខ្មោចតាចន្ទទៅកប់ ធ្វើដូចបណ្ដាំគាត់ មិនហ៊ានខាន ។

និយាយពីសត្វទាំង ៤ ដែលមានពៀរានឹងគ្នានោះ កាលតាចន្ទស្លាប់ទៅបាន ៣ ថ្ងៃ សត្វចចក ស៊ើបដឹងថា តាចន្ទស្លាប់ ក៏ទៅប្រាប់ខ្លាឃ្មុំ ។ ប្រាប់ដំរី ។ ប្រាប់ខ្លាធំ ភ្ជុំបបួលគ្នាចូលមកកកាយខ្មោចតាចន្ទរំលៀកស៊ី ។ ចចក កាយចុងជើង ខ្លាឃ្មុំកាយក្បាល ខ្លាធំ កាយកណ្ដាលខ្លួន ។ ឯដំរី ឈរចាំមើល ឃើញសត្វទាំង ៣ មុតជើងពិការជាខ្លាំង ដួលដេកអស់ ។ ដំរី ខឹងនឹងខ្មោចតាចន្ទ ថា « ដើ! អាចន្ទ កាចតាំងពីរស់ទាល់តែស្លាប់ មិនលែងកាចសោះ ទុកឲ្យអញឈូសតែម្ដងឲ្យប៉ើងខ្មោចមកនៅលើគោក»។ ដំរី ខឹងណាស់ លើកជើងឈូសជាខ្លាំង ត្រូវនឹងករបិតមុតពេញជើង ក៏ដេកដួលទាំងអស់គ្នា ។

ដល់កំណត់ ថ្ងៃ ៧ កូនចៅតាចន្ទ នាំគ្នាទៅមើលខ្មោច ស្រាប់តែឃើញដំរី ខ្លា ចចក ស្លាប់ខាងផ្នូរ ក៏នាំគ្នាពន្លះយកសាច់ ស្បែក ឆ្អឹង ភ្លុក មកលក់យកប្រាក់ធ្វើបុណ្យ ឧទ្ទិសបញ្ជូនឲ្យខ្មោចតាចន្ទរំលៀកជាសួរគេហោង ។

**ទឹកខាត ប្រមាថខុស**

## ៣៤ - រឿង អន្តរាយវិទ្ធីនៃសត្វអស្សតរ(១)

លោកអ្នកដែលបានឮឬទេ ? ចាស់ ៗ តែងនិយាយត ៗ គ្នាមកថា « សត្វ-អស្សតរ គឺសេះ ពីដើមមក ជាសត្វវិសេស ចេះហោះហើរដើរលើអាកាសបាន តែពមកខាងក្រោយ ក៏ត្រូវគេកាត់សរសៃហោះចោលទៅ » ដូចមានស្នាមនៅជើង អស្សតរជាភស្តុតាងស្រាប់ តែពុំដឹងជាអ្នកឯណាកាត់ ហើយកាត់នោះ តើដោយ ហេតុអ្វី ពុំមានចែងច្បាស់ ។

លោកអ្នក ដែលបានឃើញឬទេ ? សត្វអស្សតរ កាន់ចរិតមួយយ៉ាងជាប់ជា និច្ច គឺថា សត្វពួកនេះ តែជួបគ្នាវេលាណា តែងចូលទៅហិតមាត់គ្នាជាដរាប, ដែលវាប្រព្រឹត្តដូច្នេះ ដោយមានហេតុរឿងដើមដូចម្ដេច ? ។ ចាស់ ៗ បាន ដំណាលបក ថា :

ក្នុងសម័យបឋមកប្បនោះ សត្វអស្សតរទាំងឡាយ ចេះហោះច្រៀងប្រែលើ អាកាស ឥតទើសទាល់ តែសត្វទាំងនោះ ពុំទាន់កើតសម្បុណ៌ដូចសព្វថ្ងៃនេះទេ មាននៅតែក្នុងវត្ត ជាយានជំនិះរបស់អ្នកបួស ដែលកាន់ធម៌សុចរិត សម្រាប់ជិះ ហោះ ទៅយកចង្ហាន់ នៅឧត្តរកុរុទ្វីបម្ដង ៗ ។

មានសម័យថ្ងៃមួយនោះ ព្រះមហាក្សត្រ ចាត់អាមាត្យដាំបាយ មធុបាយាស យកទៅប្រគេនលោកអ្នកបួសទាំងនោះ ។ លោកក៏ទទួលទុក ដើម្បីឆាន់ដល់ទៅ

---

១ កម្ពុជសុរិយា លេខ ២ ឆ្នាំ ១៩៤៣ ទំព័រ ៨៩ រៀបរៀងដោយអ្នកឧកញ៉ា ឥស្សរ វង្សា សំ-ស៊ុន ជាក្រុមប្រឹក្សាសាលាឧទ្ធរណ៍ ។

ពេលថ្ងៃត្រង់តែម្តង ហើយបានទុកដាក់យ៉ាងប្រយ័ត្ន គឺលោកដាក់ក្នុងសង្រែក ហើយចងព្យួរទុកយ៉ាងខ្ពស់ ជិតដល់ទៅដំបូលកុដិ រួចលោកនាំអ្នកបួសជាបរិស័ទ ចូលទៅស្មឹងស្មាធិនៅក្នុងវិហារ ដើម្បីថ្វាយព្រះរាជកុសល ដល់ព្រះមហាក្សត្រ ដែលជាម្ចាស់ទាន លុះចប់កិច្ចហើយ លោកក៏នាំបរិស័ទមកកាន់កុដិវិញ ។ នៅឱកាស ដែលលោកប្រជុំស្មឹងស្មាធិនោះ សត្វអស្សុតរ ធុំក្លិនក្រអូបបាយមធុបាយាស ទ្រាំ ពុំបាន ក៏ហោះចូលទៅក្នុងកុដិ ហើយគយគន់រក ស្រង់តាមក្លិនទៅ ឃើញបាយ មធុបាយាសព្យួរទុកលើសង្រែក ក៏យកមកបរិភោគអស់រលីង ឥតសេសសល់ ហើយ ហោះចេញទៅកាន់ទីកន្លែងរបស់ខ្លួនវិញ ។

លុះដល់ពេលថ្ងៃត្រង់ លោកប្រជុំពួកអ្នកបួសជាបរិស័ទ ដើម្បីចែកបាយមធុបា-យាសនោះ ព្រោះជាបាយត្រកាលណាស់ មានតែព្រះមហាក្សត្រ ទើបទាន សោយ ។ លុះលោកអ្នកបួសមកប្រជុំហើយ ក៏បង្គាប់ឲ្យសាមណេរមួយរូប ឲ្យ ឡើងលើធ្នឹម បង្ហូតសង្រែកចុះមក ស្រាប់តែសាមណេរនោះ ស្រែកឡើងថា " ពុំ ឃើញមានអ្វី នៅក្នុងកញ្ជើលើសង្រែក " ថាហើយ ក៏ស្រាយខ្សែបង្ហូតសង្រែក នោះចុះមក ។ លោកគ្រូចៅអធិការ ទឹកហ្មួសចិត្តណាស់ ក៏លាន់ព្រះឧស្ម ថា " យើអើ ! ឯងអត់ចង្ហាន់តាំងពីព្រឹក ថាទុកពោះឲ្យទំនេរ ដល់ថ្ងៃត្រង់ នឹងឆាន់ បាយមធុបាយាសឲ្យពេញទំហឹងតែម្តង ព្រោះក្នុងមួយជាតិ កម្របានបាយត្រកាល បែបនេះឆាន់ណាស់, ឱកម្មអើយ ! ឥឡូវ នឹងឲ្យដណ្តាំបាយក៏មិនទាន់ ព្រោះ ថ្ងៃជ្រេពីត្រង់ទៅហើយ ណ្ហើយ ! អស់លោកនិមន្តទៅវិញចុះ ចាំស្អែក សឹមបិណ្ឌ បាតឆាន់ទៅ " ។ ពួកអ្នកបួស និមន្តចុះពីកុដិលោកគ្រូចៅអធិការអស់ទៅ ។

រីឯលោកគ្រូចៅអធិការ ទាកាលមានហេតុ នាំឲ្យមានវិតក្កដូច្នេះហើយ ក៏ លោកនិមន្តចូលទៅក្នុងកុដិ សម្ងំស្មឹងស្មាធិ តម្លើងមេកថ្វាយរមិលមើលហេតុភេទទៅ ឃើញច្បាស់ ថា មានសត្វអស្សុតរមួយហោះចូលមក បរិភោគបាយមធុបាយាស នោះអស់ទៅ ទើបលោកហៅប្រជុំពួកអស្សុតរទាំងប៉ុន្មានមកពិសោធ ។ ក្នុងចំ-

ណោមអស្សុតរទាំងនោះ អស្សុតរជាតួរចោរ ក៏ចូលមកប្រជុំដែរ តែអស្សុតរទាំងប៉ុន្មានបាននាំគ្នាបដិសេធពាក្យចោទទាំងអស់ ។ លោកគ្រូចៅអធិការ ក៏ជ្រាបច្បាស់ថា តួអស្សុតរណាក៏ចោរដែរ តែមិនមែនបានផ្ចាញ់ផ្ចាលទេ ដោយលោកពិចារណាទៅ យល់ឃើញថា «តួអស្សុតរ ចំណេរទៅមុខ បើនៅតែមានរិទ្ធិ ហោះហើរលើអាកាសបានដូច្នេះ មុខជានឹងធ្វើអន្តរាយផ្សេងៗដល់ពួកមនុស្សខ្លាំងណាស់» ទើបលោកមានពុទ្ធដីកាថា "ចាប់ដើមពីថ្ងៃនេះតទៅ អញនឹងបន្ថយរិទ្ធិឯងរាល់គ្នាឲ្យសមនឹងសភាពរបស់ឯង ដែលលួចទៅរួមជាមួយនឹងពួកមនុស្សលោកបាន" ។ លុះលោកបានប្រាប់ដូច្នេះហើយ ទើបលោកយកកាំបិតកោរ រះកាត់សរសៃហោះរបស់សត្វអស្សុតរទាំងនោះចេញ ហើយលោកប្រាប់ថា "តាំងពីថ្ងៃនេះតរៀងទៅ ត្រូវឯងរាល់គ្នា ទៅជាសត្វបំរើមនុស្សលោក ដើម្បីដោះថ្លៃបាយមធុបាយាស ដែលមនុស្សទាំងឡាយ គេចិញ្ចឹមអ្នកបួស" ។ ចាប់ដើមពីនោះមក សត្វអស្សុតរទាំងឡាយ លែងចេះហោះហើរបានទៀត ក៏មានសេក្តីតូចចិត្ត ទោមនស្សនឹងអស្សុតរដែលរកមុខមិនឃើញ ក្នុងកិច្ចប្រព្រឹត្តចោរកម្មនោះ ទើបនាំគ្នាតាំងប្តេជ្ញា ថា "នឹងស៊ើបរកមុខឲ្យឃើញប្រាកដ ហើយនឹងព្រួតគ្នាធ្វើទណ្ឌកម្មឲ្យធ្ងន់ពេញកម្លាំងតែម្តង" ។

ហេតុនេះហើយ បានជាអស្សុតរតាំងឡាយ តែកាលណាបាន ជួបគ្នា រាតែងហិតគ្នាទៅវិញទៅមក លុះហិតបានក្លិនទៅវិញទៅមក ឃើញដូចជាក្លិនបាយមធុបាយាស ក៏ចោទគ្នាទៅវិញទៅមក ហើយស្រែកប្រកែកដោយសំឡេងយ៉ាងខ្លាំង ។ ថា "ទេៗ" ។

**លួចគេខាស្រាន់ តែគេឆាន់ខាគ្រែល**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ**ករុណាខ្មែរ**

Scan ជា eBook ដោយ **ប៉ោ ភារម្យ**

ក្រោមការឧបត្ថម្ភពី

**ខ្វៅ សំរ៉ង** និង **កែ ក្រានីត**

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ

ឧបាសក ខ្វៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំ កំពង់ឃ្លាំង ស្រុក ជីក្រែង ខេត្រ សៀមរាប)

ខែ កុម្ភៈ ឆ្នាំ២០១៤